ADB

ឯកសារគោលនយោបាយ

ខែ មិថុនា ឆ្នាំ ២០០៩

# សេចក្ដីថ្លែងការណ៍នៃគោលនយោបាយការពារ

ធនាគារអភិវឌ្ឍន៍អាស៊ី

## អក្សរកាត់

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CSS | country safeguard systems | ប្រព័ន្ធការពារក្នុងប្រទេស |
| DMC | developing member country | ប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក |
| EBRD | European Bank for Reconstruction and Development | ធនាគារអឺរ៉ុបសម្រាប់ការស្ថាបនា និងអភិវឌ្ឍន៍ |
| EIA | environmental impact assessment | ការវាយតម្លៃផលប៉ះពាល់បរិស្ថាន |
| EMP | environmental management plan | ផែនការគ្រប់គ្រងបរិស្ថាន |
| ESMS | environmental and social management system | ប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម |
| FI | financial intermediary | អន្តរការីហិរញ្ញវត្ថុ |
| IEE | initial environmental examination | ការត្រួតពិនិត្យបរិស្ថានជំហានដំបូង |
| IFC | International Finance Corporation | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| IPP | Indigenous Peoples plan | ផែនការក្រុមជនជាតិដើមភាគតិច |
| IPPF | Indigenous Peoples planning framework | ក្របខណ្ឌរៀបចំផែនការក្រុមជនជាតិដើមភាគតិច |
| MFF | multitranche financing facility | ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញប្បទានពហុភាគី |
| MFI | multilateral financial institution | ស្ថាប័នហិរញ្ញវត្ថុពហុភាគី |
| NGO | nongovernment organization | អង្គការមិនមែនរដ្ឋាភិបាល |
| OCR | ordinary capital resources | ធនធានមូលធនធម្មតា |
| OED | Operations Evaluation Department | នាយកដ្ឋានវាយតម្លៃប្រតិបត្តិការ |
| SES | special evaluation study | ការសិក្សាវាយតម្លៃពិសេស |
| SIA | social impact assessment | ការវាយតម្លៃផលប៉ះពាល់សង្គម |
| SPS | safeguard policy statement | សេចក្តីថ្លែងការណ៍គោលនយោបាយការពារ |
| SPU | safeguard policy update | គោលនយោបាយការពារកែសម្រួលថ្មី |
| UNDRIP | United Nations Declaration on the Rights of Indigenous Peoples | សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិក្រុមជនជាតិដើមភាគតិច |

| | |
|---|---|
| អនុប្រធាន | U. Schäfer-Preuss ទទួលបន្ទុកគ្រប់គ្រងចំណេះដឹង និងអភិវឌ្ឍន៍ដោយនិរន្តរភាព |
| អគ្គនាយក | X. Yao នាយកដ្ឋានអភិវឌ្ឍន៍តំបន់ និងដោយនិរន្តរភាព (RSDD) |
| នាយក | N. J. Ahmad ការិយាល័យបរិស្ថាន និងគោលនយោបាយការពារនៃ RSDD |
| ប្រធានក្រុម | X. Ma អ្នកឯកទេសបរិស្ថានជាន់ខ្ពស់នៃ RSDD |
| | J. Perera អ្នកឯកទេសគោលនយោបាយការពារជាន់ខ្ពស់នៃនាយកដ្ឋានអាស៊ីខាងត្បូង |
| | I. Simbolon អ្នកឯកទេសការអភិវឌ្ឍន៍សង្គមជាន់ខ្ពស់ (គោលនយោបាយការពារ) នៃ RSDD |

## អំណះអំណាង

"ឯកសារនេះត្រូវបានបកប្រែចេញពីភាសាអង់គ្លេសដើម្បីផ្សព្វផ្សាយដល់សាធារណៈជនអោយបានទូលំទូលាយបន្ថែមទៀត។ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានខិតខំប្រឹងប្រែងដើម្បីផ្ទៀងផ្ទាត់ទៅលើភាពជាក់លាក់នៃការបកប្រែនេះ។ ភាសាអង់គ្លេសគឺជាភាសាការងាររបស់ ADB ហើយឯកសារច្បាប់ដើមជាភាសាអង់គ្លេសគឺជាឯកសារដែលត្រឹមត្រូវ និងផ្លូវការតែមួយគត់របស់ខ្លួន។ សេចក្តីដកស្រង់ណាមួយចេញពីឯកសារនេះ ត្រូវតែយោងទៅលើឯកសារច្បាប់ដើមក្នុងភាសាអង់គ្លេស" ។

## សន្ទានុក្រម

**ជីវៈចម្រុះ :** សំដៅលើបណ្តាសារពាង្គកាយខុសគ្នាក្នុងប្រភេទតែមួយ ឬប្រភេទផ្សេងគ្នា និងបណ្តាសារពាង្គកាយរស់នៃគ្រប់លំដាប់ថ្នាក់ និងប្រភពទាំងអស់ រួមទាំង ប្រព័ន្ធអេកូឡូស៊ីដែនគោក ដែនសមុទ្រ ដែនទឹកសាប និងបណ្តាទំនាក់ទំនងអេកូឡូស៊ី ដែលនៅក្នុងនោះមានប្រព័ន្ធអេកូឡូស៊ីទាំងនេះ។

**ការយល់ព្រមរបស់សហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ :** នៅក្នុងការអនុវត្តគោលនយោបាយ ការយល់ព្រមរបស់សហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ សំដៅលើការបញ្ជាក់ជារួមរបស់សហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ តាមរយៈបុគ្គលណាមួយ និង/ឬ តំណាងរបស់ពួកគេ ក្នុងការគាំទ្រជារួមពីសហគមន៍ចំពោះសកម្មភាពគម្រោង។ ការគាំទ្រជារួមពីសហគមន៍ក៏អាចនឹងមានផងដែរ បើទោះជាមានការជំទាស់ចំពោះសកម្មភាពគម្រោងពីសំណាក់បុគ្គល ឬក្រុមមួយចំនួនក៏ដោយ។

**ប្រព័ន្ធការពារក្នុងប្រទេស :** ក្របខណ្ឌស្ថាប័ន និងច្បាប់របស់ប្រទេស ដែលរួមមានស្ថាប័នអនុវត្តច្បាប់ លិខិតបទដ្ឋាន វិធាន និងនិតិវិធីពាក់ព័ន្ធនឹងគោលនយោបាយការពារសង្គម និងបរិស្ថាន។

**ជំរកសំខាន់ :** ជំរកសំខាន់ គឺជាអនុក្រុមនៃជំរកធម្មជាតិ និងកែច្នៃ ដែលត្រូវការការចាប់អារម្មណ៍ជាពិសេស។ ជំរកសំខាន់ រួមមានតំបន់ដែលមានតម្លៃផ្នែកជីវៈចម្រុះខ្ពស់ ដូចជា តំបន់ដែលចាំបាច់ចំពោះការរស់រានរបស់ប្រភេទសត្វដែលកំពុងរងគ្រោះ ឬកំពុងរងគ្រោះធ្ងន់ធ្ងរ តំបន់ដែលមានសារៈសំខាន់ជាពិសេសចំពោះប្រភេទសត្វប្រចាំតំបន់ ឬប្រភេទសត្វកម្រ តំបន់ដែលមានសារៈសំខាន់ចំពោះការរស់រានរបស់ប្រភេទសត្វដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយ តំបន់ទ្រទ្រង់ជាសកលដល់ការប្រមូលផ្តុំនៃប្រភេទសត្វប្រមូលផ្តុំ តំបន់មានប្រភេទសត្វប្លែកៗ ឬដែលមានជាប់ពាក់ព័ន្ធនឹងដំណើរការវិវត្តផ្លាស់ប្តូរគន្លឹះ ឬតំបន់ដែលមានមុខងារអេកូឡូស៊ីសំខាន់ និងតំបន់ដែលជីវៈចម្រុះមានសារៈសំខាន់ខាងសង្គម សេដ្ឋកិច្ច និងវប្បធម៌ចំពោះសហគមន៍មូលដ្ឋាន។

**ប្រជាជនដែលរុះរើលំនៅដ្ឋាន :** ក្នុងបរិបទនៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត មនុស្សដែលរុះរើលំនៅដ្ឋាន សំដៅលើអ្នកដែលត្រូវផ្លាស់ទីលំនៅរូបវន្ត (ប្តូរទីតាំង បាត់បង់ដីលំនៅដ្ឋាន ឬបាត់បង់ទីជំរក) និង/ឬ ផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ច (បាត់បង់ដីធ្លី ទ្រព្យសកម្ម សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ប្រភពចំណូល និងមធ្យោបាយចិញ្ចឹមជីវិត) ដោយសារតែ (១) លទ្ធកម្មដីដោយមិនស្ម័គ្រចិត្ត ឬ (២) ការកំណត់ដោយមិនស្ម័គ្រចិត្តក្នុងការប្រើប្រាស់ដី ឬសិទ្ធិប្រើប្រាស់ឧទ្យានជាតិ និងតំបន់ការពារធម្មជាតិដែលកំណត់ដោយច្បាប់។

**ការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ច :** ការបាត់បង់ដីធ្លី ទ្រព្យសកម្ម សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ប្រភពចំណូល និងមធ្យោបាយចិញ្ចឹមជីវិតដោយសារតែ (១) លទ្ធកម្មដីដោយមិនស្ម័គ្រចិត្ត ឬ (២) ការកំណត់ដោយមិនស្ម័គ្រចិត្តលើការប្រើប្រាស់ដី ឬសិទ្ធិប្រើប្រាស់ឧទ្យានជាតិ និងតំបន់ការពារធម្មជាតិដែលកំណត់ដោយច្បាប់។

**អ្នកជំនាញពីខាងក្រៅ :** អ្នកជំនាញដែលមិនពាក់ព័ន្ធនឹងការអនុវត្ត ឬត្រួតពិនិត្យគម្រោងប្រចាំថ្ងៃ។

**គម្រោងដែលមានភាពស្មុគស្មាញ និងងាយរងការប៉ះពាល់ខ្លាំង** : គម្រោងដែល ADB គិតថា មានហានិភ័យខ្ពស់ ឬត្រូវប្រុងប្រយ័ត្ន ឬពាក់ព័ន្ធនឹងការប៉ះពាល់បរិស្ថាន និងសង្គមខ្លាំង ច្រើនផ្នែក និងពាក់ព័ន្ធគ្នាទៅវិញទៅមក។

**ការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យ** : ការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យ គឺជាដំណើរការដែល (១) ចាប់ផ្តើមនៅដើមដំណាក់កាលនៃការរៀបចំគម្រោង និងបន្តធ្វើ ជាប់ជានិច្ចនៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង (២) ធ្វើការផ្តល់ព័ត៌មានពាក់ព័ន្ធ និងសមស្របទាន់ពេលវេលា និងជាព័ត៌មានដែលក្រុមមនុស្សរងផលប៉ះពាល់អាចរកបាន និងអាចយល់បានដោយងាយស្រួល (៣) ធ្វើឡើងនៅក្នុងបរិយាកាសដែលគ្មានការគំរាមកំហែង និងបង្ខិតបង្ខំ (៤) មានការគិតគូរពីបញ្ហាយេនឌ័រ និងមានការតម្រែតម្រង់ទៅតាមតម្រូវការក្រុមទន់ខ្សោយ និងងាយរងគ្រោះ និង (៥) ជម្រុញឱ្យមានការបញ្ចូលគំនិតយោបល់របស់ក្រុមមនុស្សរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធ ក្នុងការធ្វើការសម្រេចចិត្តពីការចនាគម្រោង វិធានការកាត់បន្ថយផលប៉ះពាល់ ការចែករំលែកអត្ថប្រយោជន៍ និងឱកាសដែលបានមកពីការអភិវឌ្ឍន៍ និងបញ្ហាអនុវត្តគម្រោង។

**ជំរកធម្មជាតិ** : តំបន់ដីគោក និងដែនទឹក ដែលបណ្តុំជីវៈសាស្រ្តកកើតឡើងពីប្រភេទសត្វ និងរុក្ខជាតិប្រចាំតំបន់ជាចំបង និងជាតំបន់ ដែលសកម្មភាពរបស់មនុស្សមិនបានកែប្រែជាសារវន្តទៅលើមុខងារអេកូឡូស៊ីចំបងរបស់តំបន់នោះ។

**ធនធានវប្បធម៌រូបវន្ត** : សំដៅលើចលន និងអចលនវត្ថុ ទីកន្លែង សំណង់ បណ្តុំសំណង់ តំបន់មានលក្ខណៈពិសេស និងតំបន់ទេសភាពធម្មជាតិ ដែលមានសារៈសំខាន់ខាងបុរាណវត្ថុវិទ្យា ហ្វូស៊ីលវិទ្យា ប្រវត្តិសាស្រ្ត ស្ថាបត្យកម្ម សាសនា សោភ័ណភាព ឬវប្បធម៌។ ធនធានវប្បធម៌រូបវន្ត អាចមានទីតាំងស្ថិតនៅតំបន់ទីក្រុង ឬជនបទ និងអាចស្ថិតនៅលើ ឬនៅក្រោមដី ឬនៅក្រោមទឹក។ អត្ថប្រយោជន៍ខាងវប្បធម៌របស់ធនធាននេះ អាចស្ថិតក្នុងកម្រិតតំបន់ ខេត្ត-ក្រុង ជាតិ ឬអន្តរជាតិ។

**ការផ្លាស់ទីលំនៅរូបវន្ត** : ការផ្លាស់ប្តូរទីតាំង ការបាត់បង់ដីលំនៅដ្ឋាន ឬការបាត់បង់ទីជម្រក ដោយសារតែ (១) លទ្ធកម្មដីដោយមិនស្ម័គ្រចិត្ត ឬ (២) ការកំណត់ដោយមិនស្ម័គ្រចិត្តលើការប្រើប្រាស់ដី ឬសិទ្ធិប្រើប្រាស់តំបន់ឧទ្យានជាតិ និងតំបន់ការពារធម្មជាតិដែលកំណត់ដោយច្បាប់។

**ការកែប្រែ ឬការរេចរិលសំខាន់ៗ** : (១) ការលុបបំបាត់ ឬការធ្វើឱ្យថយចុះបូរណភាពនៃជំរកសត្វ ដោយសារតែការផ្លាស់ប្តូរច្រើនក្នុងរយៈពេលវែងក្នុងការប្រើប្រាស់ដី និងទឹក ឬ (២) ការកែប្រែជំរកសត្វដែលបណ្តាលឱ្យមានការ កាត់បន្ថយយ៉ាងខ្លាំងនូវលទ្ធភាពរបស់ជំរកក្នុងការរក្សាការរស់រានរបស់ប្រភេទពូជប្រចាំតំបន់។

## មាតិកា

ទំព័រ

**I. ប្រវត្តិ និង សេចក្តីផ្តើម** ---------------------------------------------------------- ៨

**II. ការប្រែប្រួលនៃបរិបទ** ---------------------------------------------------------- ១០

**III. គោលនយោបាយការពារ និង បទពិសោធន៍បច្ចុប្បន្ន** ------------------------------- ១៣

ក. គោលនយោបាយការពារបច្ចុប្បន្នរបស់ ADB ---------------------------------------------- ១៣

ខ. ការត្រួតពិនិត្យអនុលោមភាព ---------------------------------------------------------- ១៥

គ. បទពិសោធន៍ ADB ក្នុងការអនុវត្តគោលនយោបាយការពារ : ----------------------------- ១៥

**IV. បញ្ហាគោលនយោបាយ និង ការគិតគូរពិចារណាសំខាន់ៗ** ----------------------------- ១៩

ក. ការរៀបរាប់ និងវិសាលភាពគោលនយោបាយ ------------------------------------------------- ១៩

ខ. ការប្រើប្រាស់គោលនយោបាយ និងបញ្ហាអនុវត្តគោលនយោបាយ ------------------------ ២២

គ. ការឆ្លើយតបនឹងការប្រែប្រួលនៃលក្ខខណ្ឌតម្រូវសម្រាប់អតិថិជន និង និរន្តរភាពរយៈពេលវែងនៃប្រព័ន្ធការពារ ---------------------------------------------------------- ២៤

**V. ពង្រាងនៃសេចក្តីថ្លែងការណ៍គោលនយោបាយការពារ** --------------------------------- ២៧

ក. សេចក្តីថ្លែងការណ៍ដ៏សំខាន់ស្តីពីការប្តេជ្ញារបស់ ADB និង គោលការណ៍គោលនយោបាយ------- ២៧

ខ. ដំណើរការអនុវត្តគោលនយោបាយ ---------------------------------------------------------- ៣៨

គ. តួនាទី និង ការទទួលខុសត្រូវ ---------------------------------------------------------- ៤៨

**VI. រៀបចំការអនុវត្ត និង ប្រើប្រាស់ធនធាន** ---------------------------------------------- ៤៩

ក. ការអនុវត្ត និង ការតាមដាន ---------------------------------------------------------- ៤៩

ខ. ធនធាន ---------------------------------------------------------- ៥០

គ. កាលបរិច្ឆេទចូលជាធរមាន និង អំឡុងពេលអន្តរកាល ------------------------------------ ៥២

ឃ. ការត្រួតពិនិត្យគោលនយោបាយឡើងវិញ ------------------------------------------------ ៥២

**VII. អនុសាសន៍** ---------------------------------------------------------- ៥២

**សេចក្តីបន្ថែម :**

១. លក្ខខណ្ឌតម្រូវសម្រាប់ការពារ ១ : បរិស្ថាន -------------------------------------------------- ៥៣

២. លក្ខខណ្ឌតម្រូវសម្រាប់ការពារ ២ : ការតាំងលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត --------------------------- ៧២

៣. លក្ខខណ្ឌតម្រូវសម្រាប់ការពារ ៣ : ក្រុមជនជាតិដើមភាគតិច ----------------------------------- ៨៧

៤. លក្ខខណ្ឌតម្រូវសម្រាប់ការពារ ៤ : លក្ខខណ្ឌតម្រូវពិសេសសម្រាប់ទម្រង់ហិរញ្ញវត្ថុផ្សេងៗ -------------- ១០០

៥. បញ្ជីសកម្មភាពវិនិយោគដែលត្រូវបានហាមឃាត់ដោយ ADB ------------------------------------ ១១២

៦. ការពង្រឹង និង ការប្រើប្រាស់ប្រព័ន្ធការពារក្នុងប្រទេសដើម្បីដោះស្រាយបញ្ហាការពារបរិស្ថាន និងសង្គម ------ ១១៤

<u>**ឯកសារភ្ជាប់ :**</u>

១. បទពិសោធន៍របស់ស្ថាប័នហិរញ្ញវត្ថុពហុភាគីផ្សេងទៀត ------------------------------------------ ១២២

២. ផែនការសកម្មភាពពាក់កណ្តាលត្រីមាស (២០១០-២០១២) ------------------------------------ ១៣០

# I. ប្រវត្តិ និង សេចក្តីផ្តើម

១. គោលនយោបាយប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មានគោលនយោបាយការពារចំនួនបី : *គោលនយោបាយស្តីពីការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត* (១៩៩៥) *គោលនយោបាយស្តីពីក្រុមជនជាតិដើមភាគតិច* (១៩៩៨) និង *គោលនយោបាយស្តីពីបរិស្ថាន* (២០០២)។ គោលនយោបាយការពារទាំងបីនេះដល់ពេលកំណត់ដែលត្រូវកែសម្រួលថ្មី។ ADB ត្រូវដោះស្រាយបញ្ហាប្រឈមបរិស្ថាន និងសង្គម ក្នុងការអភិវឌ្ឍន៍នៅប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក (DMC) ឆ្លើយតបនឹងមេរៀនដែលទទួលបានពីបទពិសោធន៍ក្នុងការអនុវត្តគោលនយោបាយការពារបច្ចុប្បន្ន និងសម្របសម្រួលខ្លួនទៅតាមគំរូផ្តល់ប្រាក់កម្ចី និងលិខិតុបករណ៍ផ្តល់ហិរញ្ញប្បទានថ្មីៗរបស់ខ្លួន។ លើសពីនេះ គោលនយោបាយ ADB ត្រូវតែឆ្លុះបញ្ចាំងពីការប្រែប្រួលនៃការអនុវត្តល្អរបស់ស្ថាប័នហិរញ្ញវត្ថុពហុភាគី (MFI) និងស្ថាប័នវិស័យឯកជន ដូចជា ស្ថាប័នហិរញ្ញវត្ថុប្រកាន់គោលការណ៍ស្មើភាពគ្នា (Equator Principles)[១] ជាដើម។ នៅខែ ធ្នូ ឆ្នាំ ២០០៤ ថ្នាក់ដឹកនាំ ADB បានអនុម័តលើឯកសារគោលគំនិតកែសម្រួលគោលនយោបាយការពារ (SPU) ដើម្បីពង្រឹងនូវប្រសិទ្ធភាពនៃគោលនយោបាយ ADB និងដើម្បីធានាថាគោលនយោបាយទាំងនេះនៅតែបំពេញបានតាមតម្រូវការប្រែប្រួលរបស់អតិថិជន និងឱកាសអាជីវកម្មថ្មីៗ។

២. SPU បានព្យាយាម (១) រៀបរាប់គោលនយោបាយការពារឱ្យកាន់តែប្រសើរដើម្បីបង្កើនភាពច្បាស់លាស់ សង្គតភាព និងភាពស្របគ្នា (២) ថ្លឹងថ្លែងវិធីសាស្ត្រតម្រូវឱ្យអនុវត្តជាមុនជាមួយនឹងវិធីសាស្ត្រដែលផ្តោតលើលទ្ធផលនៅអំឡុងពេលអនុវត្ត (៣) សម្រួលការអនុវត្តគោលនយោបាយឱ្យស្របទៅតាមការវិវត្តនៃផលិតផលផ្តល់កម្ចី និងគំរូហិរញ្ញប្បទានថ្មីៗ (៤) ធ្វើឱ្យមានភាពស្របគ្នារវាងគោលនយោបាយការពារនានារបស់ MFI និងកែតម្រូវវិធីសាស្ត្រការពារទៅតាមអតិថិជននីមួយៗដែលមានសមត្ថភាពខុសៗគ្នា និង (៤) លើកកម្ពស់ដំណើរការផ្ទៃក្នុង និងការបែងចែកធនធាន។

៣. SPU បានក្លាយជាគោលនយោបាយបង្រួបបង្រួមដែលមានរចនាសម្ព័ន្ធដូចខាងក្រោម :

(i) សេចក្តីថ្លែងគោលនយោបាយការពារ (SPS) ដែលរៀបរាប់ពីកម្មវត្ថុរួមនៃគោលនយោបាយការពាររបស់ ADB គោលការណ៍គោលនយោបាយ និងរៀបរាប់ត្រួសៗពីដំណើរការអនុវត្តគោលនយោបាយការពាររបស់ ADB។ SPS ត្រូវបានរចនាឡើងសម្រាប់អនុវត្តចំពោះគំរូផ្តល់ប្រាក់កម្ចីនៅពេលបច្ចុប្បន្ន និងពេលអនាគត ទៅតាមសមត្ថភាព និងតម្រូវការរបស់អតិថិជន DMC ទាំងនៅក្នុងវិស័យសាធារណៈ និងឯកជន។

(ii) បណ្តុំលក្ខខណ្ឌតម្រូវសម្រាប់ការពារជាក់លាក់ ដែលអ្នកខ្ចី/អតិថិជនត្រូវបំពេញនៅពេលដោះស្រាយផលប៉ះពាល់ និងហានិភ័យសង្គម និងបរិស្ថាន។ តាមរយៈការអង្កេតលម្អិត វាយតម្លៃ និងត្រួតពិនិត្យ បុគ្គលិក ADB នឹងធានាថា អ្នកខ្ចី/អតិថិជនគោរពតាមលក្ខខណ្ឌតម្រូវទាំងនេះនៅអំឡុងពេលរៀបចំ និងអនុវត្តគម្រោង។ នៅពេលអនាគត ADB អាចនឹងអនុម័តលក្ខខណ្ឌតម្រូវសម្រាប់ការពារបន្ថែម ឬធ្វើបច្ចុប្បន្នភាពលក្ខខណ្ឌតម្រូវ

---

[១] ស្ថាប័នហិរញ្ញវត្ថុប្រកាន់គោលការណ៍ស្មើភាពគ្នា គឺជាស្ថាប័នទាំងឡាយណាដែលប្រកាន់យកគោលការណ៍អេក្វាទ័រ ដែលជាក្របខណ្ឌឧស្សាហកម្ម ហិរញ្ញវត្ថុក្នុងការដោះស្រាយហានិភ័យបរិស្ថាន និងសង្គមក្នុងគម្រោងហិរញ្ញប្បទាន។

ដែលមានស្រាប់ ដើម្បីពង្រឹងនូវប្រសិទ្ធភាព ឆ្លើយតបតាមតម្រូវការប្រែប្រួល និងឆ្លុះបញ្ចាំងនូវការវិវត្តនៃទម្លាប់អនុវត្តល្អ។

(iii) ផ្នែកបញ្ចូលគ្នានៃ *សៀវភៅណែនាំប្រតិបត្តិការ* ដែលមានកំណត់ពីនីតិវិធីវាយតម្លៃផ្ទៃក្នុងរបស់ ADB ទៅលើការអង្កេតលម្អិត និងត្រួតពិនិត្យ ក្នុងវដ្តគម្រោងទាំងមូល។

៤. ក្រោយពេលក្រុមប្រឹក្សាភិបាលរបស់ ADB អនុម័តយល់ព្រម SPS និងលក្ខខណ្ឌតម្រូវការពារសម្រាប់អ្នកខ្ចី/អតិថិជន នឹងជំនួសគោលនយោបាយការពារដែលមានស្រាប់ទាំងបី ហើយផ្នែករបស់ *សៀវភៅណែនាំប្រតិបត្តិការ* ថ្មី នឹងជំនួសផ្នែក F1, F2 និង F3 របស់ *សៀវភៅណែនាំប្រតិបត្តិការ* ចាស់។ ADB នឹងធ្វើបច្ចុប្បន្នភាព *សៀវភៅណែនាំស្តីពីការតាំងទីលំនៅជាថ្មី*[២] និង *គោលការណ៍ណែនាំស្តីពីការវាយតម្លៃបរិស្ថាន* (២០០៣) និងរៀបចំសៀវភៅណែនាំស្តីពីក្រុមជនជាតិដើមភាគតិច ដើម្បីផ្តល់នូវការណែនាំបច្ចេកទេស និងអនុសាសន៍ពីការអនុវត្តល្អ។

៥. សេចក្តីព្រាងពិគ្រោះយោបល់នៃ SPS បានផ្សព្វផ្សាយនៅលើគេហទំព័ររបស់ ADB នៅខែតុលា ឆ្នាំ ២០០៧ សម្រាប់ការពិគ្រោះយោបល់ពីខាងក្រៅ។ នៅអំឡុងពេលពិគ្រោះយោបល់ (ខែវិច្ឆិកា ឆ្នាំ ២០០៧ ដល់ខែមេសា ឆ្នាំ ២០០៨) ADB ទទួលបានការផ្តល់មតិ និងយោបល់លម្អិតជាច្រើន តាមរយៈសិក្ខាសាលាពិគ្រោះយោបល់អ្នកពាក់ព័ន្ធចម្រុះចំនួន ១៤ ដែលបានរៀបចំធ្វើទាំងនៅក្នុង និងនៅក្រៅតំបន់។ ADB ក៏ទទួលបានព័ត៌មានត្រឡប់ជាច្រើនតាមរយៈការផ្ញើលិខិតជាលាយលក្ខណ៍អក្សរ ការពិភាក្សាពីប្រធានបទ និងការប្រជុំមិនផ្លូវការ និងទូរសន្និសីទ។ មតិយោបល់ទាំងអស់ដែលទទួលបាននៅមុនពេលផុតកំណត់អំឡុងពេលពិគ្រោះយោបល់ ត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័ររបស់ ADB។ ដើម្បីឆ្លើយតបទៅនឹងមតិយោបល់ដ៏ច្រើនបែបនេះ ថ្នាក់ដឹកនាំ ADB សម្រេចរៀបចំសេចក្តីព្រាងលើកទី ២ នៃ SPS ផ្អែកលើមតិ និងយោបល់ដែលទទួលបានពីការពិគ្រោះយោបល់ពីខាងក្រៅ និងរៀបចំសិក្ខាសាលាពិគ្រោះយោបល់មួយទៀតនៅទីក្រុងម៉ានីល ដើម្បីឱ្យអ្នកពាក់ព័ន្ធមានឱកាសវាយតម្លៃឯកសារកែសម្រួលថ្មី។

៦. សេចក្តីព្រាង SPS លើកទី ២ បានផ្សព្វផ្សាយនៅលើគេហទំព័ររបស់ ADB ចាប់ពីថ្ងៃទី ០៣ ខែតុលា ដល់ថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ ២០០៨ សម្រាប់ឱ្យសាធារណៈជនបញ្ចេញយោបល់។ ម៉ាទ្រីសមតិឆ្លើយតបលម្អិត ត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រ SPU របស់ ADB នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ ដែលមានមតិយោបល់ដែលទទួលបានពីការពិគ្រោះយោបល់ និងលិខិតជាលាយ-លក្ខណ៍អក្សរផ្ញើមកពីបណ្តាប្រទេស/អនុតំបន់ចំនួន ១៤ នៅអំឡុងពេលផ្តល់យោបល់ពីថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៧ ដល់ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨។ សេចក្តីព្រាងបឋមនៃនីតិវិធីវាយតម្លៃគោលនយោបាយការពារ (សេចក្តីព្រាងសៀវភៅណែនាំប្រតិ-បត្តិការ) បានត្រូវផ្សព្វផ្សាយនៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៨។ លើសពីទៀត (តាមការស្នើសុំរបស់អ្នកពាក់ព័ន្ធជាច្រើន) សេចក្តីព្រាងសទ្ទានុក្រមនៃពាក្យបច្ចេកទេស ក៏ត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រផងដែរ។ សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តី-ព្រាង SPS លើកទី ២ បានរៀបចំធ្វើនៅថ្ងៃទី ១៨-២១ ខែ វិច្ឆិកា ឆ្នាំ ២០០៨ នៅទីក្រុងម៉ានីល ដើម្បីឱ្យមានការពិភាក្សាស៊ី

---

[២] ADB. ១៩៩៨. *សៀវភៅណែនាំស្តីពីការតាំងទីលំនៅជាថ្មី: មគ្គុទេសក៍ទៅកាន់ការអនុវត្តល្អ* ម៉ានីល

ជម្រៅលើសេចក្តីព្រាង SPS លើកទី ២ ដោយសង្កត់ធ្ងន់ទៅលើការឆ្លើយតបរបស់ ADB ចំពោះមតិយោបល់របស់អ្នកពាក់ព័ន្ធ ដែលមានចំពោះសេចក្តីព្រាងពិគ្រោះយោបល់ SPS (សូមមើលគេហទំព័រ SPU របស់ ADB ដើម្បីរកមើលរបាយការណ៍ស្តីពីការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ)។

៧. ឯកសារពិភាក្សា SPS ត្រូវបានរៀបចំ និងបញ្ចូលឱ្យក្រុមប្រឹក្សាភិបាលរបស់ ADB ដើម្បីពិនិត្យ និងសុំការណែនាំ នៅខែមករា ឆ្នាំ ២០០៩ ហើយក្រុមប្រឹក្សាភិបាលបានរៀបចំការពិភាក្សានៅខែកុម្ភៈ ឆ្នាំ ២០០៩។ ឯកសារនេះ គឺជាលទ្ធផលនៃដំណើរការពិគ្រោះយោបល់ផ្ទៃក្នុង និងក្រៅ ដែលមានការចូលរួមពីក្រុមប្រឹក្សាភិបាល និងបុគ្គលិករបស់ ADB និងអ្នកពាក់ព័ន្ធពីខាងក្រៅ រួមមានរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងបណ្ឌិតសភា។

## II. ការប្រែប្រួលនៃបរិបទ

៨. តំបន់អាស៊ី និងប៉ាស៊ីហ្វិក ដែលជាតំបន់មានប្រជាជនរស់នៅ និងមានកំណើនលឿនបំផុតនៅលើពិភពលោក កំពុងតែឆ្លងកាត់ការប្រែប្រួលសង្គម និងបរិស្ថានយ៉ាងខ្លាំង។ ក្តីបារម្ភពីនិរន្តរភាពរយៈពេលវែងនៃការអភិវឌ្ឍន៍ កំពុងតែមានការកើនឡើងនៅបណ្តាប្រទេសជាច្រើននៅតំបន់អាស៊ី។ ឧស្សាហកាវូបនីយកម្ម និងនគរូបនីយកម្មយ៉ាងឆាប់រហ័ស រួមជាមួយនឹងកំណើនតម្រូវការធនធានធម្មជាតិ បានធ្វើឱ្យមានការប្រែប្រួលដល់ការប្រើប្រាស់ដី និងការតាំងទីលំនៅរបស់មនុស្ស ឱនភាពបរិមាណ និងគុណភាពទឹក ការបាត់បង់ជីវចម្រុះ ការកាប់បំផ្លាញព្រៃឈើ និងរហោដ្ឋានីយកម្ម កំណើនការបំពុលបរិស្ថាន និងផលប៉ះពាល់អវិជ្ជមានចំពោះសុខភាពមនុស្ស។ ការគំរាមកំហែងនេះមាននិន្នាការប៉ះពាល់មិនសមមាត្រចំពោះអ្នកក្រីក្រ។ ដង់ស៊ីតេប្រជាជនខ្ពស់ និងកំណើនតម្រូវការដីសម្រាប់ការអភិវឌ្ឍន៍ទីក្រុង និងហេដ្ឋានរចនាសម្ព័ន្ធនានា បានបង្កើនហានិភ័យនៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តរបស់មនុស្ស និងផលប៉ះពាល់អវិជ្ជមានចំពោះក្រុមងាយរងគ្រោះ ដូចជាអ្នកក្រីក្រ និងក្រុមជនជាតិដើមភាគតិច។ ក្នុងចំណោមក្រុមជនជាតិដើមភាគតិច ២៥០លាននាក់នៅក្នុងពិភពលោក មានក្រុមជនជាតិដើមភាគតិចប្រមាណជា ៧០% រស់នៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក។ ភាសាប្រមាណជា ១២០ បានកំពុងនឹងរងគ្រោះ ឬវិនាសបាត់បង់ ដែលនេះជាការបង្ហាញនូវការគំរាមកំហែងចំពោះវប្បធម៌ និងបូរណភាពរបស់ក្រុមជនជាតិដើមភាគតិច។ បញ្ហាប្រឈមនៃការបង្កាការបាត់បង់បន្ថែមទៀតដែលកើតចេញពីការរេចរឹលបរិស្ថាន និងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ការទទួលស្គាល់នូវតម្រូវការពិសេស និងគោរពសិទ្ធិក្រុមជនជាតិដើមភាគតិច និងក្រុមងាយរងគ្រោះផ្សេងទៀត និងការលើកកម្ពស់គោលនយោបាយ និងកសាងសមត្ថភាពរបស់ DMC ក្នុងការគ្រប់គ្រងផលប៉ះពាល់ទាំងនេះ មិនមែនជារឿងតូចតាចឡើយ។

៩. DMC បានឆ្លើយតបនឹងបញ្ហាប្រឈមសង្គម និងបរិស្ថានថ្មីៗ ក្នុងកម្រិតខុសៗគ្នា។ DMC មួយចំនួនបានលើកកម្ពស់គោលនយោបាយការពារបរិស្ថាន និងសង្គម និងក្របខណ្ឌនិយតកម្ម ចំណែកឯ DMC ផ្សេងទៀតនៅតែប្រើប្រព័ន្ធមិនទាន់សម័យ និងតែងតែពឹងផ្អែកលើនីតិវិធី និងគោលនយោបាយរបស់ទីភ្នាក់ងារផ្តល់ជំនួយ។ ដំណើរការអភិវឌ្ឍន៍ក្នុងតំបន់ បានកែប្រែតួនាទី និងការទទួលខុសត្រូវរបស់អង្គភាពរដ្ឋ និងឯកជន សង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន ឱ្យគាំទ្រដល់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពបរិស្ថាន និងសង្គម និងការរំពឹងចង់បានកាន់តែខ្លាំងនូវតម្លាភាព និងការចូលរួមរបស់ប្រជាជន។ ដូចគ្នានេះដែរ តួនាទីរបស់

ធនាគារពាណិជ្ជ និងអន្តរការីហិរញ្ញវត្ថុ បានកើនឡើងស្របទៅតាមការដាក់សម្ពាធឱ្យសាជីវកម្មធ្វើការទទួលខុសត្រូវសង្គម និងបរិស្ថានឱ្យបានប្រាកដប្រជា។ DMC ទទួលស្គាល់កាន់តែខ្លាំងឡើងនូវតម្រូវការលើកកម្ពស់ស្តង់ដាររបស់ពួកគេឆ្ពោះទៅទម្លាប់អនុវត្តល្អជាអន្តរជាតិ អភិវឌ្ឍន៍សមត្ថភាពដើម្បីឆ្លើយតបនឹងហានិភ័យបរិស្ថាន និងសង្គមក្នុងតំបន់ និងសកល និងជម្រុញកំណើនប្រកបដោយនិរន្តរភាពសង្គម និងបរិស្ថាន។ លើសពីនេះទៀត អ្នកគាំទ្រគម្រោងវិស័យឯកជន បានបង្កើននូវឆន្ទៈក្នុងការអនុម័តយកនូវទម្លាប់វិនិយោគវិវត្តដែលមានការទទួលខុសត្រូវសង្គម និងបរិស្ថាន ហើយពួកគេអាចនឹងធ្វើលើសពីការអនុលោមតាមនិយតកម្មទាំងនេះ ប្រសិនបើពួកគេមានមូលហេតុពាណិជ្ជកម្មច្បាស់លាស់ក្នុងការធ្វើបែបនេះ។

១០. MFI បានធ្វើបច្ចុប្បន្នភាពគោលនយោបាយការពារបរិស្ថាន និងសង្គមរបស់ពួកគេ ដើម្បីធានាថាគោលនយោបាយការពារទាំងនេះអាចឆ្លើយតបនឹងតម្រូវការប្រែប្រួល។ នៅឆ្នាំ ២០០៥ ធនាគារពិភពលោកបានអនុវត្តកម្មវិធីសាកល្បងប្រើប្រាស់ប្រព័ន្ធការពារក្នុងប្រទេសដើម្បីដោះស្រាយ បញ្ហាការពារសង្គម និងបរិស្ថាន នៅក្នុងប្រតិបត្តិការដែលគាំទ្រដោយធនាគារ[៣]។ នៅខែមករា ឆ្នាំ ២០០៨ ធនាគារពិភពលោកបានចេញរបាយការណ៍វាយតម្លៃជំហានដំបូងនៃកម្មវិធីសាកល្បងប្រើប្រាស់ប្រព័ន្ធការពារក្នុងប្រទេស[៤]។ យោងតាមរបាយការណ៍នេះ ធនាគារពិភពលោកបានអនុម័តបន្តកម្មវិធីនេះ ដោយពង្រីកគំនិតផ្តួចផ្តើមនេះបន្តិចម្តងៗពីកម្រិតគម្រោងទៅកម្រិតថ្នាក់ជាតិ ដើម្បីឱ្យអ្នកខ្ចី និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត អាចផ្តល់ការការពារបានទូលំទូលាយ និងដើម្បីអាចកសាងសមត្ថ-ភាពអ្នកខ្ចីឱ្យមាននិរន្តរភាពជាជាងការសម្រេចបាននៅត្រឹមកម្រិតគម្រោង។ ធនាគារពិភពលោក ក៏បានកែសម្រួលគោលនយោបាយការពារក្រុមជនជាតិដើមភាគតិចឆ្នាំ ២០០៥ និងគោលនយោបាយការពារធនធានវប្បធម៌រូបវន្តឆ្នាំ ២០០៦ របស់ខ្លួនផងដែរ ដើម្បីឆ្លុះបញ្ចាំងពីការប្រែប្រួល។ នៅឆ្នាំ ២០០៦ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បានអនុម័ត *គោលនយោបាយ និងស្តង់ដារអនុវត្តស្តីពីនិរន្តរភាពសង្គម និងបរិស្ថាន*[៥] ដែលដាក់ឱ្យអនុវត្តនូវលក្ខខណ្ឌតម្រូវផ្អែកលើលទ្ធផល និងទម្លាប់អនុវត្តល្អសម្រាប់វិស័យឯកជន។ ស្ថាប័នហិរញ្ញវត្ថុពាណិជ្ជកម្មប្រមាណជា ៦០ បានអនុម័តយកស្តង់ដារអនុវត្តថ្មីរបស់ IFC សម្រាប់គម្រោងហិរញ្ញប្បទាន។ នៅឆ្នាំ ២០០៦ ធនាគារអភិវឌ្ឍន៍អន្តរអាមេរិក បានចេញ *គោលនយោបាយបរិស្ថាន និងអនុលោមភាពការពារ*[៦] ដែលបានចែងពីការគិតគូរការប្រើប្រាស់ "ប្រព័ន្ធក្នុងប្រទេស"។ នៅខែឧសភា ឆ្នាំ ២០០៨ ធនាគារអឺរ៉ុបសម្រាប់ការស្ថាបនា និងអភិវឌ្ឍន៍ (EBRD) បានអនុម័ត *គោលនយោបាយបរិស្ថាន និងសង្គម*[៧] និងលក្ខខណ្ឌតម្រូវអនុវត្តចំនួន ១០ ផ្សេងទៀត ដែលត្រូវអនុវត្តជំនួសគោល-នយោបាយបរិស្ថានឆ្នាំ ២០០៣ របស់ខ្លួន។ គោលនយោបាយ និងលក្ខខណ្ឌតម្រូវអនុវត្តថ្មីរបស់ EBRD កំណត់ពីការការពារប្រហាក់

---

៣ ធនាគារពិភពលោក ២០០៥. *ការសាកល្បងប្រើប្រាស់ប្រព័ន្ធរបស់អ្នកខ្ចីក្នុងការដោះស្រាយបញ្ហាការពារបរិស្ថាន និងសង្គមនៅក្នុងគម្រោងដែលគាំទ្រដោយធនាគារ* Washington, DC.

៤ ធនាគារពិភពលោក ២០០៨. *ការវាយតម្លៃជំហានដំបូងនៃកម្មវិធីសាកល្បងប្រើប្រាស់ប្រព័ន្ធការពារក្នុងប្រទេសក្នុងការការពារបរិស្ថាន និងសង្គម* Washington, DC.

៥ IFC ២០០៦. *គោលនយោបាយ និងស្តង់ដារអនុវត្តស្តីពីនិរន្តរភាពសង្គម និងបរិស្ថាន* Washington, DC.

៦ ធនាគារអភិវឌ្ឍន៍អន្តរអាមេរិក ២០០៦. *គោលនយោបាយបរិស្ថាន និងអនុលោមភាពការពារ* Washington, DC.

៧ EBRD. ២០០៨. *គោលនយោបាយបរិស្ថាន និងសង្គម EBRD* ទីក្រុងឡុងដ៍

ប្រហែល នឹងលក្ខខណ្ឌតម្រូវការពាររបស់ IFC ដែរ ប៉ុន្តែបានឆ្លុះបញ្ចាំងពីលក្ខណៈដាច់ដោយឡែកជាក់លាក់នៃតំបន់ប្រតិបត្តិការរបស់ EBRD និងការប្តេជ្ញារបស់ EBRD តាមគោលការណ៍បរិស្ថានរបស់សហគមន៍អឺរ៉ុប ដែល EBRD ជាភាគីហត្ថលេខី ។

១១. ការធ្វើឱ្យមានភាពស្របគ្នារវាងប្រព័ន្ធការពាររបស់ម្ចាស់ជំនួយ និងប្រព័ន្ធការពារក្នុងប្រទេស កំពុងតែទទួលបាននូវការចាប់អារម្មណ៍កាន់តែខ្លាំងឡើងៗ។ នៅឆ្នាំ ២០០៥ សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពជំនួស បានបង្កើតនូវការប្តេជ្ញាជាសកលរបស់ម្ចាស់ជំនួយ និងប្រទេសជាដៃគូ ក្នុងការលើកកម្ពស់ការគ្រប់គ្រង និងប្រសិទ្ធភាពជំនួយ ដើម្បីកាត់បន្ថយភាពក្រីក្រ និងអសមត្ថភាព ជម្រុញកំណើន កសាងសមត្ថភាព និងពន្លឿននូវការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ។ សេចក្តីថ្លែងការណ៍មានគោលការណ៍ ៥ : (១) ធានានូវភាពជាម្ចាស់របស់ប្រទេស (២) តម្រង់ឱ្យស្របគ្នារវាងកម្មវិធីម្ចាស់ជំនួយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ អាទិភាព និងនីតិវិធីរបស់ប្រទេស (៣) ឱ្យបណ្តាម្ចាស់ជំនួយធ្វើឱ្យស្របគ្នា នូវវិធីសាស្ត្រ និងសកម្មភាពរបស់ពួកគេ (៤) គ្រប់គ្រងដើម្បីលទ្ធផលអភិវឌ្ឍន៍ និង (៥) មានគណនេយ្យភាពទៅវិញទៅមក ។ គោលការណ៍ទាំងនេះ បានផ្តល់សន្ទុះជម្រុញយ៉ាងខ្លាំងដល់ម្ចាស់ជំនួយក្នុងការជួយដល់ការធ្វើសមាហរណកម្មការគិតគូរពីសង្គម និងបរិស្ថាន ទៅក្នុងយុទ្ធសាស្ត្រ និងអាទិភាពរបស់ប្រទេសជាដៃគូ និងបន្តពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការធ្វើឱ្យស្របគ្នានូវវិធីសាស្ត្រដោះស្រាយបញ្ហាសង្គម និងបរិស្ថាន។ របៀបវារៈសកម្មភាពទីក្រុង Accra ដែលបានអនុម័តនៅឆ្នាំ ២០០៨ បានអះអាងជាថ្មីម្តងទៀតនូវគោលការណ៍ទាំងនេះ និងបានធ្វើការសង្កត់ធ្ងន់បន្ថែមទៀតពីសារៈសំខាន់នៃប្រព័ន្ធការពារក្នុងប្រទេស។ ការពិគ្រោះយោបល់ដែលរៀបចំធ្វើក្នុងបរិបទនៃកិច្ចខិតខំប្រឹងប្រែងរបស់ ADB ក្នុងគោលបំណងពង្រឹងការគាំទ្រដល់អ្នកខ្ចីធនធានមូលធនធម្មតា (OCR) បានបង្ហាញឱ្យឃើញថា អតិថិជនវិស័យសាធារណៈ បានឯកភាពជារួមជាមួយនឹងកម្មវត្ថុ និងគោលការណ៍ការពាររបស់ ADB បើទោះជាមានអតិថិជន OCR មួយចំនួន ជឿជាក់ថា គោលការណ៍ការពារចម្រុះ អាចនឹងមានប្រសិទ្ធភាពប្រសើរជាង ប្រសិនបើប្រើប្រាស់ប្រព័ន្ធការពាររបស់ពួកគេ ជាជាងប្រើប្រាស់នីតិវិធីរបស់ ADB ។

១២. លក្ខណៈអាជីវកម្មរបស់ ADB ក៏កំពុងតែមានការប្រែប្រួល។ ឆ្លើយតបនឹងកំណើនសេដ្ឋកិច្ចតាមការរំពឹងទុក និងការប្រែប្រួលក្នុងការអភិវឌ្ឍន៍ ជំនួយ និងទិដ្ឋភាពហិរញ្ញវត្ថុនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក ADB នឹងផ្លាស់ប្តូរខ្លួនទៅតាមបញ្ហាប្រឈមទាំងនេះ ប៉ុន្តែនៅតែរក្សានូវគោលដៅជារួមរបស់ខ្លួនជានិច្ច : កាត់បន្ថយភាពក្រីក្រនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក។ ADB នឹងសម្រេចនូវទស្សនៈវិស័យ និងបេសកកម្មរបស់ខ្លួន តាមរយៈការផ្តោតលើកំណើនស៊ីជម្រៅ កំណើនប្រកបដោយនិរន្តរភាពបរិស្ថាន និងសហរណកម្មតំបន់។ ក្របខណ្ឌយុទ្ធសាស្ត្ររយៈពេលវែង ២០០៨-២០២០ របស់ ADB (យុទ្ធសាស្ត្រ ២០២០)[៨] ផ្តោតលើការកែប្រែសំខាន់ៗចំនួន ៥ : (១) ប្រតិបត្តិការ និងការអភិវឌ្ឍន៍វិស័យឯកជន (២) អភិបាលកិច្ចល្អ និងការអភិវឌ្ឍន៍សមត្ថភាព (៣) សមត្ថភាពយេនឌ័រ (៤) ដំណោះស្រាយចំណេះដឹង និង (៥) ភាពជាដៃគូ។ ADB ក៏ផ្តោតប្រតិបត្តិការរបស់ខ្លួនលើផ្នែកឯកទេសស្នូលចំនួន ៥ : (១) ហេដ្ឋារចនាសម្ព័ន្ធ (២) បរិស្ថាន រួមទាំងការប្រែប្រួលអាកាសធាតុ (៣) សមាហរណកម្ម និងសហប្រតិបត្តិការតំបន់ (៤) ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និង (៥) ការអប់រំ។ ដោយសារតែការពង្រីកកម្មវិធីវិស័យឯកជន ការវិនិយោគ និងអតិថិជនចម្រុះក្នុងវិស័យហិរញ្ញវត្ថុ និងទីផ្សារមូលធន និងការកើនឡើងនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំដែលផល

[៨] ADB. ២០០៨. *យុទ្ធសាស្ត្រ ២០២០: ក្របខណ្ឌយុទ្ធសាស្ត្ររយៈពេលវែង ២០០៨-២០២០ របស់ធនាគារអភិវឌ្ឍន៍អាស៊ី* ទីក្រុងម៉ានីល

ប៉ះពាល់លើសង្គម និងបរិស្ថាន អាចនឹងមានភាពស្មុគស្មាញ និងងាយរងការប៉ះពាល់ខ្លាំង គោលនយោបាយការពារចាំបាច់ត្រូវតែធ្វើបច្ចុប្បន្នភាព ដើម្បីធានានិរន្តរភាពសង្គម និងបរិស្ថានរបស់គម្រោង។ នេះគឺជាសមាសធាតុដ៏សំខាន់នៃលទ្ធផលវិជ្ជមាននៃការអភិវឌ្ឍន៍។

១៣. នៅខែសីហា ឆ្នាំ ២០០៤ ADB បានអនុម័តរបៀបវារៈកំណែទម្រង់ស៊ីជម្រៅមួយ និងបានដាក់ឱ្យប្រើគំរូ និងលិខិតុបករណ៍ផ្តល់ប្រាក់កម្ចីថ្មីៗ ដើម្បីពង្រឹងនូវប្រសិទ្ធភាពអភិវឌ្ឍន៍នៃប្រតិបត្តិការរបស់ខ្លួន។ គំនិតផ្តួចផ្តើមថ្មីៗរបស់ ADB - ការគ្រប់គ្រងលទ្ធផលអភិវឌ្ឍន៍ ការច្នៃប្រឌិត និង ប្រសិទ្ធភាពនៃគំនិតផ្តួចផ្តើម និងការពង្រឹងការគាំទ្ររបស់ ADB ចំពោះប្រទេសមានចំណូលមធ្យម និងអ្នកខ្ចី OCR - បានវិវត្តស្របទៅតាមមតិយល់ឃើញជារួមរបស់អន្តរជាតិ អំពីតម្រូវការក្នុងការលើកកំពស់ប្រសិទ្ធភាពជំនួយ។ គោលនយោបាយការពារបច្ចុប្បន្ន ត្រូវបានរៀបចំឡើងនៅពេលដែលការផ្តល់ប្រាក់កម្ចីដោយផ្ទាល់ដល់គម្រោងគឺជាគំរូមួយដ៏សំខាន់ក្នុងការផ្តល់ជំនួយអភិវឌ្ឍន៍។ គោលនយោបាយការពារ ត្រូវតែកែសម្រួលទៅតាមការវិវត្តនៃផលិតផលផ្តល់ប្រាក់កម្ចី និងគំរូផ្តល់ហិរញ្ញប្បទានថ្មីៗរបស់ ADB ដែលញឹកញាប់ត្រូវបានអនុវត្តមិនបានល្អដោយយុទ្ធវិធីការពារកម្រិតគម្រោងដែលបានធ្វើកន្លងមក។ គំរូផ្តល់ប្រាក់កម្ចី និងលិខិតុបករណ៍ហិរញ្ញវត្ថុថ្មីៗ ដូចជា ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញប្បទានពហុភាគី (MFF) បានធ្វើឱ្យការអនុវត្តគោលនយោបាយការពារ និងការធានានូវអនុលោមភាពកាន់តែមានភាពស្មុគស្មាញ។ គំរូផ្តល់ប្រាក់កម្ចីថ្មីៗ និងការបន្តលេចចេញនូវគំរូថ្មីៗបន្ថែមទៀត ព្រមទាំងការប្រែប្រួលស្ថានភាពអតិថិជន គឺជាការផ្តល់តម្រុយឱ្យធ្វើការពង្រឹងនូវភាពពាក់ព័ន្ធ និងប្រសិទ្ធភាពនៃការការពាររបស់ ADB។

## III. គោលនយោបាយការពារ និង បទពិសោធន៍បច្ចុប្បន្ន

### ក. គោលនយោបាយការពារបច្ចុប្បន្នរបស់ ADB

១៤. **ក្របខណ្ឌគោលនយោបាយការពារ ADB :** គោលនយោបាយការពារ ជាគោលនយោបាយប្រតិបត្តិការដែលព្យាយាមបញ្ចៀស បន្ធូរបន្ថយ ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមានចំពោះបរិស្ថាន និងសង្គម រួមទាំងការពារសិទ្ធិរបស់មនុស្ស ដែលត្រូវរងផលប៉ះពាល់ ឬត្រូវបាត់បង់ឥទ្ធិពលដោយសារដំណើការអភិវឌ្ឍន៍។ ក្របខណ្ឌគោលនយោបាយការពាររបស់ ADB មានគោលនយោបាយប្រតិបត្តិការចំនួន ៣ : គោលនយោបាយស្តីពីបរិស្ថាន[៩] ក្រុមជនជាតិដើមភាគតិច និងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត។ គោលនយោបាយទាំងនេះ ត្រូវបានអមដោយ *សៀវភៅណែនាំប្រតិបត្តិការ* ផ្នែកស្តីពីការគិតគូរពីបរិស្ថានក្នុងប្រតិបត្តិការរបស់ ADB[១០] ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត[១១] និងក្រុមជនជាតិដើមភាគតិច[១២]។ ក្រៅពីគោលនយោបាយការពារទាំងបី

---

[៩] *គោលនយោបាយស្តីពីបរិស្ថាន* មានធាតុចំបងៗចំនួន ៥ ប៉ុន្តែមានតែធាតុទី ៥ ប៉ុណ្ណោះដែលពាក់ព័ន្ធ នឹងការការពារបរិស្ថាន (ដាក់បញ្ចូលការគិតគូរពីបរិស្ថានក្នុងប្រតិបត្តិការរបស់ ADB) កថាខណ្ឌ ៣០ និង ៥០-៧០)។

[១០] ADB. ២០០៦. *សៀវភៅណែនាំពីប្រតិបត្តិការ ផ្នែក F1 : ការគិតគូរពីបរិស្ថានក្នុងប្រតិបត្តិការរបស់ ADB* ទីក្រុងម៉ានីល

[១១] ADB. ២០០៦. *សៀវភៅណែនាំពីប្រតិបត្តិការ ផ្នែក F2 : ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត* ទីក្រុងម៉ានីល

[១២] ADB. ២០០៦. *សៀវភៅណែនាំពីប្រតិបត្តិការ ផ្នែក F3 : ក្រុមជនជាតិដើមភាគតិច* ទីក្រុងម៉ានីល

គោលនយោបាយតាមវិស័យមួយចំនួនក៏មានចែងពីការការពារបរិស្ថានផងដែរ ដូចជាគោលនយោបាយដែលពាក់ព័ន្ធនឹងទឹក ថាមពល និងព្រៃឈើ ។

១៥. **លក្ខខណ្ឌតម្រូវសម្រាប់ការពារ :** គោលនយោបាយការពារទាំងបី មានចែងពីដំណើរដែលមានលក្ខណៈជាប្រព័ន្ធក្នុងការវាយតម្លៃផលប៉ះពាល់ ការរៀបចំផែនការ និងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានរបស់គម្រោងក្នុងមួយវដ្តគម្រោង ។ គោលនយោបាយការពារតម្រូវឱ្យ (១) កំណត់ និងវាយតម្លៃផលប៉ះពាល់នៅដើមដំណាក់កាលនៃវដ្តគម្រោង (២) រៀបចំ និងអនុវត្តផែនការបញ្ចៀស បន្ធូរបន្ថយ កាត់បន្ថយ ឬប៉ះប៉ូវសងនូវផលប៉ះពាល់អវិជ្ជមាន និង (៣) ជូនដំណឹង និងពិគ្រោះយោបល់ជាមួយក្រុមមនុស្សរងផលប៉ះពាល់នៅអំឡុងពេលរៀបចំ និងអនុវត្តគម្រោង ។ គោលនយោបាយទាំងនេះ អនុវត្តចំពោះគ្រប់គម្រោងទាំងអស់ដែលទទួលបានហិរញ្ញប្បទានពី ADB រួមទាំងប្រតិបត្តិការវិស័យឯកជន និងសមាសភាគគម្រោងទាំងអស់ ។ លក្ខខណ្ឌតម្រូវនីតិវិធីផ្ទៃក្នុង មានលម្អិតនៅក្នុង *សៀវភៅណែនាំប្រតិបត្តិការ* (លេខយោង ១០-១២) និងមានដំណើរការអនុវត្តប្រហាក់ប្រហែលគ្នាដូចតទៅ : សម្រិតសម្រាំង និងកំណត់វិសាលភាពនៃបញ្ហាចំបងៗឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន នៅក្រោយពេលដែលគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយ ADB ត្រូវបានកំណត់ និងបន្តធ្វើនៅពេញមួយវដ្តគម្រោង ។ (២) វាយតម្លៃផលប៉ះពាល់ និងរៀបចំផែនការការពារដែលមានសង្ខេបពីវិធានការកាត់បន្ថយ កម្មវិធីតាមដាន និងការរៀបចំស្ថាប័ន និងធ្វើការរៀបចំបញ្ចូលការការពារក្នុងការរចនា និងការអនុវត្តគម្រោង ។ (៣) ពិគ្រោះយោបល់ជាមួយក្រុមមនុស្សរងផលប៉ះពាល់ក្នុងអំឡុងពេលរៀបចំ និងអនុវត្តគម្រោង ហើយព័ត៌មានត្រូវផ្សព្វផ្សាយក្នុងទម្រង់ លក្ខណៈ និងភាសាដែលពួកគេអាចយល់បាន និង (៤) ផ្សព្វផ្សាយផែនការការពារជាសាធារណៈ និងធ្វើបច្ចុប្បន្នភាពព័ត៌មានទាំងនោះនៅដំណាក់កាលនានានៃវដ្តគម្រោង [១៣] ។ គោលនយោបាយការពាររបស់ ADB តម្រូវឱ្យគោរពតាមទាំងលក្ខខណ្ឌតម្រូវការពាររបស់ ADB និងលក្ខខណ្ឌតម្រូវការពាររបស់ DMC ។

១៦. **តួនាទី និង ការទទួលខុសត្រូវ :** គោលការណ៍មូលដ្ឋាននៃគោលនយោបាយការពារបច្ចុប្បន្នទាំង ៣ គឺការអនុវត្តបទ-បញ្ញត្តិនៃគោលនយោបាយគឺជាការទទួលខុសត្រូវរបស់អ្នកខ្ចី/អតិថិជន ។ អ្នកខ្ចី/អតិថិជន ត្រូវធ្វើការវាយតម្លៃបរិស្ថាន និងសង្គម រៀបចំការពិគ្រោះយោបល់ជាមួយក្រុមមនុស្ស និងសហគមន៍រងផលប៉ះពាល់ រៀបចំ និងអនុវត្តផែនការការពារ តាមដានការអនុវត្តផែនការការពារ និងរៀបចំ និងផ្ញើរបាយការណ៍តាមដាន ។ តួនាទីរបស់ ADB គឺពន្យល់បកស្រាយលក្ខខណ្ឌតម្រូវគោលនយោបាយដល់អ្នកខ្ចី/អតិថិជន ជួយអ្នកខ្ចី/អតិថិជនបំពេញលក្ខខណ្ឌតម្រូវទាំងនេះ នៅអំឡុងពេលរៀបចំចាត់ចែង និងអនុវត្តគម្រោង តាមរយៈកម្មវិធីកសាងសមត្ថភាព ធានានូវការអង្កេត និងវាយតម្លៃលម្អិត និងធ្វើការតាមដាន និងត្រួតពិនិត្យ ។ ចំណាប់អារម្មណ៍ជាច្រើនត្រូវបានផ្តោតលើការរៀបចំចាត់ចែង និងអនុម័តគម្រោងនៅក្នុងវដ្តគម្រោង តែតួនាទីរបស់ ADB ក្នុងការតាមដានអនុលោមភាពនៅតែបន្តនៅអំឡុងពេលអនុវត្តគម្រោង ។ របាយការណ៍បញ្ចប់គម្រោង និងរបាយការណ៍វាយតម្លៃលទ្ធផលគម្រោងរបស់ ADB មានធ្វើការវាយតម្លៃការអនុវត្តគោលនយោបាយការពារ ។

---

[១៣] *គោលនយោបាយទំនាក់ទំនងសាធារណៈ* (២០០៥) របស់ ADB ចែងពីលក្ខខណ្ឌតម្រូវផ្សព្វផ្សាយសម្រាប់សកម្មភាពនានារបស់ ADB រួមទាំងការការពារ ។

## ខ.    ការត្រួតពិនិត្យអនុលោមភាព

១៧.    **ប្រព័ន្ធអនុលោមភាព :** ក្រោយការរៀបចំរចនាសម្ព័ន្ធអង្គការជាថ្មីនៅឆ្នាំ ២០០២[១៤] ADB បង្កើតនូវការរៀបចំតាមដានអនុលោមភាពរបស់គម្រោងក្នុងការអនុវត្តគោលនយោបាយការពារ។ ដោយមានការគាំទ្រពីផ្នែកការពារបរិស្ថាន និងសង្គម ប្រធានមន្ត្រីអនុលោមភាពរបស់ ADB ជាអ្នកទទួលខុសត្រូវគ្រប់គ្រង និងចាត់ចែងនាយកដ្ឋានអនុលោមភាពការពារ និងការណែនាំ និងនីតិវិធីប្រតិបត្តិការពាក់ព័ន្ធ។ ការអនុវត្តតាមគោលនយោបាយការពារត្រូវបានតាមដានពេញមួយវដ្តគម្រោង។ ប្រសិនបើគម្រោងអាចនឹងមានហានិភ័យនៃការមិនអនុលោមតាម  អនុសាសន៍សកម្មភាពធានាអនុលោមនឹងត្រូវផ្តល់នៅក្នុងកិច្ចប្រជុំវាយតម្លៃរបស់ថ្នាក់គ្រប់គ្រង ហើយអនុលោមភាពគម្រោងនឹងត្រូវវាយតម្លៃជាថ្មីម្តងទៀតនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការវាយតម្លៃរបស់បុគ្គលិក។ នាយកដ្ឋានប្រតិបត្តិការចាត់វិធានការធានានូវការបំពេញលក្ខខណ្ឌតម្រូវការពារដែលមិនទាន់បានបំពេញ នៅមុនពេលក្រុមប្រឹក្សាភិបាលអនុម័តយល់ព្រម។ បេសកកម្មវាយតម្លៃ ត្រូវបានរៀបចំធ្វើនៅអំឡុងពេលអនុវត្តគម្រោង ដើម្បីតាមដានការអនុវត្តតាមបទបញ្ញត្តិស្តីពីការការពារដែលមានចែងក្នុងកិច្ចព្រមព្រៀងតាមច្បាប់ និងដើម្បីចាត់វិធានការសមស្រប ប្រសិនបើគម្រោងអាចនឹងមិនមានអនុលោមភាព។

១៨.    **យន្តការគណនេយ្យភាព :** នៅខែ ឧសភា ឆ្នាំ ២០០៣ ADB បានអនុម័តយន្តការគណនេយ្យភាពថ្មីមួយ[១៥] ដែលក្រុមមនុស្សរងផលប៉ះពាល់ អវិជ្ជមានពីគម្រោងផ្តល់ហិរញ្ញប្បទានដោយ ADB អាចប្តឹងតវ៉ាទាមទារដំណោះស្រាយ និងរាយការណ៍ពីការរំលោភបំពានគោលនយោបាយប្រតិបត្តិការ និងនីតិវិធីរបស់ ADB រួមទាំងគោលនយោបាយការពារផង។ យន្តការគណនេយ្យភាព ជាយន្តការជំនួស *តួនាទីអធិការកិច្ច* (១៩៩៥)[១៦] របស់ ADB។ យន្តការគណនេយ្យភាពរបស់ ADB មានមុខងារដាច់ដោយឡែក (តែពាក់ព័ន្ធគ្នា) ចំនួន ២ : (១) ការពិគ្រោះយោបល់ (ដែលដឹកនាំដោយអ្នកសម្របសម្រួលគម្រោងពិសេសរបស់ ADB) ដើម្បីជួយក្រុមមនុស្សដែលរងផលប៉ះពាល់អវិជ្ជមានពីគម្រោងផ្តល់ហិរញ្ញប្បទានដោយ ADB ក្នុងការស្វែងរកដំណោះស្រាយចំពោះបញ្ហារបស់ពួកគេ និង (២) ផ្តល់នូវដំណើរដែលក្រុមមនុស្សរងផលប៉ះពាល់ពីគម្រោងអាចដាក់ពាក្យបណ្តឹងពីអនុលោមភាពដែលនឹងត្រូវពិនិត្យដោយគណៈកម្មការពិនិត្យអនុលោមភាពរបស់ ADB។

## គ.    បទពិសោធន៍ ADB ក្នុងការអនុវត្តគោលនយោបាយការពារ :

១៩.    **បរិស្ថាន :** ADB ចាប់អនុវត្តការវាយតម្លៃបរិស្ថានជាផ្លូវការនៅក្នុងប្រតិបត្តិការផ្តល់កម្ចីរបស់ខ្លួននៅឆ្នាំ ១៩៧៩[១៧]។ គិតត្រឹមដល់ពេលដែល *គោលនយោបាយស្តីពីបរិស្ថាន* នៅពេលបច្ចុប្បន្នត្រូវបានអនុម័តនៅឆ្នាំ ២០០២ ADB មានបទពិសោធន៍ជាង ២ ទសវត្សរ៍ក្នុងការវាយតម្លៃ និងគ្រប់គ្រងបរិស្ថាន។ នៅអំឡុងពេលនោះ គោលការណ៍គោលនយោបាយ និងទំហំនៃការការពារ

---

[១៤] ADB. ២០០១. *ការរៀបចំរចនាសម្ព័ន្ធអង្គការជាថ្មីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី* ទីក្រុងម៉ានីល

[១៥] ADB. ២០០៣. *ការវាយតម្លៃតួនាទីអធិការកិច្ច : ការបង្កើតយន្តការគណនេយ្យភាពថ្មីរបស់ ADB* ទីក្រុងម៉ានីល

[១៦] ADB. ១៩៩៥. *ការបង្កើតតួនាទីអធិការកិច្ច* ទីក្រុងម៉ានីល

[១៧] ADB. ១៩៧៩. ការគិតគូរពីបរិស្ថានក្នុងប្រតិបត្តិការរបស់ ADB ទីក្រុងម៉ានីល

បរិស្ថាន បានវិវត្តពីការផ្ដោតជាបឋមលើការវាយតម្លៃបច្ចេទេស និងវិធានការកាត់បន្ថយ ឆ្ពោះទៅរកការអភិវឌ្ឍន៍ និងអនុវត្តផែនការគ្រប់គ្រងបរិស្ថាន (EMP) ស៊ីជម្រៅ។ ធាតុសំខាន់ៗនៃ EMP រួមមានវិធានការកាត់បន្ថយ កម្មវិធីតាមដាន ការប៉ាន់ស្មានសោហ៊ុយចំណាយ កញ្ចប់ថវិកា និងរៀបចំស្ថាប័នសម្រាប់ការអនុវត្ត។ ក្រៅពីនេះ ដំណើរការវាយតម្លៃបរិស្ថាន សង្កត់ធ្ងន់ទៅលើការពិគ្រោះយោបល់ជាមួយសាធារណជន ការផ្សព្វផ្សាយព័ត៌មាន និងការពិចារណាពីជម្រើសផ្សេងទៀត។ បើទោះជានីតិវិធីអនុលោមភាពបានត្រូវលើកកម្ពស់ជាលំដាប់ ចំណុចសំខាន់នៃអនុលោមភាព ដែលមានដូចជាការដាក់បញ្ចូលលទ្ធផល និងអនុសាសន៍នៃការវាយតម្លៃបរិស្ថានទៅក្នុងការរចនាគម្រោង ភាពជាម្ចាស់របស់អ្នកខ្ចី/អតិថិជនលើ EMP និងប្រសិទ្ធភាពនៃការអនុវត្ត EMP នៅតែជាបញ្ហាប្រឈមដដែល។

២០. *ការសិក្សាវាយតម្លៃពិសេសស្ដីពីការការពារបរិស្ថាន*[១៨] ឆ្នាំ ២០០៦ របស់នាយកដ្ឋានវាយតម្លៃប្រតិបត្តិការ បានសន្និដ្ឋានថា ធាតុការពារនៃគោលនយោបាយបរិស្ថានរបស់ ADB មានការពាក់ព័ន្ធ និងមានប្រសិទ្ធភាពក្នុងការបញ្ចៀសនូវផលប៉ះពាល់អវិជ្ជមាន ពីគម្រោងផ្ដល់ហិរញ្ញប្បទានដោយ ADB បើទោះជាសោហ៊ុយចំណាយបានកាត់បន្ថយប្រសិទ្ធភាពនៃការរៀបចំចាត់ចែងគម្រោងក៏ដោយ។ ការសិក្សាបានផ្ដល់អនុសាសន៍ឱ្យធ្វើការកែសម្រួល *គោលនយោបាយបរិស្ថាន* ដើម្បី (១) បង្វែរការយកចិត្តទុកដាក់ពី "ការរៀបចំចាត់ចែង និងអនុម័តប្រាក់កម្ចីទុកជាមុន" ទៅផ្ដោតលើការសម្រេចលទ្ធផល (២) ធ្វើឱ្យប្រសើរឡើងនូវការបញ្ចូល និងធ្វើឱ្យស្របគ្នារវាងប្រព័ន្ធ និងនីតិវិធីការពារក្នុងប្រទេស និងគោលនយោបាយវាយតម្លៃបរិស្ថាន (៣) ពង្រីកការផ្ដោតការអនុវត្តគោលនយោបាយពីគម្រោងទៅការកសាងសមត្ថភាព និង (៤) ធ្វើឱ្យប្រសើរឡើងនូវការបញ្ចូលការការពារបរិស្ថាន និងសង្គម ដើម្បីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។ ការសិក្សាក៏បានផ្ដល់អនុសាសន៍ឱ្យ ADB ពិចារណា (១) ពង្រឹងជំនាញបរិស្ថានរបស់ស្ថានបេសកកម្ម (២) ផ្ដល់ឱ្យអង្គការមិនមែនរដ្ឋាភិបាល (NGO) នូវតួនាទីឱ្យបានទូលំទូលាយជាងនេះក្នុងការតាមដាន (៣) វាយតម្លៃការអនុវត្តគម្រោងប្រភេទ B ដែលងាយប៉ះពាល់ដល់បរិស្ថាន និងវិធានផ្សព្វផ្សាយព័ត៌មានក្នុងរយៈពេល ១២០ ថ្ងៃ សម្រាប់គម្រោងប្រភេទ A (៤) ពង្រឹងប្រព័ន្ធការពារក្នុងប្រទេស និង (៥) អភិវឌ្ឍន៍ផែនការសកម្មភាពដើម្បីអនុវត្តគោលនយោបាយបរិស្ថានកែសម្រួលថ្មី រួមទាំងការចាប់អារម្មណ៍ជាពិសេសក្នុងការធានាភាពស្របគ្នារវាងសមត្ថភាពរបស់ ADB និងលក្ខខណ្ឌតម្រូវរបស់គោលនយោបាយ។

២១. **ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត :** *គោលនយោបាយស្ដីពីការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត* បានរៀបចំឡើងនៅឆ្នាំ ១៩៩៥ ដោយយកគំរូតាមគោលនយោបាយតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តរបស់ធនាគារពិភពលោក។ ដោយសារគម្រោងផ្ដល់ហិរញ្ញប្បទានដោយ ADB កាន់តែមានភាពស្មុគ្រស្មាញ គម្រោងត្រូវតែធ្វើការដោះស្រាយផលប៉ះពាល់លើទ្រព្យសម្បត្តិ ទ្រព្យសកម្ម និងការបាត់បង់មធ្យោបាយចិញ្ចឹមជីវិត ដោយមិនចាំបាច់ផ្លាស់ទីលំនៅរូបវន្ត ជាពិសេសនៅតំបន់ទីក្រុងដែលមានអ្នកតាំងទីលំនៅក្រៅប្រព័ន្ធជាច្រើនរស់នៅ។ បទពិសោធន៍ក្នុងការអនុវត្តគោលនយោបាយទាំងនេះបានឱ្យដឹងថា គោលនយោបាយនេះនៅមានចំណុចជាច្រើនដែលអាចកែសម្រួលបាន ដូចជា (១) ដំណោះស្រាយសម្រាប់អ្នកគ្មានប័ណ្ណកម្មសិទ្ធិច្បាស់លាស់ (ឧ. អ្នកនៅសំណង់អាណាធិបតេយ្យ ឬអ្នកតាំងទីលំនៅក្រៅប្រព័ន្ធផ្សេងទៀត) (២) ចំនួនប្រាក់សំណងតាំងទីលំនៅជាថ្មី ដែលមានសោហ៊ុយ

---

[១៨] ADB. ២០០៦. *ការសិក្សាវាយតម្លៃពិសេសស្ដីពីការការពារបរិស្ថាន* ទីក្រុងម៉ានីល

តាំងទីលំនៅសមស្រប ការជួសជុល និង/ឬ ការស្តារនីតិសម្បទាន និងមធ្យោបាយចិញ្ចឹមជីវិត (៣) និយមន័យច្បាស់លាស់នៃពាក្យថា "ក្រុមមនុស្សរងផលប៉ះពាល់" និង "អ្នកបាត់បង់លំនៅដ្ឋាន" និង (៤) ការអភិវឌ្ឍន៍សមត្ថភាពរបស់ DMC ក្នុងការវាយតម្លៃផលប៉ះពាល់ និងរៀបចំ និងអនុវត្តផែនការតាំងទីលំនៅជាថ្មី។

២២. ការសិក្សាវាយតម្លៃពិសេសស្តីពីការការពារការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តឆ្នាំ ២០០៦[១៩] របស់ OED បានសន្និដ្ឋានថា *គោលនយោបាយតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត* មានប្រសិទ្ធភាពយ៉ាងខ្លាំងក្នុងការសម្រេចលទ្ធផលឱ្យក្រុមមនុស្សរងផលប៉ះពាល់ និងក្នុងការកសាងសមត្ថភាពតាំងទីលំនៅជាថ្មីរបស់ DMC ជាច្រើន។ ប៉ុន្តែ សមត្ថភាព និងដំណើរការរបស់គោលនយោបាយ ត្រូវបានវាយតម្លៃថាមិនសូវជាមានប្រសិទ្ធផល ហើយវិធីសាស្ត្រគោលនយោបាយបច្ចុប្បន្នប្រហែលជាគ្មាននិរន្តរភាពឡើយ ដោយសារតែបន្ទុកចំណាយខ្ពស់របស់ ADB និងរបស់អ្នកខ្ចី/អតិថិជន។ ហេតុនេះ ការសិក្សាវាយតម្លៃពិសេសបានផ្តល់អនុសាសន៍ថា នៅអំឡុងពេលធ្វើ SPU, ADB គួរតែ (១) សម្រុះសម្រួលនូវភាពខុសគ្នារវាង *គោលនយោបាយតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត* ឆ្នាំ ១៩៩៥ និង *សៀវភៅណែនាំប្រតិបត្តិការ* និងបញ្ជាក់ឱ្យបានច្បាស់លាស់ថាតើគោលនយោបាយគ្របដណ្តប់ទាំងការផ្លាស់ទីលំនៅរូបវន្ត និងការផ្លាស់ទីលំនៅសេដ្ឋកិច្ចឬយ៉ាងណា (២) ធ្វើការបញ្ជាក់នូវពាក្យបច្ចេកទេស និងគំរូអនុវត្តមិនច្បាស់លាស់ រួមទាំងសោហ៊ុយចំណាយតាំងទីលំនៅជាថ្មី ប្រាក់សំណង និងជំនួយផ្លាស់ទីលំនៅ សិទ្ធិរបស់អ្នករស់នៅសំណង់អាណាធិបតេយ្យ និងនីតិវិធីលទ្ធកម្មដី (៣) អភិវឌ្ឍន៍ក្របខណ្ឌផ្អែកលើលទ្ធផល ដោយមានបណ្តុំស្តង់ដារប្រតិបត្តិការ (៤) បង្កើនសមត្ថភាពរបស់ DMC និងការពឹងផ្អែកលើប្រព័ន្ធការពារក្នុងប្រទេសក្នុងការធ្វើលទ្ធកម្មដី និងការពារការតាំងទីលំនៅជាថ្មី និង (៥) ផ្តល់ការណែនាំ និងនីតិវិធីក្នុងការធ្វើប្រតិបត្តិការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តឱ្យបានច្បាស់លាស់។ SES ក៏បានកំណត់នូវភាពមិនស្របគ្នារវាងលក្ខខណ្ឌតម្រូវគោលនយោបាយ និងធនធានបុគ្គលដែលមាន និងបានផ្តល់អនុសាសន៍ឱ្យបញ្ចូលផែនការអនុវត្តគោលនយោបាយក្នុង SPU។

២៣. **ក្រុមជនជាតិដើមភាគតិច** : ADB អនុម័ត *គោលនយោបាយក្រុមជនជាតិដើមភាគតិច* នៅឆ្នាំ ១៩៩៨។ និយមន័យទូទៅនៃពាក្យថា "ក្រុមជនជាតិដើមភាគតិច" នៅក្នុងគោលនយោបាយ កំណត់តាមការឯកភាពជារួមជាអន្តរជាតិដែលបានលេចចេញក្នុងទសវត្សរ៍ថ្មីៗនេះ ការចាត់ចំណាត់ថ្នាក់ក្រុមជនជាតិដើមភាគតិចជាទូទៅដោយស្ថាប័នអន្តរជាតិដូចជា អង្គការសហប្រជាជាតិ និងអង្គការពលកម្មអន្តរជាតិ និងលក្ខន្តិកៈក្រុមជនជាតិដើមភាគតិចដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ។ ការអនុវត្តគោលនយោបាយមានបញ្ហាប្រឈមមួយចំនួនក្នុងតំបន់ ដោយសារថាប្រទេសនីមួយៗមានប្រវត្តិ វប្បធម៌ មនោគមវិជ្ជា ធនធានសេដ្ឋកិច្ច ប្រជាសាស្ត្រ និងក្របខណ្ឌស្ថាប័ននយោបាយខុសៗគ្នា។ ច្បាប់ជាតិ និងនិយមន័យ "ក្រុមជនជាតិដើមភាគតិច" របស់ប្រទេស (ប្រសិនបើមាន) កម្រនឹងស្របគ្នាទាំងស្រុងជាមួយនឹងគោលនយោបាយរបស់ ADB ណាស់។ បទពិសោធន៍ក្នុងការអនុវត្តគោលនយោបាយមានលក្ខណៈចម្រុះ ហើយបញ្ហាប្រឈមចំបងៗនៅតែមាន ដូចជា : ការទទួលស្គាល់អត្តសញ្ញាណវប្បធម៌ និងសិទ្ធិដែលក្រុមជនជាតិដើមភាគតិចមានចំពោះដីដូនតា និងធនធាន (២) ការទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍន៍ដោយស្មើភាពគ្នាក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ និងសហគមន៍ក្នុងសង្គមផ្សេងទៀត និង (៣) ការពិគ្រោះយោបល់ពោរពេញដោយ

[១៩] ADB. ២០០៦. *ការសិក្សាវាយតម្លៃពិសេសស្តីពីការការពារតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត* ទីក្រុងម៉ានីល

អត្ថន័យ និងមានលក្ខណៈសមស្របនឹងវប្បធម៌របស់ក្រុមជនជាតិដើមភាគតិច ក្នុងការរៀបចំ និងអនុវត្តគម្រោងដែលអាចនឹងប៉ះ-ពាល់ដល់ការរស់នៅរបស់ពួកគេ។

២៤. ការសិក្សាវាយតម្លៃពិសេសស្តីពីការការពារក្រុមជនជាតិដើមភាគតិចឆ្នាំ ២០០៧[២០] របស់ OED បានសន្និដ្ឋានគោល-នយោបាយនេះ ពាក់ព័ន្ធនឹង ADB និងអ្នកខ្ចី/អតិថិជន ប៉ុន្តែមិនសូវមានប្រសិទ្ធភាព។ ជាទូទៅ គម្រោងផ្តល់ហិរញ្ញប្បទានដោយ ADB បានបញ្ចៀស ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ប៉ុន្តែនេះគឺជាលទ្ធផលនៃការអនុវត្តផែនការតាំងទីលំនៅជាថ្មី និងផែនការគ្រប់គ្រងបរិស្ថាន មិនមែនផែនការក្រុមជនជាតិដើមភាគតិចឡើយ។ យោងតាម SES ការបាត់បង់តម្លៃរបស់ផែនការក្រុមជនជាតិដើមភាគតិចនៅពេលមានវត្តមានផែនការការពារផ្សេងទៀត បានធ្វើឱ្យវិធីសាស្ត្ររបស់គោលនយោបាយបច្ចុប្បន្នមិនសូវជាមានប្រសិទ្ធផល ហើយប្រហែលជាគ្មាននិរន្តរភាពឡើយ ដោយសារតែបន្ទុកចំណាយខ្ពស់របស់ ADB និងរបស់អ្នកខ្ចី/អតិថិជន។ SES បានផ្តល់អនុសាសន៍ថានៅអំឡុងពេលធ្វើ SPU, ADB គួរតែ (១) បញ្ជាក់ឱ្យច្បាស់លាស់នូវចំណុចដែលយល់ច្រឡំ ឬមិនច្បាស់-លាស់ រួមទាំងនិយមន័យ "ក្រុមជនជាតិដើមភាគតិច" ក្នុង *គោលនយោបាយក្រុមជនជាតិដើមភាគតិច* (២) ដាក់បញ្ចូលបញ្ហាក្រុមជនជាតិដើមភាគតិច ក្នុងផែនការតាំងទីលំនៅជាថ្មី ឬ EMP ប្រសិនបើហានិភ័យរបស់ក្រុមជនជាតិដើមភាគតិចមានការពាក់-ព័ន្ធដោយផ្ទាល់នឹងការតាំងទីលំនៅជាថ្មី ឬការខូចខាតបរិស្ថាន (៣) បញ្ជាក់ឱ្យច្បាស់លាស់នូវលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងដំណើរការពិគ្រោះយោបល់ នៅអំឡុងពេលរៀបចំ និងអនុវត្តគម្រោង (៤) អភិវឌ្ឍន៍វិធីសាស្ត្រកសាងសមត្ថភាពក្នុងការអនុវត្តគោល-នយោបាយការពារក្រុមជនជាតិដើមភាគតិច និង (៥) អភិវឌ្ឍន៍ផែនការអនុវត្តគោលនយោបាយការពារក្រុមជនជាតិដើមភាគតិច។ ការឆ្លើយតបរបស់ថ្នាក់ដឹកនាំ ADB និងអនុសាសន៍របស់គណៈកម្មាធិការប្រសិទ្ធភាពនៃការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាភិបាលចំពោះការសិក្សាវាយតម្លៃពិសេសស្តីពីការការពារក្រុមជនជាតិដើមភាគតិច ព្រមទាំងការសិក្សាវាយតម្លៃពិសេសស្តីពីការការពារបរិស្ថាន និងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត មាននៅលើគេហទំព័ររបស់ ADB[២១]។

២៥. **បញ្ហាចម្រុះ** : នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ការវាយតម្លៃផ្ទៃក្នុងលើការអនុវត្តគោលនយោបាយបរិស្ថាន និងសង្គមរបស់ ADB ក៏បានគូសបញ្ជាក់នូវតម្រូវការក្នុងការលើកកម្ពស់ការអនុវត្តផងដែរ។ បញ្ហាពាក់ព័ន្ធនឹងការរៀបចំ និងចាត់ចែងគម្រោង រួមមាន (១) គុណភាពនៃការពិគ្រោះយោបល់ និងការផ្សព្វផ្សាយព័ត៌មាន (២) ការវាយតម្លៃសមស្របចំពោះក្របខណ្ឌ និងសមត្ថភាពរបស់ DMC (៣) លំដាប់នៃការរៀបចំផែនការការពារនៅក្នុងវដ្តគម្រោង និង (៤) គុណភាពខុសៗនៃឯកសារការពារ។ ចំណុចសំខាន់មួយទៀតគឺភាពគ្រប់គ្រាន់នៃការបែងចែកថវិកាសម្រាប់ការការពារ។ បញ្ហាអនុវត្តមានការពាក់ព័ន្ធជុំវិញនឹង (១) ការកំណត់ខ្ទង់ថវិកាសម្រាប់លក្ខខណ្ឌតម្រូវការពារ (ការប្រែប្រួលប្លង់រចនា ការបង់ប្រាក់សំណង និងបញ្ហាប្រហាក់ប្រហែល) (២) ការអនុវត្តវិធានការកាត់បន្ថយ (៣) ការធានាថាផែនការការពារត្រូវបានធ្វើបច្ចុប្បន្នភាពផ្អែកលើប្លង់លម្អិត និងការប្រែប្រួលទំហំ

---

[២០] ADB. ២០០៧. *ការសិក្សាវាយតម្លៃពិសេសស្តីពីការការពារក្រុមជនជាតិដើមភាគតិច* ទីក្រុងម៉ានីល

[២១] ADB. OED ធ្វើការវាយតម្លៃឯករាជ្យចំពោះគោលនយោបាយការពាររបស់ ADB : http://www.adb.org/Evaluation/safeguard-policies.asp

(៤) ការលើកកម្ពស់ការត្រួតពិនិត្យរបស់ទីភ្នាក់ងារនៅកម្រិតអ្នកម៉ៅការ និង (៤) ការធានាការត្រួតពិនិត្យ និងតាមដានឱ្យបានគ្រប់គ្រាន់ពី ADB ជាពិសេសការត្រួតពិនិត្យនៅទីឯកន្លែងផ្ទាល់។

## IV. បញ្ហាគោលនយោបាយ និង ការគិតគូរពិចារណាសំខាន់ៗ

### ក. ការរៀបរាប់ និងវិសាលភាពគោលនយោបាយ

២៦. **បង្កើនភាពច្បាស់លាស់ សង្គតភាព និង ភាពស្របគ្នា៖** បើទោះជាគោលនយោបាយការពារទាំងបីមានគោលការណ៍ និងធាតុផ្សំរួមគ្នាក៏ដោយ ក៏នៅចំណុចមួយចំនួនដែលមានភាពមិនច្បាស់លាស់ ជាន់គ្នា និងមិនស្របគ្នាផងដែរ។ ឧ. (១) ទំហំនៃធាតុសង្គមនៅក្នុងការវាយតម្លៃបរិស្ថានចាំបាច់ត្រូវតែបញ្ជាក់ឱ្យច្បាស់លាស់ (២) ធាតុមួយចំនួននៃ *គោលនយោបាយស្តីពីក្រុមជនជាតិដើមភាគតិច* ក៏មានចែងនៅក្នុង *គោលនយោបាយស្តីពីការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត* ផងដែរ។ (៣) គោលនយោបាយទាំងបីសុទ្ធតែតម្រូវឱ្យធ្វើការផ្សព្វផ្សាយព័ត៌មាន និងការពិគ្រោះយោបល់ ប៉ុន្តែលក្ខខណ្ឌតម្រូវ និងដំណើរការមិនមានលក្ខណៈស្របគ្នាឡើយ។ (៤) ទំហំគោលនយោបាយអនុវត្តចំពោះឧបករណ៍ខ្ចីខុសៗគ្នា និងនីតិវិធីឆ្លើយតប មានលក្ខណៈមិនដូចគ្នាឡើយ។ (៥) នៅពេលបច្ចុប្បន្ននេះ លក្ខខណ្ឌតម្រូវនីតិវិធីត្រូវបានចែងចម្រុះជាមួយនឹងគោលការណ៍គោលនយោបាយគន្លឹះ ដែលមានពេលខ្លះបានផ្តោតការយកចិត្តទុកដាក់ជ្រុលលើការអនុវត្តតាមនីតិវិធីដែលមិនសូវជាមានសារៈសំខាន់ដល់ការសម្រេចនូវកម្មវត្ថុរបស់គោល-នយោបាយ។ និង (៥) គោលនយោបាយ និងនីតិវិធីប្រតិបត្តិបច្ចុប្បន្ន បានចែងចម្រុះនូវការណែនាំដល់បុគ្គលិក ADB ជាមួយនឹងលក្ខខណ្ឌតម្រូវសម្រាប់ឱ្យអ្នកខ្ចី/អតិថិជនអនុវត្ត នៅក្នុងឯកសារតែមួយ ដែលជាហេតុធ្វើឱ្យព្រំដែនរវាងការទទួលខុសត្រូវ និងគណនេយ្យភាព មានភាពមិនច្បាស់លាស់។ ភាពស្របគ្នាប្រសើរជាងនេះរវាងគោលនយោបាយ និងភាពច្បាស់លាស់នៃគោលការណ៍គោលនយោបាយ លក្ខខណ្ឌតម្រូវសម្រាប់អ្នកខ្ចី/អតិថិជន និងនីតិវិធីអនុវត្តផ្ទៃក្នុង នឹងជួយដល់បុគ្គលិក ADB និងអ្នកខ្ចី/អតិថិជនឱ្យយល់ដឹងកាន់តែច្បាស់ពីអ្វីដែលត្រូវធ្វើ ដើម្បីសម្រេចឱ្យបាននូវកម្មវត្ថុនៃគោលនយោបាយការពារ និងយល់ដឹងពីតួនាទី និងការទទួលខុសត្រូវផ្សេងៗគ្នារបស់ពួកគេ ក្នុងការពង្រឹងគុណភាពនៃសមិទ្ធផលអភិវឌ្ឍន៍។

២៧. **ចែកឱ្យដាច់គោលនយោបាយការពារពីគោលដៅអភិវឌ្ឍន៍៖** ធាតុ "មិនបង្កការខូចខាត" នៃគោលនយោបាយការពារ កំពុងត្រូវបានចម្រុះជាមួយនឹងគោលដៅអភិវឌ្ឍន៍ក្នុងបរិមាណខុសៗគ្នានៅក្នុងគោលនយោបាយការពារទាំងបី។ ជាក់ស្តែង *គោលនយោបាយស្តីពីបរិស្ថាន* របស់ ADB មានធាតុសំខាន់ៗចំនួន ៥ ៖ (១) លើកកម្ពស់អន្តរាគមន៍បរិស្ថាន ដើម្បីកាត់បន្ថយភាពក្រីក្រ (២) បញ្ជ្រាបការគិតគូរពីបរិស្ថានទៅក្នុងកំណើនសេដ្ឋកិច្ច (៣) រក្សាប្រព័ន្ធទ្រទ្រង់ជីវិតប្រចាំតំបន់ និងសកល (៤) កសាងភាពជាដៃគូ និង (៥) សមាហរណកម្មគោលនយោបាយការពារបរិស្ថានទៅក្នុងប្រតិបត្តិការរបស់ ADB។ ប៉ុន្តែធាតុបួនដំបូងលើកឡើងពីយុទ្ធសាស្ត្របរិស្ថានរួមរបស់ ADB ហើយមានតែធាតុទី ៥ ប៉ុណ្ណោះដែលលើកឡើងពីបញ្ហាការពារបរិស្ថាន និងការវាយតម្លៃនៅកម្រិតគម្រោង។ ការបំបែកធាតុប៉ងប្រាថ្នាចម្រុះនៃបញ្ហាបរិស្ថានចេញពីលក្ខខណ្ឌតម្រូវសម្រាប់ការពារនឹងអាចឱ្យយើងអាចដោះស្រាយបញ្ហានីមួយៗតាមរយៈការពង្រឹងការផ្តោកការយកចិត្តទុកដាក់លើការអនុវត្តសមស្រប។ ក្នុងពេលជាមួយគ្នានោះ ធាតុប៉ងប្រាថ្នានៃ *គោលនយោបាយស្តីពីបរិស្ថាន* អាចនឹងសម្រេចបានតាមរយៈយុទ្ធសាស្ត្របរិស្ថានរួម។ ជាមួយគ្នា

នេះ ការដោះស្រាយបំណងប្រាថ្នាអភិវឌ្ឍន៍នៃ *គោលនយោបាយស្តីពីក្រុមជនជាតិដើមភាគតិច* នៅកម្រិតយុទ្ធសាស្ត្រទូលំទូលាយ អាចនឹងមានប្រសិទ្ធភាពជាងការដោះស្រាយនៅក្នុងបរិបទមានកម្រិតនៃការអនុវត្តតាមគោលនយោបាយការពារ ។ ហេតុនេះ SPS ដែលផ្តោតលើការការពារជាជាងផ្តោតលើកម្មវត្ថុបំណងប្រាថ្នា ត្រូវបានចាត់ទុកថាមានលក្ខណៈសមស្រប ។

២៨. **លើកឡើងពីធាតុការពារបរិស្ថាននៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រផ្សេងទៀត :** នៅពេលបច្ចុប្បន្ននេះ លក្ខខណ្ឌតម្រូវសម្រាប់ការពារមួយចំនួនដែលមានលើកឡើងពីបញ្ហាពាក់ព័ន្ធនឹងបរិស្ថាន មាននៅពាសពេញយុទ្ធសាស្ត្រ និងគោលនយោបាយតាមប្រធានបទ និងវិស័យរបស់ ADB[២២] ។ គោលនយោបាយ យុទ្ធសាស្ត្រ និង លក្ខខណ្ឌតម្រូវសម្រាប់ការពារទាំងនេះ កំពុងតែត្រូវបានអនុវត្តជាបណ្តើរៗ និងពឹងផ្អែកមួយផ្នែកលើដំណើរការអនុវត្តនៃ *គោលនយោបាយស្តីពីបរិស្ថាន* របស់ធនាគារ ។ ការកំណត់នៅដាច់ចេញពីគ្នាបែបនេះ បានកាត់បន្ថយនូវឱកាសយល់ឱ្យបានទាំងស្រុងពីផលប៉ះពាល់របស់គម្រោង ។ លើសពីនេះទៀត ធាតុការពារនៃ *គោលនយោបាយស្តីពីបរិស្ថាន* ដែលមានស្រាប់ ផ្តោតតែទៅលើគោលការណ៍ និងនីតិវិធីនៃការវាយតម្លៃបរិស្ថានតែប៉ុណ្ណោះ ។ គោលនយោបាយនេះ មិនបានកំណត់ឱ្យបានច្បាស់លាស់ពីគោលការណ៍គោលនយោបាយ និងលក្ខខណ្ឌតម្រូវក្នុងការដោះស្រាយផលប៉ះពាល់ និងហានិភ័យរបស់គម្រោង ពាក់ព័ន្ធនឹងការបង្ការ និងការកាត់បន្ថយផលប៉ះពាល់ (រួមទាំងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់) ការគ្រប់គ្រង ធនធានធម្មជាតិ និងជីវចម្រុះ និងធនធានវប្បធម៌រូបវន្ត ។ ការវាយតម្លៃបរិស្ថានរបស់គម្រោង ដោះស្រាយបញ្ហាទាំងនេះតែនៅពេលដែលត្រូវការចាំបាច់ (អាដហុក) តែប៉ុណ្ណោះ ។ ហេតុនេះ ADB គួរតែប្រមាច់បញ្ចូលគ្នានូវធាតុការពារបរិស្ថានទាំងអស់ដែលនៅពេលបច្ចុប្បន្ននេះមានចែងនៅក្នុងយុទ្ធសាស្ត្រ និងគោលនយោបាយតាមវិស័យនានារបស់ ADB ។ គោលការណ៍ និងលក្ខខណ្ឌតម្រូវសម្រាប់ការពារបរិស្ថានចាំបាច់ត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់ពីបញ្ហានៅតាមវិស័យ និងត្រូវតែមានចែងពី (១) ការវាយតម្លៃបរិស្ថាន (២) ការបង្ការ និងការកាត់បន្ថយការបំពុល (៣) ការគ្រប់គ្រងធនធានធម្មជាតិ និងជីវៈចម្រុះ (៤) សុខភាព និងសុវត្ថិភាពការងារ និងសហគមន៍ និង (៥) ធនធានវប្បធម៌រូបវន្ត ។

២៩. **បញ្ចូលទិដ្ឋភាពសង្គមដូចជាស្តង់ដារការងារស្នូល និងបញ្ហាយេនឌ័រ :** អ្នកពាក់ព័ន្ធមួយចំនួនបានស្នើសុំឱ្យមានបទបញ្ញត្តិគោលនយោបាយស្តីពីស្តង់ដារការងារស្នូល និងបញ្ហាយេនឌ័រនៅក្នុងសេចក្តីថ្លែងការណ៍គោលនយោបាយការពារ ។ ស្តង់ដារការងារស្នូល និងបញ្ហាការពារសង្គមផ្សេងទៀត ត្រូវបានចែងរួចហើយនៅក្នុង *យុទ្ធសាស្ត្រការពារសង្គម* (២០០១) របស់ ADB ។ ទិដ្ឋភាពសង្គមផ្សេងទៀត ក៏ត្រូវបានដោះស្រាយតាមរយៈ *សៀវភៅណែនាំពីប្រតិបត្តិការ* នៅក្នុងផ្នែកដែលនិយាយពីការដាក់បញ្ចូលទិដ្ឋភាពសង្គមទៅក្នុងប្រតិបត្តិការរបស់ ADB[២៣] ។ បញ្ហាយេនឌ័រ បានទទួលរួចហើយនូវការយកចិត្តទុកដាក់ជាក់លាក់ជាពិសេសនៅក្នុងប្រតិបត្តិការរបស់ ADB តាមរយៈការអនុវត្ត *គោលនយោបាយស្តីពីយេនឌ័រ និងការអភិវឌ្ឍន៍* (១៩៩៨) របស់ ADB និង *សៀវភៅណែនាំពីប្រតិបត្តិការ* នៅក្នុងផ្នែកដែលនិយាយពីយេនឌ័រ និងការអភិវឌ្ឍន៍[២៤] ។ ប៉ុន្តែ ការគិតគូរពីបញ្ហាយេនឌ័រ

---

[២២] ដូចជា គោលនយោបាយស្តីពីព្រៃឈើរបស់ធនាគារ (១៩៩៥) គំនិតផ្តួចផ្តើមគោលនយោបាយសម្រាប់វិស័យថាមពលរបស់ធនាគារ (១៩៩៥) និងគោលនយោបាយទឹករបស់ធនាគារអភិវឌ្ឍន៍អាស៊ី (២០០១) ។

[២៣] ADB. ២០០៧. *សៀវភៅណែនាំពីប្រតិបត្តិការ ផ្នែក គ.៣. : ការដាក់បញ្ចូលទិដ្ឋភាពសង្គមទៅក្នុងប្រតិបត្តិការរបស់ ADB* ម៉ានីល

[២៤] ADB. ២០០៦. *សៀវភៅណែនាំពីប្រតិបត្តិការ ផ្នែក គ.២. : យេនឌ័រ និង ការអភិវឌ្ឍន៍* ម៉ានីល

ចាំបាច់ត្រូវតែឆ្លុះបញ្ចាំងនៅក្នុងគោលនយោបាយការពារ ដោយសារថាបញ្ហានេះមានការពាក់ព័ន្ធជាពិសេសនឹងគោលនយោបាយការពារ។

៣០. **បង្កើនភាពច្បាស់លាស់នៃទំហំគោលនយោបាយ និងការជម្រុញ :** បទពិសោធន៍របស់ ADB ក្នុងការអនុវត្ត *គោលនយោបាយតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត* និង *គោលនយោបាយស្តីពីក្រុមជនជាតិដើមភាគតិច* បានបង្ហាញថា ចាំបាច់ត្រូវធ្វើការបង្កើនភាពច្បាស់លាស់ និងការជម្រុញនៃគោលនយោបាយនីមួយៗ។ ដូចបានលើកឡើងនៅក្នុងការសិក្សាវាយតម្លៃពិសេស (លេខយោង ១៩) ភាពច្បាស់លាស់គឺជាអ្វីដែលត្រូវការជាចាំបាច់ដើម្បីពន្យល់ថា *គោលនយោបាយតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត* នឹងត្រូវចាប់ផ្តើមអនុវត្តនៅពេលមានលទ្ធកម្មដោយមិនស្ម័គ្រចិត្តនូវដី និងទ្រព្យសកម្មដែលមាននៅលើដី ការដាក់កម្រិតការប្រើប្រាស់ដី និងការដាក់កម្រិតសិទ្ធិចេញ-ចូលតំបន់ការពារធម្មជាតិកំណត់ដោយច្បាប់។ ភាពច្បាស់លាស់គឺជាអ្វីដែលត្រូវការផងដែរក្នុងការពន្យល់ថាគោលនយោបាយបច្ចុប្បន្នគ្របដណ្តប់ទាំងការផ្លាស់ទីលំនៅរូបវន្ត និងការផ្លាស់ទីលំនៅសេដ្ឋកិច្ច ហើយដែលលក្ខខណ្ឌទាំងនេះ ចាំបាច់ត្រូវតែកំណត់ឱ្យបានច្បាស់លាស់។ មានពេលខ្លះ គម្រោងអាចនឹងបណ្តាលឱ្យមានការកម្រិតសិទ្ធិប្រើប្រាស់ធនធានធម្មជាតិ ដូចជា សិទ្ធិប្រើប្រាស់តំបន់នេសាទ និងការថយចុះនូវបរិមាណទឹកជាដើម។ គោលនយោបាយការពារចាំបាច់ត្រូវគ្របដណ្តប់ផលប៉ះពាល់ទាំងនេះដែលអាចកើតចេញពីលទ្ធកម្មដី។ ភាពច្បាស់លាស់ក៏ចាំបាច់ផងដែរក្នុងការបញ្ជាក់ថា ផលប៉ះពាល់ទាំងនេះនឹងត្រូវបញ្ចៀស បន្ធូរបន្ថយ កាត់បន្ថយ ឬប៉ះប៉ូវ។

៣១. នៅក្នុងបច្ចុប្បន្ននេះ *គោលនយោបាយស្តីពីក្រុមជនជាតិដើមភាគតិច* មិនបានផ្តល់និយមន័យឱ្យបានច្បាស់លាស់ពី "ក្រុមជនជាតិដើមភាគតិច" ឡើយ។ តម្រូវការឱ្យមានការវិភាគតាមស្ថានភាព និងការយល់ឃើញផ្សេងៗគ្នាក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិចអំពីដីដូនតា និងសិទ្ធិសហគមន៍ បានបង្កឱ្យមានភាពស្មុគស្មាញកាន់តែខ្លាំងឡើង ក្នុងការកំណត់អត្តសញ្ញាណក្រុមជនជាតិដើមភាគតិចក្នុងគោលបំណងអនុវត្តគោលនយោបាយ។ ហេតុនេះ លក្ខណៈវិនិច្ឆ័យក្នុងការកំណត់អត្តសញ្ញាណក្រុមជនជាតិដើមភាគតិច ចាំបាច់ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់។ លើសពីនេះទៀត ផលប៉ះពាល់ចំពោះភាពថ្លៃថ្នូរ សិទ្ធិមនុស្ស ប្រព័ន្ធចិញ្ចឹមជីវិត វប្បធម៌ ដីដូនតា ទ្រព្យសកម្មសហគមន៍ និងធនធានដែនដី ធម្មជាតិ និងវប្បធម៌របស់ក្រុមជនជាតិដើមភាគតិច ចាំបាច់ត្រូវកំណត់ធ្វើជាព្រឹត្តិការណ៍គន្លឹះរបស់គោលនយោបាយ។

៣២. **ពង្រឹងការពិគ្រោះយោបល់ និង ការចូលរួម :** ការពិគ្រោះយោបល់ និងការចូលរួម គឺជាចំណុចសំខាន់នៃការសម្រេចឱ្យបាននូវកម្មវត្ថុនៃគោលនយោបាយការពារ។ គោលនយោបាយការពារនៅពេលបច្ចុប្បន្នរបស់ ADB មានលក្ខខណ្ឌតម្រូវសម្រាប់ការពិគ្រោះយោបល់ខុសៗពីគ្នា។ គោលនយោបាយទាំងនោះ សុទ្ធតែបានកំណត់ដោយប្រយោលនូវការតម្រូវឱ្យមានការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមុនជាមួយក្រុមមនុស្ស និងសហគមន៍រងផលប៉ះពាល់ ក្នុងបរិបទនៃការរៀបចំផែនការការពារ និងតម្រូវការឱ្យមានការពិគ្រោះយោបល់ ជាបន្តបន្ទាប់នៅអំឡុងពេលអនុវត្តគម្រោង ដើម្បីកំណត់ និងជួយដោះស្រាយបញ្ហាការពារដែលអាចនឹងមាន។ ADB ត្រូវតែកំណត់ឱ្យច្បាស់លាស់ថា ខ្លួនតម្រូវឱ្យអ្នកខ្ចី/អតិថិជនរៀបចំធ្វើការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយក្រុមមនុស្ស និងសហគមន៍រងផលប៉ះពាល់ នៅក្នុងការអនុវត្តគោលនយោបាយការពារទាំងបី។ លើសពីនេះទៀត ADB ចាំបាច់ត្រូវកំណត់អត្ថន័យនៃឃ្លា "ការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យ" ឱ្យបានច្បាស់លាស់។ នៅក្នុងការ

អនុវត្តគោលនយោបាយ ការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យ គឺជាដំណើរការដែល (១) ចាប់ផ្តើមនៅដើមដំណាក់កាលនៃការរៀបចំគម្រោង និងបន្តធ្វើជាប់ជានិច្ចនៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង (២) ធ្វើការផ្តល់ព័ត៌មានដែលពាក់ព័ន្ធ និងសមស្របទាន់ពេលវេលា និងជាព័ត៌មានដែលក្រុមមនុស្សរងផលប៉ះពាល់អាចរកបាន និងអាចយល់បានដោយងាយស្រួល (៣) ធ្វើឡើងនៅក្នុងបរិយាកាសដែលគ្មានការគំរាមកំហែង និងបង្ខិតបង្ខំ (៤) មានការគិតគូរពីបញ្ហាយេនឌ័រ និងមានការតម្រែតម្រង់ទៅតាមតម្រូវការក្រុមទន់ខ្សោយ និងងាយរងគ្រោះ និង (៥) អនុញ្ញាតឱ្យមានការបញ្ចូលគំនិតយោបល់របស់ក្រុមមនុស្សរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធ ក្នុងការធ្វើការសម្រេចចិត្តអំពីគម្រោង វិធានការកាត់បន្ថយផលប៉ះពាល់ ការចែករំលែកអត្ថប្រយោជន៍ និងឱកាសដែលបានមកពីការអភិវឌ្ឍន៍ និងបញ្ហាអនុវត្តគម្រោង។

៣៣. នៅខែកញ្ញា ឆ្នាំ ២០០៧ មហាសន្និបាតលើកទី ៦១ របស់អង្គការសហប្រជាជាតិ បានអនុម័តសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ក្រុមជនជាតិដើមភាគតិច (UNDRIP) ដែលមានគោលបំណង "ស្នើសុំការយល់ព្រមដែលមានលក្ខណៈសេរី ជាមុន និងដែលមានការយល់ដឹងច្បាស់ ពីសហគមន៍ជនជាតិដើមភាគតិច នៅមុនពេលអនុម័តយល់ព្រមលើគម្រោងណាមួយដែលនឹងប៉ះពាល់ដល់ពួកគេ។" សេចក្តីប្រកាសមិនភ្ជាប់កាតព្វកិច្ចនេះ ត្រូវបានគាំទ្រដោយបណ្តាប្រទេសជាច្រើននៅអាស៊ី និងប៉ាស៊ីហ្វិក។ ក្នុងការទទួលស្គាល់សិទ្ធិរបស់ក្រុមជនជាតិដើមភាគតិចក្នុងការតម្រង់ទិសដៅអភិវឌ្ឍន៍ និងយោងតាមការពិភាក្សារបស់ក្រុមប្រឹក្សាភិបាលរបស់ ADB គោលនយោបាយការពាររបស់ ADB គួរតែមានចំណុចដូចតទៅ : អះអាងបញ្ជាក់នូវការយល់ព្រមរបស់សហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ចំពោះសកម្មភាពគម្រោង ដែលត្រូវបានសន្មតថា ក្រុមជនជាតិដើមភាគតិចងាយទទួលរងគ្រោះជាពិសេស : (១) ការអភិវឌ្ឍន៍ពាណិជ្ជកម្មលើធនធានវប្បធម៌ និងចំណេះដឹងរបស់ក្រុមជនជាតិដើមភាគតិច (២) ការផ្លាស់ទីលំនៅរូបវន្តរបស់ក្រុមជនជាតិដើមភាគតិចចេញពីទឹកដីប្រពៃណី ឬទំនៀមទំលាប់ និង (៣) សកម្មភាពអភិវឌ្ឍន៍ពាណិជ្ជកម្មលើធនធានធម្មជាតិក្នុងទឹកដីប្រពៃណី ដោយមានការប្រើប្រាស់ដែលអាចនឹងប៉ះពាល់ដល់មធ្យោបាយចិញ្ចឹមជីវិត ឬការប្រើប្រាស់ដីដើម្បីប្រយោជន៍ខាងវប្បធម៌ ពិធីបុណ្យ ឬជំនឿសាសនា ដែលជាអត្តសញ្ញាណនៃសហគមន៍ជនជាតិដើមភាគតិច។ នៅក្នុងការអនុវត្តគោលនយោបាយ មានការស្នើឡើងថា ការយល់ព្រមរបស់សហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ សំដៅលើការបញ្ជាក់ជារួមរបស់សហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ តាមរយៈបុគ្គលណាមួយ និង/ឬ តំណាងរបស់ពួកគេ ក្នុងការគាំទ្រជារួមពីសហគមន៍ចំពោះសកម្មភាពគម្រោង។ ការគាំទ្រជារួមពីសហគមន៍ ក៏អាចនឹងមានផងដែរ បើទោះជាមានការជំទាស់ចំពោះសកម្មភាពគម្រោងពីសំណាក់បុគ្គល ឬក្រុមមួយចំនួនក៏ដោយ។

## ៩. ការប្រើប្រាស់គោលនយោបាយ និងបញ្ហាអនុវត្តគោលនយោបាយ

៣៤. **ថ្លឹងថ្លែងលក្ខខណ្ឌតម្រូវជាមុនជាមួយនឹងការអនុវត្ត :** គោលនយោបាយការពារនៅពេលបច្ចុប្បន្នសង្កត់ធ្ងន់លើការបំពេញលក្ខខណ្ឌតម្រូវអនុវត្ត និងគោលដៅកំណត់ ក្នុងអំឡុងពេលដំណើរការគម្រោង។ គោលនយោបាយនៅពេលបច្ចុប្បន្នមិនសូវផ្តោតលើការតាមដាន និងការសម្រេចលទ្ធផលនៅអំឡុងពេលអនុវត្តគម្រោងឡើយ។ ពេលវេលា និងលំដាប់នៃលក្ខខណ្ឌតម្រូវអនុវត្តជាមុន មិនមែនសុទ្ធតែមានលក្ខណៈប្រសើរបំផុតឡើយ ហើយការសម្រេចបាននូវលក្ខខណ្ឌតម្រូវទាំងនេះ ក៏មិនធានា

ថានឹងទទួលបានលទ្ធផលការពារតាមការចង់បានដែរ។ ជាក់ស្ដែង នៅអំឡុងពេលដំណើរការគម្រោង និងនៅមុនពេលវាយតម្លៃគម្រោង មានការចំណាយកម្លាំងជាខ្លាំងក្នុងការរៀបចំសេចក្ដីព្រាងផែនការតាំងទីលំនៅជាថ្មីដោយយោងលើរបាយការណ៍សិក្សាអំពីលទ្ធភាពគម្រោង ប៉ុន្តែសកម្មភាពសំខាន់ៗក្នុងការរៀបចំ និងអនុវត្តផែនការតាំងទីលំនៅជាថ្មី អាចនឹងត្រូវធ្វើជាផ្នែកមួយនៃសកម្មភាពរៀបចំគម្រោងលម្អិតដែលនឹងត្រូវធ្វើនៅអំឡុងពេលអនុវត្តគម្រោង។ ដូចគ្នានេះផងដែរ កម្លាំងបុគ្គលិកជាច្រើន ត្រូវបានប្រើប្រាស់នៅក្នុងការរៀបចំសេចក្ដីព្រាងសង្ខេបនៃរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន ដើម្បីគោរពតាមនីតិវិធីផ្សព្វផ្សាយព័ត៌មានសម្រាប់គម្រោងដែលអាចមានផលប៉ះពាល់ដល់បរិស្ថាន ប៉ុន្តែការបញ្ចប់ និងការអនុវត្ត EMP ដ៏ល្អមួយ (ដែលជាមូលដ្ឋានសម្រាប់ការអនុវត្តគម្រោង) តែងតែទទួលបានការចាប់អារម្មណ៍តិចតួចណាស់។ បទពិសោធន៍របស់ ADB ក្នុងការអនុវត្តគោលការណ៍ការពារ និង SES ថ្មីរបស់ OED បានកត់សម្គាល់ឃើញថា គោលនយោបាយការពារត្រូវការនូវការចាប់អារម្មណ៍ឱ្យបានច្រើនជាងនេះនៅអំឡុងពេលអនុវត្តគម្រោង។ លក្ខខណ្ឌតម្រូវគោលនយោបាយ គួរតែមានបញ្ចូលនូវបទបញ្ញត្តិស្តីពីការបង្កើនការពិនិត្យតាមដានដោយអ្នកឯកទេសគោលនយោបាយការពារ បង្កើតយន្តការដោះស្រាយបណ្តឹងតវ៉ាមូលដ្ឋាន ការប្រើប្រាស់អ្នកជំនាញការពីខាងក្រៅក្នុងការពិនិត្យបញ្ជាក់របាយការណ៍តាមដាន និងការប្រើប្រាស់ក្រុមទីប្រឹក្សាឯករាជ្យ។

៣៥. **ពង្រឹងក្របខណ្ឌការពារ :** ក្របខណ្ឌការពារដែលកំពុងអនុវត្តចំពោះប្រាក់កម្ចីតាមវិស័យ និង MFF (ពោលគឺក្របខណ្ឌពិនិត្យ និងវាយតម្លៃបរិស្ថាន ក្របខណ្ឌតាំងទីលំនៅជាថ្មី និងក្របខណ្ឌរៀបចំផែនការក្រុមជនជាតិដើមភាគតិច) បានផ្តល់ការណែនាំពីការពិនិត្យគោលនយោបាយការពារ ការវាយតម្លៃ ការរៀបចំអង្គការ និងដំណើរការដែលត្រូវអនុវត្តតាម សម្រាប់អនុគម្រោង និងផ្នែកបន្តបន្ទាប់ដែលត្រូវរៀបចំនៅក្រោយការអនុម័តយល់ព្រមរបស់ក្រុមប្រឹក្សាភិបាល។ ក្របខណ្ឌការពារក៏កំណត់ពីលក្ខណៈវិនិច្ឆ័យនៃអ្នកមានសិទ្ធិទទួលបានផងដែរ ដែលនឹងអាចធានាថា អនុគម្រោងមានគុណភាព នឹងត្រូវបានកំណត់ និងផ្សព្វផ្សាយ។ ប៉ុន្តែ *គោលនយោបាយស្តីពីការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត* និង *គោលនយោបាយស្តីពីក្រុមជនជាតិដើមភាគតិច* នៅពេលបច្ចុប្បន្ន មិនមានបទបញ្ញត្តិជាក់លាក់ពីការប្រើប្រាស់ក្របខណ្ឌឡើយ ហើយក៏មិនឃើញមានគោលនយោបាយការពារណាមួយចែងពីលក្ខខណ្ឌតម្រូវ MFF ផងដែរ។ លើសពីនេះទៀត គ្មានបទបញ្ញត្តិផ្លូវការណាមួយបានចែងពីការប្រើប្រាស់ក្របខណ្ឌចំពោះសមាសធាតុមិនសើបរបស់គម្រោងឡើយ ខណៈដែលការរៀបចំគម្រោងលម្អិតធ្វើឡើងនៅក្រោយការអនុម័តយល់ព្រមរបស់ក្រុមប្រឹក្សាភិបាល។ គម្លាតគោលនយោបាយទាំងនេះ បានត្រូវដោះស្រាយនៅក្នុងគោលនយោបាយកែសម្រួលថ្មី។ លើសពីនេះ បញ្ហាគន្លឹះពាក់ព័ន្ធនឹងវិធីសាស្ត្រនេះ គឺការធានាថាអ្នកខ្ចី/អតិថិជន នឹងអនុវត្តក្របខណ្ឌការពារបានត្រឹមត្រូវ នៅពេលរៀបចំ និងអនុវត្តផែនការការពាររបស់អនុគម្រោងនៅក្រោយការអនុម័តយល់ព្រមរបស់ក្រុមប្រឹក្សាភិបាល។ ដើម្បីធានាថាក្របខណ្ឌការពារត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ចាំបាច់ត្រូវតែយកចិត្តទុកដាក់ឱ្យបានខ្លាំងជាងនេះ ក្នុងការវាយតម្លៃសមត្ថភាពស្ថាប័នរបស់អ្នកខ្ចី/អតិថិជន ហើយចាំបាច់ត្រូវតែអភិវឌ្ឍន៍ និងបញ្ចូលយន្តការ និងវិធីសាស្ត្រកសាងសមត្ថភាពទៅក្នុងការរៀបចំគម្រោង។ ក្រៅពីនេះ ក៏ត្រូវបង្កើនការចាប់អារម្មណ៍ចំពោះការតាមដាន និងការត្រួតពិនិត្យអនុគម្រោងផងដែរ ដើម្បីចៀសវាងបញ្ហាមិនអនុវត្តតាមគោលនយោបាយការពារ។

៣៦. **គ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមក្នុងអន្តរការីកម្មហិរញ្ញវត្ថុ :** ADB បានបង្កើនបរិមាណនៃគម្រោងវិនិយោគជាមួយអន្តរការីហិរញ្ញវត្ថុ ជាពិសេសនៅក្នុងប្រតិបត្តិការវិស័យឯកជនរបស់ខ្លួន។ គម្រោងអន្តរការីហិរញ្ញវត្ថុ បានបង្កើនឱ្យមានទូវបញ្ហាប្រឈមពិសេសមួយក្នុងការការពារ។ ADB មិនអាចធ្វើការត្រួតពិនិត្យដោយផ្ទាល់ ឬមានឥទ្ធិពលខ្លាំងក្លាលើអនុគម្រោងឡើយ ដោយសារថា មិនអាចកំណត់បានអនុគម្រោងនៅមុនពេលវាយតម្លៃអន្តរការីហិរញ្ញវត្ថុ (FI) មូលនិធិត្រូវបែងចែកជាទូទៅឱ្យទៅអនុគម្រោងជាច្រើន ហើយហិរញ្ញប្បទានអន្តរការីហិរញ្ញវត្ថុអាចនឹងមានអន្តរការីជាច្រើនជាន់ ដែលធ្វើឱ្យការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមកាន់តែស្មុគស្មាញ។ *គោលនយោបាយស្តីពីបរិស្ថាន* មានបទបញ្ញត្តិមួយចំនួនពាក់ព័ន្ធនឹងអន្តរការីកម្មហិរញ្ញវត្ថុ ប៉ុន្តែ *គោលនយោបាយស្តីពីការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត* និង *គោលនយោបាយស្តីពីក្រុមជនជាតិដើមភាគតិច* មិនមានចែងពីបញ្ហានេះឡើយ។ គម្លាតគោលនយោបាយនេះចាំបាច់ត្រូវតែបំបាត់ចោល។ លើសពីនេះទៀត ចាំបាច់ត្រូវធ្វើការបញ្ជាក់ឱ្យបានច្បាស់លាស់ (១) លក្ខខណ្ឌតម្រូវនៅកម្រិត FI និងនៅកម្រិតអនុគម្រោង និង (២) តួនាទី និងការទទួលខុសត្រូវរបស់ ADB និងអតិថិជន FI។ ប្រសិនអាចធ្វើទៅបាន គួរតែតម្រង់លក្ខខណ្ឌតម្រូវសម្រាប់អន្តរការីហិរញ្ញវត្ថុ ទៅតាមផលប៉ះពាល់ និង/ឬ ហានិភ័យដែលអាចកើតមានចំពោះបរិស្ថាន និងសង្គម។ ការធ្វើបែបនេះ ត្រូវទាមទារឱ្យធ្វើការពង្រឹងការអង្កេតលម្អិត និងការពិនិត្យវាយតម្លៃរបស់ ADB ចំពោះសកម្មភាពអាជីវកម្មរបស់អន្តរការីហិរញ្ញវត្ថុ និងសមត្ថភាពរបស់អន្តរការីនោះក្នុងការគ្រប់គ្រងបរិស្ថាន និងសង្គម។ លើសពីនេះ អន្តរការីហិរញ្ញវត្ថុអាចនឹងពិចារណាប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គមចម្រុះ (ESMS) ជាជាងប្រើប្រាស់ប្រព័ន្ធបីដាច់ដោយឡែកពីគ្នា។ ជាចុងក្រោយ បើទោះជានៅពេលបច្ចុប្បន្ននេះ ADB មិនទាន់កំណត់នូវបញ្ជីវិនិយោគដែលត្រូវបានហាមឃាត់ក៏ដោយ ADB គួរតែចាប់ផ្តើមកំណត់ឱ្យមាននូវបញ្ជីនេះ។

## ត. ការឆ្លើយតបនឹងការប្រែប្រួលនៃលក្ខខណ្ឌតម្រូវសម្រាប់អតិថិជន និង និរន្តរភាពរយៈពេលវែងនៃប្រព័ន្ធការពារ

៣៧. **ពង្រឹង និង ប្រើប្រាស់ប្រព័ន្ធការពារក្នុងប្រទេស :** ការពិគ្រោះយោបល់ដែលរៀបចំធ្វើក្នុងបរិបទនៃកិច្ចខិតខំប្រឹងប្រែងរបស់ ADB ក្នុងគោលបំណងពង្រឹងការគាំទ្រដល់អ្នកខ្ចី OCR បានបង្ហាញឱ្យឃើញថា អ្នកខ្ចី/អតិថិជនជាច្រើនជឿជាក់ថាសោហ៊ុយចំណាយក្នុងការអនុវត្តតាមគោលនយោបាយការពាររបស់ ADB មានកម្រិតច្រើនហួសហេតុ ហើយតំណាងរបស់ប្រទេសមានចំណូលមធ្យមជឿថា គោលការណ៍ការពាររួមអាចនឹងមានប្រសិទ្ធភាពប្រសើរជាង ប្រសិនបើប្រើប្រាស់ប្រព័ន្ធការពាររបស់ពួកគេជាជាងប្រើប្រាស់នីតិវិធីរបស់ ADB។ ពួកគេជឿថា នីតិវិធី និងវិធីសាស្ត្ររបស់ ADB គួរតែកែសម្រួល ដើម្បីអាចឆ្លុះឱ្យបានប្រសើរជាងនេះនូវភាពខុសគ្នានៃតម្រូវការ របស់អតិថិជន និងសមត្ថភាពផ្សេងៗគ្នារបស់ DMC ក្នុងការអនុវត្តគោលនយោបាយការពារ។ ADB ទទួលស្គាល់ថា DMC មានប្រព័ន្ធផ្ទាល់ខ្លួនរបស់ពួកគេក្នុងការផ្តល់ការការពារ ហើយក៏ទទួលស្គាល់ផងដែរថា ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ DMC ក្នុងការពង្រឹង និងប្រើប្រាស់ប្រព័ន្ធការពាររបស់ពួកគេ នឹងអាចពង្រឹងភាពជាម្ចាស់របស់ប្រទេសម្ចាស់ផ្ទះ លាតសន្ធឹងឥទ្ធិពលនៃការអភិវឌ្ឍន៍ និងកាត់បន្ថយនូវសោហ៊ុយចំណាយ។ ការធ្វើបែបនេះ ក៏ស្របទៅនឹងនិន្នាការឆ្ពោះទៅភាពជាម្ចាស់របស់ប្រទេស និងការបង្កើនភាពស៊ីគ្នាជាមួយនឹងប្រព័ន្ធក្នុងប្រទេស ដែលមាននៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពជំនួស និងរបៀបវារៈសកម្មភាពទីក្រុង Accra។ ADB ចាំបាច់ត្រូវអភិវឌ្ឍន៍វិធីសាស្ត្ររបស់ខ្លួនឱ្យឆ្ពោះទៅរក

ការពង្រឹងប្រព័ន្ធការពារក្នុងប្រទេស (CSS) និងប្រើប្រាស់ប្រព័ន្ធនេះនៅ ក្នុងគម្រោងរបស់ ADB ដោយរៀនសូត្រតាមបទ-ពិសោធន៍របស់ធនាគារពិភពលោកក្នុងការសាកល្បងប្រើប្រាស់ CSS ។ ប៉ុន្តែ ត្រូវមានការធានាថា គោលនយោបាយការពាររបស់ ADB មិនត្រូវបានសម្រុះសម្រួល និងថា ហានិភ័យពាក់ព័ន្ធនឹង CSS ត្រូវបានគ្រប់គ្រង ។ ហេតុនេះ វិធីសាស្ត្រត្រូវតែមានលក្ខណៈសន្ទឹមៗ និងមានគុណលក្ខណៈដូចតទៅ : (១) លក្ខខណ្ឌអនុវត្ត CSS (២) វិធីសាស្ត្រវាយតម្លៃ CSS (៣) ដំណើរការពិគ្រោះយោបល់ និងសុពលកម្ម (៤) តួនាទី និងការទទួលខុសត្រូវរបស់ ADB និងអ្នកខ្ចី (៥) នីតិវិធី និងលក្ខខណ្ឌពាក់ព័ន្ធផ្សេងទៀត ដូចជាការបំបាត់គម្លាតជាដើម និង (៦) ផលវិបាកធនធាន ។

៣៨. **ធ្វើឱ្យស្របគ្នាជាមួយគោលនយោបាយរបស់ MFI ផ្សេងទៀត :** ប្រមាណជា ៥ ឆ្នាំកន្លងទៅនឹង មាន MFI មួយចំនួនបានធ្វើ ឬកំពុងនឹងធ្វើបច្ចុប្បន្នភាពគោលនយោបាយការពាររបស់ពួកគេ ។ ភាពលូតលាស់នៃគោលនយោបាយដែល MFI ទាំងនេះ សម្រេចបាន និងការអនុវត្តល្អដែលប្រកាន់យកដោយពួកគេ មានពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ ADB ។ ការធ្វើឱ្យស្របគ្នារវាង គោលការណ៍គោលនយោបាយការពារ និងលក្ខខណ្ឌតម្រូវរបស់ ADB ជាមួយនឹងគោលការណ៍ និងលក្ខខណ្ឌការពាររបស់ MFI ផ្សេងទៀត ជាការចាំបាច់ដែលត្រូវធ្វើ ដើម្បីពង្រឹងផលវិជ្ជមានរបស់គម្រោង កាត់បន្ថយសោហ៊ុយចំណាយ និងលើកទឹកចិត្តឱ្យមានការចូលរួមសហការ ។ MFI បានធ្វើឱ្យមានការរីកចម្រើនមួយចំនួនក្នុងការកំណត់ក្របខណ្ឌរួមនៃគោលការណ៍ក្នុងការវាយតម្លៃបរិស្ថាន[២៥] ប៉ុន្តែចាំបាច់ត្រូវតែបន្តធ្វើឱ្យមានភាពស្របគ្នាក្នុងការអនុវត្តគោលការណ៍ការពាររបស់ MFI ទាំងឡាយ ។ ADB ជឿជាក់ថា ADB គួរតែធ្វើឱ្យគោលនយោបាយការពាររបស់ខ្លួនស្របគ្នាជាមួយនឹងគោលនយោបាយរបស់ MFI ផ្សេងទៀត ជាពិសេសគឺគោលការណ៍គោនយោបាយសំខាន់ៗ លើកលែងតែនីតិវិធីអនុវត្តរបស់ MFI ដែលត្រូវកែតម្រូវឱ្យស្របតាមអតិថិជន និងស្ថានភាពនីមួយៗ ។ ហេតុនេះ SPU បានធានាថា គោលការណ៍គោលនយោបាយ និងលក្ខខណ្ឌតម្រូវបរិស្ថាន ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និងក្រុមជនជាតិដើមភាគតិច ត្រូវបានរៀបចំឡើងស្របទៅតាមគោលនយោបាយរបស់ MFI ផ្សេងទៀត ជាពិសេស គឺធនាគារពិភពលោក IFC និង EBRD ។

៣៩. **ធ្វើការជាមួយអតិថិជនវិស័យឯកជន :** កម្មវិធីវិនិយោគវិស័យឯកជនរបស់ ADB បានរីកចម្រើនយ៉ាងឆាប់រហ័សនៅក្នុងអំឡុងពេល ៥ ឆ្នាំកន្លងមកនេះ ។ អតិថិជនវិស័យឯកជនមានប្រភពមកពីក្រុមដែលមានសមត្ថភាព និងការយល់ដឹងពីបរិស្ថាន និងសង្គមខុសៗគ្នា ហើយគម្រោងដែលពួកគេផ្តល់ហិរញ្ញប្បទានក៏អាចនឹងមានទំហំ និងលក្ខណៈខុសៗគ្នាផងដែរ ដែលមានចាប់ពីសហគ្រាសថាមពលកកើតឡើងវិញ ឬថាមពលមានប្រសិទ្ធភាពខ្នាតតូច និងមធ្យម រហូតដល់ក្រុមហ៊ុនខ្នាតធំនៃឧស្សាហកម្មយករ៉ែ ថាមពល និងហេដ្ឋារចនាសម្ព័ន្ធ ។ ជាធម្មតា វដ្តនៃប្រតិបត្តិការច្រើនតែមានរយៈពេលខ្លីជាងវដ្តគម្រោងនៅក្នុងវិស័យសាធារណៈ ហើយការសិក្សាលម្អិតអង្កេតពីការពារ ច្រើនតែមានរយៈពេលខ្លី ។ រចនាសម្ព័ន្ធផ្តល់ហិរញ្ញប្បទានស្មុគស្មាញ ដូចជា ក្រុមហ៊ុនបង្កើតឡើងដើម្បីគោលបំណងពិសេស (SPV) ដើម្បីធ្វើមូលបត្រភាវូបនីយកម្ម ឬអន្តរការីហិរញ្ញវត្ថុពហុជាន់ បានបង្កនូវការលំបាកកាន់តែខ្លាំងឡើង ដល់ការកំណត់ពីរបៀបដែលត្រូវអនុវត្តគោលនយោបាយការពាររបស់ ADB ។ បើទោះជានីតិវិធីអនុវត្តគោលនយោ-បាយដែលមានស្រាប់ នៅតែអាចយកមកអនុវត្តចំពោះហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុបែបបុរាណ ការប្រែប្រួលនៃបរិយាកាសអាជីវ-

---

[២៥] ក្រុមការងារបរិស្ថាននៃស្ថាប័នហិរញ្ញវត្ថុពហុភាគី ២០០៥ *ក្របខណ្ឌរួមសម្រាប់ការវាយតម្លៃបរិស្ថាន : កំណត់សម្គាល់ការអនុវត្តល្អ*

កម្មជាប់ជានិច្ច ភាពមាននៃផលិតផលហិរញ្ញវត្ថុផ្សេងៗ និងការកើនឡើងនៃភាពស្មុគ្រស្មាញនៃការធ្វើអន្តរាគមន៍របស់ ADB ក្នុងវិស័យហិរញ្ញវត្ថុ និងទីផ្សារមូលធន ទាមទារឱ្យមាននូវវិធីសាស្ត្រផ្សេងពីនេះ។ គោលការណ៍គោលនយោបាយការពារ គួរតែអនុវត្តដូចគ្នាចំពោះគម្រោងវិស័យសាធារណៈ និងគម្រោងវិស័យឯកជន ប៉ុន្តែនីតិវិធីអនុវត្តគម្រោងអាចនឹងខុសគ្នា។

៤០. **អភិវឌ្ឍន៍សមត្ថភាពរបស់ ADB និងបង្កើនប្រសិទ្ធភាពនៃការបែងចែកធនធាន :** ការបង្កើនប្រសិទ្ធភាពគោលនយោបាយការពារ ទាមទារឱ្យធ្វើការពង្រឹងសមត្ថភាពរបស់ ADB ជាពិសេសការបន្ថែមកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តគម្រោងការវាយតម្លៃ CSS និងការអភិវឌ្ឍន៍សមត្ថភាពនៅក្នុង DMC។ ការកសាងសមត្ថភាពរបស់ ADB ត្រូវតែរៀបចំធ្វើឡើង ដើម្បីឱ្យ ADB មានការយល់ដឹងឱ្យកាន់តែប្រសើរឡើងពីក្របខណ្ឌការពាររបស់ DMC តាមដានការអនុវត្តគោលនយោបាយការពារ និងជួបពិភាក្សាជាមួយអ្នកខ្ចី/អតិថិជនពីតថភាពជាក់ស្តែងនៃការអនុវត្តគោលនយោបាយការពារ។ ជាពិសេស ក្រុមការងារគម្រោងត្រូវតែយល់ដឹងច្បាស់ពីកម្មវត្ថុ និងគោលការណ៍នៃគោលនយោបាយការពារ ដោយសារថា ពួកគេជាអ្នកស្ថិតនៅជួរមុខក្នុងការធានានូវការអនុវត្តគោលនយោបាយ។ ប៉ុន្មានឆ្នាំកន្លងមកនេះ ADB បានរៀបចំកម្មវិធីបណ្តុះបណ្តាលពីគោលនយោបាយការពារទាំងបី ហើយការបណ្តុះបណ្តាលនេះ ត្រូវតែរៀបចំធ្វើបន្តទៅទៀត ទាំងនៅទីស្នាក់ការកណ្តាល និងនៅនិវេសនដ្ឋានបេសកកម្ម។ ក្នុងពេលជាមួយគ្នានេះ ធនធានបុគ្គលសម្រាប់ការអនុវត្តគោលនយោបាយការពារនៅក្នុងនាយដ្ឋានប្រតិបត្តិការ និងនាយកដ្ឋានអភិវឌ្ឍន៍និរន្តរភាព និងប្រចាំតំបន់ ចាំបាច់ត្រូវតែបង្កើនប្រសិទ្ធភាព ដើម្បីធានាថា មានការយកចិត្តទុកដាក់គ្រប់គ្រាន់ចំពោះការអនុវត្ត និងត្រួតពិនិត្យគម្រោង បើទោះជាកំពុងតែបំពេញតម្រូវការក្នុងការរៀបចំគម្រោង និងលក្ខខណ្ឌតម្រូវសម្រាប់ការអង្កេតលម្អិតក៏ដោយ។ តម្រូវការដ៏សំខាន់មួយ គឺធានាថានិវេសនដ្ឋានបេសកកម្ម មានអ្នកជំនាញគោលនយោបាយការពារពាក់ព័ន្ធគ្រប់គ្រាន់ ជាពិសេសនិវេសនដ្ឋាននៅក្នុង DMC ដែលមានគម្រោងមានភាពស្មុគស្មាញ និងងាយរងការប៉ះពាល់ខ្លាំង។ ការបង្កើនប្រសិទ្ធភាពនៃការបែងចែងធនធានក្នុងការអនុវត្ត និងតាមដានគោលនយោបាយ នៅតែជាចំណុចសំខាន់ក្នុងការបង្កើនការផ្តល់ការការពារ។

៤១. **កាត់បន្ថយសោហ៊ុយចំណាយ :** បើទោះជាប្រសិទ្ធភាពនៃគម្រោងគាំទ្រដោយ ADB បានត្រូវពង្រឹងគួរឱ្យកត់សម្គាល់តាមរយៈការយកចិត្តទុកដាក់ចំពោះគោលនយោបាយការពារក៏ដោយ អ្នកខ្ចី/អតិថិជនមួយចំនួនមានចម្ងល់ថា តើសោហ៊ុយចំណាយក្នុងការគោរពតាមគោលនយោបាយការពាររបស់ ADB មានកម្រិតខ្ពស់ពេក ឬក៏ព្រោះតែមានការចំណាយមិនចាំបាច់ដោយសារតែលក្ខខណ្ឌតម្រូវរបស់ ADB និងប្រទេសម្ចាស់ផ្ទះមានភាពដូចគ្នា? ការសិក្សាពិនិត្យពីផលចំណេញ និងការខាតបង់ក្នុងការអនុវត្តគោលនយោបាយការពារបានសន្និដ្ឋានថា គោលនយោបាយទាំងនេះ ជាឧបករណ៍ដ៏មានសារៈសំខាន់ក្នុងការធានានូវនិរន្តរភាពគម្រោង[២៦]។ ប្រសិនការអនុវត្តគោលនយោបាយទាំងនេះគ្មានប្រសិទ្ធភាព ឬមានការចំណាយមិនចាំបាច់ មូលហេតុចំបងៗរួមមាន : (១) លក្ខខណ្ឌតម្រូវដែលបានកំណត់ មានកម្រិតហួសពីសមត្ថភាពបំពេញរបស់អ្នកខ្ចី (២) លក្ខខណ្ឌតម្រូវសំខាន់ៗរបស់គោល-នយោបាយមានភាពមិនច្បាស់លាស់ (៣) មានការស្ទាក់ស្ទើរ និងមានការពន្យារពេលអនុម័តផែនការការពារ (៤) មិនចេះបត់បែនក្នុងការអនុវត្ត (បកស្រាយគោលនយោបាយ "តាមច្បាប់" ជាជាងតាមការវិនិច្ឆ័យវិជ្ជាជីវៈ) និង (៥) ការរេចរឹលសមត្ថភាព (បណ្តាលមកពីការប្រកាន់យកវិធីសាស្ត្រ "រឹតត្បិតធនធាន")។ អនុសាសន៍បានផ្តោតលើវិធីសាស្ត្រយុទ្ធសាស្ត្រក្នុងការពង្រឹងផល

---

[២៦] ធនាគារពិភពលោក ២០០១ *សោហ៊ុយចំណាយក្នុងការធ្វើជំនួញ* Washington, DC.

វិជ្ជមាននៃការអភិវឌ្ឍន៍របស់គោលនយោបាយ និងកាត់បន្ថយសោហ៊ុយចំណាយ តាមរយៈការ (១) បញ្ជាក់ឱ្យបានច្បាស់លាស់នូវការទទួលខុសត្រូវរបស់ MFI និងអ្នកខ្ចី ដោយមានការយកចិត្តទុកដាក់ជាពិសេសចំពោះប្រតិបត្តិការដែលមានហានិភ័យខ្ពស់ (២) លុបបំបាត់ភាពមិនច្បាស់លាស់ក្នុង គោលនយោបាយ (៣) ធ្វើឱ្យមានភាពស្របគ្នាជាមួយគោលនយោបាយរបស់ MFI ផ្សេងទៀត ដើម្បីកាត់បន្ថយការភាន់ច្រឡំ (៤) ធានានូវធនធានគ្រប់គ្រាន់សម្រាប់ពង្រឹងជំនាញផ្ទៃក្នុង និងពង្រីកការត្រួតពិនិត្យគម្រោង (៥) ផ្តល់ការលើកទឹកចិត្តឱ្យរុញច្រានការវិភាគគោលនយោបាយការពារទៅថ្នាក់លើ និង (៦) កសាងសមត្ថភាពរបស់អ្នកខ្ចី និងប្រើប្រាស់ប្រព័ន្ធការពារក្នុងប្រទេស។ លទ្ធផល និងអនុសាសន៍ប្រហាក់ប្រហែលនេះ មានរៀបរាប់នៅក្នុងការសិក្សាវាយតម្លៃពិសេសរបស់ OED លើគោលនយោបាយការពាររបស់ ADB។ គំនិតយោបល់ទាំងនេះ បានត្រូវយកមកពិចារណានៅពេលរៀបចំ SPU ហើយត្រូវបានលើកឡើងនៅក្នុងចំណុចគោលទាំង ៥ នៃ SPU (កថាខណ្ឌ ២)។

## V. ពង្រាងនៃសេចក្តីថ្លែងការណ៍គោលនយោបាយការពារ

### ក. សេចក្តីថ្លែងការណ៍ស្តីពីការប្តេជ្ញារបស់ ADB និង គោលការណ៍គោលនយោបាយ

៤២. ADB អះអាងថា និរន្តរភាពបរិស្ថាន និងសង្គម ជាគោលគ្រឹះនៃកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក។ ហេតុនេះ យុទ្ធសាស្ត្រឆ្នាំ ២០២០ របស់ ADB ផ្តោតលើការជួយ DMC ក្នុងការសម្រេចឱ្យបាននូវនិរន្តរភាពបរិស្ថាន និងកំណើនសេដ្ឋកិច្ច។ លើសពីនេះទៀត ADB ប្តេជ្ញាធានានូវនិរន្តរភាពសង្គម និងបរិស្ថាននៃគម្រោងដែលខ្លួនគាំទ្រ។ ក្នុងបរិបទនេះ គោលដៅរបស់ SPS គឺជម្រុញឱ្យមាននិរន្តរភាពនៃលទ្ធផលរបស់គម្រោង តាមរយៈការពារបរិស្ថាន និងមនុស្សពីផលប៉ះពាល់អវិជ្ជមានដែលអាចកើតចេញពីគម្រោង។

៤៣. កម្មវត្ថុនៃគោលនយោបាយការពាររបស់ ADB មានដូចតទៅ :

(i) ចៀសវាងផលប៉ះពាល់អវិជ្ជមានរបស់គម្រោងចំពោះបរិស្ថាន និងក្រុមមនុស្សរងផលប៉ះពាល់ ប្រសិនបើអាច។

(ii) បន្ធូរបន្ថយ កាត់បន្ថយ និង/ឬ ប៉ះប៉ូវសងនូវផលប៉ះពាល់អវិជ្ជមានរបស់គម្រោងចំពោះបរិស្ថាន និងក្រុមមនុស្សរងផលប៉ះពាល់ ប្រសិនបើការបញ្ចៀសមិនអាចធ្វើទៅបាន។ និង

(iii) ជួយអ្នកខ្ចី/អតិថិជនពង្រឹងប្រព័ន្ធការពាររបស់ពួកគេ និងអភិវឌ្ឍន៍សមត្ថភាពគ្រប់គ្រងហានិភ័យសង្គម និងបរិស្ថាន។

៤៤. ADB គោរពតាមកម្មវត្ថុនៃគោលនយោបាយការពារ និងការអនុវត្តគោលនយោបាយទាំងនេះ។ ADB ទទួលខុសត្រូវក្នុងការរៀបចំការអង្កេតលម្អិត និងវាយតម្លៃ តាមដាន និងត្រួតពិនិត្យគម្រោងនៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង ស្របតាមគោលការណ៍ និងលក្ខខណ្ឌតម្រូវដែលមានចែងក្នុង SPS។ តាមរយៈការគោរពតាមគោលនយោបាយការពារបរិស្ថាន និងសង្គម ADB ពង្រឹងនូវទស្សលទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃសកម្មភាព និងការសម្រេចចិត្តរបស់ខ្លួន ជួយអ្នកខ្ចី/អតិថិជនគ្រប់គ្រង

ផលប៉ះពាល់ និងហានិភ័យសង្គម និងបរិស្ថាន និងជម្រុញឱ្យមាននិរន្តរភាពវិនិយោគរយៈពេលវែង។ ការប្រែក្លាយការប្តេជ្ញានេះឱ្យទៅជាលទ្ធផលជាក់ស្តែង អាស្រ័យទៅលើកិច្ចខិតខំប្រឹងប្រែងរួមគ្នា (តែខុសប្លែកពីគ្នា) រវាង ADB និងអ្នកខ្ចី/អតិថិជន។

៤៥. SPS របស់ ADB កំណត់នូវគោលដៅគោលនយោបាយ ទំហំ ចំណុចគន្លឹះ និងគោលការណ៍របស់គោលនយោបាយការពារសំខាន់ចំនួន ៣ :

(i) គោលនយោបាយការពារបរិស្ថាន

(ii) គោលយោបាយការពារការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និង

(iii) គោលនយោបាយការពារក្រុមជនជាតិដើមភាគតិច។

៤៦. ដើម្បីសម្រេចកម្មវត្ថុគោលនយោបាយ និងដើម្បីអនុវត្តគោលការណ៍គោលនយោបាយ ADB ធ្វើសកម្មភាពដែលមាននៅក្នុងអនុផ្នែកខាងក្រោម (ខ. ដំណើរការអនុវត្តគោលនយោបាយ)។ ដើម្បីជួយអ្នកខ្ចី/អតិថិជន និងគម្រោងរបស់ពួកគេឱ្យសម្រេចនូវលទ្ធផលតាមការចង់បាន ADB អនុម័តនូវបណ្តុំលក្ខខណ្ឌតម្រូវការការពារសម្រាប់ការពារជាក់លាក់មួយចំនួន ដែលអ្នកខ្ចី/អតិថិជនត្រូវតែបំពេញ ក្នុងពេលធ្វើដោះស្រាយផលប៉ះពាល់ និងហានិភ័យបរិស្ថាន និងសង្គម។ បុគ្គលិក ADB (តាមរយៈការអង្កេតលម្អិត វាយតម្លៃ និងត្រួតពិនិត្យ) នឹងធានាថាអ្នកខ្ចី/អតិថិជនគោរពតាមលក្ខខណ្ឌតម្រូវទាំងនេះ នៅអំឡុងពេលរៀបចំ និងអនុវត្តគម្រោង។ លក្ខខណ្ឌតម្រូវសម្រាប់ការពារទាំងនេះ មានដូចតទៅ :

(i) លក្ខខណ្ឌតម្រូវសម្រាប់ការពារ ១ : បរិស្ថាន (សេចក្តីបន្ថែម ១)

(ii) លក្ខខណ្ឌតម្រូវសម្រាប់ការពារ ២ : ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ( សេចក្តីបន្ថែម ២)

(iii) លក្ខខណ្ឌតម្រូវសម្រាប់ការពារ ៣ : ក្រុមជនជាតិដើមភាគតិច ( សេចក្តីបន្ថែម ៣) និង

(iv) លក្ខខណ្ឌតម្រូវសម្រាប់ការពារ ៤ : លក្ខខណ្ឌតម្រូវពិសេសសម្រាប់ទម្រង់ហិរញ្ញវត្ថុផ្សេងៗ (សេចក្តីបន្ថែម ៤)។

៤៧. ADB នឹងមិនផ្តល់ហិរញ្ញប្បទានដល់គម្រោងដែលមិនគោរពតាមសេចក្តីថ្លែងការណ៍គោលនយោបាយការពាររបស់ខ្លួនឡើយ ហើយក៏មិនផ្តល់ហិរញ្ញប្បទានដល់គម្រោងដែលមិនគោរពតាមច្បាប់ និងបទបញ្ញាពាក់ព័ន្ធនឹងបរិស្ថាន និងសង្គមរបស់ប្រទេសម្ចាស់ផ្ទះឡើយ រួមទាំងច្បាប់ដែលតម្រូវឱ្យប្រទេសម្ចាស់ផ្ទះបំពេញកាតព្វកិច្ចដែលមានចែងក្នុងច្បាប់អន្តរជាតិផង។ លើសពីនេះ ADB នឹងមិនផ្តល់ហិរញ្ញប្បទានចំពោះសកម្មភាពដែលមានក្នុងបញ្ជីសកម្មភាពវិនិយោគដែលត្រូវបានហាមឃាត់ឡើយ (សេចក្តីបន្ថែម ៥)។

៤៨. សេចក្តីថ្លែងការណ៍គោលនយោបាយការពារនេះ អនុវត្តចំពោះរាល់គ្រប់គម្រោងដែលផ្តល់ហិរញ្ញប្បទានដោយ ADB និង/ឬ គម្រោងដែលស្ថិត និងមិនស្ថិតនៅក្រោមការគ្រប់គ្រងរដ្ឋបាលដោយ ADB រួមទាំងសមាសភាគគម្រោងទាំងនោះផង ដោយមិនគិតពីប្រភពនៃហិរញ្ញប្បទាន ព្រមទាំងគម្រោងវិនិយោគដែលផ្តល់ហិរញ្ញប្បទានដោយប្រាក់កម្ចី និង/ឬ ជំនួយឥតសំណង និង/ឬ ដោយវិធីសាស្ត្រផ្សេងទៀត ដូចជា ការវិនិយោគភាគហ៊ុន និង/ឬ ការធានា (ហៅកាត់ជារួមថាគម្រោង)។

## ១. គោលនយោបាយការពារបរិស្ថាន

**កម្មវត្ថុ :** ដើម្បីធានានូវនិរន្តរភាព និងភាពប្រសើរនៃបរិស្ថានរបស់គម្រោង និងដើម្បីគាំទ្រដល់ការដាក់បញ្ចូលការគិតគូរពិចារណាពីបរិស្ថានចូលទៅក្នុងដំណើរការសម្រេចចិត្តរបស់គម្រោង។

**ទំហំ និង ការជម្រុញ:** គោលនយោបាយការពារបរិស្ថាន នឹងត្រូវយកមកអនុវត្ត ប្រសិនបើគម្រោងអាចនឹងមានហានិភ័យ និងមានផលប៉ះពាល់ចំពោះបរិស្ថាន។

**គោលការណ៍គោលនយោបាយ :**

១. ប្រើប្រាស់ដំណើរការសម្រិតសម្រាំងគម្រោងដែលបានស្នើនីមួយៗឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ដើម្បីកំណត់ទំហំ និងប្រភេទសមស្របនៃការវាយតម្លៃបរិស្ថាន ដើម្បីអាចធ្វើការសិក្សាដែលសមាមាត្រនឹងកម្រិតនៃហានិភ័យ និងផលប៉ះពាល់ដែលអាចមាន។

២. រៀបចំធ្វើការវាយតម្លៃបរិស្ថានចំពោះគម្រោងដែលបានស្នើនីមួយៗ ដើម្បីកំណត់ផលប៉ះពាល់ និងហានិភ័យដោយផ្ទាល់ ដោយប្រយោល និងផលប៉ះពាល់ និងហានិភ័យបង្គរ និងបង្ក ដែលអាចមានឥទ្ធិពលលើធនធានរូបវន្ត ជីវៈសាស្ត្រ សង្គម-សេដ្ឋកិច្ច (រួមទាំងផលប៉ះពាល់ចំពោះមធ្យោបាយចិញ្ចឹមជីវិតដែលពឹងផ្អែកលើបរិស្ថាន សុខភាព និងសុវត្ថិភាព ក្រុមងាយរងគ្រោះ និងបញ្ហាយេនឌ័រ) និងធនធានវប្បធម៌រូបវន្ត ក្នុងបរិបទនៃតំបន់រងការប៉ះពាល់របស់គម្រោង។ វាយតម្លៃផលប៉ះពាល់ឆ្លងដែន និងសកល រួមទាំងការប្រែប្រួលអាកាសធាតុ។ ប្រើប្រាស់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រប្រសិនបើសមស្រប។

៣. រកមើលជម្រើសផ្សេងទៀតនៃទីតាំង ប្លង់គម្រោង បច្ចេកវិទ្យា និងសមាសធាតុ និងសិក្សាពីផលប៉ះពាល់ដែលអាចមានចំពោះបរិស្ថាន និងសង្គម និងកត់ត្រានូវមូលហេតុនៃការសម្រេចជ្រើសរើសជម្រើសជាក់លាក់ណាមួយ។ ពិចារណាផងដែរពីជម្រើស "គ្មានគម្រោង"។

៤. បញ្ចៀស (និងក្នុងករណីដែលការបញ្ចៀសមិនអាចធ្វើទៅបាន) បន្ធូរបន្ថយ កាត់បន្ថយ និង/ឬ ប៉ះប៉ូវសងនូវផលប៉ះពាល់អវិជ្ជមាន និងពង្រឹងផលប៉ះពាល់វិជ្ជមានតាមរយៈការរៀបចំផែនការ និងការគ្រប់គ្រងបរិស្ថាន។ រៀបចំ ផែនការគ្រប់គ្រងបរិស្ថាន (EMP) ដែលមានបញ្ចូលនូវសំណើវិធានការកាត់បន្ថយផលប៉ះពាល់ ការតាមដានបរិស្ថាន និងលក្ខខណ្ឌតម្រូវក្នុងការរាយការណ៍ ការរៀបចំអង្គការ ឬស្ថាប័នពាក់ព័ន្ធ ការកសាងសមត្ថភាព និងវិធានការបណ្តុះបណ្តាល កម្មវិធីអនុវត្ត សោហ៊ុយចំណាយប៉ាន់ស្មាន និងសូចនាករលទ្ធផល។ ចំណុចគិតគូរពិចារណាសំខាន់ៗក្នុងការរៀបចំ EMP រួមមាន ការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន ឱ្យបានដល់កម្រិត "គ្មានខូចខាតធ្ងន់ធ្ងរដល់តតិយជន" និងអ្នកបំពុលបរិស្ថានបង់សំណងការខូចខាត។

៥. រៀបចំការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយក្រុមមនុស្សរងផលប៉ះពាល់ និងសម្របសម្រួលការចូលរួមរបស់

ពួកគេ។ ធានានូវការចូលរួមរបស់ស្ត្រីនៅក្នុងការពិគ្រោះយោបល់។ បញ្ចូលអ្នកពាក់ព័ន្ធ ដូចជាក្រុមមនុស្សរងផលប៉ះពាល់ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ នៅដើមដំណាក់កាលនៃការរៀបចំគម្រោង និងធានាថាអ្នកសម្រេចចិត្តបានដឹង និងយល់ពីគំនិតយោបល់ និងក្តីបារម្ភរបស់ពួកគេ ហើយគំនិតយោបល់ និងក្តីបារម្ភទាំងនោះត្រូវបានយកមកពិចារណា។ បន្តធ្វើការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនៅអំឡុងពេលអនុវត្តគម្រោងប្រសិនបើចាំបាច់ ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការវាយតម្លៃបរិស្ថាន។ បង្កើតឱ្យមាននូវយន្តការដោះស្រាយបណ្តឹងតវ៉ា ដើម្បីទទួល និងសម្របសម្រួលដោះស្រាយក្តីបារម្ភ និងការប្តឹងតវ៉ាពីបញ្ហាបរិស្ថានរបស់គម្រោង របស់ក្រុមមនុស្សរងផលប៉ះពាល់។

៦. ផ្សព្វផ្សាយសេចក្តីព្រាងនៃការវាយតម្លៃបរិស្ថាន (រួមទាំង EMP) ឱ្យបានទាន់ពេលវេលា នៅមុនពេលវាយតម្លៃគម្រោង និងត្រូវផ្តល់ឱ្យនៅកន្លែង និងក្នុងទម្រង់ និងភាសាដែលក្រុមមនុស្សរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធអាចយល់បាន។ ផ្សព្វ-ផ្សាយការវាយតម្លៃបរិស្ថានចុងក្រោយ (និងការកែសម្រួលថ្មីនានា ប្រសិនបើមាន) ឱ្យក្រុមមនុស្សរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធផ្សេងទៀតបានដឹង។

៧. អនុវត្ត EMP និងតាមដានប្រសិទ្ធភាពរបស់ EMP។ កត់ត្រាលទ្ធផលនៃការតាមដាន រួមទាំងការវិវត្ត និងការអនុវត្តសកម្ម-ភាពកែតម្រូវ និងផ្សព្វផ្សាយរបាយការណ៍តាមដាន។

៨. មិនអនុវត្តសកម្មភាពគម្រោងនៅក្នុងតំបន់ដែនជំរកសំខាន់ លើកលែងតែ (១) គ្មានផលប៉ះពាល់អវិជ្ជមានចំពោះដែនជំរកសំខាន់ ដែលអាចនឹងបណ្តាលឱ្យប៉ះពាល់លទ្ធភាពទ្រទ្រង់របស់ដែនជំរកនោះ (២) គ្មានការកាត់បន្ថយចំនួនសត្វដែលគេទទួលស្គាល់ថាកំពុងរងគ្រោះ ឬរងគ្រោះធ្ងន់ធ្ងរ និង (៣) ផលប៉ះពាល់ផ្សេងទៀតត្រូវបានកាត់បន្ថយ។ ប្រសិនបើគម្រោងស្ថិតនៅតំបន់ការពារធម្មជាតិ អនុវត្តកម្មវិធីបន្ថែម ដើម្បីលើកកម្ពស់ និងលើកស្ទួយគោលដៅអភិរក្សតំបន់ការពារធម្មជាតិ។ នៅក្នុងតំបន់ដែនជម្រកធម្មជាតិ មិនត្រូវធ្វើការកែប្រែ ឬធ្វើឱ្យមានការសឹករេចរឹលធ្ងន់ធ្ងរឡើយ លើកលែងតែ (១) គ្មានជម្រើសផ្សេងទៀត (២) អត្ថប្រយោជន៍កើតចេញពីគម្រោង នឹងទទួលបានច្រើនក្រាស់ក្រែលជាងការខូចខាតបរិស្ថានដោយសារគម្រោង និង (៣) រាល់ការកែប្រែ ឬការធ្វើឱ្យសឹករេចរឹល ត្រូវបានកាត់បន្ថយសមស្រប។ ប្រើវិធីសាស្ត្របង្ការក្នុងការប្រើប្រាស់ អភិ-វឌ្ឍន៍ និងគ្រប់គ្រងធនធានធម្មជាតិកកើតឡើងវិញ។

៩. អនុវត្តវិធានការបង្ការការបំពុលបរិស្ថាន និងបច្ចេកវិទ្យាគ្រប់គ្រង និងទំលាប់អនុវត្តដែលស្របនឹងទំលាប់អនុវត្តល្អដូចមានចែងក្នុងបទដ្ឋានដែលមានការទទួលស្គាល់ជាអន្តរជាតិ ដូចជា គោលការណ៍ណែនាំស្តីពីបរិស្ថាន សុខភាព និងសុវត្ថិភាពរបស់ធនាគារពិភពលោកជាដើម។ ប្រកាន់យកដំណើរផលិតកម្មដែលមិនសូវមានផលប៉ះពាល់ចំពោះបរិស្ថាន និងទម្លាប់អនុវត្តដែលមានប្រសិទ្ធផលថាមពល។ បញ្ចៀសនូវការបំពុលបរិស្ថាន (ឬ ក្នុងករណីដែលការបញ្ចៀសមិនអាចធ្វើទៅបាន) កាត់បន្ថយ ឬគ្រប់គ្រងកម្រិត ឬបរិមាណ នៃការបញ្ចេញជាតិពុល រួមទាំងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយផ្ទាល់ និងដោយប្រយោល ការបញ្ចេញកាកសំណល់ និងការបញ្ចេញសារធាតុគ្រោះថ្នាក់ពីដំណើរការផលិតកម្ម ដឹកជញ្ជូន រក្សា និងការស្តុកទុក។ បញ្ចៀសការប្រើប្រាស់សារធាតុគ្រោះថ្នាក់ដែលត្រូវបានហាមឃាត់ ឬកាត់បន្ថយការប្រើប្រាស់ជាអន្តរជាតិ។ ទិញ ប្រើប្រាស់ និងគ្រប់

គ្រងថ្នាំសម្លាប់សត្វល្អិតតាមវិធីសាស្ត្រគ្រប់គ្រងសត្វល្អិតចម្រុះ និងកាត់បន្ថយការពឹងផ្អែកលើថ្នាំគីមីសម្លាប់សត្វល្អិត។

១០. ផ្តល់ឱ្យកម្មករនូវលក្ខខណ្ឌការងារសុវត្ថិភាព និងសុខភាព និងបង្ការមិនឱ្យមានឧបទ្ទវហេតុ ការរងរបួស និងជំងឺ។ បង្កើតវិធានការបង្ការ និងវិធានការត្រៀម និងឆ្លើយតបនឹងគ្រោះអាសន្ន ដើម្បីបញ្ចៀស (ឬក្នុងករណីបញ្ចៀសមិនអាចធ្វើទៅបាន) កាត់បន្ថយហានិភ័យ និងផលប៉ះពាល់អវិជ្ជមានចំពោះសុខភាព និងសុវត្ថិភាពសហគមន៍មូលដ្ឋាន។

១១. អភិរក្សធនធានវប្បធម៌រូបវន្ត និងបញ្ចៀសការបំផ្លាញ និងការធ្វើឱ្យខូចខាតដល់ធនធានទាំងនោះ តាមរយៈការចុះអង្កេតនៅមូលដ្ឋានដោយអ្នកជំនាញដែលមានគុណវុឌ្ឍិ និងបទពិសោធន៍គ្រប់គ្រាន់ នៅអំឡុងពេលវាយតម្លៃបរិស្ថាន។ ដាក់ឱ្យប្រើនូវនីតិវិធី "រកឃើញចៃដន្យ" ដែលមានបញ្ចូលការគ្រប់គ្រង និងអភិរក្សធនធានដែលអាចនឹងរកឃើញនៅមុនពេលមានការបញ្ជាក់ទទួលស្គាល់ នៅអំឡុងពេលអនុវត្តគម្រោង។

## ២. គោលនយោបាយការពារការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត

| |
|---|
| **កម្មវត្ថុ :** ដើម្បីបញ្ចៀសការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តប្រសិនបើអាចធ្វើទៅបាន។ កាត់បន្ថយការតាំងទីលំនៅជាថ្មីដោយបង្ខំតាមរយៈការសិក្សារកមើលជម្រើសគម្រោង និងរៀបចំប្លង់ផ្សេងទៀត។ លើកស្ទួយ (ឬយ៉ាងហោចណាស់ស្តារ) មធ្យោបាយចិញ្ចឹមជីវិតរបស់អ្នកបាត់បង់លំនៅដ្ឋាន ឱ្យបានក្នុងកម្រិតមួយប្រហាក់ប្រហែលនឹងកម្រិតនៅមុនពេលមានគម្រោងអភិវឌ្ឍន៍។ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ជនក្រីក្រដែលត្រូវផ្លាស់ទីលំនៅ និងក្រុមងាយរងគ្រោះផ្សេងទៀត។ |
| **ទំហំ និង ការជម្រុញ:** គោលនយោបាយការពារការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត គ្របដណ្តប់លើការផ្លាស់ទីលំនៅរូបវន្ត (ប្តូរទីតាំង បាត់បង់ដីលំនៅដ្ឋាន ឬបាត់បង់ទីជំរក) និង/ឬ ផ្លាស់ទីលំនៅសេដ្ឋកិច្ច (បាត់បង់ដីធ្លី ទ្រព្យសកម្ម សិទ្ធិចេញ-ចូលទៅទ្រព្យសកម្ម ប្រភពចំណូល និងមធ្យោបាយចិញ្ចឹមជីវិត) ដោយសារតែ (១) លទ្ធកម្មដីដោយមិនស្ម័គ្រចិត្ត ឬ (២) ការកំណត់ដោយមិនស្ម័គ្រចិត្តលើការប្រើប្រាស់ដី ឬសិទ្ធិចេញ-ចូលទៅកាន់ឧទ្យានជាតិ និងតំបន់ការពារធម្មជាតិដែលកំណត់ដោយច្បាប់។ គោលនយោបាយការពារនេះ កំណត់មើលថាតើការបាត់បង់ និងការកំណត់ដោយមិនស្ម័គ្រចិត្តនោះ មានលក្ខណៈទាំងស្រុង ឬដោយផ្នែក មានលក្ខណៈជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្ន។ |
| **គោលការណ៍គោលនយោបាយ :**<br>១. សម្រិតសម្រាំងគម្រោងនៅដំណាក់កាលដំបូងបង្អស់ដើម្បីកំណត់ពីផលប៉ះពាល់ និងហានិភ័យនៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តនៅពេលអតីតកាល បច្ចុប្បន្ន និងអនាគត។ កំណត់ទំហំនៃការរៀបចំផែនការតាំងទីលំនៅជាថ្មី តាមរយៈការចុះអង្កេត និង/ឬ ជំរឿនអ្នកបាត់បង់លំនៅដ្ឋាន រួមទាំងការវិភាគយេនឌ័រដែលពាក់ព័ន្ធជាពិសេសនឹងផលប៉ះពាល់ និងហានិភ័យនៃការតាំងទីលំនៅជាថ្មី។<br>២. រៀបចំការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយក្រុមមនុស្សរងផលប៉ះពាល់ សហគមន៍ម្ចាស់ផ្ទះ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ។ ជូនដំណឹងដល់អ្នកបាត់បង់លំនៅដ្ឋានពីសិទ្ធិ និងជម្រើសក្នុងការតាំងទីលំនៅជាថ្មីរបស់ពួកគេ។ ធានានូវការចូលរួមរបស់ពួកគេក្នុងការរៀបចំផែនការ អនុវត្ត និងតាមដាន និងវាយតម្លៃកម្មវិធីតាំងទីលំនៅជាថ្មី។ ចាប់អារម្មណ៍ជាពិសេសចំពោះតម្រូវការរបស់ក្រុមងាយរងគ្រោះ ជាពិសេសក្រុមមនុស្សដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ អ្នកគ្មានដីធ្លី ចាស់ជរា ស្ត្រី និងកុមារ និងក្រុមជនជាតិភាគតិច និងអ្នកគ្មានសិទ្ធិកម្មសិទ្ធិដី និងធានានូវការចូលរួមរបស់ពួកគេក្នុងការពិគ្រោះយោបល់។ បង្កើតយន្តការដោះស្រាយបណ្តឹងតវ៉ា ដើម្បីទទួល និងសម្របសម្រួលដោះស្រាយក្តីបារម្ភរបស់ក្រុមមនុស្សរងផលប៉ះពាល់។ គាំទ្រស្ថាប័នវប្បធម៌ និងសង្គមរបស់អ្នកបាត់បង់លំនៅដ្ឋាន និងប្រជាពលរដ្ឋម្ចាស់ផ្ទះ។ ប្រសិនបើផលប៉ះ-ពាល់ និងហានិភ័យនៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តមានលក្ខណៈស្មុគស្មាញ និងងាយរងការប៉ះពាល់ខ្លាំង សំណង និងការសម្រេចពីការតាំងទីលំនៅជាថ្មី គួរធ្វើនៅមុនដំណាក់កាលរៀបចំសង្គម។<br>៣. លើកកម្ពស់ (ឬយ៉ាងហោចណាស់ស្តារ) មធ្យោបាយចិញ្ចឹមជីវិតរបស់អ្នកបាត់បង់លំនៅដ្ឋានតាមរយៈ (១) យុទ្ធសាស្ត្រដោះ |

ដូរដីប្រសិនបើមធ្យោបាយចិញ្ចឹមជីវិតរបស់អ្នកបាត់បង់លំនៅដ្ឋានពឹងផ្អែកទៅលើដី ប្រសិនបើអាច ឬផ្តល់សំណងជាសាច់ប្រាក់ ប្រសិនបើការបាត់បង់ដីមិនប៉ះពាល់ដល់មធ្យោបាយចិញ្ចឹមជីវិត (២) ដាក់ជំនួសឱ្យបានទាន់ពេលវេលានូវទ្រព្យសកម្ម តាមរយៈការផ្តល់នូវសិទ្ធិទទួលបានទ្រព្យសកម្មដែលមានតម្លៃស្មើ ឬខ្ពស់ជាង (៣) ផ្តល់ប្រាក់សំណងដោះដូរទាំងស្រុងចំពោះទ្រព្យសកម្មដែលមិនអាចស្តារ និង (៤) ផ្តល់សេវា និងប្រាក់ចំណូលបន្ថែម តាមរយៈកម្មវិធីចែករំលែកអត្ថប្រយោជន៍ ប្រសិនបើអាច។

៤. ផ្តល់ឱ្យអ្នកបាត់បង់លំនៅដ្ឋានរូបវន្ត និងសេដ្ឋកិច្ច នូវជំនួយចាំបាច់នានា ដូចជា : (១) ប្រសិនបើមានការផ្លាស់ទីលំនៅ ធានានូវសិទ្ធិកាន់កាប់ដីថ្មី ផ្ទះសម្បែងនៅតំបន់តាំងទីលំនៅថ្មីដែលមានលក្ខខណ្ឌល្អប្រសើរជាងកន្លែងចាស់ ជាមួយនឹងសិទ្ធិទទួលបានការងារ និងឱកាសផលិតកម្មដែលអាចប្រៀបធៀបបានជាមួយនឹងកន្លែងចាស់ សមាហរណកម្មសេដ្ឋកិច្ច និងសង្គមក្រុមមនុស្សដែលត្រូវតាំងទីលំនៅជាថ្មីទៅក្នុងសមហគមន៍ម្ចាស់ផ្ទះ និងពង្រីកអត្ថផលប្រយោជន៍គម្រោងឱ្យដល់សហគមន៍ម្ចាស់ផ្ទះ (២) ជំនួយគាំទ្រអន្តរកាល និងជំនួយអភិវឌ្ឍន៍ ដូចជា ការអភិវឌ្ឍន៍ដី ហេដ្ឋារចនាសម្ព័ន្ធឥណទាន ការបណ្តុះបណ្តាល ឬឱកាសការងារ និង (៣) ហេដ្ឋានរចនាសម្ព័ន្ធស៊ីវិល និង សេវាសហគមន៍ដែលចាំបាច់។

៥. លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ជនក្រីក្រដែលត្រូវផ្លាស់ទីលំនៅ និងក្រុមងាយរងគ្រោះផ្សេងទៀត ដូចជាស្ត្រី យ៉ាងហោចណាស់ត្រឹមកម្រិតអប្បបរមាថ្នាក់ជាតិ។ នៅតំបន់ជនបទ ផ្តល់ឱ្យពួកគេនូវសិទ្ធិស្របច្បាប់សមស្របក្នុងប្រើប្រាស់ដី និងធនធាន ចំណែកនៅតំបន់ទីក្រុង ផ្តល់ឱ្យពួកគេនូវប្រភពចំណូលសមស្រប និងសិទ្ធិស្របច្បាប់សមស្របក្នុងការទទួលបានទីជម្រក។

៦. អភិវឌ្ឍន៍នីតិវិធីដែលមានតម្លាភាព សង្គតភាព និងសមភាព ប្រសិនបើលទ្ធកម្មដីធ្វើឡើងតាមរយៈការដោះស្រាយចរចាគ្នា ដើម្បីធានាថា មនុស្សដែលចូលរួមដោះស្រាយចរចាគ្នា អាចរក្សាបាននូវកម្រិតចំណូល និងមធ្យោបាយចិញ្ចឹមជីវិតដដែល ឬប្រសើរជាង។

៧. ធានាថាអ្នកបាត់បង់លំនៅដ្ឋាន និងដែលគ្មានសិទ្ធិកម្មសិទ្ធិដី ឬសិទ្ធិកាន់កាប់ដីស្របច្បាប់ណាមួយ មានសិទ្ធិទទួលបានជំនួយឧបត្ថម្ភក្នុងការតាំងទីលំនៅជាថ្មី និងប្រាក់សំណងចំពោះការបាត់បង់ទ្រព្យសកម្មក្រៅពីដី។

៨. រៀបចំផែនការតាំងទីលំនៅជាថ្មី ដោយមានការពន្យល់លម្អិតពីសិទ្ធិរបស់អ្នកបាត់បង់លំនៅដ្ឋាន យុទ្ធសាស្ត្រស្តារប្រភពប្រាក់ចំណូល និងមធ្យោបាយចិញ្ចឹមជីវិត ការរៀបចំស្ថាប័ន ក្របខណ្ឌតាមដាន និងរាយការណ៍ កញ្ចប់ថវិកា និងកម្មវិធីអនុវត្ត។

៩. ផ្សព្វផ្សាយសេចក្តីព្រាងផែនការតាំងទីលំនៅជាថ្មី រួមទាំងឯកសារកត់ត្រាដំណើរការពិគ្រោះយោបល់ ឱ្យបានទាន់ពេលវេលានៅមុនពេលវាយតម្លៃគម្រោង និងត្រូវផ្តល់ឱ្យនៅកន្លែង និងក្នុងទម្រង់ និងភាសាដែលក្រុមមនុស្សរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធផ្សេងទៀតអាចយល់បាន។ ផ្សព្វផ្សាយផែនការតាំងទីលំនៅជាថ្មីចុងក្រោយ និងការកែសម្រួលថ្មីនានា ឱ្យក្រុមមនុស្សរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធផ្សេងទៀតបានដឹង។

១០. ចាត់ទុក និងអនុវត្តការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តជាផ្នែកមួយនៃគម្រោង ឬកម្មវិធីអភិវឌ្ឍន៍។ បញ្ចូលសោហ៊ុយចំណាយទាំងស្រុងក្នុងការតាំងទីលំនៅជាថ្មីទៅក្នុងសោហ៊ុយចំណាយ និងអត្ថប្រយោជន៍គម្រោង។ ចំពោះគម្រោងដែលមាន

ផលប៉ះពាល់នៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តធ្ងន់ធ្ងរ ពិចារណាប្រែក្លាយការអនុវត្តកម្មវិធីតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តក្នុងនាមជាសមាសភាគមួយរបស់គម្រោង ឱ្យទៅជាប្រតិបត្តិការឯករាជ្យ ។

១១. បង់ប្រាក់សំណង និងផ្តល់សិទ្ធិតាំងទីលំនៅជាថ្មីផ្សេងទៀត នៅមុនពេលផ្លាស់ទីលំនៅរូបវន្ត ឬសេដ្ឋកិច្ច ។ អនុវត្តផែនការតាំងទីលំនៅជាថ្មីក្រោមការត្រួតពិនិត្យយ៉ាងជិតដល់នៅអំឡុងពេលអនុវត្តគម្រោង ។

១២. តាមដាន និងវាយតម្លៃលទ្ធផលនៃការតាំងទីលំនៅជាថ្មី ផលប៉ះពាល់ចំពោះមធ្យោបាយចិញ្ចឹមជីវិតរបស់អ្នកបាត់បង់លំនៅដ្ឋាន និងការសម្រេច ឬមិនសម្រេចកម្មវត្ថុនៃផែនការតាំងទីលំនៅជាថ្មី តាមរយៈការប្រៀបធៀបលក្ខខណ្ឌគោល និងលទ្ធផលនៃការតាមដាន ។ ផ្សព្វផ្សាយរបាយការណ៍តាមដាន ។

## ៣. គោលនយោបាយការពារក្រុមជនជាតិដើមភាគតិច

| |
|---|
| **កម្មវត្ថុ :** ដើម្បីរៀបចំ និងអនុវត្តគម្រោងក្នុងវិធីសាស្ត្រដែលជម្រុញការគោរពអត្តសញ្ញាណ សេចក្តីថ្លៃថ្នូរ សិទ្ធិមនុស្ស មធ្យោបាយចិញ្ចឹមជីវិត និងវប្បធម៌របស់ក្រុមជនជាតិដើមភាគតិច ដែលកំណត់ដោយក្រុមជនជាតិដើមភាគតិចដោយខ្លួនឯង ដើម្បីឱ្យពួកគេ (១) អាចទទួលបានអត្ថប្រយោជន៍សង្គម និងសេដ្ឋកិច្ចដែលសមស្របតាមវប្បធម៌របស់ពួកគេ (២) មិនរងផលប៉ះពាល់អវិជ្ជមានដែលកើតចេញពីគម្រោង និង (៣) អាចចូលរួមយ៉ាងសកម្មក្នុងគម្រោងដែលជះឥទ្ធិពលមកលើពួកគេ។ |
| **ទំហំ និង ការជម្រុញ:** គោលនយោបាយការពារក្រុមជនជាតិដើមភាគតិច នឹងត្រូវលើកយកមកអនុវត្ត ប្រសិនបើគម្រោងមានការប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោល ចំពោះសេចក្តីថ្លៃថ្នូរ សិទ្ធិមនុស្ស មធ្យោបាយចិញ្ចឹមជីវិត ឬវប្បធម៌របស់ក្រុមជនជាតិដើមភាគតិច ឬប៉ះពាល់ដល់ទឹកដី ឬធនធានធម្មជាតិ ឬវប្បធម៌ ដែលក្រុមជនជាតិដើមភាគតិចកាន់កាប់ ប្រើប្រាស់ រស់នៅ ឬអះអាងថាជាទឹកដីដូនតា ឬទ្រព្យសកម្មរបស់ពួកគេ។ ពាក្យថា "ក្រុមជនជាតិដើមភាគតិច" ត្រូវបានប្រើជាទូទៅ សំដៅលើក្រុមវប្បធម៌ សង្គម និងក្រុមងាយរងគ្រោះខុសៗគ្នា ដែលមានភិនភាគសម្គាល់ដូចខាងក្រោម : (១) ទទួលស្គាល់ដោយខ្លួនឯងថាជាសមាជិកនៃក្រុមវប្បធម៌ជនជាតិដើម ហើយការទទួលស្គាល់អត្តសញ្ញាណនេះ ត្រូវបានទទួលស្គាល់ពីអ្នកដទៃ (២) ភ្ជាប់រួមគ្នានឹងតំបន់ភូមិសាស្ត្ររស់នៅ ឬផែនដីដូនតាដែលស្ថិតនៅក្នុងតំបន់គម្រោង និងធនធានធម្មជាតិ នៅក្នុងតំបន់ជំរក និងដែនដីទាំងនោះ (៣) មានស្ថាប័ននយោបាយ សង្គម សេដ្ឋកិច្ច ឬវប្បធម៌ដាច់ដោយឡែកពីសង្គម និងវប្បធម៌ជនជាតិភាគច្រើន និង (៤) ប្រើភាសាដោយឡែកដែលជាទូទៅខុសពីភាសាផ្លូវការរបស់ប្រទេស ឬតំបន់។ ក្នុងការពិចារណាពីភិនភាគសម្គាល់ទាំងនេះ ច្បាប់ជាតិ ទម្លាប់អនុវត្ត និងអនុសញ្ញាអន្តរជាតិផ្សេងទៀតដែលរដ្ឋជាភាគី នឹងត្រូវលើកយកមកពិចារណាផងដែរ។ ក្រុមដែលបាត់បង់ការភ្ជាប់រួមគ្នានឹងតំបន់ភូមិសាស្ត្ររស់នៅ ឬផែនដីដូនតាដែលស្ថិតនៅក្នុងតំបន់គម្រោងដោយសារតែការផ្តាច់ចេញដោយមិនស្ម័គ្រចិត្ត នៅតែមាន សិទ្ធិទទួលបាននៅក្រោមគោលនយោបាយនេះ។ |
| **គោលការណ៍គោលនយោបាយ :**<br>១. សម្រិតសម្រាំងនៅដើមដំណាក់កាលគម្រោងដើម្បីកំណត់ថា : (១) មាន ឬមិនមានជនជាតិដើមភាគតិចនៅក្នុង (ឬការភ្ជាប់រួមគ្នាទៅនឹង) តំបន់គម្រោង និង (២) មាន ឬមិនមានផលប៉ះពាល់ចំពោះក្រុមជនជាតិដើមភាគតិច។<br>២. ធ្វើការវាយតម្លៃផលប៉ះពាល់សង្គមដែលមានការគិតគូរពីបញ្ហាយេនឌ័រ និងដែលមានលក្ខណៈសមស្របនឹងវប្បធម៌របស់ក្រុមជនជាតិដើមភាគតិច ឬប្រើប្រាស់វិធីសាស្ត្រប្រហាក់ប្រហែល ដើម្បីវាយតម្លៃផលប៉ះពាល់ដែលអាចមាន (ទាំងវិជ្ជមាន និងអវិជ្ជមាន) ចំពោះក្រុមជនជាតិដើមភាគតិច។ គិតគូរពីជម្រើសដែលក្រុមជនជាតិដើមភាគតិចចង់បាន ក្នុងការបែងចែកអត្ថ-ប្រយោជន៍គម្រោង និងប្លង់រចនាវិធានការកាត់បន្ថយ។ កំណត់អត្ថប្រយោជន៍សង្គម និងសេដ្ឋកិច្ចដែលសមស្របនឹងវប្បធម៌របស់ក្រុមជនជាតិដើមភាគតិច និងដែលមានគិតគូរពីបញ្ហាយេនឌ័រ និងអន្តរជំនាន់ និងអភិវឌ្ឍន៍វិធានការបញ្ចៀស បន្ធូរបន្ថយ និង/ឬ កាត់បន្ថយផលប៉ះពាល់អវិជ្ជមានចំពោះក្រុមជនជាតិដើមភាគតិច។ |

៣. ធ្វើការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយសហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ និង អង្គការជនជាតិដើមភាគតិចពាក់ព័ន្ធ ដើម្បីជម្រុញនូវការចូលរួមរបស់ពួកគេក្នុងការ (១) រៀបចំ អនុវត្ត និងតាមដានវិធានការនានា ដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមានចំពោះពួកគេ ឬ (ក្នុងករណីមិនបញ្ចៀសបាន) បន្ធូរបន្ថយ កាត់បន្ថយ និងទូទាត់សងចំពោះផលប៉ះពាល់ទាំងនោះ និង (២) កែតម្រូវអត្ថប្រយោជន៍គម្រោងឱ្យស្របតាមវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ ។ ដើម្បីពង្រឹងការចូលរួមដ៏សកម្មរបស់ក្រុមជនជាតិដើមភាគតិច គម្រោងដែលមានផលប៉ះពាល់ចំពោះពួកគេនឹងផ្តល់កម្មវិធីកសាងសមត្ថភាពដែលមានលក្ខណៈសមស្របនឹងវប្បធម៌របស់ពួកគេ និងដែលមានគិតគូរពីបញ្ហាយេនឌ័រ ។ បង្កើតយន្តការដោះស្រាយបណ្តឹងតវ៉ាដែលមានលក្ខណៈសមស្របនឹងវប្បធម៌របស់ពួកគេ និងដែលមានគិតគូរពីបញ្ហាយេនឌ័រ ដើម្បីទទួល និងសម្របសម្រួលដោះស្រាយក្តីបារម្ភរបស់ក្រុមជនជាតិដើមភាគតិច ។

៤. បញ្ជាក់នូវការយល់ព្រមរបស់សហគមន៍ជនជាតិដើមភាគតិចចំពោះសកម្មភាពគម្រោងដូចខាងក្រោម : (១) ការអភិវឌ្ឍន៍ពាណិជ្ជកម្មលើធនធានវប្បធម៌ និងចំណេះដឹងរបស់ក្រុមជនជាតិដើមភាគតិច (២) ការផ្លាស់ទីលំនៅរូបវន្តរបស់ក្រុមជនជាតិដើមភាគតិចចេញពីទឹកដីប្រពៃណី ឬទំនៀមទំលាប់ និង (៣) សកម្មភាពអភិវឌ្ឍន៍ពាណិជ្ជកម្មលើធនធានធម្មជាតិក្នុងទឹកដីប្រពៃណី ដោយមានការប្រើប្រាស់ដែលអាចនឹងប៉ះពាល់ដល់មធ្យោបាយចិញ្ចឹមជីវិត ឬការប្រើប្រាស់ដីដើម្បីប្រយោជន៍ខាងវប្បធម៌ ពិធីបុណ្យ ឬជំនឿសាសនា ដែលជាអត្តសញ្ញាណនៃសហគមន៍ជនជាតិដើមភាគតិច ។ នៅក្នុងការអនុវត្តគោលនយោបាយ ការយល់ព្រមរបស់សហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ សំដៅលើការបញ្ជាក់ជារួមរបស់សហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ តាមរយៈបុគ្គលណាមួយ និង/ឬ តំណាងរបស់ពួកគេ ក្នុងការគាំទ្រជារួមពីសហគមន៍ចំពោះសកម្មភាពគម្រោង ។ ការគាំទ្រជារួមពីសហគមន៍ ក៏អាចនឹងមានផងដែរ បើទោះជាមានការជំទាស់ចំពោះសកម្មភាពគម្រោងពីសំណាក់បុគ្គល ឬក្រុមមួយចំនួនក៏ដោយ ។

៥. បញ្ចៀស (តាមកម្រិតដែលអាចធ្វើទៅបាន) ការរឹតត្បិតសិទ្ធិប្រើប្រាស់ និងការផ្លាស់ទីលំនៅពីតំបន់ការពារធម្មជាតិ និងធនធានធម្មជាតិ ។ ប្រសិនបើការបញ្ចៀសមិនអាចធ្វើទៅបាន ធានាថាសហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ បានចូលរួមក្នុងការរចនា អនុវត្ត តាមដាន និងការវាយតម្លៃកម្មវិធីគ្រប់គ្រងតំបន់ និងធនធានធម្មជាតិទាំងនោះ និងធានាថាពួកគេទទួលបានអត្ថប្រយោជន៍ពីគម្រោងក្នុងចំណែកស្មើៗគ្នា ។

៦. រៀបចំផែនការក្រុមជនជាតិដើមភាគតិច (IPP) ដែលផ្អែកលើការវាយតម្លៃផលប៉ះពាល់សង្គម ដោយមានជំនួយពីអ្នកជំនាញការដែលមានគុណវុឌ្ឍិ និងបទពិសោធន៍គ្រប់គ្រាន់ និងដែលផ្អែកលើចំណេះដឹងពីជនជាតិដើមភាគតិច និងការចូលរួមរបស់សហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ ។ IPP មានចែងពីក្របខណ្ឌនៃការបន្តការពិគ្រោះយោបល់ជាមួយសហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់នៅអំឡុងពេលអនុវត្តគម្រោង វិធានការដាក់លាក់ក្នុងការធានាថាក្រុមជនជាតិដើមភាគតិចទទួលបានអត្ថប្រយោជន៍សមស្របនឹងវប្បធម៌របស់ពួកគេ កំណត់វិធានការបញ្ចៀស បន្ធូរបន្ថយ កាត់បន្ថយ ឬទូទាត់សងនូវផលប៉ះពាល់អវិជ្ជមាននានារបស់គម្រោង និងបញ្ចូលនូវនីតិវិធីដោះស្រាយបណ្តឹងតវ៉ាដែលសមស្របនឹងវប្បធម៌របស់ពួកគេ កម្មវិធីវាយ

តម្លៃ និងតាមដាន កញ្ចប់ថវិកា និងកម្មវិធីអនុវត្តវិធានការដែលបានព្រាងទុក ។

៧. ផ្សព្វផ្សាយសេចក្តីព្រាង IPP រួមទាំងឯកសារកត់ត្រាដំណើរការពិគ្រោះយោបល់ និងលទ្ធផលនៃការវាយតម្លៃផលប៉ះពាល់សង្គម ឱ្យបានទាន់ពេលវេលា នៅមុនពេលវាយតម្លៃគម្រោង និងត្រូវផ្តល់ឱ្យនៅកន្លែង និងក្នុងទម្រង់ និងភាសាដែលសហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធផ្សេងទៀតអាចយល់បាន ។ IPP ចុងក្រោយ និងការកែសម្រួលថ្មីក៏នឹងត្រូវផ្សព្វផ្សាយឱ្យសហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធផ្សេងទៀតបានដឹងផងដែរ ។

៨. រៀបចំផែនការសកម្មភាពទទួលស្គាល់តាមផ្លូវច្បាប់នូវសិទ្ធិប្រពៃណីដែលក្រុមជនជាតិដើមភាគតិចចំពោះទឹកដី ឬដែនដីដូនតា ប្រសិនបើគម្រោងមានពាក់ព័ន្ធនឹង (១) សកម្មភាពដែលពឹងផ្អែកលើការបង្កើតនូវការទទួលស្គាល់តាមផ្លូវច្បាប់នូវសិទ្ធិកាន់កាប់ដី និងដែនដី ដែលក្រុមជនជាតិដើមភាគតិចកាប់កាន់ ឬប្រើប្រាស់ ឬតាំងទីលំនៅជាប្រពៃណី ឬ (២) លទ្ធកម្មដោយមិនស្ម័គ្រចិត្តចំពោះដីទាំងនេះ ។

៩. តាមដានការអនុវត្ត IPP ដោយអ្នកជំនាញការដែលមានគុណវុឌ្ឍិ និងមានបទពិសោធន៍គ្រប់គ្រាន់ ។ ប្រកាន់យកនូវវិធីសាស្ត្រតាមដានមានការចូលរួម ប្រសិនបើអាច ។ និង វាយតម្លៃថាតើកម្មវត្ថុ IPP និងលទ្ធផលដែលចង់បាន បានសម្រេច ឬមិនបានសម្រេច តាមរយៈការប្រៀបធៀបលក្ខខណ្ឌគោល និងលទ្ធផលនៃការតាមដាន IPP ។ ផ្សព្វផ្សាយរបាយការណ៍តាមដាន ។

## ខ. ដំណើរការអនុវត្តគោលនយោបាយ

### ១. លក្ខខណ្ឌតម្រូវទូទៅ

៤៩. **ការត្រួតពិនិត្យ និង ចាត់ចំណាត់ថ្នាក់ :** ADB នឹងអនុវត្តការត្រួតពិត្យ និងចាត់ចំណាត់ថ្នាក់នៅជំហានដំបូងបំផុតនៃការរៀបចំគម្រោងនៅពេលដែលមានព័ត៌គ្រប់គ្រាន់សម្រាប់ធ្វើការត្រួតពិនិត្យ និងចាត់ចំណាត់ថ្នាក់នេះ។ ការត្រួតពិនិត្យ និងចាត់ចំណាត់ថ្នាក់ត្រូវអនុវត្តឡើងដើម្បី (១) បង្ហាញកម្រិតនៃការប៉ះពាល់ ឬហានិភ័យសំខាន់ៗដែលគម្រោងអាចបង្កឱ្យមាន (២) កំណត់ពីកម្រិតនៃការវាយតម្លៃ និងធនធានស្ថាប័នដែលត្រូវការសម្រាប់វិធានការការពារសុវត្ថិភាព និង (៣) កំណត់លក្ខខណ្ឌតម្រូវក្នុងការផ្តល់ព័ត៌មាន។

៥០. **ការចាត់ចំណាត់ថ្នាក់ផ្នែកបរិស្ថាន :** ADB ប្រើប្រាស់ប្រព័ន្ធបែងចែកចំណាត់ថ្នាក់ដើម្បីបង្ហាញពីកម្រិតនៃការប៉ះពាល់បរិស្ថានសំខាន់ៗ។ ចំណាត់ថ្នាក់គម្រោងត្រូវកំណត់ដោយសមាសភាគប៉ះពាល់បរិស្ថាន ដោយរួមបញ្ចូលទាំងការប៉ះពាល់ផ្ទាល់ ប្រយោល ត្រួតស៊ីគ្នា និងជាការបង្កនៅតំបន់គោលដៅគម្រោង។ គម្រោងដាក់ស្នើនីមួយៗ ត្រូវទទួលការពិនិត្យយ៉ាងម៉ត់ចត់ទៅតាមប្រភេទ ទីតាំង ទំហំ ភាពងាយរងការប៉ះពាល់ និងកម្រិតនៃការប៉ះពាល់បរិស្ថាន។ គម្រោងទាំងឡាយត្រូវបែងចែកចំណាត់ថ្នាក់ជា ៤ ដូចខាងក្រោម :

(i) **ប្រភេទ (A) :** គម្រោងដាក់ស្នើត្រូវបានរៀបចំកំណត់ជាប្រភេទ (A) ប្រសិនបើគម្រោងនោះអាចមានកម្រិតនៃការប៉ះពាល់ផ្នែកបរិស្ថានខ្លាំងដែលមិនអាចកែលម្អ បញ្ច្រាស ឬមិនធ្លាប់មានពីមុនមក។ ផលប៉ះពាល់នេះ អាចនឹងមានឥទ្ធិពលលើសពីតំបន់ ឬហេដ្ឋារចនាសម្ព័ន្ធគម្រោង អាស្រ័យទៅតាមការងាររូបវ័ន្ត។ គម្រោងនេះត្រូវការការពិនិត្យបរិស្ថានជាមុនសិន។

(ii) **ប្រភេទ (B) :** គម្រោងដាក់ស្នើត្រូវបានរៀបចំកំណត់ជាប្រភេទ (B) ប្រសិនបើលទ្ធភាពនៃការប៉ះពាល់ផ្នែកបរិស្ថានមានកម្រិតទាបជាងគម្រោងប្រភេទ (A)។ ការប៉ះពាល់ទាំងនោះកើតមានពិតប្រាកដតែក្នុងតំបន់ការងារ អាចកែលម្អបាន អាចងាយបង្កើតវិធានការកាត់បន្ថយការប៉ះពាល់បានងាយជាងគម្រោងប្រភេទ (ក)។ គម្រោងនេះត្រូវការការពិនិត្យបរិស្ថានជាមុនសិន។

(iii) **ប្រភេទ (C) :** គម្រោងដាក់ស្នើត្រូវបានរៀបចំកំណត់ជាប្រភេទ (C) ប្រសិនបើគម្រោងនោះអាចនឹងមានការប៉ះពាល់តិចតួច រឺក៏គ្មានប៉ះពាល់ផ្នែកបរិស្ថានតែម្តង។ គម្រោងនេះមិនតម្រូវឱ្យមានការវាយតម្លៃបរិស្ថានទេ ទោះបីយ៉ាងណាក៏ដោយ ត្រូវមានការពិនិត្យផ្នែកបរិស្ថាន។

(iv) **ប្រភេទ (FI) :** គម្រោងដាក់ស្នើត្រូវបានចាត់ចំណាត់ថ្នាក់ជាប្រភេទ (FI) ប្រសិនបើគម្រោងនោះពាក់ព័ន្ធនឹងការវិនិយោគរបស់ ADB ឬតាមរយៈ (FI) (សូមអាននៅកថាខណ្ឌ ៦៥-៦៧)។

៥១. **ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត :** ADB នឹងធ្វើការត្រួតពិនិត្យគ្រប់គម្រោងទាំងអស់ដើម្បីកំណត់ថាតើ

គម្រោងនោះមានពាក់ព័ន្ធនឹងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តដែរឬទេ។ ចំពោះគម្រោងទាក់ទងនឹងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ត្រូវរៀបចំផែនការតាំងទីលំនៅជាថ្មីឱ្យបានសមរម្យទៅនឹងទំហំ និងកម្រិតនៃការប៉ះពាល់។ កម្រិតនៃការប៉ះពាល់ត្រូវកំណត់ដោយ (i) វិសាលភាពនៃការផ្លាស់ទីលំនៅរូបវ័ន្ត និងសេដ្ឋកិច្ច (ii) ភាពងាយទទួលរងគ្រោះរបស់ក្រុមមនុស្សរងការប៉ះពាល់។ ចំពោះគម្រោងប្រភេទ (FI) សូមអានកថាខណ្ឌ ៦៥-៦៧។

៥២. **ក្រុមជនជាតិដើមភាគតិច :** ADB នឹងធ្វើការត្រួតពិនិត្យគ្រប់គម្រោងទាំងអស់ដើម្បីកំណត់ថាតើគម្រោងនោះមានការប៉ះពាល់ដល់ជនជាតិដើមភាគតិចដែរឬទេ។ ចំពោះគម្រោងដែលមានការប៉ះពាល់ដល់ជនជាតិដើមភាគតិច នឹងត្រូវមានរៀបចំផែនការជួយជនជាតិដើមភាគតិច។ កម្រិតលម្អិត និងភាពទូលំទូលាយនៃផែនការ នឹងមានលក្ខណៈស្របទៅនឹងកម្រិតនៃការប៉ះពាល់។ កម្រិតនៃការប៉ះពាល់ត្រូវបានកំណត់ដោយ (១) កម្រិតនៃការប៉ះពាល់ទៅលើសិទ្ធិប្រពៃណីរបស់ជនជាតិដើមភាគតិច និងលទ្ធភាពទទួលបានដីធ្លី និងធនធានធម្មជាតិ ស្ថានភាពសេដ្ឋកិច្ច វប្បធម៌ និងបូរណភាពទឹកដី សុខភាព ការអប់រំ ការចិញ្ចឹមជីវិត និងសន្តិសុខសង្គម ឬចំណេះដឹងជនជាតិដើមភាគតិច (២) ភាពងាយទទួលរងគ្រោះរបស់ជនជាតិដើមភាគតិចដែលរងការប៉ះពាល់។ ចំពោះគម្រោងប្រភេទ (FI) សូមអានកថាខណ្ឌ ៦៥-៦៧។

៥៣. **ការផ្សព្វផ្សាយព័ត៌មាន :** ស្របទៅនឹងគោលនយោបាយទំនាក់ទំនងសាធារណៈរបស់ ADB ADB ព្យាយាមធ្វើការជាមួយអ្នកខ្ចី/អតិថិជនដើម្បីធានាថា រាល់ព័ត៌មានពាក់ព័ន្ធ (វិជ្ជមាន ឬ អវិជ្ជមាន) អំពីការការពារសង្គម និងបរិស្ថាន ត្រូវបានផ្សព្វផ្សាយទាន់ពេលវេលានៅទីកន្លែងដែលអាចទទួលបាន និងក្នុងទម្រង់ និងភាសាងាយយល់ដល់ជនជាតិដើមភាគតិចដែលរងការប៉ះពាល់ និងអ្នកពាក់ព័ន្ធផ្សេងទៀត រួមទាំងសាធារណៈជន ដើម្បីពួកគេមានឱកាសរួមចំណែកដល់ការរៀបចំ និងអនុវត្តគម្រោង។ ADB នឹងធ្វើការផ្សព្វផ្សាយឯកសារស្តីពីការការពារដូចខាងក្រោមនៅក្នុងគេហទំព័ររបស់ខ្លួន។

(i) ចំពោះគម្រោងបរិស្ថានប្រភេទ (A) រៀបចំរបាយការណ៍វាយតម្លៃពីការប៉ះពាល់ផ្នែកបរិស្ថានយ៉ាងហោចណាស់រយៈពេល ១២០ថ្ងៃ មុនពេលក្រុមប្រឹក្សាភិបាលធ្វើការពិចារណា។

(ii) រៀបចំពង្រាងការវាយតម្លៃបរិស្ថាន និងត្រួតពិនិត្យក្របខណ្ឌការងារ។ ធ្វើពង្រាងក្របខណ្ឌការងារ និងផែនការតាំងទីលំនៅជាថ្មី និងធ្វើពង្រាងក្របខណ្ឌការងារ ឬផែនការសម្រាប់ជនជាតិដើមភាគតិច មុនពេលធ្វើការវាយតម្លៃគម្រោង។

(iii) ការវាយតម្លៃការប៉ះពាល់បរិស្ថាន និងការពិនិត្យបរិស្ថាន ផែនការតាំងទីលំនៅជាថ្មី និងផែនការក្រុមជនជាតិដើមភាគតិច (ឯកសារចុងក្រោយ និងថ្មី១)។

(iv) របាយការណ៍ត្រួតពិនិត្យបរិស្ថាន ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និងជនជាតិភាគតិច ដែលអ្នកខ្ចី/អតិថិជនបាន ផ្ញើនៅអំឡុងអនុវត្តគម្រោង។

៥៤. **ការពិគ្រោះយោបល់ និង ការចូលរួម :** ADB ព្យាយាមធ្វើការជាមួយអ្នកខ្ចី/អតិថិជនដើម្បីដំណើរការការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យ។ ក្នុងការអនុវត្តគោលនយោបាយ ការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យ គឺជាដំណើរការ

ដែល (១) ចាប់ផ្ដើមនៅដើមដំណាក់កាលនៃការរៀបចំគម្រោង និងបន្តធ្វើជាប់ជានិច្ចនៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង (២) ធ្វើការផ្ដល់ព័ត៌មានពាក់ព័ន្ធ និងសមស្របទាន់ពេលវេលា និងជាព័ត៌មានដែលក្រុមមនុស្សរងផលប៉ះពាល់អាចរកបាន និងអាចយល់បានដោយងាយស្រួល (៣) ធ្វើឡើងនៅក្នុងបរិយាកាសដែលគ្មានការគំរាមកំហែង និងបង្ខិតបង្ខំ (៤) មានការគិតគូរពីបញ្ហាយេនឌ័រ និងមានការតម្រែតម្រង់ទៅតាមតម្រូវការក្រុមទន់ខ្សោយ និងងាយរងគ្រោះ និង (៥) អនុញ្ញាតឱ្យមានការបញ្ចូលគំនិតយោបល់របស់ក្រុមមនុស្សរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធ ក្នុងការធ្វើការសម្រេចចិត្តពីការរៀបចំគម្រោង វិធានការកាត់បន្ថយផលប៉ះពាល់ ការចែករំលែកអត្ថប្រយោជន៍ និងឱកាសដែលបានមកពីការអភិវឌ្ឍន៍ និងបញ្ហាអនុវត្តគម្រោង។ ADB នឹងតម្រូវអោយអ្នកខ្ចី/អតិថិជនទាំងអស់ បញ្ចូលសហគមន៍ ក្រុម ឬក៏ប្រជាពលរដ្ឋ រងការប៉ះពាល់ដោយគម្រោងដែលបានស្នើ និងជាមួយសង្គមស៊ីវិល តាមរយៈការផ្ដល់ព័ត៌មាន ការពិគ្រោះយោបល់ និងការចូលរួមដោយមានព័ត៌មាន ដោយស្របទៅនឹងហានិភ័យ និងការប៉ះពាល់ចំពោះសហគមន៍ដែលរងការប៉ះពាល់។ ចំពោះគម្រោងដែលមានការប៉ះពាល់បរិស្ថាន ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ឬការប៉ះពាល់ចំពោះជនជាតិដើមភាគតិចក្នុងកម្រិតខ្ពស់ ក្រុមការងារ ADB នឹងចូលរួមនៅក្នុងសកម្មភាពពិគ្រោះយោបល់ដើម្បីយល់ពីកង្វល់របស់ក្រុមមនុស្សរងផលប៉ះពាល់ និងធានាថាមានការបញ្ចូលកង្វល់ទាំងនោះទៅក្នុងការរៀបចំគម្រោង និងផែនការការពារ។

៥៥. លើសពីនេះទៀត ADB ទទួលស្គាល់ថា ជនជាតិដើមភាគតិចអាចមានភាពងាយរងគ្រោះខ្លាំងចំពោះស្ថានភាពគម្រោងមួយចំនួន។ ហេតុនេះ ត្រូវមានការយល់ព្រមពីសហគមន៍ជនជាតិដើមភាគតិច តាមរយៈការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យចំពោះសកម្មភាពគម្រោងដូចតទៅ : (១) ការអភិវឌ្ឍន៍ពាណិជ្ជកម្មលើធនធានវប្បធម៌ និងចំណេះដឹងរបស់ក្រុមជនជាតិដើមភាគតិច (២) ការផ្លាស់ទីលំនៅរូបវន្តរបស់ក្រុមជនជាតិដើមភាគតិចចេញពីទឹកដីប្រពៃណី ឬទំនៀមទំលាប់ និង (៣) សកម្មភាពអភិវឌ្ឍន៍ពាណិជ្ជកម្មលើធនធានធម្មជាតិក្នុងទឹកដីប្រពៃណី ដោយមានការប្រើប្រាស់ដែលអាចនឹងប៉ះពាល់ដល់មធ្យោបាយចិញ្ចឹមជីវិត ឬការប្រើប្រាស់ដីដើម្បីប្រយោជន៍ខាងវប្បធម៌ ពិធីបុណ្យ ឬជំនឿសាសនា ដែលជាអត្តសញ្ញាណនៃសហគមន៍ជនជាតិដើមភាគតិច។ នៅក្នុងការអនុវត្តគោលនយោបាយ ការយល់ព្រមរបស់សហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ សំដៅលើការបញ្ជាក់ជារួមរបស់សហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ តាមរយៈបុគ្គលណាមួយ និង/ឬ តំណាងរបស់ពួកគេ ក្នុងការគាំទ្រជារួមពីសហគមន៍ចំពោះសកម្មភាពគម្រោង។ ការគាំទ្រជារួមពីសហគមន៍ ក៏អាចនឹងមានផងដែរ បើទោះជាមានការជំទាស់ចំពោះសកម្មភាពគម្រោងពីសំណាក់បុគ្គល ឬក្រុមមួយចំនួនក៏ដោយ។ អ្នកខ្ចី/អតិថិជន នឹងត្រូវធានាថា សហគមន៍ជនជាតិដើមភាគតិចដែលរងការប៉ះពាល់ផ្ដល់ការគាំទ្រទូលំទូលាយចំពោះសកម្មភាពគម្រោង និងនៅកន្លែងណាដែលសហគមន៍គាំទ្រ IPP នឹងចងក្រងឯកសារឱ្យបានច្បាស់ពីដំណើរការពិគ្រោះយោបល់។ ADB នឹងត្រួតពិនិត្យឯកសាររបស់អតិថិជនស្ដីពីដំណើរការពិគ្រោះយោបល់នេះ។ លើសពីនេះទៀត តាមរយៈការស៊ើបអង្កេតរបស់ខ្លួន នឹងធានាថាសហគមន៍ដែលរងការប៉ះពាល់បង្ហាញពីការគាំទ្រទូលំទូលាយចំពោះសកម្មភាពគម្រោង។ ADB នឹងមិនផ្ដល់ហិរញ្ញប្បទានចំពោះគម្រោងឡើយ ប្រសិនបើគ្មានការគាំទ្រជារួមពីសហគមន៍ជនជាតិដើមភាគតិចនោះទេ។

៥៦. **ការអង្កេតលម្អិត និង ការវាយតម្លៃ :** ចំពោះគម្រោងស្នើសុំហិរញ្ញប្បទាន ADB នឹងរៀបចំការវាយតម្លៃការការពារដែលរួមទាំងការវាយតម្លៃឯកសារការពាររបស់អ្នកខ្ចី/អតិថិជន ដែលនេះជាផ្នែកមួយនៃការអង្កេតលម្អិត។ ក្រៅពីការចងក្រងឯកសារ

ការពារ ការអង្កេតលម្អិត និងការវាយតម្លៃការការពាររបស់ ADB សង្កត់ធ្ងន់លើការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម និងដំណើរការរៀបចំផែនការ។ ការអង្កេតលម្អិត និងការវាយតម្លៃ មានទាំងការចុះអង្កេតនៅមូលដ្ឋាន និងការវាយតម្លៃនៅការិយាល័យ។ តាមរយៈការអង្កេតលម្អិត និងការវាយតម្លៃ ADB ធានាអះអាងថា : (១) រាល់ផលប៉ះពាល់ និងហានិភ័យសង្គម និងបរិស្ថានរបស់គម្រោងត្រូវបានកំណត់ (២) វិធានមានប្រសិទ្ធភាពក្នុងការបញ្ចៀស បន្ធូរបន្ថយ កាត់បន្ថយ និងប៉ះប៉ូវសងនូវផលប៉ះពាល់អវិជ្ជមាន ត្រូវបានដាក់បញ្ចូលក្នុងផែនការការពារ និងប្លង់រចនាគម្រោង (៣) អ្នកខ្ចី/អតិថិជន យល់ពីគោលការណ៍គោលនយោបាយការពារ និងលក្ខខណ្ឌតម្រូវរបស់ ADB ដែលមានចែងក្នុងលក្ខខណ្ឌតម្រូវសម្រាប់ការពារ ១-៤ និងមានការប្តេជ្ញាចិត្ត និងលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងផលប៉ះពាល់ និង/ឬ ហានិភ័យសង្គម និងបរិស្ថាន (៤) តួនាទីរបស់តតិយជនត្រូវបានកំណត់យ៉ាងសមស្របក្នុងផែនការការពារ និង (៥) ការពិគ្រោះយោបល់ជាមួយក្រុមមនុស្សរងផលប៉ះពាល់ត្រូវរៀបចំធ្វើស្របតាមលក្ខខណ្ឌតម្រូវរបស់ ADB។ ក្នុងករណីដែលការវាយតម្លៃ និងការរៀបចំផែនការ ឬឯកសារការពារ មិនបំពេញតាមលក្ខខណ្ឌតម្រូវការពាររបស់ ADB អ្នកខ្ចី/អតិថិជននឹងត្រូវតម្រូវឱ្យធ្វើការវាយតម្លៃបន្ថែម និង/ឬ កែសម្រួលផែនការការពារ។ ប្រសិនអ្នកខ្ចី/អតិថិជនគ្មានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តផែនការការពាររបស់គម្រោងដែលបានស្នើសុំនោះទេ គម្រោងនឹងមានបញ្ចូលសមាសធាតុពង្រឹងសមត្ថភាពរបស់អ្នកខ្ចី/អតិថិជន។ ចំពោះគម្រោងដែល ADB សន្មតថាមានលក្ខណៈស្មុគស្មាញ និងងាយរងការប៉ះពាល់ខ្លាំង[២៧] ADB នឹងតម្រូវឱ្យអ្នកខ្ចី/អតិថិជនជួលក្រុមទីប្រឹក្សាឯករាជ្យ នៅអំឡុងពេលរៀបចំ និងអនុវត្តគម្រោង។

៥៧. **ការតាមដាន និង ការរាយការណ៍ :** អ្នកខ្ចី/អតិថិជន និង ADB មានការទទួលខុសត្រូវក្នុងការតាមដានដាច់ចេញពីគ្នា។ ទំហំនៃសកម្មភាពតាមដាន (រួមទាំងវិសាលភាព និងសាមយិកភាព) ត្រូវសមមាត្រជាមួយនឹងផលប៉ះពាល់ និងហានិភ័យរបស់គម្រោង។ អ្នកខ្ចី/អតិថិជន ត្រូវអនុវត្តវិធានការការពារ និងផែនការការពារពាក់ព័ន្ធ ដូចមានចែងក្នុងកិច្ចព្រមព្រៀង និងផ្ញើរបាយការណ៍សាមយិកស្តីពីការតាមដានលទ្ធផលអនុវត្តរបស់ពួកគេ។ ADB នឹងតម្រូវឱ្យអ្នកខ្ចី/អតិថិជន :

(i) បង្កើត និងរក្សានីតិវិធីតាមដានការវិវត្តនៃការអនុវត្តផែនការការពារ។

(ii) បញ្ជាក់នូវការអនុលោមតាមវិធានការការពារ និងការវិវត្តឆ្ពោះទៅលទ្ធផលរំពឹងទុក។

(iii) កត់ត្រា និងផ្សព្វផ្សាយលទ្ធផលតាមដាន និងកំណត់នូវសកម្មភាពកែតម្រូវ និងសកម្មភាពបង្ការ ក្នុងរបាយការណ៍តាមដានសាមយិក។

(iv) តាមដានមើលសកម្មភាពទាំងនេះ ដើម្បីធានានូវការវិវត្តឆ្ពោះទៅលទ្ធផលរំពឹងទុក។

(v) ជួលអ្នកជំនាញពីខាងក្រៅដែលមានគុណវុឌ្ឍិ និងមានបទពិសោធន៍[២៨] ឬ NGO ដែលមានគុណវុឌ្ឍិ ឱ្យធ្វើការបញ្ជាក់លើព័ត៌មានតាមដាន ចំពោះគម្រោងដែលមានផលប៉ះពាល់ និងហានិភ័យធ្ងន់ធ្ងរ។

---

[២៧] គម្រោងមានភាពស្មុគស្មាញ និងងាយរងការប៉ះពាល់ខ្លាំង ជាគម្រោងដែល ADB គិតថាមានហានិភ័យខ្ពស់ ឬត្រូវប្រុងប្រយ័ត្ន ឬពាក់ព័ន្ធនឹងការប៉ះពាល់បរិស្ថាន និងសង្គមខ្លាំង ច្រើនផ្នែក និងពាក់ព័ន្ធគ្នាទៅវិញទៅមក។

[២៨] អ្នកជំនាញពីខាងក្រៅសំដៅលើអ្នកជំនាញដែលមិនពាក់ព័ន្ធនឹងការអនុវត្ត ឬត្រួតពិនិត្យគម្រោងប្រចាំថ្ងៃ។

(vi) ប្រើប្រាស់ក្រុមទីប្រឹក្សាឯករាជ្យក្នុងការតាមដានការអនុវត្តគម្រោងដែលមានភាពស្មុគស្មាញ និងងាយរងការប៉ះ-ពាល់ខ្លាំង ។ និង

(vii) ផ្ញើរបាយការណ៍តាមដានសាមយិកពីវិធានការការពារដូចបានព្រមព្រៀងជាមួយ ADB ។

៥៨. ADB វាយតម្លៃលទ្ធផលគម្រោងធៀបជាមួយនឹងការប្តេជ្ញារបស់អ្នកខ្ចី/អតិថិជនដែលបានព្រមព្រៀងក្នុងកិច្ចព្រមព្រៀង ។ ទំហំនៃសកម្មភាពតាមដាន និងត្រួតពិនិត្យរបស់ ADB ត្រូវសមមាត្រជាមួយនឹងផលប៉ះពាល់ និងហានិភ័យរបស់គម្រោង ។ ការតាមដាន និងការត្រួតពិនិត្យការការពារបរិស្ថាន និងសង្គម ត្រូវបានបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងលទ្ធផលអនុវត្តគម្រោង ។ ADB នឹងតាមដានគម្រោងជាប្រចាំ រហូតទាល់តែមានការចេញរបាយការណ៍បញ្ចប់គម្រោង ។ ADB នឹងធ្វើសកម្មភាពតាមដានដូចខាងក្រោម ដើម្បីត្រួតពិនិត្យការអនុវត្តគម្រោង :

(i) រៀបចំចុះត្រួតពិនិត្យដល់មូលដ្ឋានជាទៀងទាត់ សម្រាប់គម្រោងដែលមានផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសង្គម ។

(ii) រៀបចំបេសកម្មចុះត្រួតពិនិត្យដោយមានការវាយតម្លៃលម្អិតដោយមន្ត្រី/អ្នកឯកទេសគោលនយោបាយការពារ ឬទីប្រឹក្សារបស់ ADB សម្រាប់គម្រោងដែលមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់សង្គម និងបរិស្ថាន ។

(iii) វាយតម្លៃរបាយការណ៍តាមដានសាមយិកដែលអ្នកខ្ចី/អតិថិជនផ្ញើមក ដើម្បីធានាថាផលប៉ះពាល់ និងហានិភ័យអវិជ្ជមានត្រូវបានកាត់បន្ថយតាមការគ្រោងទុក និងតាមការព្រមព្រៀងជាមួយ ADB ។

(iv) ធ្វើការជាមួយអ្នកខ្ចី/អតិថិជនដើម្បីកែតម្រូវតាមលទ្ធភាពដែលអាចធ្វើទៅបាន នូវការមិនបំពេញតាមការសន្យាការពាររបស់អ្នកខ្ចី/អតិថិជននៅក្នុងកិច្ចព្រមព្រៀង និងធ្វើការដោះស្រាយបង្កើតឱ្យមានអនុលោមភាពឡើងវិញ ។ និង

(v) រៀបចំរបាយការណ៍បញ្ចប់គម្រោងដែលវាយតម្លៃពីការសម្រេច ឬមិនសម្រេចបានកម្មវត្ថុ និងលទ្ធផលតាមការរំពឹងទុកនៃផែនការការពារ តាមរយៈការប្រៀបធៀបលក្ខខណ្ឌគោល និងលទ្ធផលនៃការតាមដាន ។

៥៩. **យន្តការដោះស្រាយបណ្តឹងតវ៉ាថ្នាក់មូលដ្ឋាន :** ADB តម្រូវឱ្យអ្នកខ្ចី/អតិថិជនបង្កើត និងរក្សាយន្តការដោះស្រាយបណ្តឹងតវ៉ាមួយ ដើម្បីទទួល និងសម្របសម្រួលដោះស្រាយក្តីបារម្ភ និងបណ្តឹងរបស់ក្រុមមនុស្សរងផលប៉ះពាល់ ពីបញ្ហាបរិស្ថាន និងសង្គមដែលកើតមានដោយសារគម្រោងរបស់អ្នកខ្ចី/អតិថិជន ។ យន្តការដោះស្រាយបណ្តឹងតវ៉ា ត្រូវមានទំហំសមមាត្រនឹងផលប៉ះពាល់ និងហានិភ័យរបស់គម្រោង ។ យន្តការនេះ ត្រូវតែអាចដោះស្រាយក្តីបារម្ភ និងបណ្តឹងតវ៉ារបស់ក្រុមមនុស្សរងផលប៉ះពាល់បានឆាប់រហ័ស ដោយប្រើប្រាស់នូវដំណើរការដែលងាយយល់ និងមានតម្លាភាព និងដែលមានការគិតគូរពីយេនឌ័រ មានលក្ខណៈសមស្របនឹងវប្បធម៌របស់ក្រុមមនុស្សរងផលប៉ះពាល់ និងអាចប្រើប្រាស់បានដោយក្រុមមនុស្សរងផលប៉ះពាល់គ្រប់ស្រទាប់វណ្ណៈ ។

៦០. **យន្តការគណនេយ្យភាព :** ក្រុមមនុស្សរងផលប៉ះពាល់ពីគម្រោង ក៏អាចដាក់ពាក្យបណ្តឹងតាមរយៈយន្តការគណនេយ្យ

ភាពរបស់ ADB ផងដែរ។ យន្តការគណនេយ្យភាព បង្កើតឱ្យមាននូវដំណើរការ និងវេទិកាឯករាជ្យមួយ ដែលក្រុមមនុស្សរងផលប៉ះពាល់ អវិជ្ជមានពីគម្រោងផ្តល់ហិរញ្ញប្បទានដោយ ADB អាចប្តឹងតវ៉ាទាមទារដំណោះស្រាយចំពោះបញ្ហារបស់ពួកគេ និងរាយការណ៍ពីរំលោភបំពានគោលនយោបាយប្រតិបត្តិការ និងនីតិវិធីរបស់ ADB។ យន្តការគណនេយ្យភាព ចែកចេញជាដំណាក់កាលដាច់ដោយឡែក (តែពាក់ព័ន្ធគ្នា) ចំនួន ២ : (១) ដំណាក់កាលពិគ្រោះយោបល់ ដែលដឹកនាំដោយអ្នកសម្របសម្រួលគម្រោងពិសេសរបស់ ADB ដែលរាយការណ៍ប្រាប់ប្រធាន ADB ដោយផ្ទាល់ ដើម្បីជួយក្រុមមនុស្សដែលរងផលប៉ះពាល់ពីគម្រោង ក្នុងការស្វែងរកដំណោះស្រាយចំពោះបញ្ហារបស់ពួកគេ និង (២) ដំណាក់កាលវាយតម្លៃអនុលោមភាព ដែលដឹកនាំដោយគណៈកម្មការពិនិត្យអនុលោមភាពដែលមានសមាជិក ៣ រូប ហើយដែលគណៈកម្មការនេះនឹងរាយការណ៍ប្រាប់ក្រុមប្រឹក្សាភិបាល។ គណៈកម្ម-ការពិនិត្យអនុលោមភាព ស៊ើបអង្កេតរាល់ការប្តឹងពីការរំលោភបំពានគោលនយោបាយប្រតិបត្តិការ និងនីតិវិធីដែលកំណត់ដោយក្រុមប្រឹក្សាភិបាលរបស់ ADB រួមទាំងគោលនយោបាយការពារផង ដែលការរំលោភបំពាននោះបណ្តាលឱ្យ ឬអាចនឹងបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដោយផ្ទាល់ចំពោះក្រុមមនុស្សរងផលប៉ះពាល់ពីគម្រោង និងផ្តល់អនុសាសន៍ពីរបៀបធានានូវភាពអនុលោមតាមគោលនយោបាយ និងនីតិវិធីទាំងនោះ។

## ២. លក្ខខណ្ឌតម្រូវពិសេស

៦១. ក្រៅពីគម្រោងប្រាក់កម្ចីស្តង់ដារដែលគោរពតាមលក្ខខណ្ឌតម្រូវទូទៅដែលមានចែងក្នុងកថាខណ្ឌ ៤៩-៦០ មានករណីជាក់លាក់មួយចំនួនដែលតម្រូវឱ្យធ្វើការកែសម្រួលវិធីសាស្ត្រក្នុងការដោះស្រាយហានិភ័យ និងផលប៉ះពាល់ចំពោះសង្គម និងបរិស្ថាន។ សេចក្តីបន្ថែម ៤ កំណត់ពីលក្ខខណ្ឌតម្រូវបន្ថែមសម្រាប់កម្មវិធីផ្តល់ប្រាក់កម្ចី ប្រាក់កម្ចីតាមវិស័យ របៀបផ្តល់ហិរញ្ញប្បទានពហុភាគី ជំនួយប្រាក់កម្ចីបន្ទាន់ របៀបដែលមានស្រាប់ អន្តរការីហិរញ្ញវត្ថុ និងហិរញ្ញវត្ថុសហគ្រាសទូទៅ។ ប្រសិនបើមានការអភិវឌ្ឍន៍គំរូផ្តល់ប្រាក់កម្ចីថ្មី សេចក្តីបន្ថែម ៤ នឹងធ្វើបច្ចុប្បន្នភាពដើម្បីដោះស្រាយជាមួយនឹងគំរូថ្មីនោះ។

### ក. ក្របខណ្ឌការពារ

៦២. ក្របខណ្ឌការពារអនុវត្តចំពោះគម្រោងដែលកើតចេញពីប្រាក់កម្ចីតាមវិស័យ MFF ជំនួយប្រាក់កម្ចីបន្ទាន់ ឬគំរូផ្តល់ប្រាក់កម្ចីផ្សេងទៀត រួមទាំងគម្រោងដែលមានអនុគម្រោង និងសមាសភាគគម្រោងរៀបចំនៅក្រោយការអនុម័តរបស់ ក្រុមប្រឹក្សា-ភិបាល។ គោលបំណងនៃក្របខណ្ឌការពារ គឺដើម្បីធានាថាអនុគម្រោង ឬសមាសភាគគម្រោងត្រូវបានអនុវត្តស្របតាម ក្របខណ្ឌ និងអនុលោមតាមកម្មវត្ថុ គោលការណ៍ និងលក្ខខណ្ឌតម្រូវការពាររបស់ ADB។ ក្របខណ្ឌការពារ (រួមមានដូចជាក្របខណ្ឌវាយតម្លៃ និងត្រួតពិនិត្យបរិស្ថាន ក្របខណ្ឌតាំងទីលំនៅជាថ្មី និងក្របខណ្ឌរៀបចំផែនការក្រុមជនជាតិដើមភាគតិច) ត្រូវតែមាននៅមុនពេលអនុម័តគម្រោង ដើម្បីផ្តល់ការណែនាំពីការពិនិត្យ និងចាត់ចំណាត់ថ្នាក់ ការវាយតម្លៃ ការរៀបចំផែនការ ការរៀបចំ អង្គការ និងដំណើរការដែលត្រូវអនុវត្តតាម សម្រាប់អនុគម្រោង និង/ឬ សមាសភាគគម្រោង ដែលត្រូវរៀបចំនៅក្រោយការអនុម័តរបស់ក្រុមប្រឹក្សាភិបាល។ ការវាយតម្លៃផលប៉ះពាល់ និងផែនការការពារ ត្រូវរៀបចំនៅពេលរៀបចំអនុគម្រោង ឬសមាសភាគគម្រោង

អនុលោមតាមក្របខណ្ឌការពារដែលបានព្រមព្រៀងរវាង ADB និងអ្នកខ្ចី/អតិថិជន។ ក្របខណ្ឌការពារ នឹងមិនត្រូវយកទៅប្រើ ចំពោះអនុគម្រោងស្មុគ្រស្មាញ និងងាយរងការប៉ះពាល់ខ្លាំងនៃប្រាក់កម្ចីតាមវិស័យ ឬផ្នែកនៃប្រាក់កម្ចីតាមវិស័យរបស់ MFF ឡើយ។

៦៣. ក្របខណ្ឌការពារ នឹងត្រូវរៀបចំសម្រាប់តំបន់ការពារនីមួយៗ ហើយនឹង :

(i) ឆ្លុះបញ្ចាំងពីកម្មវត្ថុគោលនយោបាយ និងគោលការណ៍គោលនយោបាយ និងលក្ខខណ្ឌតម្រូវការពារ ដែលគ្រប់គ្រងការរៀបចំ និងការអនុវត្តអនុគម្រោង និង/ឬ សមាសភាគគម្រោង។

(ii) ពន្យល់ផលប៉ះពាល់ជាទូទៅដែលបានរំពឹងទុករបស់អនុគម្រោង និង/ឬ សមាសភាគគម្រោងដែលទទួលហិរញ្ញប្បទានពីគម្រោងដែលបានស្នើសុំ។

(iii) កំណត់លក្ខខណ្ឌតម្រូវដែលត្រូវគោរពតាមក្នុងការពិនិត្យ និងចាត់ចំណាត់ថ្នាក់អនុគម្រោង ការវាយតម្លៃ និងការរៀបចំផែនការ រួមទាំងការរៀបចំផ្សព្វផ្សាយព័ត៌មាន ការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យដែលមានការចូលរួមពីក្រុមងាយរងគ្រោះដូចជាស្ត្រី យន្តការដោះស្រាយបណ្តឹងតវ៉ា និង (ប្រសិនបើអាច) លក្ខណៈវិនិច្ឆ័យការពារដែលប្រើក្នុងការជ្រើសរើសអនុគម្រោង និង/ឬ សមាសភាគគម្រោង។

(iv) រៀបរាប់ពីនីតិវិធីអនុវត្ត រួមទាំងកញ្ចប់ថវិកា ការរៀបចំស្ថាប័ន និងលក្ខខណ្ឌតម្រូវអភិវឌ្ឍន៍សមត្ថភាព។

(v) កំណត់លក្ខខណ្ឌតម្រូវតាមដាន និងរាយការណ៍។ និង

(vi) កំណត់ពីការទទួលខុសត្រូវ និងសិទ្ធិអំណាចរបស់អ្នកខ្ចី/អតិថិជន ADB និងទីភ្នាក់ងាររដ្ឋាភិបាល ក្នុងការរៀបចំ បញ្ជូន ពិនិត្យ និងវាយតម្លៃឯកសារការពាររបស់អនុគម្រោង និងតាមដាន និងត្រួតពិនិត្យការអនុវត្តផែនការការពារ។

៦៤. ដើម្បីកំណត់ថាតើការអនុវត្តក្របខណ្ឌការពារមានភាពសមស្រប ឬមិនសមស្រប ADB នឹងវាយតម្លៃសមត្ថភាពរបស់អ្នកខ្ចី/អតិថិជនក្នុងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់ចំពោះបរិស្ថាន និងសង្គម និងក្នុងការអនុវត្តច្បាប់ជាតិ និងលក្ខខណ្ឌតម្រូវរបស់ ADB។ ប្រសិនបើមានគម្លាតរវាងលក្ខខណ្ឌតម្រូវរបស់ ADB និងច្បាប់របស់ប្រទេស ឬប្រសិនអ្នកខ្ចីនៅមានគម្លាតសមត្ថភាព ក្របខណ្ឌការពារគួរតែមានកំណត់លម្អិតពីលក្ខខណ្ឌតម្រូវជាក់លាក់ក្នុងការបំបាត់គម្លាតនោះ ដើម្បីធានានូវការសម្រេចបានតាមគោលការណ៍គោលនយោបាយ និងលក្ខខណ្ឌតម្រូវការពារ។

### ខ. អន្តរការីហិរញ្ញវត្ថុ

៦៥. ចំពោះគម្រោងដែលវិនិយោគដោយមូលនិធិរបស់ ADB ឬអន្តរការីហិរញ្ញវត្ថុ (FI) ADB រៀបចំការអង្កេតលម្អិតពីការការពារ ដើម្បីវាយតម្លៃហានិភ័យ និងផលប៉ះពាល់ដែលអាចមានចំពោះសង្គម និងបរិស្ថាន ដែលពាក់ព័ន្ធនឹង FI ដែលមានស្រាប់ និងផលប័ត្រគម្រោងដែលអាចមាននៅពេលអនាគត និងពិនិត្យមើលការប្តេជ្ញា និងសមត្ថភាពរបស់ខ្លួនក្នុងការគ្រប់គ្រងសង្គម

និងបរិស្ថាន។ FI ទាំងអស់នឹងធានាថា ការវិនិយោគរបស់ពួកគេអនុលោមតាមច្បាប់ និងបទបញ្ញាជាតិ ដែលនៅជាធរមាន និងគោរពតាមតារាងសកម្មភាពវិនិយោគដែលត្រូវហាមឃាត់ (ឧបសម្ព័ន្ធ ៥) ចំពោះអនុគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយ ADB ។ ប្រសិនបើការវិនិយោគរបស់អន្តរការីហិរញ្ញវត្ថុ (FI) មានផលប៉ះពាល់ចំពោះសង្គម និងបរិស្ថានតិចតួច ឬគ្មានផលប៉ះពាល់អវិជ្ជមាន គម្រោង FI នឹងត្រូវចាត់ទុកជាគម្រោងប្រភេទ C ហើយមិនចាំបាច់អនុវត្តលក្ខខណ្ឌតម្រូវជាក់លាក់ផ្សេងទៀតឡើយ។ គម្រោង FI ផ្សេងទៀត ចាំបាច់ត្រូវមាន ឬបង្កើតឱ្យមានប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) ដែលមានទំហំសមាមាត្រនឹងលក្ខណៈ និងហានិភ័យនៃការវិនិយោគរបស់ FI នៅពេលអនាគត ដែលប្រព័ន្ធនេះនឹងត្រូវរក្សាជាផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រងទាំងមូលរបស់ FI ។

៦៦. ESMS មានធាតុដូចតទៅ : (១) គោលនយោបាយបរិស្ថាន និងសង្គម (២) នីតិវិធីពិនិត្យ ចាត់ចំណាត់ថ្នាក់ និងវាយតម្លៃ (៣) រចនាសម្ព័ន្ធអង្គការ និងបុគ្គលិក ព្រមទាំងជំនាញ និងសមត្ថភាពពាក់ព័ន្ធនឹងបរិស្ថាន និងសង្គម (៤) លក្ខខណ្ឌតម្រូវក្នុងការបណ្តុះបណ្តាល និង (៥) ការតាមដាន និងការរាយការណ៍។ ESMS នឹងចងក្រងជាឯកសារ និងដាក់សុំការព្រមព្រៀងរវាង ADB និង FI ។ ប្រសិនបើអនុគម្រោងរបស់ FI ដែលទទួលបានមូលនិធិពី ADB តាមរយៈឥណទានអតិបរមា ការផ្តល់កម្ចីផ្សេងទៀត ការវិនិយោគភាគហ៊ុន ការធានា ឬលិខិតុបករណ៍ហិរញ្ញវត្ថុផ្សេងទៀត អាចមានផលប៉ះពាល់ធ្ងន់ធ្ងរចំពោះបរិស្ថាន និងសង្គម FI ត្រូវតែធានាថាអនុគម្រោងនោះបំពេញតាមលក្ខខណ្ឌតម្រូវរបស់ ADB ដែលមានចែងក្នុងលក្ខខណ្ឌតម្រូវសម្រាប់ការពារ ១-៣។ ADB ក៏អាចនឹងកំណត់លក្ខខណ្ឌតម្រូវបន្ថែមសម្រាប់សកម្មភាពរបស់ FI ដែលជាទូទៅអាស្រ័យលើទំហំនៃការវិនិយោគរបស់ FI និងប្រព័ន្ធការពាររបស់ប្រទេសម្ចាស់ផ្ទះ។ ADB នឹងតាមដានការអនុវត្តរបស់ FI ដោយផ្អែកលើប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គមរបស់ FI ។

៦៧. ADB នឹងវាយតម្លៃសមត្ថភាពរបស់ FI ក្នុងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់ចំពោះសង្គម និងបរិស្ថាន។ ប្រសិនបើសមត្ថភាពរបស់ FI នៅមានគម្លាត ADB និង FI នឹងរៀបចំផែនការបំបាត់គម្លាតដែលបានកំណត់។ ADB នឹងសហការជាមួយអតិថិជនក្នុងការលើកកម្ពស់សមត្ថភាពជារួមរបស់ពួកគេ ក្នុងការដោះស្រាយហានិភ័យសង្គម និងបរិស្ថាន។

### គ. ពង្រឹង និង ប្រើប្រាស់ប្រព័ន្ធការពារក្នុងប្រទេស

៦៨. ADB ទទួលស្គាល់ថា DMC មានប្រព័ន្ធផ្ទាល់ខ្លួនរបស់ពួកគេក្នុងការផ្តល់ការការពារក្នុងកម្រិតខុសៗគ្នា ហើយក៏ទទួលស្គាល់ផងដែរថា ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ DMC ក្នុងការពង្រឹង និងប្រើប្រាស់ប្រព័ន្ធការពាររបស់ពួកគេ នឹងអាចពង្រឹងភាពជាម្ចាស់របស់ប្រទេសម្ចាស់ផ្ទះ កាត់បន្ថយនូវសោហ៊ុយចំណាយ និងលាតសន្ធឹងឥទ្ធិពលនៃការអភិវឌ្ឍន៍ក្នុងរយៈពេលវែង។ ADB ប្តេជ្ញាគាំទ្រដល់ការពង្រឹង និងការអនុវត្តឱ្យមានប្រសិទ្ធភាពនូវប្រព័ន្ធការពារក្នុងប្រទេស (CSS) របស់ DMC ដោយផ្តោតសំខាន់លើការអភិវឌ្ឍន៍សមត្ថភាពរបស់អ្នកខ្ចី។ ក្នុងពេលជាមួយគ្នានេះ ADB ចាំបាច់ត្រូវធានាថា ការអនុវត្ត CSS នៅក្នុងគម្រោងរបស់ ADB នឹងមិនធ្វើឱ្យអន្តរាយដល់គោលនយោបាយ គោលដៅ និងគោលការណ៍របស់ ADB ឡើយ។ យុទ្ធសាស្ត្រជារួមរបស់ ADB ក្នុងការពង្រឹង នឹងប្រើប្រាស់ CSS មានធាតុដូចខាងក្រោម និងផ្តោតលើវិធីសាស្ត្រជាដំណាក់កាល :

(i) **និយមន័យ :** CSS សំដៅលើក្របខណ្ឌស្ថាប័ន និងច្បាប់របស់ប្រទេស ដែលមានស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ឬស្ថាប័នតាមផ្នែករបស់ខ្លួន និង ច្បាប់ បទបញ្ញត្តិ វិធាន និងនិតិវិធីដែលពាក់ព័ន្ធនឹងវិស័យគោលនយោបាយការពារ ។

(ii) **បុរេលក្ខខណ្ឌក្នុងការប្រើប្រាស់ប្រព័ន្ធការពារក្នុងប្រទេស - ការវាយតម្លៃភាពសមមូល និង ភាពអាចទទួលយកបាន :** ការអនុវត្ត CSS ក្នុងគម្រោងផ្តល់ហិរញ្ញទានដោយ ADB មិនមែនធ្វើឡើងដោយស្វ័យប្រវត្តិ ឬជាកាតព្វកិច្ចនោះទេ ។ ADB អាចនឹងពិចារណាប្រើប្រាស់ CSS របស់អ្នកខ្ចីក្នុងការកំណត់ និងគ្រប់គ្រងផលប៉ះពាល់ និងហានិភ័យសង្គម និងបរិស្ថាន ដែលពាក់ព័ន្ធនឹងគម្រោងផ្តល់ហិរញ្ញប្បទានដោយ ADB នៅកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់តំបន់ ឬកម្រិតទីភ្នាក់ងារ លុះត្រាតែ (ក) CSS មានកម្រិតសមមូលនឹងលក្ខខណ្ឌតម្រូវរបស់ ADB (ការវាយតម្លៃភាពសមមូល) ពោលគឺ CSS ត្រូវបានរចនាឡើង ដើម្បីសម្រេចកម្មវត្ថុ ទំហំគោលនយោបាយ ការជម្រុញនិងគោលការណ៍ដែលមានចែងក្នុង SPS (ទំព័រទី ១៦-១៨) និង (២) អ្នកខ្ចីមានទម្លាប់អនុវត្ត ប្រវត្តិអនុវត្ត និងលទ្ធភាពដែលអាចទទួលយកបាន (ការវាយតម្លៃភាពអាចទទួលយកបាន) និងការប្តេជ្ញាក្នុងការគោរពតាមច្បាប់ បទបញ្ញត្តិ វិធាន និងនីតិវិធីដែលនៅជាធរមាននៅក្នុងប្រទេសសម្រាប់វិស័យជាក់លាក់ ឬរបស់ទីភ្នាក់ងារពាក់ព័ន្ធ ។

(iii) **ដោះស្រាយពីតម្រូវការក្នុងការពង្រឹង CSS និងការអភិវឌ្ឍន៍សមត្ថភាព :** ប្រសិនបើអ្នកខ្ចីត្រូវពង្រឹង CSS របស់ខ្លួន ដើម្បីបំពេញតាមកម្មវត្ថុ និងដើម្បីគោរពទៅតាមទំហំគោលនយោបាយ ការជម្រុញនិងគោល-ការណ៍ពាក់ព័ន្ធដែលចែងក្នុង SPS របស់ ADB (ទំព័រទី ១៦-១៨) ហើយមានការប្តេជ្ញាថានឹងធ្វើបែបនេះតាមរយៈការអនុវត្តផែនការសកម្មភាពដែលមានវិធានការជាក់លាក់ ADB អាចនឹងយកវិធានការទាំងនេះមកពិចារណានៅពេលកំណត់ភាពសមមូល ។ ដូចគ្នានេះដែរ ប្រសិនបើអ្នកខ្ចីចាំបាច់ត្រូវពង្រឹងសមត្ថភាពអនុវត្តរបស់ខ្លួន ហើយមានការប្តេជ្ញាក្នុងការធ្វើបែបនេះ តាមរយៈការអនុវត្តផែនការសកម្មភាពដែលមានវិធានការជាក់លាក់ ADB អាចនឹងយកវិធានការទាំងនេះមកពិចារណា នៅពេលកំណត់ពីភាពអាចទទួលយកបាន ។ វិធានការនេះ ត្រូវតែធ្វើមុនពេលអ្នកខ្ចីចាប់ផ្តើមអនុវត្តសកម្មភាពគម្រោងពាក់ព័ន្ធ ហើយវិធានការនេះ អាចបញ្ចូលនូវកិច្ចខិតខំប្រឹងប្រែងដែលគាំទ្រដោយ ADB ។

(iv) **ទំហំនៃការអនុវត្តប្រព័ន្ធការពារក្នុងប្រទេស :** ដោយសារតែវិសាលភាពនៃភាពសមមូល និងភាពអាចទទួលយកបាន គឺដើម្បីផ្តល់ការការពារជាក់លាក់ ប្រទេស តំបន់ ឬទីភ្នាក់ងារមួយ អាចប្រើប្រាស់យុទ្ធវិធី CSS តែមួយ ទាំងពីរ ឬទាំងបីរួមគ្នា អាស្រ័យលើលទ្ធផលនៃការវាយតម្លៃ CSS ។

(v) **ការបដិសេធប្រព័ន្ធការពារក្នុងប្រទេស :** CSS នឹងមិនត្រូវបានយកទៅអនុវត្តក្នុងគម្រោងដែលផ្តល់ហិរញ្ញ-ប្បទានដោយ ADB ដែលមានភាពស្មុគស្មាញ និងងាយរងការប៉ះពាល់ខ្លាំងឡើយ ។

(vi) **ការផ្តល់ព័ត៌មាន និង ការពិគ្រោះយោបល់ :** ក្រោយពេលបញ្ចប់ សេចក្តីព្រាងនៃការវាយតម្លៃភាពសមមូល និងភាពអាចទទួលយកបាន (រួមនឹងវិធានការបំបាត់គម្លាត ប្រសិនបើមាន) នៅកម្រិតថ្នាក់ជាតិ ក្រោមជាតិ តំបន់ និងកម្រិតទីភ្នាក់ងារ នឹងត្រូវរៀបចំចងក្រងជាឯកសារ និងផ្សព្វផ្សាយនៅលើគេហទំព័ររបស់ ADB ដើម្បីឱ្យសាធារណៈជនផ្តល់យោបល់។ ADB នឹងរៀបចំសិក្ខាសាលាពិគ្រោះយោបល់នៅក្នុងប្រទេស ដើម្បីសុំមតិយោបល់ពីអ្នកពាក់ព័ន្ធ រួមទាំងរដ្ឋាភិបាល និង NGO។ ក្រោយពេលបញ្ចប់ របាយការណ៍វាយតម្លៃភាពសមមូល និងភាពអាចទទួលយកបានចុងក្រោយ នឹងត្រូវផ្សព្វផ្សាយលើគេហទំព័ររបស់ ADB។ ការផ្សព្វផ្សាយ និងការពិគ្រោះយោបល់ពាក់ព័ន្ធនឹងការវាយតម្លៃភាពអាចទទួលយកបាននៅកម្រិតគម្រោង នឹងធ្វើទៅតាមដំណើរការពិគ្រោះយោបល់ និងផ្សព្វផ្សាយឯកសារការពារ ដែលធ្វើឡើងជាធម្មតាសម្រាប់ការរៀបចំគម្រោង ដូចមានចែងក្នុងកថាខណ្ឌ ៥៣-៥៥។

(vii) **តួនាទី និង ការទទួលខុសត្រូវរបស់ ADB :** ADB ទទួលខុសត្រូវវាយតម្លៃ និងកំណត់ភាពសមមូលនៃ CSS និងភាពអាចទទួលយកបាននៃលទ្ធភាព និងទម្លាប់អនុវត្តរបស់អ្នកខ្ចី។ ADB សហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ផ្សេងទៀត នៅពេលរៀបចំវាយតម្លៃភាពសមមូល និងភាពអាចទទួលយកបាន[២៩] ។ ចំពោះគម្រោងដែលប្រើ CSS ការទទួលខុសត្រូវរបស់ ADB ក្នុងការវាយតម្លៃការការពារ និងការអង្កេតលម្អិត មានដូចក្នុងគម្រោងផ្សេងទៀតដែលផ្តល់ហិរញ្ញប្បទានដោយ ADB។ ការអង្កេតលម្អិត និងការវាយតម្លៃ នឹងផ្អែកទៅលើលក្ខខណ្ឌតម្រូវរបស់ CSS និងផែនការសកម្មភាពដែលបានព្រមព្រៀង (ជាជាងផ្អែកលើលក្ខខណ្ឌតម្រូវរបស់ ADB)។ នៅក្រោយពេលដែលក្រុមប្រឹក្សាភិបាលបានអនុម័តយល់ព្រមលើគម្រោងដែលប្រើ CSS, ADB នឹងធ្វើទៅតាមនីតិវិធីដែលប្រើសម្រាប់គម្រោងផ្សេងទៀតដែលផ្តល់ហិរញ្ញប្បទានដោយ ADB។

(viii) **តួនាទី និង ការទទួលខុសត្រូវរបស់អ្នកខ្ចី :** អ្នកខ្ចី ជាអ្នកទទួលខុសត្រូវក្នុងការសម្រេច និងរក្សាឱ្យបាននូវភាពសមមូល ក៏ដូចជារៀបចំការប្រតិបត្តិ កំណត់ហេតុតាមដាន និងសមត្ថភាពដែលអាចទទួលយកបានស្របតាមការវាយតម្លៃរបស់ ADB។ ចំពោះគម្រោងជាក់លាក់ណាមួយ អ្នកខ្ចីត្រូវបង្ហាញបទបញ្ញត្តិរបស់ CSS ដែលចាំបាច់ដើម្បីធានាថា កម្មវត្ថុ និងគោលការណ៍គោលនយោបាយដែលមានចែងក្នុង SPS ត្រូវបានបំពេញ។ បទបញ្ញត្តិទាំងនេះ អាចមានភាពខុសប្លែកគ្នាតាមគម្រោងនីមួយៗ អាស្រ័យលើកត្តានានាដូចជារចនាសម្ព័ន្ធរបស់ CSS និងប្រភេទនៃប្រតិបត្តិការជាដើម។ នៅគ្រប់ករណីទាំងអស់ បទបញ្ញត្តិ និងវិធានការបន្ថែមដែលអ្នកខ្ចីត្រូវបំពេញដើម្បីសម្រេច និងរក្សាឱ្យបាននូវភាពសមមូល និងការអនុវត្តដែលអាចទទួលយកបាន នឹងក្លាយជាផ្នែកមួយនៃកាតព្វកិច្ច តាមកិច្ចសន្យារបស់អ្នកខ្ចី និងជាវិធានការកែតម្រូវតាមកិច្ចសន្យារបស់ ADB។

---

[២៩] ការវាយតម្លៃ និងការងារវិភាគថ្មីៗរបស់ដៃគូអភិវឌ្ឍន៍ផ្សេងទៀត (ដែលអាចត្រូវធ្វើបច្ចុប្បន្នភាពប្រសិនបើចាំបាច់) អាចនឹងត្រូវយកមកប្រើ។ ការវាយតម្លៃរួមគ្នាជាមួយដៃគូអភិវឌ្ឍន៍ផ្សេងទៀតត្រូវបានលើកទឹកចិត្ត។

(ix) **យន្តការគណនេយ្យភាពរបស់** ADB : ការប្រើប្រាស់ CSS នឹងមិនធ្វើឱ្យប្រែប្រួលដល់តួនាទីយន្តការគណនេយ្យ-ភាពរបស់ ADB ឡើយ ។

(x) **វិធីសាស្ត្រអនុវត្តជាដំណាក់កាល** : ការប្រើប្រាស់ CSS នឹងធ្វើនៅតាមបណ្តាប្រទេសក្នុងចំនួនកម្រិតមួយ ដោយផ្តោតលើកម្រិតក្រោមជាតិ តំបន់ និងកម្រិតទីភ្នាក់ងារ នៅក្នុងអំឡុងពេលបីឆ្នាំដំបូង បន្ទាប់ពីគោល-នយោបាយចូលជាធរមាន ។ ការវាយតម្លៃប្រតិបត្តិការចំពោះប្រសិទ្ធភាពនៃការអនុវត្ត និងប្រើប្រាស់ CSS នឹងធ្វើនៅឆ្នាំទីបីក្រោយពេលដែលគោលនយោបាយចូលជាធរមាន ។

៦៩. សេចក្តីបន្ថែម ៦ មានចែងលម្អិតពីវិធីសាស្ត្រពង្រឹង និងប្រើប្រាស់ CSS ។

### ឃ. គម្រោងសហហិរញ្ញប្បទាន

៧០. ADB នឹងព្យាយាមសហការជាមួយអ្នកខ្ចី/អតិថិជន និងសហហិរញ្ញប្បទានិកផ្សេងទៀត ក្នុងការអនុម័តដំណើរការឯកភាពក្នុងការរៀបចំផែនការ និងវាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាន និងបង្រួមបង្រួមឯកសារការពារ ការពិគ្រោះយោបល់ និងលក្ខខណ្ឌតម្រូវផ្សព្វផ្សាយព័ត៌មាន ដើម្បីបំពេញតាមគោលការណ៍ការពារ និងលក្ខខណ្ឌតម្រូវរបស់ ADB និងរបស់សហហិរញ្ញ-ប្បទានិក ។

## គ. តួនាទី និង ការទទួលខុសត្រូវ

### ១. តួនាទី និង ការទទួលខុសត្រូវរបស់ ADB

៧១. ADB ទទួលខុសត្រូវ (១) ត្រួតពិនិត្យគម្រោងដើម្បីកំណត់លក្ខខណ្ឌតម្រូវការពាររបស់ ADB (២) រៀបចំការអង្កេតលម្អិត និងវាយតម្លៃផែនការ និងការវាយតម្លៃសង្គម និងបរិស្ថានរបស់អ្នកខ្ចី/អតិថិជន ដើម្បីធានាថាមានវិធានការការពារដើម្បីបញ្ចៀស បន្ធូរបន្ថយ កាត់បន្ថយ និងទូទាត់សងចំពោះផលប៉ះពាល់អវិជ្ជមានចំពោះសង្គម និងបរិស្ថាន ស្របទៅតាមគោលការណ៍គោលនយោបាយការពាររបស់ ADB និងលក្ខខណ្ឌតម្រូវសម្រាប់ការពារ ១-៤ (៣) កំណត់លទ្ធភាពហិរញ្ញប្បទានរបស់ ADB (៤) ជួយអ្នកខ្ចី/អតិថិជនក្នុងការកសាងសមត្ថភាពអនុវត្តការការពារ និង (៥) តាមដាន និងត្រួតពិនិត្យការអនុវត្តការការពារសង្គម និងបរិស្ថានរបស់អ្នកខ្ចី/អតិថិជននៅក្នុងវដ្តគម្រោង ។ ADB ផ្សព្វផ្សាយក្របខណ្ឌ និងផែនការការពារ ព្រមទាំងរបាយការណ៍វាយតម្លៃ និងតាមដានបរិស្ថាន នៅលើគេហទំព័ររបស់ខ្លួន ។

៧២. ប្រសិនបើអ្នកខ្ចី/អតិថិជនខកខានមិនគោរពតាមកិច្ចព្រមព្រៀងស្តីពីលក្ខខណ្ឌតម្រូវការពារ រួមទាំងលក្ខខណ្ឌតម្រូវដែលមានចែងក្នុងក្របខណ្ឌការពារ និងផែនការការពារ ADB នឹងអនុវត្តវិធានការកែតម្រូវ និងសហការជាមួយអ្នកខ្ចី/អតិថិជនឱ្យមកគោរពតាមកិច្ចព្រមព្រៀងវិញ ។ ប្រសិនបើអ្នកខ្ចី/អតិថិជននៅតែខកខានមិនគោរពតាមកិច្ចព្រមព្រៀងទៀត ADB នឹងអនុវត្តសិទ្ធិដោះស្រាយតាមផ្លូវច្បាប់ ដែលមានដូចជាការព្យួរ ការលុបចោល ឬការបញ្ចប់មុនកាលកំណត់ ដែលមានចែងក្នុងកិច្ចព្រមព្រៀងរបស់

ADB ។ មុនពេលចាត់វិធានការដោះស្រាយខាងលើនេះ ADB ប្រើប្រាស់វិធីសាស្ត្រផ្សេងទៀតដែលមានក្នុងការស្តារស្ថានការណ៍ឱ្យបានតាមការចង់បានរបស់ភាគីទាំងអស់តាមកិច្ចព្រមព្រៀង រួមទាំងការជជែកពិភាក្សាជាមួយភាគីពាក់ព័ន្ធដើម្បីសម្រេចអនុលោមភាពតាមកិច្ចព្រមព្រៀង ។

### ២. តួនាទី និង ការទទួលខុសត្រូវរបស់អ្នកខ្ចី/អតិថិជន

៧៣. អ្នកខ្ចី/អតិថិជន ទទួលខុសត្រូវវាយតម្លៃគម្រោង និងផលប៉ះពាល់បរិស្ថាន និងសង្គម រៀបចំចំផែនការការពារ និងជួបជាមួយសហគមន៍រងផលប៉ះពាល់ តាមរយៈការផ្សព្វផ្សាយព័ត៌មាន ការពិគ្រោះយោបល់ និងការចូលរួម និងគោរពតាមគោលការណ៍គោលនយោបាយ និងលក្ខខណ្ឌតម្រូវការពារទាំងអស់។ អ្នកខ្ចី/អតិថិជន នឹងផ្ញើព័ត៌មានចាំបាច់នានា រួមទាំងរបាយការណ៍វាយតម្លៃ ក្របខណ្ឌ/ផែនការការពារ និងរបាយការណ៍តាមដាន ឱ្យ ADB ត្រួតពិនិត្យ។ អ្នកខ្ចី/អតិថិជន ត្រូវគោរពតាមច្បាប់ បទបញ្ជា និងបទដ្ឋានរបស់ប្រទេសម្ចាស់ផ្ទះ រួមទាំងកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិដែលប្រទេសម្ចាស់ផ្ទះត្រូវបំពេញផងដែរ។ លើសពីនេះ អ្នកខ្ចី/អតិថិជនត្រូវអនុវត្តវិធានការការពារដែលបានព្រមព្រៀងជាមួយ ADB ដើម្បីបំពេញតាមគោលការណ៍គោលនយោបាយ និងលក្ខខណ្ឌតម្រូវដែលមានចែងក្នុងលក្ខខណ្ឌតម្រូវសម្រាប់ការពារ ១-៤។ ដើម្បីធានាថាអ្នកម៉ៅការអនុវត្តវិធានការដែលបានព្រម-ព្រៀងបានត្រឹមត្រូវ អ្នកខ្ចី/អតិថិជននឹងបញ្ចូលលក្ខខណ្ឌតម្រូវការពារក្នុងឯកសារភ្ជាប់កាតព្វកិច្ច និងកិច្ចសន្យាការងារស៊ីវិល។ ប្រសិនបើគោលនយោបាយ និងបទបញ្ជាការពារថ្នាក់ជាតិខុសពីគោលនយោបាយការពាររបស់ ADB ដែលមានចែងក្នុងលក្ខខណ្ឌតម្រូវសម្រាប់ការពារ ១-៤ ADB និងអ្នកខ្ចី/អតិថិជន នឹងបង្កើត និងព្រមព្រៀងពីវិធានការជាក់លាក់មួយចំនួន ដើម្បីធានាថាគោល-ការណ៍គោលនយោបាយ និងលក្ខខណ្ឌតម្រូវការពាររបស់ ADB ត្រូវបានគោរពតាមទាំងស្រុង។

## IV. រៀបចំការអនុវត្ត និង ប្រើប្រាស់ធនធាន

### ក. ការអនុវត្ត និង ការតាមដាន

៧៤. ការអនុវត្ត SPS នៅកម្រិតសាជីវកម្ម នឹងត្រូវតម្រែតម្រង់ដោយផែនការសកម្មភាពសម្រាប់រយៈពេលមធ្យមបីឆ្នាំចាប់ផ្តើមនៅអំឡុងឆ្នាំ ២០១០-២០១២។ ផែនការសកម្មភាពត្រូវអភិវឌ្ឍន៍ដោយផ្អែកលើធាតុសំខាន់៧ដូចខាងក្រោម : (១) គាំទ្រដល់ការអភិវឌ្ឍន៍សមត្ថភាពរបស់អ្នកខ្ចី/អតិថិជនក្នុងការអនុវត្តវិធានការការពារ (២) អភិវឌ្ឍន៍ និងរក្សាឧបករណ៍ និងសម្ភារៈ (ដូចជាគោលការណ៍ណែនាំ និងសៀវភៅណែនាំ) ដើម្បីជួយដល់ការអនុវត្ត SPS (៣) ធានាសមត្ថភាពស្ថាប័ន និងធនធានរបស់ ADB ក្នុងការអនុវត្ត SPS និង (៤) លើកកម្ពស់ និងរក្សាការវាយតម្លៃផ្ទៃក្នុង និងប្រព័ន្ធតាមដានអនុលោមភាព។ ផែនការសកម្មភាពឆ្នាំ ២០១០-២០១២ ព្រមទាំងសកម្មភាពស្នើសុំនានា ដែលពាក់ព័ន្ធនឹងលទ្ធផល និងធនធានចាំបាច់ មានចែងក្នុងឯកសារភ្ជាប់ ២។

៧៥. ADB នឹងតាមដាន និងវាយតម្លៃលទ្ធផលការពារជារួមធៀបជាមួយនឹងកម្មវត្ថុរបស់ SPS ។ ADB នឹងរក្សាការវាយតម្លៃផ្ទៃក្នុង និងប្រព័ន្ធតាមដានអនុលោមភាពដើម្បីវាយតម្លៃលទ្ធផលធនាគារ និងលទ្ធផលគម្រោង ក្នុងការអនុវត្តគោលនយោបាយការពាររបស់ ADB ។

## ៩. ធនធាន

៧៦. ADB នឹងបែងចែកធនធានសមស្របដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្ត SPS ។ ដើម្បីប្រើប្រាស់ និងបែងចែកធនធានឱ្យមានប្រសិទ្ធភាព ជម្រើសនានាកំពុងត្រូវបានយកមកពិចារណាក្នុងបរិបទដូចតទៅ : (១) ចំណែកបែងចែកដែលមានប្រសិទ្ធផល និងប្រសិទ្ធភាពនៃតម្រូវការធនធានដែលកើនឡើងជាលំដាប់សម្រាប់កញ្ចប់ថវិការដ្ឋបាលផ្ទៃក្នុង ជំនួយបច្ចេកទេស និងប្រាក់កម្ចីដែលកំណត់ដោយព្រំដែននៃការទទួលខុសត្រូវរបស់ ADB និងអ្នកខ្ចី/អតិថិជន (២) ប្រសិទ្ធផល និងការបញ្ច្រាបលក្ខខណ្ឌតម្រូវនីតិវិធីផ្ទៃក្នុង ដែលសម្រេចកម្មវត្ថុការពាររបស់ ADB និងគោរពតាមគោលការណ៍របស់ SPS និង (៣) វិធានការមានប្រសិទ្ធផលដែលរួមមានការលើកកម្ពស់ជំនាញចម្រុះ និងសមត្ថភាព ការបង្កើនប្រសិទ្ធភាពនៃអ្នកជំនាញគោលការណ៍ការពារនៅទីស្នាក់ការកណ្តាល និងនៅនិវេសនដ្ឋានបេសកកម្ម និងការបង្កើនឯកទេសកម្មតាមវិស័យ និងបណ្តុំធនធានអ្នកឯកទេស ។

៧៧. SPS ផ្តោតការសង្កត់ធ្ងន់លើតម្រូវការក្នុងការជួយ DMC ក្នុងការពង្រឹងប្រព័ន្ធការពាររបស់ពួកគេ និងការអភិវឌ្ឍន៍សមត្ថភាពក្នុងការអនុវត្តប្រព័ន្ធនេះ។ ការអភិវឌ្ឍន៍សមត្ថភាពនេះ នឹងធ្វើឡើងតាមរយៈដៃគូទ្វេភាគី ឬពហុភាគី អាស្រ័យលើតម្រូវការរបស់ DMC ។ ធនធានចំនួន ៨០-១០០ លានដុល្លា (តាមរយៈការបង្កើនមូលនិធិទំនុកចិត្ត (Trust Fund) ដើម្បីប្រមូលធនធានពីខាងក្រៅ) នឹងត្រូវការសម្រាប់រយៈពេលមធ្យម ដើម្បី (១) គាំទ្រ DMC ក្នុងការពង្រឹងគោលនយោបាយការពារក្របខណ្ឌច្បាប់ បទបញ្ជា វិធាន និងនីតិវិធីរបស់ពួកគេ (២) គាំទ្រការអភិវឌ្ឍន៍សមត្ថភាពរបស់ទីភ្នាក់ងាររដ្ឋាភិបាលរបស់ DMC អ្នកខ្ចី/អតិថិជន និងសង្គមស៊ីវិល នៅថ្នាក់ជាតិ ក្រោមជាតិ តំបន់ ទីភ្នាក់ងារ និងកម្រិតគម្រោង និង (៣) សហការជាមួយ DMC ក្នុងការវាយតម្លៃភាពសមមូល និងភាពអាចទទួលយកបានរបស់ CSS និងធ្វើការវិភាគតាមតម្រូវការ ។

៧៨. ADB មានការវិវត្តឈានឡើងជាប្រព័ន្ធក្នុងការជ្រើសរើសអ្នកឯកទេសគោលនយោបាយការពារ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ។ ចាប់តាំងពី *គោលនយោបាយបរិស្ថាន* បានត្រូវអនុម័តនៅឆ្នាំ ២០០២ ដែលជាពេលដែល ADB មានអ្នកឯកទេសបរិស្ថានចំនួន ១៩ នាក់រួចទៅហើយ (១៨ រូបជាបុគ្គលិកវិជ្ជាជីវៈ និង ១ រូបជាមន្ត្រីថ្នាក់ជាតិ) ចំនួនអ្នកឯកទេសបរិស្ថានបានកើនឡើងចំនួន ១៤ នាក់បន្ថែម (៨ រូបជាបុគ្គលិកវិជ្ជាជីវៈ និង ៦ រូបជាមន្ត្រីថ្នាក់ជាតិ) ។ ចាប់តាំងពី *គោលនយោបាយស្តីពីការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត* ត្រូវបានអនុម័តនៅឆ្នាំ ១៩៩៥ ហើយក្រោយមក *គោលនយោបាយស្តីពីក្រុមជនជាតិដើមភាគតិច* ត្រូវបានអនុម័តនៅឆ្នាំ ១៩៩៨ ចំនួនបុគ្គលិកដែលមានជំនាញការពារសង្គម បានកើនឡើងពីបុគ្គលិកវិជ្ជាជីវៈតែ ១ រូប រហូតដល់មានបុគ្គលិកវិជ្ជាជីវៈចំនួន ២២ រូប និងមន្ត្រីថ្នាក់ជាតិចំនួន ៩ រូប គិតត្រឹមខែ ឧសភា ឆ្នាំ ២០០៩។ បច្ចុប្បន្ននេះ ADB មានបុគ្គលិកវិជ្ជាជីវៈសរុបចំនួន ៤៨ រូបទទួលខុសត្រូវការងារវាយតម្លៃវិធានការការពារ ដែល ២៦ រូបជាអ្នកឯកទេសបរិស្ថាន និង ២២

រូបជាអ្នកឯកទេសអភិវឌ្ឍន៍សង្គម[៣០] ។ ADB មានបុគ្គលិកមូលដ្ឋានបន្ថែមចំនួន ១៧ រូបទៀតដែលធ្វើការងារការពារ ដែល ៨ រូបជាមន្ត្រីបរិស្ថាន និង ៩ រូបជាមន្ត្រីការពារសង្គម និងមាន ១២ មុខតំណែងទៀតដែលត្រូវបែងចែងនៅតាមបណ្ដានិវេសនដ្ឋានបេសកម្មទាំង ៧ ។

៧៩. ផលវិបាកធនធានត្រូវបានពិនិត្យវាយតម្លៃក្នុងបរិបទនៃការស្ទាបស្ទង់មតិផ្ទៃក្នុង និងការអនុវត្តមេគុណបុគ្គលិក-សប្ដាហ៍ ក្នុងការងារអង្កេតលម្អិតការការពារ ការវាយតម្លៃ និងការតាមដាន នៅក្នុង ADB ។ ការប៉ាន់ស្មានបានឱ្យដឹងថា នឹងត្រូវការបង្កើនជាលំដាប់នូវធនធានបុគ្គលិកដែលមានចាប់ពី ១២៥៣-១៧៤៩ បុគ្គលិក-សប្ដាហ៍ ក្នុងមួយឆ្នាំ ដើម្បីបំពេញការងារវាយតម្លៃវិធានការការពារ ក្នុងរយៈពេលខ្លី និងរយៈពេលមធ្យម (២០១០-២០១២)[៣១] ។ ការកើនឡើងតម្រូវការធនធានមនុស្ស កើតឡើងដោយសារតែការកើនឡើងនូវទំហំប្រតិបត្តិការយ៉ាងឆាប់រហ័សនៅប៉ុន្មានឆ្នាំកន្លងមកនេះ និងនៅក្នុងបរិបទនៃការបង្កើនមូលធនទូទៅលើកទី ៥ ។ ការប៉ាន់ស្មាននេះ ផ្អែកលើការសន្មតពាក់ព័ន្ធនឹងនីតិវិធីវាយតម្លៃការការពារផ្ទៃក្នុង ការដាក់ពង្រាយជាថ្មីធនធានបុគ្គលនៅក្នុង ADB ពេលវេលាបុគ្គលិកចំណាយពិតប្រាកដចំពោះការងារការពារ និងសមាសភាព និងភាពចម្រុះរបស់គម្រោងបំពង់បង្ហូរ[៣២] ។ ធនធានបន្ថែម នឹងត្រូវបំពេញក្នុងអំឡុងពេល ៣ ឆ្នាំនៃផែនការសកម្មភាពរយៈពេលមធ្យម តាមរយៈបុគ្គលិកមុខតំណែង (ទាំងបុគ្គលិកវិជ្ជាជីវៈ និងមន្ត្រីថ្នាក់ជាតិ) និងបុគ្គលិកទីប្រឹក្សា ។ ប្រសិនបើអាច ការបង្កើនសមត្ថភាពបុគ្គលិកនឹងត្រូវផ្ដល់ជាអាទិភាពឱ្យនិវេសនដ្ឋានបេសកកម្ម ។ តួនាទីរបស់មន្ត្រីថ្នាក់ជាតិ នឹងពង្រីកតាមរយៈកម្មវិធីបណ្ដុះបណ្ដាលសមស្រប ។ មន្ត្រីថ្នាក់ជាតិ នឹងត្រូវតម្រូវឱ្យទទួលខុសត្រូវបីផ្នែក : (១) ពង្រឹងការអនុវត្តលក្ខខណ្ឌតម្រូវគោលនយោបាយដែលមានស្រាប់ ដែលនឹងត្រូវដាក់បញ្ចូលក្នុង SPS (២) អនុវត្តលក្ខខណ្ឌតម្រូវថ្មីក្នុងការជួបជាមួយសហគមន៍ និង (៣) ចុះធ្វើបេសកកម្មវាយតម្លៃការការពារបន្ថែម នៅអំឡុងពេលអនុវត្តគម្រោង សម្រាប់គម្រោងដែលមានផលប៉ះពាល់ និងហានិភ័យធ្ងន់ធ្ងរ ។ លើសពីនេះទៀត អាចនឹងត្រូវការធនធានបន្ថែមសម្រាប់អ្នកជំនាញផ្នែកច្បាប់នៅការិយាល័យអគ្គទីប្រឹក្សា ដើម្បីដោះស្រាយបញ្ហាផ្នែកច្បាប់ក្នុងការអនុវត្តគោលនយោបាយការពារ និងក្នុងការវាយតម្លៃភាពសមមូលរបស់ CSS ។

៨០. ក្នុងរយៈពេលមធ្យម សោហ៊ុយចំណាយពាក់ព័ន្ធនឹង CSS នឹងកើនឡើង ។ នៅរៀងរាល់ឆ្នាំ បុគ្គលិកអាចនឹងត្រូវធ្វើការបន្ថែមសប្ដាហ៍ ដើម្បីរៀបចំវាយតម្លៃភាពសមមូលរបស់ CSS តាមតម្រូវការ ។ ការវាយតម្លៃភាពសមមូលនីមួយៗ អាចត្រូវការ ៥-១២ បុគ្គលិក-សប្ដាហ៍ ហើយការវាយតម្លៃភាពអាចទទួលយកបាន ត្រូវការបុគ្គលិក និងរយៈពេលប៉ុន្មានសប្ដាហ៍បន្ថែមទៀត ។

---

[៣០] បុគ្គលិកទាំងនេះមិនមែនធ្វើតែការងារការពារនោះទេ ។ ពេលវេលាដែលពួកគេចំណាយចំពោះការងារការពារមានចាប់ពី ៣០% ដល់ ៩០% ។

[៣១] ការវាយតម្លៃពីតម្រូវការធនធានបុគ្គលិក បានផ្អែកលើការវិភាគដែលរៀបចំឡើងដើម្បី (១) វាយតម្លៃភាពគ្រប់គ្រាន់នៃធនធានបុគ្គលិកក្នុងការអនុវត្តលក្ខខណ្ឌតម្រូវការពារដែលមានស្រាប់ ដែលនឹងត្រូវដាក់បញ្ចូលក្នុងគោលនយោបាយថ្មី (២) កំណត់ផលវិបាកធនធាននៃគោលនយោបាយការពារកែសម្រួលថ្មី និង (៣) កំណត់ជម្រើសដែលអាចប្រើប្រាស់ និងបែងចែកធនធានមនុស្សដែលមានប្រសិទ្ធភាពបំផុតសម្រាប់ការងារការពារ ។

[៣២] តួលេខប៉ាន់ស្មាននៃគម្រោងបំពង់បង្ហូរដែលប្រើសម្រាប់ការប៉ាន់ស្មានធនធាន ត្រូវបានផ្អែកលើទិន្នន័យរបស់ប្រព័ន្ធព័ត៌មានអនុវត្តគម្រោង (PPIS) ។

ការប្រើប្រាស់ធនធាន ក៏អាចនឹងត្រូវកើនឡើងផងដែរ នៅពេលដែលត្រូវការជួលបុគ្គលិកទីប្រឹក្សាតាមតម្រូវការ។ លើសពីនេះ ធនាគារពិភពលោក ដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ និងអនុវត្តវិធីសាស្ត្រវាយតម្លៃ CSS និងមានការចាប់អារម្មណ៍ក្នុងការរួមគ្នាជាមួយស្ថាប័នដៃគូក្នុងការធ្វើកិច្ចការនេះ។ ការរួមសហការជាមួយស្ថាប័នដៃគូដូចជាធនាគារពិភពលោក នឹងជួយបង្កើនប្រសិទ្ធភាព និងធានានូវប្រសិទ្ធផលនៃការចំណាយធនធានបន្ថែមមួយកម្រិតទៀត។

## ឆ. កាលបរិច្ឆេទចូលជាធរមាន និង អំឡុងពេលអន្តរកាល

៨១. SPS និងឧបសម្ព័ន្ធ ១-៦ នឹងត្រូវចូលជាធរមានក្នុងរយៈពេល ៦ ខែក្រោយការអនុម័តរបស់ក្រុមប្រឹក្សាភិបាល។ ចំពោះគម្រោងដែលចាប់ផ្តើមរៀបចំនៅក្រោយការបរិច្ឆេទចូលជាធរមាន SPS និងសេចក្តីបន្ថែម ១-៦ នឹងត្រូវអនុវត្ត។ គម្រោងដែលបានឆ្លងកិច្ចប្រជុំវាយតម្លៃគ្រប់គ្រងរួចហើយ ឬចំណែកគម្រោងណាមួយដែលនៅក្រោម MFF ដែលការវាយតម្លៃគ្រប់គ្រងបានបញ្ចប់នៅមុនការបរិច្ឆេទចូលជាធរមាន ត្រូវអនុវត្ត *គោលនយោបាយស្តីពីការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត* (១៩៩៥) *គោលនយោបាយស្តីពីក្រុមជនជាតិដើមភាគតិច* (១៩៩៨) និង *គោលនយោបាយស្តីពីបរិស្ថាន* (២០០២)។

## ជ. ការត្រួតពិនិត្យគោលនយោបាយឡើងវិញ

៨២. ការត្រួតពិនិត្យនឹងធ្វើនៅឆ្នាំទី ៥ ក្រោយកាលបរិច្ឆេទចូលជាធរមាននៃសេចក្តីថ្លែងការណ៍គោលនយោបាយការពារ ដើម្បីត្រួតពិនិត្យប្រសិទ្ធភាពរបស់វាក្នុងការសម្រេចកម្មវត្ថុការពាររបស់ ADB។ លើសពីនេះ ការត្រួតពិនិត្យប្រតិបត្តិការនឹងធ្វើនៅឆ្នាំទី ៣ ក្រោយពេលគោលនយោបាយចូលជាធរមាន ដោយផ្តោតជាសំខាន់លើ (១) ការវិវត្តនៃការប្រើប្រាស់ CSS និងប្រសិទ្ធភាពរបស់ CSS និង (២) ការអនុវត្តលក្ខខណ្ឌតម្រូវការពារក្នុងគម្រោង FI និងប្រសិទ្ធភាពរបស់លក្ខខណ្ឌតម្រូវទាំងនេះ។ ការត្រួតពិនិត្យ ៣ ឆ្នាំ និង ៥ ឆ្នាំ នឹងរៀបចំធ្វើដោយនាយកដ្ឋានវាយតម្លៃឯករាជ្យ។ លទ្ធផលនៃការត្រួតពិនិត្យនឹងផ្ញើជូនក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំរបស់ ADB។ ដោយពិចារណាលើអនុសាសន៍ដែលមានក្នុងការវាយតម្លៃ ៣ ឆ្នាំ និងការយល់ឃើញរបស់គណៈកម្មាធិការប្រសិទ្ធភាពអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំនឹងផ្ញើឯកសារស្តីពីការអនុវត្ត CSS និងការអនុវត្តលក្ខខណ្ឌតម្រូវការពារក្នុងគម្រោង FI ដើម្បីសុំឱ្យក្រុមប្រឹក្សាភិបាលអនុម័ត។ ថ្នាក់ដឹកនាំក៏នឹងផ្ញើឯកសារឱ្យក្រុមប្រឹក្សាភិបាល ដោយពិចារណាពីការត្រួតពិនិត្យ ៥ ឆ្នាំ ផងដែរ។

# VII. អនុសាសន៍

៨៣. ប្រធានធនាគារផ្តល់អនុសាសន៍ឱ្យក្រុមប្រឹក្សាភិបាលអនុម័តលើសេចក្តីថ្លែងការណ៍គោលនយោបាយការពាររបស់ ADB ដូចមានចែងក្នុងឯកសារនេះ រួមទាំងជំពូក ៥ និងជំពូក ៦ និងឧបសម្ព័ន្ធ ១-៦ ដែលនឹងជំនួស *គោលនយោបាយស្តីពីការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត* (១៩៩៥) *គោលនយោបាយស្តីពីក្រុមជនជាតិដើមភាគតិច* (១៩៩៨) *គោលនយោបាយស្តីពីបរិស្ថាន* (២០០២) និងប្រយោគទី ២ នៃកថាខណ្ឌទី ៧៣ កថាខណ្ឌ ៧៧-៨៥ និងកថាខណ្ឌទី ៩២ នៃ *គោលនយោបាយស្តីការទំនាក់ទំនងសាធារណៈ* (២០០៥)។

# លក្ខខណ្ឌតម្រូវសម្រាប់ការពារ ១ : បរិស្ថាន

## ក. សេចក្តីផ្តើម

១. លក្ខខណ្ឌតម្រូវសម្រាប់ការពារ ១ កំណត់ពីលក្ខខណ្ឌដែលអ្នកខ្ចី/អតិថិជនត្រូវបំពេញ នៅពេលអនុវត្តវិធានការការពារបរិស្ថាន ចំពោះគម្រោងដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ លក្ខខណ្ឌនេះកំណត់ពីកម្មវត្ថុ និងទំហំនៃការអនុវត្ត និងគូសបញ្ជាក់ពី លក្ខខណ្ឌតម្រូវដែលត្រូវបំពេញក្នុងដំណើរការវាយតម្លៃបរិស្ថាន។ លក្ខខណ្ឌតម្រូវទាំងនេះ រួមមាន ការវាយតម្លៃផលប៉ះពាល់ ការរៀបចំផែន ការគ្រប់គ្រងដើម្បីកាត់បន្ថយផលប៉ះពាល់ ការរៀបចំរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន ការផ្តល់ព័ត៌មាន និងការពិគ្រោះយោបល់ ការបង្កើតយន្តការដោះស្រាយបណ្តឹងតវ៉ា និងការតាមដាន និងរាយការណ៍។ ឯកសារនេះ ក៏មានបញ្ចូលផងដែរនូវលក្ខខណ្ឌតម្រូវសម្រាប់ការពារបរិស្ថានជាក់លាក់មួយចំនួន ដែលពាក់ព័ន្ធនឹងការអភិរក្សជីវៈចម្រុះ និងការគ្រប់-គ្រងធនធានធម្មជាតិដោយនិរន្តរភាព ការបង្ការ និងការបន្ថយការបំពុលបរិស្ថាន សុខភាព និងសុវត្ថិភាពការងារ និងសហគមន៍ និង ការអភិរក្សធនធានវប្បធម៌រូបវន្ត។ ការអនុវត្ត លក្ខខណ្ឌតម្រូវជាក់លាក់មួយចំនួន អាចធ្វើទៅបានតាមរយៈដំណើរការវាយតម្លៃបរិស្ថាន ហើយការគោរពតាមលក្ខខណ្ឌតម្រូវទាំងនេះ អាចសម្រេចទៅបានតាមរយៈផែនការគ្រប់គ្រងបរិស្ថានដែលព្រមព្រៀងរវាង ADB និងអ្នកខ្ចី/អតិថិជន។

## ខ. កម្មវត្ថុ

២. កម្មវត្ថុនៃលក្ខខណ្ឌនេះ គឺដើម្បីធានានូវនិរន្តរភាព និងភាពប្រសើរនៃបរិស្ថានរបស់គម្រោង និងដើម្បីគាំទ្រដល់ការដាក់បញ្ចូលការគិតគូរពិចារណាពីបរិស្ថានចូលទៅក្នុងដំណើរការសម្រេចចិត្តរបស់គម្រោង។

## គ. ទំហំនៃការអនុវត្ត

៣. លក្ខខណ្ឌទាំងនេះ អនុវត្តចំពោះរាល់គ្រប់គម្រោងដែលផ្តល់ហិរញ្ញប្បទានដោយ ADB និង/ឬ គម្រោងដែលស្ថិត និងមិនស្ថិតនៅក្រោមការគ្រប់គ្រងរដ្ឋបាលដោយ ADB រួមទាំងសមាសភាគគម្រោងទាំងនោះផង ដោយមិនគិតពីប្រភពនៃហិរញ្ញប្បទានឡើយ ព្រមទាំងគម្រោងវិនិយោគដែលផ្តល់ហិរញ្ញប្បទានដោយប្រាក់កម្ចី និង/ឬ ជំនួយឥតសំណង និង/ឬ ដោយវិធីសាស្រ្តផ្សេងទៀត ដូចជា ការវិនិយោគភាគហ៊ុន និង/ឬ ការធានា ជាដើម (ហៅកាត់ជារួមថាគម្រោង)។

## ឃ. លក្ខខណ្ឌតម្រូវ

### ១. ការវាយតម្លៃបរិស្ថាន

៤. ការវាយតម្លៃបរិស្ថាន គឺជាពាក្យទូទៅប្រើសម្រាប់រៀបរាប់ពីដំណើរវិភាគ និងរៀបចំផែនការបរិស្ថាន ដើម្បីធ្វើការដោះស្រាយបញ្ហាផលប៉ះពាល់ និងហានិភ័យបរិស្ថានដែលជាប់ពាក់ព័ន្ធនឹងគម្រោង។ នៅដំណាក់កាលដំបូងនៃការរៀបចំគម្រោង អ្នកខ្ចី

/អតិថិជន នឹងធ្វើការកំណត់ពីផលប៉ះពាល់ និងហានិភ័យដោយផ្ទាល់ ដោយប្រយោល និងផលប៉ះពាល់ និងហានិភ័យបង្ករ និងបង្ក ដែលមានឥទ្ធិពលលើធនធានរូបវន្ត ជីវៈសាស្ត្រ សង្គម-សេដ្ឋកិច្ច និងធនធានវប្បធម៌រូបវន្ត និងកំណត់ពីសារៈសំខាន់ និងទំហំនៃធនធានទាំងនេះ ដោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដូចជា អ្នករងផលប៉ះពាល់ និង NGO ពាក់ព័ន្ធនានា។ ប្រសិនបើកំណត់បាននូវផលប៉ះពាល់អវិជ្ជមាន និងហានិភ័យបរិស្ថានដែលអាចកើតមាន អ្នកខ្ចី/អតិថិជន នឹងធ្វើការវាយតម្លៃបរិស្ថានយ៉ាងឆាប់បំផុតតាមដែលអាចធ្វើទៅបាននៅក្នុងវដ្តគម្រោង។ ចំពោះគម្រោងដែលមានផលប៉ះពាល់ធ្ងន់ធ្ងរ ដែលមានលក្ខណៈខុសប្លែកពីធម្មតា មិនអាចកែប្រែបាន ឬដែលមិនធ្លាប់មានពីមុនមក អ្នកខ្ចី/អតិថិជន នឹងធ្វើការសិក្សារកជម្រើសទីតាំង ប្លង់រចនា បច្ចេកវិទ្យា និងសមាសភាគគម្រោងផ្សេងទៀត ដើម្បីបញ្ចៀស និង (ក្នុងករណីដែលមិនអាចបញ្ចៀសបាន) កាត់បន្ថយផលប៉ះពាល់អវិជ្ជមាន និងហានិភ័យបរិស្ថាន។ ហេតុផលក្នុងការជ្រើសរើសទីតាំងគម្រោង ប្លង់រចនា បច្ចេកវិទ្យា និងសមាសភាគគម្រោង ត្រូវធ្វើការកត់ត្រាឱ្យបានត្រឹមត្រូវ រួមទាំង ការវិភាគពីគុណវិបត្តិ-គុណសម្បត្តិ ដោយធ្វើការពិចារណាពីគុណវិបត្តិដែលមានចំពោះបរិស្ថាន និងគុណសម្បត្តិនៃការសម្រេចយកជម្រើសផ្សេងទៀត។ ជម្រើស "គ្មានគម្រោង" ក៏នឹងត្រូវយកមកពិចារណាផងដែរ។

៥.    ដំណើរការវាយតម្លៃ ពឹងផ្អែកទៅលើព័ត៌មានបច្ចុប្បន្ន រួមមានដូចជា ការរៀបរាប់យ៉ាងត្រឹមត្រូវពីគម្រោង និងទិន្នន័យគោលសមស្របពីសង្គម និងបរិស្ថាន។ ការវាយតម្លៃបរិស្ថាន នឹងគិតគូរពិចារណាក្នុងលក្ខណៈរួមបញ្ចូលគ្នា ពីផលប៉ះពាល់ និងហានិភ័យដែលអាចនឹងកើតចេញពីគម្រោង និងដែលអាចកើតមានចំពោះធនធានរូបវន្ត ជីវៈសាស្ត្រ សង្គម-សេដ្ឋកិច្ច (សុខភាព និងសុវត្ថិភាពការងារ សុខភាព និងសុវត្ថិភាពសហគមន៍ ក្រុមងាយរងគ្រោះ និងបញ្ហាយេនឌ័រ និងផលប៉ះពាល់ចំពោះជីវភាពរស់នៅដោយសារកត្តាបរិស្ថាន) [កថាខណ្ឌ ៦ ឧបសម្ព័ន្ធ ២] និងធនធានវប្បធម៌រូបវន្ត។ ផលប៉ះពាល់ និងហានិភ័យបរិស្ថានដែលអាចកើតចេញពីគម្រោង នឹងត្រូវវាយតម្លៃធៀបជាមួយនឹងលក្ខខណ្ឌតម្រូវដែលកំណត់ក្នុងឯកសារនេះ និងច្បាប់ និងបទបញ្ជា ពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន ដែលនៅជាធរមាននៅក្នុងដែនយុត្តាធិការដែលត្រូវអនុវត្តគម្រោង គិតរួមទាំងកាតព្វកិច្ចដែលប្រទេសម្ចាស់ផ្ទះត្រូវបំពេញស្របតាមច្បាប់អន្តរជាតិផងដែរ។

៦.    ផលប៉ះពាល់ និងហានិភ័យ នឹងត្រូវវិភាគក្នុងបរិបទនៃតំបន់រងការប៉ះពាល់ពីគម្រោង។ តំបន់រងការប៉ះពាល់ពីគម្រោង រួមមាន (១) តំបន់គម្រោងចំបង និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធដែលអ្នកខ្ចី/អតិថិជន (ព្រមទាំងអ្នកម៉ៅការ) បង្កើត ឬគ្រប់គ្រង ដូចជា បណ្តាញបញ្ជូនថាមពលអគ្គិសនី បណ្តាញលូ ព្រែក ប្រឡាយ ផ្លូវចេញ-ចូល រណ្តៅជីក និងកន្លែងចាក់សំណល់ និងទីសំណាក់ការដ្ឋានសាងសង់។ (២) ហេដ្ឋារចនាសម្ព័ន្ធបន្ទាប់បន្សំដែលមិនបានទទួលហិរញ្ញប្បទានពីគម្រោង (ហិរញ្ញប្បទានអាចផ្តល់ដាច់ដោយឡែកដោយអ្នកខ្ចី/អតិថិជន ឬដោយតតិយជន) ដែលតម្លៃ និងអត្ថិភាពនៃហេដ្ឋារចនាសម្ព័ន្ធទាំងនេះពឹងផ្អែកទាំងស្រុងលើគម្រោង ហើយដែលទំនិញ និង សេវានៃហេដ្ឋារចនាសម្ព័ន្ធទាំងនេះ មានសារៈសំខាន់ជាសារវន្តចំពោះភាពជោគជ័យក្នុងការអនុវត្តគម្រោង (៣) តំបន់ និងសហគមន៍ដែលអាចនឹងរងផលប៉ះពាល់បង្កពីផែនការអភិវឌ្ឍន៍នៅពេលអនាគតរបស់គម្រោង ពីប្រភពផ្សេងទៀត ដែលមានផលប៉ះពាល់ប្រហាក់ប្រហែលនៅក្នុងតំបន់ភូមិសាស្ត្រ ពីគម្រោង ឬស្ថានភាពដែលមានស្រាប់ និងពីការអភិវឌ្ឍន៍គម្រោងពាក់ព័ន្ធដែលត្រូវបានកំណត់យ៉ាងប្រាកដនិយមនៅពេលធ្វើការវាយតម្លៃ និង (៤) តំបន់ និងសហគមន៍ដែលអាចនឹងរងផលប៉ះ-ពាល់ពីការអភិវឌ្ឍន៍ដែលឥតគ្រោងទុក តែអាចទាយទុកជាមុនបាន ដែលបណ្តាលមកពីគម្រោងដែលកើតក្រោយ ឬនៅទីតាំងផ្សេង។

តំបន់រងការប៉ះពាល់ពីគម្រោង មិនរាប់បញ្ចូលនូវផលប៉ះពាល់ដែលអាចកើតមានដោយគ្មានគម្រោង ឬដែលឯករាជ្យពីគម្រោងឡើយ។ ផលប៉ះពាល់បរិស្ថាន និងហានិភ័យ ក៏នឹងត្រូវបានវិភាគផងដែរនៅរាល់គ្រប់ដំណាក់កាលនៃវដ្តគម្រោង រួមទាំងនៅដំណាក់មុនចាប់ផ្តើមសាងសង់ ដំណាក់កាលសាងសង់ ដំណាក់កាលប្រតិបត្តិការ ដំណាក់ការបញ្ចប់ និងសកម្មភាពក្រោយការបញ្ចប់ ដូចជា ការស្តារនីតិសម្បទា ឬការធ្វើឱ្យដូចលក្ខណៈដើម។

៧. ការវាយតម្លៃ នឹងកំណត់ពីឥទ្ធិពលឆ្លងដែនដែលអាចកើតមាន ដូចជា ការបំពុលបរិយាកាស ការបង្កើនការប្រើប្រាស់ ឬការបំពុលផ្លូវទឹកអន្តរជាតិ ព្រមទាំងផលប៉ះពាល់ជាសកល ដូចជា ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងផលប៉ះពាល់ទៅលើប្រភេទសត្វដែលកំពុងរងគ្រោះ និងទីជំរករបស់វា។

៨. ការវាយតម្លៃបរិស្ថាន នឹងសិក្សារកមើលថាតើមានបុគ្គល ឬក្រុមមនុស្សដែលអាចនឹងត្រូវរងផលប៉ះពាល់អវិជ្ជមានពីបរិស្ថានខុសប្លែកពីអ្នកដទៃ ឬមិនសមមាត្រជាមួយអ្នកដទៃ ដោយសារតែពួកគេជាបុគ្គល ឬក្រុមទន់ខ្សោយ ឬជាក្រុមងាយរងគ្រោះ ដូចជា អ្នកក្រីក្រ ស្ត្រី និងកុមារ និងជនជាតិដើមភាគតិច ជាដើម។ ប្រសិនបើកំណត់បានបុគ្គល ឬក្រុមមនុស្សប្រភេទនេះ ការវាយតម្លៃបរិស្ថាន នឹងផ្តល់អនុសាសន៍ឱ្យមានវិធានការដាច់ដោយឡែក ផ្តោតលើក្រុមមនុស្សប្រភេទនេះ ដើម្បីកុំឱ្យផលប៉ះពាល់អវិជ្ជមានពីបរិស្ថានធ្លាក់មកលើពួកគាត់ដោយមិនសមមាត្រជាមួយអ្នកដទៃ។

៩. អាស្រ័យលើកម្រិតនៃផលប៉ះពាល់ និងហានិភ័យរបស់គម្រោង ការវាយតម្លៃ អាចជាការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA) ពេញលក្ខណៈ ចំពោះគម្រោងប្រភេទ A ឬការត្រួតពិនិត្យបរិស្ថានជំហានដំបូង (IEE) ឬដំណើរការវាយតម្លៃសមមូលចំពោះគម្រោងប្រភេទ B ឬការពិនិត្យវាយតម្លៃនៅការិយាល័យ។ របាយការណ៍ EIA រួមមានធាតុសំខាន់ៗដូចតទៅ : (១) សង្ខេបប្រតិបត្តិ (២) ការពិពណ៌នាពីគម្រោង (៣) ការពិពណ៌នាពីបរិស្ថាន (ដោយមានទិន្នន័យគោលគ្រប់ជ្រុងជ្រោយ) (៤) ផលប៉ះពាល់បរិស្ថានព្យាករណ៍ទុក និងវិធានការកាត់បន្ថយផលប៉ះពាល់ (៥) ការវិភាគពីជម្រើសផ្សេងទៀត (៦) ផែនការគ្រប់គ្រងបរិស្ថាន (៧) ការពិគ្រោះយោបល់ និងការផ្តល់ព័ត៌មាន និង (៨) សេចក្តីសន្និដ្ឋាន និងអនុសាសន៍។ ឧបសម្ព័ន្ធនៃសេចក្តីបន្ថែមនេះមានធ្វើការលម្អិតច្រើនជាងនេះ។ IEE (មានវិសាលភាពតូចជាង) អាចត្រូវរៀបចំសម្រាប់គម្រោងដែលមានផលប៉ះពាល់មានកម្រិតតិចតួច ឬដែលកើតមានតែក្នុងតំបន់ជាក់លាក់មួយចំនួន ហើយដែលជាទូទៅអាចកែតម្រូវ និងអាចដោះស្រាយបាន តាមរយៈវិធានការកាត់បន្ថយផលប៉ះពាល់។

១០. ប្រសិនបើគម្រោងមានពាក់ព័ន្ធនឹងសកម្មភាព ឬហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ អ្នកជំនាញពាក់ព័ន្ធមកពីខាងក្រៅ នឹងធ្វើសវនកម្មបរិស្ថាន ដើម្បីកំណត់ពីតំបន់ដែលគម្រោងអាចនឹងបង្ក ឬកំពុងនឹងបង្កឱ្យមានផលប៉ះពាល់បរិស្ថាន ឬហានិភ័យ។ ប្រសិនបើគម្រោងមិនបានព្យាករណ៍នូវការពង្រីកបន្ថែមខ្នាតធំថ្មីណាមួយនោះទេ សវនកម្ម នឹងបង្កើតបានជាការវាយតម្លៃបរិស្ថានរបស់គម្រោង។ របាយការណ៍សវនកម្មបរិស្ថានធម្មតាមួយ រួមមានធាតុសំខាន់ៗដូចតទៅ : (១) សង្ខេបប្រតិបត្តិ (២) ការពិពណ៌នាពីហេដ្ឋារចនាសម្ព័ន្ធ រួមទាំងសកម្មភាពអតីតកាល និងបច្ចុប្បន្ន (៣) ការសង្ខេបពីច្បាប់ បទបញ្ញា និងបទដ្ឋានបរិស្ថានជាតិ តំបន់ និងបទដ្ឋានផ្សេងទៀតដែលមានជាធរមាន (៤) សវនកម្ម និងនីតិវិធីត្រួតពិនិត្យតំបន់គម្រោង (៥) លទ្ធផលនៃការត្រួតពិនិត្យ

និងចំណុចមានបញ្ហា និង (៦) ផែនការសកម្មភាពកែតម្រូវដែលកំណត់ពីសកម្មភាពកែតម្រូវសមស្របសម្រាប់ដោះស្រាយចំណុចមានបញ្ហានីមួយៗ រួមទាំង សោហ៊ុយចំណាយ និងកម្មវិធីកែតម្រូវ។

១១. ប្រសិនបើគម្រោងមានពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ ឬការកែប្រែគោលនយោបាយ ផែនការ ឬកម្មវិធីដែលអាចនឹងបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថានក្នុងតំបន់ ឬផ្នែកណាមួយនៃតំបន់ ក្នុងករណីនេះ ចាំបាច់ត្រូវធ្វើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។ របាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្ររួមមាន (១) ការវិភាគសេណារីយ៉ូ (២) ការវាយតម្លៃពីផលប៉ះពាល់រយៈពេលវែង និងប្រយោល (៣) ការពិពណ៌នាពីដំណើរការពិគ្រោះយោបល់ និង (៤) ការពន្យល់ពីការជ្រើសរើសជម្រើស។

## ២. ការរៀបចំផែនការ និងការគ្រប់គ្រងបរិស្ថាន

១២. អ្នកខ្ចី/អតិថិជន នឹងរៀបចំផែនការគ្រប់គ្រងបរិស្ថាន (EMP) ដែលកំណត់ពីដំណោះស្រាយចំពោះផលប៉ះពាល់ និងហានិភ័យដែលអាចកើតមាន និងដែលបានកំណត់ដោយការវាយតម្លៃបរិស្ថាន។ EMP នឹងមានបញ្ចូលនូវសំណើវិធានការកាត់បន្ថយផលប៉ះពាល់ ការតាមដានបរិស្ថាន និង លក្ខខណ្ឌតម្រូវក្នុងការរាយការណ៍ នីតិវិធីឆ្លើយតបក្នុងពេលមានអបញ្ហាបន្ទាន់ ការរៀបចំអង្គការ ឬស្ថាប័នពាក់ព័ន្ធ ការកសាងសមត្ថភាព និងវិធានការបណ្ដុះបណ្ដាល កម្មវិធីអនុវត្ត សោហ៊ុយចំណាយប៉ាន់ស្មាន និងសូចនាករលទ្ធផល។ ប្រសិនបើផលប៉ះពាល់ និងហានិភ័យមិនអាចបញ្ចៀស ឬបង្ការបាន វិធានការ និងសកម្មភាពកាត់បន្ថយផលប៉ះពាល់នឹងត្រូវកំណត់ ដើម្បីឱ្យការរៀបចំ និងការប្រតិបត្តិគម្រោង អាចធ្វើទៅបានស្របតាមច្បាប់ និងបទបញ្ជាដែលមានជាធរមាន និងបំពេញបានតាមលក្ខខណ្ឌតម្រូវដែលមានកំណត់ក្នុងឯកសារនេះ។ កម្រិតនៃភាពលម្អិត និងស្មុគស្មាញនៃឯកសាររៀបចំផែនការបរិស្ថាន និងអាទិភាពនៃវិធានការ និងសកម្មភាពដែលបានកំណត់ នឹងឆ្លើយតបទៅតាមទំហំនៃផលប៉ះពាល់ និងហានិយភ័យរបស់គម្រោង។ ចំណុចគិតគូរពិចារណាចំបងៗ រួមមាន ការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានឱ្យបានដល់កម្រិត "គ្មានខូចខាតធ្ងន់ធ្ងរដល់តតិយជន" អ្នកបំពុលបរិស្ថានបង់សំណងការខូចខាត វិធីសាស្ត្របង្ការជាមុន និងការគ្រង់គ្រងមានការបត់បែន។

១៣. ប្រសិនបើផលប៉ះពាល់ដែលនៅសេសសល់ នៅតែបន្តមានភាពធ្ងន់ធ្ងរក្រោយការកាត់បន្ថយ EMP នឹងដាក់បញ្ចូលផងដែរនូវវិធានការទូទាត់ (ប៉ះប៉ូវ) សមស្រប ដើម្បីធានាថាគម្រោងមិនបង្កឱ្យមានការរេចរឹលធ្ងន់ធ្ងរដល់បរិស្ថាន។ ឧទាហរណ៍ វិធានការបែបនេះ អាចនឹងមានការពាក់ព័ន្ធនឹងការអភិរក្សជំរកសត្វ និងជីវចម្រុះ ការរក្សាការពារបរិយាកាសនៅជុំវិញ និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ការទូទាត់ជាសាច់ប្រាក់ជំនួសឱ្យការប៉ះប៉ូវ អាចទទួលយកបានតែនៅក្នុងករណីដែលការទូទាត់នោះត្រូវបានប្រើដើម្បីផ្ដល់ផលប្រយោជន៍ដល់បរិស្ថានក្នុងទំហំដូចគ្នា និងសមមាត្រជាមួយនឹងផលប៉ះពាល់ដែលនៅសេសសល់របស់គម្រោង។

១៤. EMP នឹងព្យាយាមកំណត់លទ្ធផលរំពឹងទុកជាព្រឹត្តិការណ៍ដែលអាចវាយតម្លៃបាន ឱ្យអស់ពីលទ្ធភាពដែលអាចធ្វើទៅបាន ហើយនឹងដាក់បញ្ចូលផងដែរនូវសូចនាករលទ្ធផល ឬគោលដៅដែលអាចធ្វើការតាមដានបានក្នុងអំឡុងពេលកំណត់ជាក់លាក់មួយ។ លទ្ធផលពីការតាមដាននេះ នឹងបណ្ដាលឱ្យមានការ កែប្រែក្នុងការរៀបចំគម្រោង ដូចជា ការកែប្រែចំបងចំពោះទីតាំង ឬមាគ៌ាគម្រោង ឬបច្ចេកវិទ្យា ព្រឹត្តិការណ៍ឥតព្រាងទុក និងលទ្ធផលតាមដាន។

១៥. មានពេលខ្លះ ការចូលរួមរបស់តតិយជន នឹងជះឥទ្ធិពលលើការអនុវត្ត EMP ។ តតិយជន អាចជា ទីភ្នាក់ងាររដ្ឋាភិបាល អ្នកម៉ៅការ ឬប្រតិបត្តិករនៃហេដ្ឋារចនាសម្ព័ន្ធបន្ទាប់បន្សំ ។ ប្រសិនបើហានិភ័យរបស់តតិយជនមានកម្រិតខ្ពស់ ហើយអ្នកខ្ចី/អតិថិជន មានសិទ្ធិគ្រប់គ្រង ឬមានឥទ្ធិពលលើសកម្មភាព និងការប្រព្រឹត្តិរបស់តតិយជន អ្នកខ្ចី/អតិថិជននឹងសហការជាមួយតតិយជន ដើម្បី សម្រេចលទ្ធផលដែលស្របគ្នានឹងលក្ខខណ្ឌតម្រូវដែលអ្នកខ្ចី/អតិថិជនត្រូវបំពេញ ។ សកម្មភាពជាក់លាក់មួយចំនួន នឹងកំណត់តាម ករណីជាក់ស្តែងនីមួយៗ ។

១៦. អ្នកខ្ចី/អតិថិជន នឹងប្រើប្រាស់អ្នកជំនាញមានគុណវុឌ្ឍិ និងមានបទពិសោធន៍ដើម្បីរៀបចំការវាយតម្លៃបរិស្ថាន និង EMP ។ ចំពោះគម្រោងមានភាពស្មុគស្មាញ និងងាយរងការប៉ះពាល់ខ្លាំង ក្រុមទីប្រឹក្សាឯករាជ្យនៃអ្នកជំនាញដែលមិនពាក់ព័ន្ធនឹងគម្រោង នឹងត្រូវប្រើនៅអំឡុងពេលរៀបចំ និងអនុវត្តគម្រោង ។

## ៣. ការផ្តល់ព័ត៌មាន

១៧. អ្នកខ្ចី/អតិថិជន នឹងផ្ញើឱ្យ ADB នូវឯកសារដូចខាងក្រោមដើម្បីផ្សព្វផ្សាយនៅលើគេហទំព័ររបស់ ADB :

(i) សេចក្តីព្រាង EIA (រួមនឹងសេចក្តីព្រាង EMP) យ៉ាងតិច ១២០ ថ្ងៃ មុននឹងការពិនិត្យពិចារណារបស់ក្រុម ប្រឹក្សាភិបាល ADB និង/ឬ ការវាយតម្លៃបរិស្ថាន និងក្របខណ្ឌពិនិត្យវាយតម្លៃ នៅមុនពេលពិនិត្យវាយតម្លៃ គម្រោង ប្រសិនបើមាន ។

(ii) EIA/IEE ចុងក្រោយ ។

(iii) EIA/IEE ថ្មី ឬដែលបានធ្វើបច្ចុប្បន្នភាព និងផែនការសកម្មភាពកែតម្រូវដែលបានរៀបចំធ្វើនៅអំឡុងពេល អនុវត្តគម្រោង ប្រសិនបើមាន ។ និង

(iv) របាយការណ៍តាមដានបរិស្ថាន ។

១៨. អ្នកខ្ចី/អតិថិជន នឹងផ្តល់ព័ត៌មានបរិស្ថានពាក់ព័ន្ធ រួមទាំងព័ត៌មានដែលមានក្នុងឯកសារទាំងឡាយនៃកថាខណ្ឌ ១៧ ឱ្យ បានទាន់ពេលវេលា និងត្រូវផ្តល់ឱ្យនៅកន្លែង និងក្នុងទម្រង់ និងភាសាដែលក្រុមមនុស្សរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធអាចយល់ បាន ។ ចំពោះអ្នកមិនចេះអក្សរ វិធីសាស្ត្រទំនាក់ទំនងសមស្របផ្សេងទៀតនឹងត្រូវយកមកប្រើ ។

## ៤. ការពិគ្រោះយោបល់ និង ការចូលរួម

១៩. អ្នកខ្ចី/អតិថិជន នឹងធ្វើការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយក្រុមមនុស្សរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធ ផ្សេងទៀត រួមទាំងសង្គមស៊ីវិល និងសម្របសម្រួលការចូលរួមរបស់ពួកគេ ។ការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យ គឺជាដំណើរ

ការដែល (១) ចាប់ផ្តើមនៅដើមដំណាក់កាលនៃការរៀបចំគម្រោង និងបន្តធ្វើជាប់ជានិច្ចនៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង[១] (២) ធ្វើការផ្តល់ព័ត៌មានពាក់ព័ន្ធ និងសមស្របទាន់ពេលវេលា និងជាព័ត៌មានដែលក្រុមមនុស្សរងផលប៉ះពាល់អាចរកបាន និងអាចយល់បានដោយងាយស្រួល (៣) ធ្វើឡើងនៅក្នុងបរិយាកាសដែលគ្មានការគំរាមកំហែង និងបង្ខិតបង្ខំ (៤) មានការគិតគូរពីបញ្ហាយេនឌ័រ និងមានការតម្រែតម្រង់ទៅតាមតម្រូវការក្រុមទន់ខ្សោយ និងងាយរងគ្រោះ និង (៥) អនុញ្ញាតឱ្យមានការបញ្ចូលគំនិតយោបល់របស់ក្រុមមនុស្សរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធ ក្នុងការធ្វើការសម្រេចចិត្តពីការរៀបចំគម្រោង វិធានការកាត់បន្ថយផលប៉ះពាល់ ការចែករំលែកអត្ថប្រយោជន៍ និងឱកាសដែលបានមកពីការអភិវឌ្ឍន៍ និងបញ្ហាអនុវត្តគម្រោង។ ទំហំនៃការពិគ្រោះយោបល់នឹងធ្វើឡើងសមមាត្រទៅនឹងផលប៉ះពាល់ដែលមានទៅលើសហគមន៍រងផលប៉ះពាល់។ ដំណើរការពិគ្រោះយោបល់ និងលទ្ធ-ផលនៃ ការពិគ្រោះយោបល់ នឹងត្រូវកត់ត្រាទុកជាឯកសារ និងត្រូវឆ្លុះបញ្ចាំងក្នុងរបាយការណ៍វាយតម្លៃបរិស្ថាន។

## ៥. យន្តការដោះស្រាយបណ្តឹងតវ៉ា

២០. អ្នកខ្ចី/អតិថិជន នឹងបង្កើតឱ្យមាននូវយន្តការមួយដើម្បីទទួល និងសម្របសម្រួលដោះស្រាយក្តីបារម្ភ បណ្តឹង និងការតវ៉ារបស់ក្រុមមនុស្សរងផលប៉ះពាល់ ពីបញ្ហាបរិស្ថានដែលកើតមានដោយសារគម្រោង។ យន្តការដោះស្រាយបណ្តឹងតវ៉ា ត្រូវមានទំហំសមមាត្រនឹងផលប៉ះពាល់អវិជ្ជមាន និងហានិភ័យរបស់គម្រោង។ យន្តការនេះ ត្រូវតែអាចដោះស្រាយក្តីបារម្ភ និងបណ្តឹងតវ៉ារបស់ក្រុមមនុស្សរងផលប៉ះពាល់បានឆាប់រហ័ស ដោយប្រើប្រាស់នូវដំណើរការដែលងាយយល់ និងមានតម្លាភាព និងដែលមានការគិតគូរពីយេនឌ័រ មានលក្ខណៈសមស្របនឹងវប្បធម៌របស់ក្រុមមនុស្សរងផលប៉ះពាល់ និងអាចប្រើប្រាស់បានដោយក្រុមមនុស្សរងផលប៉ះពាល់គ្រប់ស្រទាប់វណ្ណៈ ដោយមិនគិតថ្លៃ និងដោយគ្មានការសងសឹក។ យន្តការនេះមិនត្រូវបង្កឱ្យមានឧបសគ្គដល់ការប្រើប្រាស់ដំណើរការដោះស្រាយវិវាទតាមរយៈប្រព័ន្ធយុត្តាធិការ ឬប្រព័ន្ធរដ្ឋបាលរបស់រដ្ឋឡើយ។ ក្រុមមនុស្សរងផលប៉ះពាល់ត្រូវតែអាចទទួលបានព័ត៌-មានពីយន្តការនេះឱ្យបានសមស្រប។

## ៦. ការតាមដាន និង ការរាយការណ៍

២១. អ្នកខ្ចី/អតិថិជន នឹងធ្វើការតាមដាន និងវាស់ស្ទង់ការវិវត្តនៃការអនុវត្ត EMP។ ទំហំនៃសកម្មភាពតាមដានត្រូវសមមាត្រជាមួយនឹងផលប៉ះពាល់ និងហានិភ័យរបស់គម្រោង។ បន្ថែមលើការកត់ត្រាព័ត៌មានដើម្បីតាមដានលទ្ធផល អ្នកខ្ចី/អតិថិជន នឹងធ្វើការត្រួតពិនិត្យដើម្បីបញ្ជាក់ពីការអនុលោមតាម EMP និងការវិវត្តឆ្ពោះទៅលទ្ធផលរំពឹងទុក។ ចំពោះគម្រោងដែលអាចនឹងមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរចំពោះបរិស្ថាន អ្នកខ្ចី/អតិថិជននឹងជួលអ្នកជំនាញពីខាងក្រៅដែលមានគុណវុឌ្ឍិ និងមានបទពិសោធន៍ ឬ NGO ដែលមានគុណវុឌ្ឍិ ឱ្យធ្វើការបញ្ជាក់លើព័ត៌មានតាមដានរបស់ខ្លួន។ អ្នកខ្ចី/អតិថិជន នឹងកត់ត្រាទុកជាឯកសារនូវរាល់លទ្ធផលតាមដាន កំណត់នូវសកម្មភាពកែតម្រូវចាំបាច់ និងឆ្លុះបញ្ចាំងសកម្មភាពទាំងនេះក្នុងផែនការសកម្មភាពកែតម្រូវ។ អ្នកខ្ចី/

---

[១] ចំពោះគម្រោងប្រភេទ ក ការពិគ្រោះយោបល់ប្រភេទនេះ ចាំបាច់ត្រូវមានការប្រឹក្សានៅដើមដំណាក់កាលចុះធ្វើការងារ EIA និងប្រសិនបើមានសេចក្តីព្រាងរបាយការណ៍ EIA នៅអំឡុងពេលរៀបចំគម្រោង និងនៅមុនពេលវាយតម្លៃគម្រោងដោយ ADB។

អតិថិជន នឹងអនុវត្ត និងតាមដានការអនុវត្តសកម្មភាពទាំងនោះ ដើម្បីធានានូវប្រសិទ្ធភាពនៃការអនុវត្ត។

២២. អ្នកខ្ចី/អតិថិជន នឹងរៀបចំរបាយការណ៍តាមដានសាមាយិក ដែលនឹងរៀបរាប់ពីការវិវត្តនៃការអនុវត្ត EMP និងបញ្ហាអនុវត្តតាម និងសកម្មភាពកែតម្រូវ ប្រសិនបើមាន។ អ្នកខ្ចី/អតិថិជន នឹងផ្ញើ យ៉ាងហោចណាស់ របាយការណ៍ត្រួតពិនិត្យប្រចាំឆមាស នៅអំឡុងពេលសាងសង់ ចំពោះគម្រោងដែលអាចនឹងបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់បរិស្ថាន និងរបាយការណ៍ត្រួតពិនិត្យប្រចាំត្រីមាស ចំពោះគម្រោងមានភាពស្មុគស្មាញ និងងាយរងការប៉ះពាល់ខ្លាំង។ ចំពោះគម្រោងដែលអាចមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរចំពោះបរិស្ថាននៅអំឡុងពេលប្រតិបត្តិការ របាយការណ៍នឹងបន្តផ្ញើយ៉ាងហោចណាស់មួយដងក្នុងមួយឆ្នាំ។ របាយ-ការណ៍សាមាយិកនេះ នឹងត្រូវផ្សព្វផ្សាយនៅទីកន្លែងដែលសាធារណៈជនអាចរកមើលបាន។ ធនាគារអភិវឌ្ឍន៍ — ធីកាគម្រោង នឹងឆ្លុះបញ្ចាំងពីសោហ៊ុយចំណាយក្នុងការបំពេញលក្ខខណ្ឌតម្រូវតាមដាន និងរាយការណ៍។

### ៧. ផលប៉ះពាល់បរិស្ថានដែលមិនបានគិតទុក

២៣. ប្រសិនបើផលប៉ះពាល់បរិស្ថានដែលមិនបានគិតទុកបានស្តែងឡើងយ៉ាងប្រត្យក្សនៅអំឡុងពេលអនុវត្តគម្រោង អ្នកខ្ចី/អតិថិជន នឹងធ្វើបច្ចុប្បន្នភាពការវាយតម្លៃបរិស្ថាន និង EMP ឬរៀបចំធ្វើការវាយតម្លៃបរិស្ថាន និង EMP ជាថ្មី ដើម្បីវាយតម្លៃផលប៉ះពាល់ ដែលអាចសិក្សាជម្រើសផ្សេងៗ និងកំណត់ត្រួសៗពីវិធានការកាត់បន្ថយផលប៉ះពាល់ និងធនធានសម្រាប់ដោះស្រាយផលប៉ះពាល់ទាំងនោះ។

### ៨. ការអភិរក្សជីវៈចម្រុះ និង ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព

២៤. អ្នកខ្ចី/អតិថិជន នឹងវាយតម្លៃពីទំហំនៃផលប៉ះពាល់ និងហានិយភ័យរបស់គម្រោងចំពោះជីវៈចម្រុះ[២] និងធនធានធម្មជាតិដែលជាផ្នែកសំខាន់នៃដំណើរការវាយតម្លៃបរិស្ថាន ដែលមានចែងក្នុងកថាខណ្ឌ ៤-១០។ ការវាយតម្លៃ នឹងផ្តោតលើការគំរាមកំហែងចំបងៗចំពោះជីវៈចម្រុះ ដែលរួមមានដូចជា ការបំផ្លាញជំរកសត្វ និងការនាំចូលប្រភេទ ពូជអុតត្បាតឆ្លងដែន និងផ្តោតលើការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ អ្នកខ្ចី/អតិថិជន ត្រូវកំណត់ពីវិធានការបញ្ចៀស បន្ធូរបន្ថយជាអប្បបរមា ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន និងហានិភ័យដែលអាចកើតមាន និង (យ៉ាងហោចណាស់) ស្នើឡើងនូវវិធានការទូទាត់នានា ដូចជាការប៉ះប៉ូវជីវៈចម្រុះ ដើម្បីរក្សាឱ្យបានទាំងស្រុង ឬដើម្បីចៀសវាងការបាត់បង់ទាំងស្រុងនូវជីវៈចម្រុះដែលរងផលប៉ះពាល់។

### ក. ជំរកកែប្រែ

២៥. នៅក្នុងតំបន់នៃជំរកកែប្រែ ប្រសិនបើជំរកធម្មជាតិត្រូវបានផ្លាស់ប្តូរ (ដែលជាធម្មតាបណ្តាលមកពីការនាំចូលប្រភេទពូជ

---

[២] សំដៅលើបណ្តាសារពាង្គកាយខុសគ្នាក្នុងប្រភេទតែមួយ ឬប្រភេទផ្សេងគ្នា និងបណ្តាសារពាង្គកាយរស់នៃគ្រប់លំដាប់ថ្នាក់ និងប្រភពទាំងអស់ រួមទាំងប្រព័ន្ធអេកូឡូស៊ីដែនគោក ដែនសមុទ្រ ដែនទឹកសាប និងបណ្តាទំនាក់ទំនងអេកូឡូស៊ី ដែលនៅក្នុងនោះមានប្រព័ន្ធអេកូឡូស៊ីទាំងនេះ។

សត្វ និងរុក្ខជាតិថ្មី) ដូចជានៅក្នុងតំបន់កសិកម្ម អ្នកខ្ចី/អតិថិជន នឹងធ្វើការប្រុងប្រយ័ត្នក្នុងការកាត់បន្ថយការកែប្រែ ឬការរេចរឹល បន្ថែមទៀតចំពោះជំរកសត្វទាំងនេះ ហើយ (អាស្រ័យទៅតាមលក្ខណៈ និងទំហំរបស់គម្រោង) នឹងកំណត់ឱកាសដើម្បីលើកស្ទួយ ជំរកសត្វ និងការពារ និងអភិរក្សជីវៈចម្រុះ ឱ្យក្លាយជាផ្នែកមួយនៃការប្រតិបត្តិគម្រោង។

## ខ. ជំរកធម្មជាតិ

២៦. នៅក្នុងតំបន់នៃជំរកធម្មជាតិ[៣] គម្រោងនឹងមិនធ្វើការកែប្រែ ឬធ្វើឱ្យរេចរឹលធ្ងន់ធ្ងរ[៤] ដល់ជំរកប្រភេទនេះឡើយ លើកលែងតែក្នុងស្ថានភាពដូចខាងក្រោម :

(i) គ្មានជម្រើសផ្សេងទៀត។

(ii) ការវិភាគគ្រប់ជ្រុងជ្រោយបង្ហាញថា អត្ថប្រយោជន៍កើតចេញពីគម្រោង នឹងទទួលបានច្រើនក្រាស់ក្រែលជាងការបាត់បង់ដោយសារគម្រោង រួមទាំង ការខាតបង់បរិស្ថានផង។

(iii) ការកែប្រែ ឬការរេចរឹលត្រូវបានកាត់បន្ថយយ៉ាងសមស្រប។

២៧. វិធានការកាត់បន្ថយផលប៉ះពាល់ នឹងត្រូវរៀបចំឡើងដើម្បីបញ្ចៀសឱ្យបាន យ៉ាងហោចណាស់ នូវការបាត់បង់ទាំងស្រុងនូវជីវៈចម្រុះ។ វិធានការនេះ អាចរួមបញ្ចូលនូវសកម្មភាពចម្រុះ ដូចជា ការស្តារជំរកសត្វឡើងវិញនៅក្រោយការអនុវត្តគម្រោង ការប៉ះប៉ូវការបាត់បង់ តាមរយៈការបង្កើត ឬការអភិរក្សយ៉ាងមានប្រសិទ្ធភាពនូវតំបន់អេកូឡូស៊ីប្រហាក់ប្រហែល ដែលនឹងត្រូវគ្រប់គ្រងដើម្បីអត្ថប្រយោជន៍របស់ជីវៈចម្រុះ តែនៅក្នុងពេលជាមួយគ្នានេះ គោរពផងដែរនូវសិទ្ធិប្រើប្រាស់ជីវៈចម្រុះទាំងនេះដោយជនជាតិដើមភាគតិច ឬសហគមន៍ព្រៃឈើ និងធ្វើសំណងទូទាត់ដល់អ្នកប្រើប្រាស់ផ្ទាល់នៃជីវៈចម្រុះ។

## គ. ជំរកសំខាន់

២៨. គ្មានសកម្មភាពគម្រោងណាមួយអាចត្រូវអនុវត្តក្នុងតំបន់នៃជំរកសំខាន់[៥] ឡើយ លើកលែងតែក្នុងករណីបំពេញលក្ខខណ្ឌ

---

[៣] តំបន់ដីគោក និងដែនទឹក ដែលបណ្តុំជីវៈសាស្ត្រកកើតឡើងពីប្រភេទសត្វ និងរុក្ខជាតិប្រចាំតំបន់ជាចំបង និងជាតំបន់ ដែលសកម្មភាពរបស់មនុស្សមិនបានកែប្រែជាសារវន្តទៅលើមុខងារអេកូឡូស៊ីចំបងរបស់តំបន់នោះ។

[៤] ការកែប្រែ ឬការរេចរឹលធ្ងន់ធ្ងរ សំដៅលើ (១) ការលុបបំបាត់ ឬការធ្វើឱ្យថយចុះបូរណភាពនៃជំរកសត្វ ដោយសារតែការផ្លាស់ប្តូរចំបងក្នុងរយៈពេលវែងក្នុងការប្រើប្រាស់ដី និងទឹក ឬ (២) ការកែប្រែជំរកសត្វដែលបណ្តាលឱ្យមានការ កាត់បន្ថយយ៉ាងខ្លាំងនូវលទ្ធភាពរបស់ជំរកក្នុងការរក្សាការរស់រានរបស់ប្រភេទពូជប្រចាំតំបន់។ ការកែប្រែធ្ងន់ធ្ងរ រួម មានដូចជា : ការឈូសឆាយដី ការបន្លាស់ចេញរុក្ខជាតិធម្មជាតិ (ឧ. ការដាំដំណាំ ឬដើមឈើ) ជំនន់អចិន្ត្រៃយ៍ (ឧ. អាងស្តុកទឹក) ប្រព័ន្ធបង្ហូរទឹក ការបូមដី ការចាក់បំពេញដី ឬការជីកព្រែកនៅតំបន់ដីសើម ឬការជីករ៉ែនៅផ្ទៃខាងលើ។

[៥] ជំរកសំខាន់ គឺជាអនុក្រុមនៃជំរកធម្មជាតិ និងជំរកកែប្រែ ដែលទាមទារនូវការចាប់អារម្មណ៍ជាពិសេស។ ជំរកសំខាន់ រួមមាន តំបន់ដែលមានតម្លៃផ្នែកជីវៈចំរុះ ដូចជា តំបន់ដែលចាំបាច់ចំពោះការរស់រានរបស់ប្រភេទសត្វដែលកំពុងរងគ្រោះ ឬកំពុងរងគ្រោះធ្ងន់ធ្ងរ តំបន់ដែល

តម្រូវដូចខាងក្រោម ៖

(i) គ្មានផលប៉ះពាល់អវិជ្ជមានណាមួយ (ឬភាពទំនងជាមានផលប៉ះពាល់) ចំពោះជំរកសំខាន់ ដែលអាចនឹងប៉ះពាល់ដល់តម្លៃជីវៈចម្រុះ ឬលទ្ធភាពបំពេញមុខងាររបស់ជំរកសំខាន់។

(ii) គម្រោងមិនត្រូវបានរំពឹងថា នឹងបណ្តាលឱ្យមានការកាត់បន្ថយចំនួនសត្វដែលគេទទួលស្គាល់ថាកំពុងរងគ្រោះ ឬកំពុងរងគ្រោះធ្ងន់ធ្ងរ[៦] ឬបណ្តាលឱ្យបាត់បង់តំបន់ជំរកសត្វប្រភេទនេះ ដែលនឹងធ្វើឱ្យប៉ះពាល់ដល់ស្ថេរភាពនៃប្រព័ន្ធអេកូឡូស៊ី។

(iii) ផលប៉ះពាល់ផ្សេងទៀតត្រូវបានកាត់បន្ថយស្របតាមកថាខណ្ឌ ២៧។

២៩. ប្រសិនបើគម្រោងមានធ្វើសកម្មភាពនៅក្នុងជំរកសំខាន់ អ្នកខ្ចី/អតិថិជន នឹងជួលអ្នកជំនាញពីខាងក្រៅដែលមានគុណវុឌ្ឍិ និងមានបទពិសោធន៍ ឱ្យជួយធ្វើការវាយតម្លៃ។

## ឃ. តំបន់ការពារធម្មជាតិកំណត់ដោយច្បាប់

៣០. ក្នុងករណីដែលសកម្មភាពគម្រោងមានទីតាំងស្ថិតនៅក្នុងតំបន់ការពារធម្មជាតិកំណត់ដោយច្បាប់ ក្រៅពីលក្ខខណ្ឌតម្រូវដែលមានកំណត់ក្នុងកថាខណ្ឌ ២៨ អ្នកខ្ចី/អតិថិជន ត្រូវបំពេញលក្ខខណ្ឌតម្រូវដូចខាងក្រោមបន្ថែមទៀត ៖

(i) ធ្វើសកម្មភាពស្របតាមផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ។

(ii) ពិគ្រោះយោបល់ជាមួយអ្នកទ្រទ្រង់ និងអ្នកគ្រប់គ្រងតំបន់ការពារធម្មជាតិ សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធសំខាន់ៗ ផ្សេងទៀតអំពីគម្រោងដែលបានស្នើឡើង។

(iii) អនុវត្តកម្មវិធីបន្ថែម (ប្រសិនបើអាច) ដើម្បីលើកកម្ពស់ និងលើកស្ទួយគោលដៅអភិរក្សតំបន់ការពារធម្មជាតិ។

## ង. ប្រភេទពូជសត្វអុតត្បាតឆ្លងដែន

៣១. អ្នកខ្ចី/អតិថិជន នឹងមិននាំចូលដោយចេតនានូវប្រភេទពូជឆ្លងដែនថ្មីៗ (ពោលគឺប្រភេទពូជដែលមិនមាននៅក្នុងប្រទេស

---

មានសារៈសំខាន់ជាពិសេសចំពោះប្រភេទសត្វប្រចាំតំបន់ ឬប្រភេទសត្វកម្រ តំបន់ដែលមានសារៈសំខាន់ ចំពោះការរស់រានរបស់ប្រភេទសត្វដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយ តំបន់ទ្រទ្រង់ជាសកលដល់ការប្រមូលផ្តុំនៃប្រភេទសត្វប្រមូលផ្តុំ តំបន់មានប្រភេទសត្វប្លែកៗ ឬដែលមានជាប់ពាក់ព័ន្ធនឹងដំណើរការវិវត្តផ្លាស់ប្តូរគន្លឹះ ឬតំបន់ដែលមានមុខងារអេកូឡូស៊ីសំខាន់ និងតំបន់ដែលជីវៈចំរុះមានសារៈសំខាន់ខាងសង្គម សេដ្ឋកិច្ច និងវប្បធម៌ចំពោះសហគមន៍មូលដ្ឋាន។ ជំរកសំខាន់ រួមបញ្ចូលនូវតំបន់ទាំងឡាយណាដែលត្រូវបានការពារដោយច្បាប់ ឬត្រូវបានស្នើសុំឱ្យការពារជាផ្លូវការ ដូចជាតំបន់ដែលបំពេញបានតាមលក្ខខណ្ឌវិនិច្ឆ័យចំណាត់ថ្នាក់របស់ "សហជីពអភិរក្សពិភពលោក" (បញ្ជីរាមសារនៃតំបន់ដីសើមដែលមានសារៈសំខាន់ជាអន្តរជាតិ) និងតំបន់បេតិកភ័ណ្ឌពិភពលោករបស់ UNESCO។

[៦] និយមន័យកំណត់ដោយបញ្ជីក្រហមនៃប្រភេទសត្វរងការគំរាមកំហែងរបស់សហជីពអភិរក្សពិភពលោក ឬនៅក្នុងច្បាប់ជាតិ។

ឬតំបន់គម្រោង) លើកលែងតែការនាំចូលនោះធ្វើឡើងស្របតាមក្របខណ្ឌបទបញ្ជាដែលមាន (ប្រសិនបើមានក្របខណ្ឌបទបញ្ជានោះ) ឬលើកលែងតែការនាំចូលនោះអនុលោមតាមការវាយតម្លៃហានិភ័យ (ជាផ្នែកមួយនៃការវាយតម្លៃបរិស្ថាន) ដើម្បីកំណត់លក្ខណៈអុតត្បាតដែលអាចមាន។ ក្នុងករណីណាក៏ដោយ ប្រភេទពូជដែលត្រូវបានគេស្គាល់ថាជាប្រភេទពូជអុតត្បាត មិនអាចត្រូវបាននាំចូលក្នុងបរិស្ថានថ្មីឡើយ។ អ្នកខ្ចី/អតិថិជន នឹងធ្វើការវាយតម្លៃពីលទ្ធភាពនៃការនាំចូលដោយចៃដន្យ ឬដោយអចេតនានៃប្រភេទពូជអុតត្បាតឆ្លងដែន និងកំណត់វិធានការកាត់បន្ថយការឆ្លងរាលដាលដែលអាចកើតមាន។

### ច. ការគ្រប់គ្រង និង ការប្រើប្រាស់ធនធានធម្មជាតិកកើតឡើងវិញ

៣២. ធនធានធម្មជាតិកកើតឡើងវិញ នឹងត្រូវគ្រប់គ្រងប្រកបដោយនិរន្តរភាព។ ការគ្រប់គ្រងធនធានប្រកបដោយនិរន្តរភាពគឺជាការគ្រប់គ្រងការប្រើប្រាស់ ការអភិវឌ្ឍន៍ និងការការពារធនធានក្នុងវិធីសាស្រ្ត (ឬក្នុងកម្រិត) មួយដែលអនុញ្ញាតឱ្យមនុស្ស និងសហគមន៍ រួមទាំងជនជាតិដើមភាគតិចផង អាចទទួលបាននូវសុខុមាលភាពសង្គម សេដ្ឋកិច្ច និងវប្បធម៌ តែនៅក្នុងពេលជាមួយគ្នានេះ ក៏អាចទ្រទ្រង់ធនធានទាំងនេះ ដើម្បីបំពេញសេចក្តីត្រូវការសមស្របនៅពេលអនាគតរបស់មនុស្សជំនាន់ក្រោយ។ ការគ្រប់គ្រងនេះ រួមមាន ការបង្ការការពារលទ្ធភាពទ្រទ្រង់ជីវិតរបស់ខ្យល់ ទឹក និងប្រព័ន្ធអេកូឡូស៊ីរបស់ដី។ ប្រសិនបើអាច អ្នកខ្ចី/អតិថិជន នឹងបង្ហាញពីការគ្រប់គ្រងធនធានប្រកបដោយនិរន្តរភាព តាមរយៈប្រព័ន្ធបញ្ជាក់ឯករាជ្យសមស្រប។

### ឆ. ការបង្ការ និង ការកាត់បន្ថយការបំពុល

៣៣. នៅអំឡុងពេលរៀបចំ សាងសង់ និងប្រតិបត្តិគម្រោង អ្នកខ្ចី/អតិថិជន នឹងដាក់អនុវត្តនូវបច្ចេកវិទ្យា និងការទំលាប់អនុវត្តក្នុងការបង្ការ និងគ្រប់គ្រងការបំពុល ស្របតាមទំលាប់អនុវត្តល្អជាអន្តរជាតិ ដូចមានឆ្លុះបញ្ចាំងក្នុងបទដ្ឋានដែលមានការទទួលស្គាល់ជាអន្តរជាតិដូចជា *គោលការណ៍ណែនាំពីបរិស្ថាន សុខភាព និង សុវត្ថិភាព*[៧] របស់ធនាគារពិភពលោក។ បទដ្ឋានទាំងនេះមានកំណត់ពីកម្រិត និងវិធានការដែលត្រូវធ្វើ ដែលជាធម្មតាអាចទទួលយកបាន និងអាចអនុវត្តបានចំពោះគម្រោង។ ប្រសិនបើបទបញ្ជារបស់ប្រទេសម្ចាស់ផ្ទះខុសពីកម្រិត និងវិធានការទាំងនេះ អ្នកខ្ចី/អតិថិជននឹងអនុវត្តកម្រិត និងវិធានការណាដែលតឹងរឹងជាង។ ប្រសិនបើកម្រិត ឬវិធានការដែលមិនសូវតឹងរឹង មានភាពសមស្របសម្រាប់គម្រោងជាក់លាក់ណាមួយ អ្នកខ្ចី/អតិថិជន នឹងផ្តល់ហេតុផលពេញលេញលម្អិតក្នុងការជ្រើសរើសជម្រើសដែលបានស្នើឡើងណាមួយ ដែលសមស្របជាមួយលក្ខខណ្ឌតម្រូវដែលមានក្នុងឯកសារនេះ។

### ជ. ការបង្ការការបំពុល ការអភិរក្សធនធាន និង ប្រសិទ្ធផលថាមពល

៣៤. អ្នកខ្ចី/អតិថិជន នឹងបញ្ចៀស ឬ ក្នុងករណីដែលការបញ្ចៀសមិនអាចធ្វើទៅបាន កាត់បន្ថយ ឬគ្រប់គ្រងបរិមាណ ឬបន្ទុកនៃការបញ្ចេញចោលសារជាតិពុល។ ក្រៅពីនេះ អ្នកខ្ចី/អតិថិជន នឹងធ្វើការសិក្សាដាក់បញ្ចូលក្នុងប្រតិបត្តិការរបស់ខ្លួននូវវិធានការ

---

[៧] ធនាគារពិភពលោក. ២០០៧. *គោលការណ៍ណែនាំទូទៅពីបរិស្ថាន សុខភាព និងសុវត្ថិភាព* Washington, DC.

អភិរក្សធនធាន និងប្រសិទ្ធផលថាមពល ស្របតាមគោលការណ៍ផលិតផលមានការបំពុលតិចតួច។ ប្រសិនបើគម្រោងអាចក្លាយជាប្រភពនៃការបញ្ចេញជាតិពុលក្នុងតំបន់ដែលទទួលរងរេចរឹលធ្ងន់ធ្ងររួចស្រាច់ហើយនោះ យុទ្ធសាស្ត្រដែលជួយលើកកម្ពស់បរិយាកាសជុំវិញ (ដូចជាការសិក្សារកមើលតំបន់គម្រោងជំនួស និងការប៉ះប៉ូវការបញ្ចេញជាតិពុល) នឹងត្រូវយកមកប្រើ។

## ខ. កាកសំណល់

៣៥. អ្នកខ្ចី/អតិថិជន នឹងបញ្ចៀស ឬ ក្នុងករណីដែលការបញ្ចៀសមិនអាចធ្វើទៅបាន កាត់បន្ថយ ឬគ្រប់គ្រងការបញ្ចេញកាកសំណល់គ្រោះថ្នាក់ និងមិនគ្រោះថ្នាក់ និងសារធាតុគ្រោះថ្នាក់ដែលកើតចេញពីសកម្មភាពគម្រោង។ ប្រសិនបើកាកសំណល់មិនអាចយកមកប្រើប្រាស់ឡើងវិញបានទេ កាកសំណល់នោះត្រូវទទួលធ្វើប្រព្រឹត្តិកម្ម កំចាត់ចោល និងបំផ្លាញចោលតាមវិធីសាស្ត្រដែលមានសុវត្ថិភាពដល់បរិស្ថាន។ ប្រសិនបើកាកសំណល់ដែលបញ្ចេញចោលជាប្រភេទកាកសំណល់មានគ្រោះថ្នាក់ អតិថិជននឹងសិក្សារកមើលជម្រើសសមស្របផ្សេងទៀតក្នុងការបញ្ចេញកាកសំណល់របស់ខ្លួនឱ្យមានសុវត្ថិភាពដល់បរិស្ថាន ដោយគិតគូរពីការដាក់កម្រិតចំពោះចលនាឆ្លងដែនរបស់កាកសំណល់នោះ[៨]។ ប្រសិនបើការបញ្ចេញកាកសំណល់ធ្វើឡើងដោយតតិយជន អ្នកខ្ចី/អតិថិជន នឹងប្រើប្រាស់អ្នកម៉ៅការដែលជាសហគ្រាសស្របច្បាប់មានកេរ្តិ៍ឈ្មោះ ដែលទទួលបានអាជ្ញាប័ណ្ណពីទីភ្នាក់ងារនិយតកម្មពាក់ព័ន្ធ។

## គ. សារធាតុគ្រោះថ្នាក់

៣៦. អ្នកខ្ចី/អតិថិជន នឹងបញ្ចៀសការផលិត ជួញដូរ និងប្រើប្រាស់សារធាតុ និងវត្ថុធាតុគ្រោះថ្នាក់ដែលត្រូវបានហាមឃាត់ ឬដែលត្រូវបានបញ្ឈប់ការប្រើប្រាស់បន្តិចម្តងៗជាអន្តរជាតិ ដោយសារតែវត្ថុធាតុទាំងនោះមានជាតិពុលខ្ពស់ចំពោះភាវៈរស់មិនងាយបំបែកធាតុដោយធម្មជាតិ អាចបណ្តាលឱ្យមានការបង្ករជីវសាស្ត្រ ឬបំផ្លាញស្រទាប់អូហ្សូន[៩] ហើយនឹងគិតគូរប្រើប្រាស់វត្ថុធាតុដែលមិនសូវមានគ្រោះថ្នាក់ ដើម្បីជំនួសសារធាតុគីមី ឬវត្ថុធាតុគ្រោះថ្នាក់ទាំងនោះ។

## ឃ. ការប្រើបាស់ និង ការគ្រប់គ្រងថ្នាំសម្លាប់សត្វល្អិត

៣៧. ការវាយតម្លៃបរិស្ថាននឹងធានាថា សកម្មភាពគ្រប់គ្រងសត្វល្អិត និង/ឬ វ៉ិកទ័រ ដែលពាក់ព័ន្ធនឹងគម្រោង នឹងប្រើប្រាស់វិធីសាស្ត្រគ្រប់គ្រងសត្វល្អិតចម្រុះ និងមានគោលដៅកាត់បន្ថយការពឹងផ្អែកទៅលើសារធាតុគីមីសម្លាប់សត្វល្អិត នៅក្នុងគម្រោងកសិកម្ម និងសុខភាពសាធារណៈ។ កម្មវិធីគ្រប់គ្រងសត្វល្អិត/វ៉ិកទ័រចម្រុះរបស់អ្នកខ្ចី/អតិថិជន នឹងដាក់បញ្ចូលនូវការប្រើប្រាស់រួមគ្នារវាងពតិមានពីសត្វល្អិត និងបរិស្ថាន និងវិធីសាស្ត្រគ្រប់គ្រងសត្វល្អិត/វ៉ិកទ័រ ដែលរួមមានដូចជា ទម្លាប់អនុវត្តជាប្រពៃណី វិធីសាស្ត្រជីវៈសាស្ត្រ សេនេទិក និង ជម្រើសចុងក្រោម សារធាតុគីមី ដើម្បីបង្ការការខូចខាតធ្ងន់ធ្ងរដោយសារសត្វល្អិតចង្រៃ។

---

[៨] ស្របតាមកម្មវត្ថុនៃអនុសញ្ញាទីក្រុងបាសែលស្តីពីការត្រួតពិនិត្យចលនាដឹកជញ្ជូនសំណល់គ្រោះថ្នាក់ឆ្លងដែន។

[៩] ស្របតាមកម្មវត្ថុនៃអនុសញ្ញាទីក្រុងស្តុកខូមស្តីពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ និងពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន។

ហានិភ័យសុខភាព និងបរិស្ថានដែលជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសត្វល្អិតចង្រៃ ត្រូវកាត់បន្ថយតាមរយៈការទ្រទ្រង់ (តាមការចាំបាច់) ដល់ការកសាងសមត្ថភាពស្ថាប័ន ការជួយគ្រប់គ្រង និងតាមដានការចែកចាយ និងប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងការលើកស្ទួយការប្រើប្រាស់វិធីសាស្ត្រគ្រប់គ្រងសត្វល្អិតចម្រុះ។

៣៨. អ្នកខ្ចី/អតិថិជន នឹងមិនប្រើប្រាស់ផលិតផលដែលស្ថិតនៅក្នុងចំណាត់ថ្នាក់គ្រោះថ្នាក់ Ia (គ្រោះថ្នាក់ខ្លាំងបំផុត) និង Ib (គ្រោះថ្នាក់ខ្លាំង) ឬចំណាត់ថ្នាក់ II (គ្រោះថ្នាក់មធ្យម) នៃការចាត់ចំណាត់ថ្នាក់ជាអនុសាសន៍នៃថ្នាំសម្លាប់របស់អង្គការសុខភាពពិភពលោកឡើយ ប្រសិនបើប្រទេសម្ចាស់ផ្ទះគ្មានការរឹតត្បិតលើការចែកចាយ និងប្រើប្រាស់សារធាតុគីមីទាំងនេះ ឬប្រសិនបើសារធាតុទាំងនេះអាចបង្ករគ្រោះថ្នាក់ដល់បុគ្គលិក ប្រសិនបើគ្មានការបណ្ដុះបណ្ដាល គ្មានសម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសមស្របក្នុងការត្រួតពិនិត្យ រក្សាទុក ប្រើប្រាស់ និងចាត់ចែងផលិតផលទាំងនេះឱ្យបានត្រឹមត្រូវ។ អ្នកខ្ចី/អតិថិជន នឹងធ្វើការត្រួតពិនិត្យ រក្សាទុក ប្រើប្រាស់ និងចាត់ចែងថ្នាំសម្លាប់សត្វល្អិត ស្របតាមទម្លាប់អនុវត្តល្អទទួលស្គាល់ជាអន្តរជាតិ ដូចជា ក្រមសីលធម៌អន្តរជាតិស្ដីពីការចែកចាយ និងការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត របស់អង្គការកសិកម្ម និងស្បៀងអាហារ។

### ង. ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

៣៩. អ្នកខ្ចី/អតិថិជន នឹងលើកកម្ពស់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលកើតចេញពីសកម្មភាពរបស់មនុស្សក្នុងការអនុវត្តគម្រោង ក្នុងកម្រិតមួយដែលសមស្របទៅនឹងលក្ខណៈ និងទំហំនៃការប្រតិបត្តិការគម្រោង និងផលប៉ះពាល់។ នៅអំឡុងពេលអភិវឌ្ឍន៍ ឬប្រតិបត្តិគម្រោងដែលត្រូវបានរំពឹង ឬកំពុងតែបានបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងបរិមាណច្រើនក្រាស់ក្រែល[១០] អ្នកខ្ចី/អតិថិជន នឹងកំណត់បរិមាណនៃការបញ្ចេញឧស្ម័នដោយផ្ទាល់ពីហេដ្ឋារចនាសម្ព័ន្ធក្នុងព្រំដែនរូបវន្តរបស់គម្រោង និងការបញ្ចេញឧស្ម័នដោយប្រយោលដែលពាក់ព័ន្ធនឹងការប្រើប្រាស់ថាមពលដែលផលិតនៅកន្លែងដទៃរបស់គម្រោង។ អ្នកខ្ចី/អតិថិជន នឹងរៀបចំធ្វើការកំណត់បរិមាណ និងតាមដានការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រចាំឆ្នាំ ស្របតាមវិធីសាស្ត្រដែលមានការទទួលស្គាល់ជាអន្តរជាតិ[១១]។ ក្រៅពីនេះ អ្នកខ្ចី/អតិថិជន នឹងធ្វើការវាយតម្លៃលទ្ធភាពបច្ចេកទេស និងហិរញ្ញវត្ថុ និងជម្រើសផលចំណេញ-ការខាតបង់ ដើម្បីកាត់បន្ថយ ឬប៉ះប៉ូវការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់គម្រោង នៅអំឡុងពេលរៀបចំ និងប្រតិបត្តិគម្រោង និងបន្តព្យាយាមស្វែងរកជម្រើស សមស្របផ្សេងទៀត។

---

[១០] បើទោះជាបរិមាណនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់គម្រោងមានកម្រិតខុសប្លែកគ្នារវាងវិស័យឧស្សាហកម្មក៏ដោយ កម្រិតបរិមាណសម្រាប់លក្ខខណ្ឌតម្រូវក្នុងករណីនេះ ត្រូវបានកំណត់ជាទូទៅត្រឹម ១០០,000 តោននៃឧស្ម័នកាបូនិចក្នុងមួយឆ្នាំ សម្រាប់ការបញ្ចេញសរុបពីប្រភពផ្ទាល់ និងមិនផ្ទាល់ដែលពាក់ព័ន្ធនឹងការទិញថាមពលអគ្គិសនីយកមកប្រើប្រាស់។

[១១] វិធីសាស្ត្រប៉ាន់ស្មាន ត្រូវបានផ្ដល់ឱ្យដោយ ក្រុមប្រឹក្សាអន្តររដ្ឋាភិបាលទទួលបន្ទុកការប្រែប្រួលអាកាសធាតុ (IPCC) អង្គការអន្តរជាតិផ្សេងៗ និងទីភ្នាក់ងារពាក់ព័ន្ធរបស់ប្រទេសម្ចាស់ផ្ទះ។

## ១០. សុខភាព និង សុវត្ថិភាព

### ក. សុខភាព និង សុវត្ថិភាពការងារ

៤០. អ្នកខ្ចី/អតិថិជន នឹងផ្ដល់ឱ្យកម្មករ[១២] នូវបរិយាកាសការងារសុវត្ថិភាព និងសុខុមាលភាព ដោយគិតគូរពីហានិភ័យដែលភ្ជាប់នឹងវិស័យជាក់លាក់មួយចំនួន និងប្រភេទនៃគ្រោះថ្នាក់មួយចំនួនដែលមាននៅទីកន្លែងធ្វើការរបស់អ្នកខ្ចី/អតិថិជន ដូចជា គ្រោះ-ថ្នាក់រូបវន្ត គីមី ជីវៈសាស្ត្រ និងគ្រោះថ្នាក់វិទ្យុសកម្ម។ អ្នកខ្ចី/អតិថិជន នឹងចាត់វិធានការនានាដើម្បីបង្ការគ្រោះថ្នាក់ ការរងរបួស និងជំងឺ ដែលកើតចេញពី ឬពាក់ព័ន្ធនឹង ឬដែលកើតមាននៅក្នុងពេលបំពេញការងារ តាមរយៈ (១) កំណត់ និងកាត់បន្ថយ (តាមដែលអាចធ្វើទៅបាន) មូលហេតុបង្កគ្រោះថ្នាក់ចំពោះកម្មករ (២) ផ្ដល់វិធានការបង្ការ និងការពារ ដូចជា ការកែប្រែ ការជំនួស ឬការលុបបំបាត់សារធាតុ ឬស្ថានភាពគ្រោះថ្នាក់ (៣) ផ្ដល់សម្ភារៈសមស្របដើម្បីកាត់បន្ថយហានិភ័យ និងតម្រូវ និងចាប់បង្ខំឱ្យប្រើប្រាស់សម្ភារៈទាំងនោះ (៤) បណ្ដុះបណ្ដាលកម្មករ និងផ្ដល់ឱ្យពួកគេនូវការលើកទឹកចិត្តសមស្របដើម្បីឱ្យពួកគេ ប្រើប្រាស់ និងអនុវត្តតាមនីតិវិធីសុវត្ថិភាព និងសុខភាព និងឧបករណ៍ការពារ (៥) កត់ត្រា និងរាយការណ៍គ្រោះថ្នាក់ ជំងឺ និងឧបទ្ទវហេតុការងារ និង (៦) មានវិធានការឆ្លើយតប ត្រៀមលក្ខណៈ និងវិធានការបង្ការរួចជាស្រេចនៅពេលមានអាសន្ន។

៤១. អ្នកខ្ចី/អតិថិជន នឹងអនុវត្តវិធានការបង្ការ និងការពារដែលអនុលោមតាមទំលាប់អនុវត្តល្អដែលមានការទទួលស្គាល់ជាអន្តរជាតិ ដូចមានឆ្លុះបញ្ចាំងក្នុងបទដ្ឋានដែលមានការទទួលស្គាល់ជាអន្តរជាតិ ដូចជា *គោលការណ៍ណែនាំស្ដីពីបរិស្ថាន សុខភាព និងសុវត្ថិភាព* របស់ធនាគារពិភពលោកជាដើម (លេខយោង ៧)។

### ខ. សុខភាព និង សុវត្ថិភាពសហគមន៍

៤២. អ្នកខ្ចី/អតិថិជន នឹងកំណត់ និងវាយតម្លៃហានិភ័យ (និងផលប៉ះពាល់ដែលអាចមានចំពោះ) សុវត្ថិភាពរបស់សហគមន៍រងផលប៉ះពាល់ នៅអំឡុងពេលរៀបចំ សាងសង់ ប្រតិបត្តិ និងបញ្ចប់គម្រោង ព្រមទាំងចាត់វិធានការបង្ការ និងរៀបចំផែនការដើម្បីដោះស្រាយហានិភ័យទាំងនោះ ក្នុងកម្រិតមួយដែលសមមាត្រទៅនឹងហានិភ័យ និងផលប៉ះពាល់ដែលបានកំណត់។ វិធានការទាំងនេះ នឹងលំអៀងទៅរកការបង្ការ ឬការបញ្ចៀសហានិភ័យ និងផលប៉ះពាល់ ជាងការបន្ធូរបន្ថយ និងការកាត់បន្ថយ។ ភាពអាចទទួលរងគ្រោះថ្នាក់ដោយថៃដន្យ និងដោយធម្មជាតិ ក៏នឹងត្រូវបានគិតគូរពិចារណាផងដែរ ជាពិសេសប្រសិនបើផ្នែកណាមួយនៃរចនាសម្ព័ន្ធរបស់គម្រោងអាចចូលទៅជិតបាន ដោយសមាជិកសហគមន៍រងផលប៉ះពាល់ ឬប្រសិនបើការដួលរលំនៃរចនាសម្ព័ន្ធទាំងនោះអាចបង្ករបួសស្នាមដល់សមាជិកសហគមន៍។ អ្នកខ្ចី/អតិថិជន នឹងបញ្ចៀស ឬកាត់បន្ថយនៃផលប៉ះពាល់ធ្ងន់ធ្ងរដែលបណ្ដាលមកពីគ្រោះធម្មជាតិ ដូចជា ការបាក់ដី ឬទឹកជំនន់ជាដើម ដែលកើតមកពីការប្រែប្រួលការប្រើប្រាស់ដីដោយសារតែសកម្មភាពគម្រោង។

៤៣. អ្នកខ្ចី/អតិថិជន នឹងជូនដំណឹងដល់សហគមន៍រងផលប៉ះពាល់ពីទំហំនៃគ្រោះថ្នាក់ដែលអាចមាន តាមរយៈវិធីសាស្ត្រមួយ

---

[១២] គិតរួមទាំង កម្មករដែលជាមិនមែននិយោជិត ដែលអ្នកខ្ចី/អតិថិជនបានជួលតាមរយៈអ្នកម៉ៅការ ឬអន្តរការីផ្សេងទៀត ឱ្យធ្វើការនៅក្នុងការដ្ឋានគម្រោង ឬធ្វើការងារដែលពាក់ព័ន្ធដោយផ្ទាល់នឹងមុខងារចំបងរបស់គម្រោង។

ដែលសមស្របនឹងវប្បធម៌របស់ពួកគេ។ អ្នកខ្ចី/អតិថិជន នឹងត្រៀមលក្ខណៈក្នុងការឆ្លើយតបនឹងស្ថានភាពដែលកើតដោយថៃដន្យ និងស្ថានភាពបន្ទាន់នានា។ ការត្រៀមលក្ខណៈនេះ រួមមានឯកសាររៀបចំផែនការឆ្លើយតបដែលមានកំណត់ពីការបណ្តុះបណ្តាលធនធាន ការទទួលខុសត្រូវ ការទំនាក់ទំនង នីតិវិធី និងបញ្ហាផ្សេងៗទៀតដែលចាំបាច់ក្នុងការឆ្លើយតបឱ្យមានប្រសិទ្ធភាពចំពោះគ្រោះបន្ទាន់ដែលពាក់ព័ន្ធនឹងគម្រោង។ ព័ត៌មានសមស្របពីការត្រៀមលក្ខណៈរួចជាស្រេចចំពោះគ្រោះអាសន្ន និងសកម្មភាពឆ្លើយតបធនធាន និងការទទួលខុសត្រូវ នឹងត្រូវផ្សព្វផ្សាយប្រាប់ដល់សហគមន៍រងផលប៉ះពាល់។

៤៤. ប្រសិនបើផ្នែក ឬសមាសភាគណាមួយនៃហេដ្ឋារចនាសម្ព័ន្ធ ដូចជា ទំនប់ ទំនប់កាកសំណល់រ៉ែ ឬបឹងសំណល់ផេះ មានទីតាំងស្ថិតនៅតំបន់មានហានិភ័យខ្ពស់ ហើយប្រសិនបើការដួលរលំ ឬការដំណើរការខុសប្រក្រតីនៃហេដ្ឋារចនាសម្ព័ន្ធទាំងនេះ អាចនឹងគំរាមកំហែងដល់សុវត្ថិភាពរបស់សហគមន៍ អ្នកខ្ចី/អតិថិជន នឹងជួលអ្នកជំនាញដែលមានគុណវុឌ្ឍិ និងមានបទពិសោធន៍ និងជាបុគ្គលដែលមិនជាប់ពាក់ព័ន្ធនឹងអ្នកជំនាញដែលទទួលខុសត្រូវរៀបចំ និងសាងសង់គម្រោង ឱ្យធ្វើការពិនិត្យវាយតម្លៃនៅដើមដំបូងបំផុត (ប្រសិនបើអាចធ្វើទៅបាន) នៃការអភិវឌ្ឍន៍គម្រោង និងក្នុងការរៀបចំ សាងសង់ និងដំណើរគម្រោង។

### ១១. ធនធានវប្បធម៌រូបវន្ត

៤៥. អ្នកខ្ចី/អតិថិជន ជាអ្នកទទួលខុសត្រូវក្នុងការកំណត់ទីតាំង និងរៀបចំគម្រោង ដើម្បីបញ្ចៀសការខូចខាតដល់ធនធានវប្បធម៌រូបវន្ត[១៣]។ ធនធានដែលអាចនឹងរងផលប៉ះពាល់ពីគម្រោង នឹងត្រូវកំណត់អត្តសញ្ញាណ ហើយអ្នកជំនាញដែលមានគុណវុឌ្ឍិ និងមានបទពិសោធន៍ នឹងវាយតម្លៃពីផលប៉ះពាល់ដែលមានចំពោះធនធានទាំងនោះ តាមរយៈការចុះអង្កេតនៅមូលដ្ឋាន ដែលដំណើរការនេះជាផ្នែកសំខាន់មួយនៃដំណើរការវាយតម្លៃបរិស្ថានដែលបានចែងក្នុងកថាខណ្ឌ ៤-១០។

៤៦. ប្រសិនបើគម្រោងអាចបង្កឱ្យមានផលប៉ះពាល់ដល់ធនធានវប្បធម៌រូបវន្ត អ្នកខ្ចី/អតិថិជន នឹងពិគ្រោះយោបល់ជាមួយសហគមន៍រងផលប៉ះពាល់ដែលប្រើប្រាស់ (ឬធ្លាប់ប្រើប្រាស់ធនធានទាំងនោះតាមការចងចាំរបស់ពួកគេ) ក្នុងគោលបំណងវប្បធម៌អស់រយៈពេលជាយូរមកហើយ ដើម្បីកំណត់អត្តសញ្ញាណធនធានវប្បធម៌រូបវន្តដែលមានសារៈសំខាន់ និងដើម្បីបញ្ចូលគំនិតយោបល់របស់សហគមន៍រងផលប៉ះពាល់អំពីធនធានទាំងនេះ ទៅក្នុងដំណើរការសម្រេចចិត្តរបស់អ្នកខ្ចី/អតិថិជន។ ការពិគ្រោះយោបល់នេះក៏នឹងមានការចូលរួមផងដែរពីសំណាក់ទីភ្នាក់ងារនិយតកម្មថ្នាក់តំបន់ និងថ្នាក់ជាតិដែលទទួលបន្ទុកការពារធនធានវប្បធម៌រូបវន្ត។ លទ្ធផលនឹងត្រូវផ្សព្វផ្សាយក្នុងផ្នែកមួយ (និងក្នុងទម្រង់ដូចគ្នា) នៃរបាយការណ៍វាយតម្លៃបរិស្ថាន លើកលែងតែក្នុងករណីដែលការផ្សព្វផ្សាយនោះធ្វើឱ្យប៉ះពាល់ ឬអន្តរាយដល់សុវត្ថិភាព ឬបូរណភាពនៃធនធានវប្បធម៌រូបវន្ត។

៤៧. ប្រសិនបើគម្រោងអាចមានផលប៉ះពាល់អវិជ្ជមានចំពោះធនធានវប្បធម៌រូបវន្ត អ្នកខ្ចី/អតិថិជន នឹងចាត់វិធានការសមស្រប

[១៣] សំដៅលើចលន និងអចលនវត្ថុ ទីកន្លែង សំណង់ បណ្តុំសំណង់ តំបន់មានលក្ខណៈពិសេស និងតំបន់ទេសភាពធម្មជាតិ ដែលមានសារៈសំខាន់ខាងបុរាណវត្ថុវិទ្យា ហ្វូស៊ីលវិទ្យា ប្រវត្តិសាស្ត្រ ស្ថាបត្យកម្ម សាសនា សោភ័ណភាព ឬដែលមានសារៈសំខាន់ផ្នែកវប្បធម៌ផ្សេងទៀត។ ធនធានវប្បធម៌រូបវន្ត អាចមានទីតាំងស្ថិតនៅតំបន់ទីក្រុង ឬជនបទ និងអាចស្ថិតនៅលើ ឬនៅក្រោមដី ឬនៅក្រោមទឹក។ អត្ថប្រយោជន៍ខាងវប្បធម៌របស់ធនធាននេះ អាចស្ថិតក្នុងកម្រិតតំបន់ ខេត្ត-ក្រុង ជាតិ ឬអន្តរជាតិ។

ដើម្បីបញ្ចៀស ឬកាត់បន្ថយផលប៉ះពាល់ទាំងនោះ ដែលនេះជាផ្នែកមួយនៃដំណើរការរៀបចំផែនការបរិស្ថានដូចមានចែងក្នុងកថា-ខណ្ឌ ១២-១៦។ វិធានការទាំងនេះ មានចាប់ពីការបញ្ចៀស រហូតដល់ការការពារតំបន់ទាំងមូល រហូតដល់ការកាត់បន្ថយជម្រើស រួមទាំងការសង្គ្រោះ និងការកត់ត្រាទុកជាឯកសារ ក្នុងករណីដែលផ្នែកណាមួយ ឬផ្នែកទាំងស្រុងនៃធនធានវប្បធម៌រូបវន្តអាចនឹងត្រូវបាត់បង់។

៤៨. ប្រសិនបើទីតាំងគម្រោងដែលបានស្នើសុំស្ថិតនៅក្នុងតំបន់ដែលគេរំពឹងថាអាចមានធនធានវប្បធម៌រូបវន្ត ដែលកំណត់បាននៅក្នុងដំណើរការវាយតម្លៃបរិស្ថាន នីតិវិធីរកឃើញចៃដន្យនឹងមានបញ្ចូលក្នុង EMP ។ ការរកឃើញចៃដន្យ នឹងមិនត្រូវបានកែប្រែឡើយ រហូតទាល់តែមានការវាយតម្លៃដោយអ្នកឯកទេសដែលមានសមត្ថភាព និងកំណត់បាននូវសកម្មភាពដែលស្របគ្នានឹងលក្ខខណ្ឌតម្រូវទាំងនេះ។

៤៩. គម្រោងនឹងមិនរុះរើធនធានវប្បធម៌រូបវន្តណាមួយឡើយ លើកលែងតែក្នុងករណីបំពេញបានតាមលក្ខខណ្ឌដូចខាងក្រោម ៖

(i) គ្មានជម្រើសផ្សេងក្រៅពីការរុះរើ។

(ii) អត្ថប្រយោជន៍របស់គម្រោងមានទំហំធំធេង ជាងការបាត់បង់បេតិកភណ្ឌធម្មជាតិដែលបានរំពឹងទុកដោយសារតែការរុះរើ។

(iii) ការរុះរើត្រូវបានធ្វើឡើងស្របតាមបទបញ្ញត្តិនៃច្បាប់ និង/ឬ បទបញ្ជាថ្នាក់តំបន់ និង/ឬ ថ្នាក់ជាតិ និងផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងកាតព្វកិច្ចរបស់រដ្ឋក្រោមច្បាប់អន្តរជាតិ និងប្រើប្រាស់នូវបច្ចេកទេសប្រសើរបំផុតដែលមាន។

# គ្រោងនៃរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន

គ្រោងនេះជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវសម្រាប់ការពារ ១។ របាយការណ៍វាយតម្លៃបរិស្ថានត្រូវតែមានជាចាំបាច់ចំពោះគម្រោងបរិស្ថានប្រភេទ A និង B។ កម្រិតនៃភាពលម្អិត និងទូលំទូលាយនៃរបាយការណ៍នេះ ត្រូវតែសមមាត្រជាមួយនឹងទំហំនៃផលប៉ះពាល់បរិស្ថាន និងហានិភ័យដែលអាចមាន។ របាយការណ៍ EIA សាមញ្ញមួយ ត្រូវមានសមាសធាតុសំខាន់ៗដូចខាងក្រោម ចំណែក IEE អាចនឹងមានវិសាលភាពតូចជាង អាស្រ័យទៅលើលក្ខណៈគម្រោង។ ចំណុចសំខាន់ៗនៃគ្រោងនេះ នឹងជួយផ្ដល់ជាមគ្គុទេសក៍ក្នុងការរៀបចំរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន តែមិនតម្រូវថាចាំបាច់ត្រូវតែធ្វើតាមលំដាប់ដែលបានបង្ហាញជូននេះទេ។

## ក. សង្ខេបប្រតិបត្តិ

ផ្នែកនេះរៀបរាប់យ៉ាងជាក់ច្បាស់ពីដំណើររឿងពិតចំបងៗ លទ្ធផលសំខាន់ៗ និងសកម្មភាពជាអនុសាសន៍។

## ខ. ក្របខណ្ឌគោលនយោបាយ ច្បាប់ និង រដ្ឋបាល

ផ្នែកនេះពិភាក្សាពីក្របខណ្ឌច្បាប់ថ្នាក់ជាតិ និងថ្នាក់តំបន់ និងក្របខណ្ឌស្ថាប័នដែលត្រូវគោរពតាមនៅពេលធ្វើការវាយតម្លៃបរិស្ថាន។ ផ្នែកនេះ ក៏កំណត់ផងដែរនូវកិច្ចព្រមព្រៀងបរិស្ថានអន្តរជាតិដែលពាក់ព័ន្ធនឹងគម្រោង និងដែលមានប្រទេសម្ចាស់ផ្ទះជាភាគី។

## គ. ការពិពណ៌នាពីគម្រោង

ផ្នែកនេះរៀបរាប់ពីគម្រោងដែលបានស្នើសុំ សមាសភាគចំបងៗរបស់គម្រោង និងបរិបទភូមិសាស្ត្រ អេកូឡូស៊ី សង្គម និងបណ្ដោះអាសន្នរបស់គម្រោង រួមទាំង ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធដែលចាំបាច់សម្រាប់គម្រោង (ឧ. ផ្លូវចេញ-ចូល រោងចក្រអគ្គិសនី ប្រព័ន្ធផ្គត់ផ្គង់ទឹក កន្លែងយកថ្ម និងរណ្ដៅដីក និងកន្លែងចាក់ចោលកាកសំណល់)។ ជាធម្មតា មានការគូសផែនទីបង្ហាញប្លង់ និងសមាសភាគគម្រោង ទីតាំងគម្រោង និងតំបន់រងការប៉ះពាល់ពីគម្រោង។

## ឃ. ការពិពណ៌នាពីបរិស្ថាន (ទិន្នន័យគោល)

ផ្នែកនេះរៀបរាប់ពីស្ថានភាពរូបវន្ត ជីវៈសាស្ត្រ និងសង្គម-សេដ្ឋកិច្ចពាក់ព័ន្ធនៅក្នុងតំបន់សិក្សា។ ផ្នែកនេះ ក៏នឹងពិនិត្យមើលពីសកម្មអភិវឌ្ឍន៍នៅពេលបច្ចុប្បន្ន និងសកម្មភាពអភិវឌ្ឍន៍ដែលបានស្នើសុំ នៅក្នុងតំបន់រងការប៉ះពាល់ពីគម្រោង រួមទាំងសកម្មភាពដែលមិនពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងគម្រោងផង។ ផ្នែកនេះ នឹងចង្អុលបង្ហាញពីភាពត្រឹមត្រូវ ភាពអាចជឿជាក់បាន និងប្រភពរបស់ទិន្នន័យ។

## ង. ផលប៉ះពាល់បរិស្ថានព្យាករណ៍ និង វិធានការកាត់បន្ថយផលប៉ះពាល់

ផ្នែកនេះ ធ្វើការព្យាករ និងវាយតម្លៃពីផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន ដោយផ្ទាល់ និងដោយប្រយោល ដែលអាចកើតមានចំពោះធនធានរូបវន្ត ជីវៈសាស្ត្រ សង្គម-សេដ្ឋកិច្ច (រួមទាំង សុខភាព និងសុវត្ថិភាពការងារ សុខភាព និងសុវត្ថិភាពសហគមន៍ ក្រុមងាយរងគ្រោះ និងបញ្ហាយេនឌ័រ និងផលប៉ះពាល់ចំពោះជីវភាពរស់ដែលពឹងផ្អែកលើបរិស្ថាន) [កថាខណ្ឌ ៦ ឧបសម្ព័ន្ធ ២] និងធនធានវប្បធម៌រូបវន្តនៅក្នុងតំបន់រងការប៉ះពាល់ពីគម្រោង តាមវិធីសាស្ត្រវិភាគតាមបែបបរិមាណ។ កំណត់វិធានការកាត់បន្ថយផលប៉ះពាល់ និងផលប៉ះពាល់អវិជ្ជមានសេសសល់ដែលមិនអាចកាត់បន្ថយបាន។ ស្វែងរកមើលឱកាសពង្រឹងលើកស្ទួយ។ កំណត់ និងព្យាករទំហំ និងគុណភាពនៃទិន្នន័យដែលមាន គម្លាតទិន្នន័យគន្លឹះ និងភាពមិនប្រាកដប្រជាដែលពាក់ព័ន្ធនឹងការព្យាករណ៍ និងប្រធានបទជាក់លាក់មួយចំនួនដែលមិនចាំបាច់ពិនិត្យសិក្សាឡើងវិញ។ និងធ្វើការសិក្សាផលប៉ះពាល់ជាសកល ឆ្លងដែន និងផលប៉ះពាល់បង្ករដែលអាចមាន។

## ច. ការវិភាគពីជម្រើសផ្សេងទៀត

ផ្នែកនេះ ធ្វើការសិក្សាពីជម្រើសផ្សេងទៀតដែលអាចយកមកប្រើជំនួសដូចជា ទីតាំងគម្រោង បច្ចេកវិទ្យា ការរៀបចំប្លង់ និងប្រតិបត្តិការដែលបានស្នើសុំ (រួមទាំង ជម្រើស "គ្មានជម្រើសផ្សេងទៀត" ផង) ដោយធ្វើការពិចារណាពីផលប៉ះពាល់ដែលជម្រើសទាំងនោះអាចមានចំពោះបរិស្ថាន។ លទ្ធភាពកាត់បន្ថយផលប៉ះពាល់របស់ជម្រើសទាំងនោះ។ ចំណាយមូលធន និងចំណាយប្រចាំលើជម្រើសទាំងនោះ។ និរន្តរភាពនៃជម្រើសទាំងនោះក្រោមលក្ខខណ្ឌតំបន់។ និងលក្ខខណ្ឌតម្រូវស្ថាប័ន បណ្តុះបណ្តាល និងតាមដានរបស់ជម្រើសទាំងនោះ។ ផ្នែកនេះ ក៏នឹងកំណត់ពីមូលដ្ឋានក្នុងការជ្រើសរើសប្លង់រចនាគម្រោងជាក់លាក់ណាមួយ និងផ្តល់មូលហេតុ នៃការសម្រេចជ្រើសរើសយកវិធីសាស្ត្រ និងកម្រិតបញ្ចេញជាតិពុលជាអនុសាសន៍ ក្នុងការបង្ការ និងការកាត់បន្ថយសារធាតុពុល។

## ឆ. ការផ្តល់ព័ត៌មាន ការពិគ្រោះយោបល់ និង ការចូលរួម

ផ្នែកនេះ នឹង:

(i) រៀបរាប់ពីដំណើរការដែលត្រូវធ្វើនៅពេលរៀបចំគម្រោង និងការត្រៀមលក្ខណៈក្នុងការជួបជាមួយអ្នកពាក់ព័ន្ធ គិតបញ្ចូលទាំងការផ្តល់ព័ត៌មាន និងការពិគ្រោះយោបល់ជាមួយក្រុមមនុស្សរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធផ្សេងទៀត។

(ii) សង្ខេបគំនិតយោបល់ និងក្តីបារម្ភដែលទទួលបានពីក្រុមមនុស្សរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធផ្សេងទៀត និងរបៀបដែលគំនិតយោបល់ទាំងនេះត្រូវបានយកមកដោះស្រាយនៅក្នុងការរៀបចំគម្រោង និងវិធានការកាត់បន្ថយផលប៉ះពាល់ ដោយផ្តល់ការចាប់អារម្មណ៍ជាពិសេសចំពោះតម្រូវការ និងក្តីបារម្ភរបស់ ក្រុមងាយរងគ្រោះ ដូចជាស្ត្រី អ្នកក្រីក្រ និងក្រុមជនជាតិភាគតិច។ និង

(iii) រៀបរាប់ពីវិធានការផ្តល់ព័ត៌មានដែលបានគ្រោងទុក (រួមមានដូចជា ប្រភេទព័ត៌មានដែលត្រូវផ្សព្វផ្សាយ និងវិធីសាស្ត្រផ្សព្វផ្សាយ) និងដំណើរការក្នុងការធ្វើការពិគ្រោះយោបល់ជាមួយក្រុមមនុស្សរងផលប៉ះពាល់ និងការជួយ សម្របសម្រួលដល់ការចូលរួមរបស់ពួកគាត់នៅអំឡុងពេលអនុវត្តគម្រោង។

## ជ. យន្តការដោះស្រាយបណ្តឹងតវ៉ា

ផ្នែកនេះ រៀបរាប់ពីប្រព័ន្ធដោះស្រាយបណ្តឹងតវ៉ា (ទាំងផ្លូវការ និងមិនផ្លូវការ) កំណត់នូវរយៈពេល និងយន្តការដោះស្រាយពាក្យបណ្តឹងអំពីស្ថានភាពបរិស្ថាន។

## ឈ. ផែនការគ្រប់គ្រងបរិស្ថាន

ផ្នែកនេះ ចែងពីបណ្តុំវិធានកាត់បន្ថយ និងគ្រប់គ្រងដែលត្រូវអនុវត្តតាមនៅអំឡុងពេលអនុវត្តគម្រោង ដើម្បីបញ្ចៀសបន្ទូរបន្ថយ កាត់បន្ថយ ឬទូទាត់សងវិញនូវផលប៉ះពាល់អវិជ្ជមានចំពោះបរិស្ថាន (តាមលំដាប់អាទិភាពនេះ)។ វិធានការនេះ អាចជាពហុផែនការគ្រប់គ្រង និងសកម្មភាព។ ផែនការនេះ មាននូវសមាសធាតុសំខាន់ៗដូចខាងក្រោម (ដែលកម្រិតនៃភាពលម្អិតរបស់ផែនការត្រូវសមមាត្រនឹងទំហំនៃផលប៉ះពាល់ និងហានិភ័យរបស់គម្រោង)។

(i) ការកាត់បន្ថយ :

(ក) កំណត់ និងសង្ខេបផលប៉ះពាល់អវិជ្ជមាន និងហានិភ័យដែលរំពឹងថានឹងកើតមានចំពោះបរិស្ថាន។

(ខ) រៀបរាប់ពីវិធានការកាត់បន្ថយនីមួយៗ ដោយលម្អិតពីផ្នែកបច្ចេកទេស រួមទាំង ប្រភេទនៃផលប៉ះពាល់ដែលជាប់ពាក់ព័ន្ធនឹងវិធានការនោះ និងលក្ខខណ្ឌដែលតម្រូវឱ្យមានវិធានការនោះ (ឧ. ជានិរន្តរ៍ ឬក្នុងករណីកើតមានជាយថាហេតុ) ព្រមទាំងការរៀបចំប្លង់ ប្រភេទឧបករណ៍សម្ភារៈ និងនីតិវិធីប្រតិបត្តិ ប្រសិន បើមាន។ និង

(គ) ធ្វើការតភ្ជាប់ជាមួយនឹងផែនការកាត់បន្ថយផលប៉ះពាល់ផ្សេងទៀត (ឧ. ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ក្រុមជនជាតិដើមភាគតិច និងការឆ្លើយតបក្នុងគ្រាមានអាសន្ន) ដែលចាំបាច់សម្រាប់គម្រោង។

(ii) ការតាមដាន :

(ក) រៀបរាប់ពីវិធានការតាមដាន ដោយធ្វើការលម្អិតពីផ្នែកបច្ចេកទេស រួមទាំង ប៉ារ៉ាម៉ែត្រដែលត្រូវតាមដាន វិធីសាស្ត្រដែលត្រូវប្រើ ទីតាំងយកភាគសំណាក ភាពញឹកញាប់ក្នុងការតាមដាន កម្រិតនៃការរកឃើញ និងកំណត់កម្រិតនៃការចាប់ផ្តើមប្រែប្រួល ដែលជាការផ្តល់សញ្ញាឱ្យចាប់ផ្តើមធ្វើសកម្មភាពកែតម្រូវ។

(ខ) រៀបរាប់ពីដំណើរការតាមដាន និងរាយការណ៍ ដើម្បីធានានូវការឆាប់បានដឹងពីស្ថានភាពដែលតម្រូវឱ្យចាត់វិធានការកាត់បន្ថយជាក់លាក់ណាមួយ និងកត់ត្រាទុកជាឯកសារនូវដំណើរការវិវត្ត និងលទ្ធផលនៃការកាត់បន្ថយ ។

(iii) ការរៀបចំការអនុវត្ត :

(ក) កំណត់កម្មវិធីអនុវត្តដោយមានបង្ហាញពីការចែកជាដំណាក់កាល និងភាពស្របគ្នាជាមួយនឹងការអនុវត្តគម្រោងទាំងមូល ។

(ខ) រៀបរាប់ពីការរៀបចំស្ថាប័ន ឬអង្គការ ពោលគឺ អ្នកទទួលខុសត្រូវអនុវត្តវិធានការកាត់បន្ថយ និងតាមដាន ដែលនឹងអាចមានការដាក់បញ្ចូលប្រធានបទបន្ថែមមួយ ឬច្រើនដូចខាងក្រោម ដើម្បីពង្រឹងលទ្ធភាពគ្រប់គ្រងបរិស្ថាន : កម្មវិធីជំនួយបច្ចេកទេស កម្មវិធីបណ្តុះបណ្តាល លទ្ធកម្មឧបករណ៍សម្ភារៈ និងការផ្គត់ផ្គង់ដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងតាមដានបរិស្ថាន និងការកែប្រែអង្គការ ។ និង

(គ) ព្យាករណ៍ចំណាយមូលធន និងចំណាយប្រចាំ និងរៀបរាប់ពីប្រភពមូលនិធិសម្រាប់ការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ។

(iv) សូចនាករលទ្ធផល : រៀបរាប់ពីលទ្ធផលរំពឹងទុកជាព្រឹត្តិការណ៍ដែលអាចវាយតម្លៃបានឱ្យអស់ពីលទ្ធភាពដែលអាចធ្វើទៅបាន ដូចជាសូចនាករលទ្ធផល គោលដៅ និងលក្ខណៈវិនិច្ឆ័យទទួលយក ដែលអាចតាមដានបានក្នុងអំឡុងពេលកំណត់ជាក់លាក់មួយ ។

## ៧. សេចក្តីសន្និដ្ឋាន និង អនុសាសន៍

ផ្នែកនេះ ធ្វើការសន្និដ្ឋានដែលបានមកពីការវាយតម្លៃ និងផ្តល់នូវអនុសាសន៍នានា ។

# លក្ខខណ្ឌតម្រូវសម្រាប់ការពារ ២ : ការតាំងលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត

## ក. សេចក្តីផ្តើម

១. បទពិសោធន៍របស់ ADB បង្ហាញថា ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តដោយសារគម្រោងអភិវឌ្ឍន៍ (ប្រសិនបើគ្មានការកាត់បន្ថយ) អាចនឹងបង្កឱ្យមានហានិភ័យសេដ្ឋកិច្ច សង្គម និងបរិស្ថានធ្ងន់ធ្ងរ : ប្រព័ន្ធផលិតកម្មត្រូវកាត់ផ្តាច់ ប្រជាជនត្រូវប្រឈមមុខ នឹងការធ្លាក់ខ្លួនក្រនៅពេលដែលទ្រព្យផលិតកម្ម ឬប្រភពចំណូលរបស់ពួកគាត់ត្រូវបាត់បង់ ប្រជាជនត្រូវផ្លាស់ទីលំនៅទៅរស់នៅក្នុងបរិស្ថានមួយដែលមិនត្រូវនឹងជំនាញផលិតកម្មរបស់ពួកគាត់ និងមានការប្រកួតប្រជែងដើម្បីធនធានកាន់តែខ្លាំងឡើង ស្ថាប័នសហគមន៍ និងបណ្តាញសង្គមចុះទន់ខ្សោយ សាច់ញាតិត្រូវបែកខ្ញែក ហើយអត្តសញ្ញាណវប្បធម៌ ការគ្រប់គ្រងបែបប្រពៃណី និងការចេះជួយគ្នាទៅវិញទៅមក ត្រូវកាត់បន្ថយ ឬបាត់បង់។ ហេតុនេះ ADB ព្យាយាមបញ្ចៀសការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តប្រសិនបើអាចធ្វើទៅបាន កាត់បន្ថយការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តតាមរយៈការសិក្សារកមើលជម្រើសគម្រោង និងការរៀបចំប្លង់ផ្សេងទៀត លើកស្ទួយ (ឬយ៉ាងហោចណាស់ស្តារ) ការចិញ្ចឹមជីវិតរបស់មនុស្សដែលត្រូវផ្លាស់ទីលំនៅឱ្យបានក្នុងកម្រិតមួយប្រហាក់ប្រហែលនឹងកម្រិតនៅមុនពេលមានគម្រោងអភិវឌ្ឍន៍ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ជនក្រីក្ររងផលប៉ះពាល់ និងក្រុមងាយរងគ្រោះ ផ្សេងទៀត។

២. លក្ខខណ្ឌតម្រូវសម្រាប់ការពារ ២ កំណត់ពីលក្ខខណ្ឌតម្រូវដែលអ្នកខ្ចី/អតិថិជនត្រូវបំពេញ ដើម្បីផ្តល់នូវការការពារក្នុងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ចំពោះគម្រោងដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ លក្ខខណ្ឌតម្រូវនេះពិភាក្សាពីកម្មវត្ថុ ទំហំនៃការអនុវត្ត និងគូសបញ្ជាក់ពីលក្ខខណ្ឌតម្រូវក្នុងដំណើរការវាយតម្លៃផលប៉ះពាល់សង្គម និងការរៀបចំផែនការតាំង ទីលំនៅជាថ្មី ការរៀបចំរបាយការណ៍វាយតម្លៃផលប៉ះពាល់សង្គម និងឯកសាររៀបចំផែនការតាំងទីលំនៅជាថ្មី សិក្សាពីការចរចាធ្វើលទ្ធកម្មដី ការផ្សព្វផ្សាយព័ត៌មាន និងការពិគ្រោះយោបល់ ការបង្កើតយន្តការដោះស្រាយបណ្តឹងតវ៉ា និងការតាមដាន និងការរាយការណ៍ពីការតាំងទីលំនៅជាថ្មី។

## ខ. កម្មវត្ថុ

៣. កម្មវត្ថុគឺព្យាយាមបញ្ចៀសការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តប្រសិនបើអាចធ្វើទៅបាន កាត់បន្ថយការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តតាមរយៈការសិក្សារកមើលជម្រើសគម្រោង និងប្លង់រចនាផ្សេងទៀត លើកស្ទួយ (ឬយ៉ាងហោចណាស់ស្តារ) ការចិញ្ចឹមជីវិតរបស់ក្រុមមនុស្សដែលត្រូវផ្លាស់ទីលំនៅ[១] ឱ្យបានក្នុងកម្រិតមួយប្រហាក់ប្រហែលនឹងកម្រិត នៅមុនពេលមានគម្រោងអភិវឌ្ឍន៍ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ជនក្រីក្រដែលត្រូវផ្លាស់ទីលំនៅ និងក្រុមងាយរងគ្រោះផ្សេងទៀត។

---

[១] ក្នុងបរិបទនៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត អ្នកបាត់បង់លំនៅដ្ឋាន សំដៅលើអ្នកដែលត្រូវផ្លាស់ទីលំនៅរូបវន្ត (ប្តូរទីតាំង បាត់បង់ដីលំនៅដ្ឋាន ឬបាត់បង់ទីជំរក) និង/ឬ ផ្លាស់ទីលំនៅសេដ្ឋកិច្ច (បាត់បង់ដីធ្លី ទ្រព្យសកម្ម សិទ្ធិចេញ-ចូលទៅទ្រព្យសកម្ម ប្រភពចំណូល និង

## គ. ទំហំនៃការអនុវត្ត

៤. លក្ខខណ្ឌទាំងនេះ អនុវត្តចំពោះរាល់គ្រប់គម្រោងដែលផ្តល់ហិរញ្ញប្បទានដោយ ADB និង/ឬ គម្រោងដែលស្ថិត និងមិនស្ថិតនៅ ក្រោមការគ្រប់គ្រងរដ្ឋបាលដោយ ADB រួមទាំងសមាសភាគគម្រោងទាំងនោះផង ដោយមិនគិតពីប្រភពនៃហិរញ្ញប្បទាន ព្រមទាំងគម្រោងវិនិយោគដែលផ្តល់ហិរញ្ញប្បទានដោយប្រាក់កម្ចី និង/ឬ ជំនួយឥតសំណង និង/ឬ ដោយវិធីសាស្ត្រផ្សេងទៀត ដូចជា ការវិនិយោគភាគហ៊ុន និង/ឬ ការធានា (ហៅកាត់ជារួមថាគម្រោង)។ លក្ខខណ្ឌតម្រូវនេះ ក៏គ្របដណ្តប់ផងដែរទៅលើសកម្មភាពតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តដែលធ្វើឡើងដោយអ្នកខ្ចី/អតិថិជន នៅអំឡុងពេលរង់ចាំការគាំទ្រពី ADB ។

៥. លក្ខខណ្ឌតម្រូវក្នុងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត អនុវត្តចំពោះការផ្លាស់ទីលំនៅរូបវន្តទាំងស្រុង ឬមួយផ្នែក អចិន្ត្រៃយ៍ ឬបណ្តោះអាសន្ន (ប្តូរទីតាំង បាត់បង់ដីលំនៅដ្ឋាន ឬបាត់បង់ទីជំរក) និង/ឬ ផ្លាស់ទីលំនៅសេដ្ឋកិច្ច (បាត់បង់ដីធ្លី ទ្រព្យសកម្ម សិទ្ធិចេញ-ចូលទៅទ្រព្យសកម្ម ប្រភពចំណូល និងមធ្យោបាយចិញ្ចឹមជីវិត) ដោយសារតែ (១) លទ្ធកម្មដីដោយមិនស្ម័គ្រចិត្ត ឬ (២) ការកំណត់ដោយមិនស្ម័គ្រចិត្តលើការប្រើប្រាស់ដី ឬសិទ្ធិចេញ-ចូលទៅកាន់ឧទ្យានជាតិ និងតំបន់ការពារធម្មជាតិដែលកំណត់ដោយច្បាប់។ ការតាំងទីលំនៅជាថ្មី ត្រូវចាត់ទុកជាការធ្វើឡើងដោយមិនស្ម័គ្រចិត្ត ប្រសិនបើបុគ្គល ឬសហគមន៍ដែលត្រូវផ្លាស់ទីលំនៅ មិនមានសិទ្ធិបដិសេធចំពោះការធ្វើលទ្ធកម្មដីដែលបណ្តាលឱ្យមានការផ្លាស់ទីលំនៅ។ ករណីនេះកើតមាននៅពេលដែល (១) ដីត្រូវបានធ្វើលទ្ធកម្មតាមរយៈអស្សាមិករណ៍ ដោយសំអាងលើសិទ្ធិរបស់រដ្ឋាភិបាលក្នុងការយកទ្រព្យឯកជនមកបម្រើផលប្រយោជន៍សាធារណៈ និង (២) ដីត្រូវបានធ្វើលទ្ធកម្មតាមរយៈការចរចាដោះស្រាយ ក្នុងករណីដែលដំណើរការអស្សាមិករណ៍អាចនឹងត្រូវយកមកអនុវត្ត នៅក្រោយការបរាជ័យនៃការចរចា។

៦. ប្រសិនផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានចំពោះសេដ្ឋកិច្ច សង្គម និងបរិស្ថាន ដោយសារសកម្មភាពគម្រោង ក្រៅពីលទ្ធកម្មដី (រួមទាំង ការកណត់ដោយមិនស្ម័គ្រចិត្តលើការប្រើប្រាស់ដី ឬសិទ្ធិចេញ-ចូលទៅកាន់ឧទ្យានជាតិ និងតំបន់ការពារធម្មជាតិដែលកំណត់ដោយច្បាប់) ត្រូវបានកំណត់ ដូចជា ការបាត់បង់សិទ្ធិចេញ-ចូលទៅកាន់ទ្រព្យសកម្ម ឬធនធាន ឬការកំណត់លើការប្រើប្រាស់ដី ផលប៉ះពាល់ទាំងនេះនឹងត្រូវបញ្ចៀស (ឬយ៉ាងហោចណាស់ បន្ធូរបន្ថយ កាត់បន្ថយ ឬទូទាត់សង) តាមរយៈដំណើរការវាយតម្លៃបរិស្ថាន។ ប្រសិនបើផលប៉ះពាល់ទាំងនេះត្រូវបានរកឃើញថាមានឥទ្ធិពលអវិជ្ជមានធ្ងន់ធ្ងរនៅដំណាក់កាលណាមួយនៃគម្រោង អ្នកខ្ចី/អតិថិជន ត្រូវតែរៀបចំ និងអនុវត្តផែនការគ្រប់គ្រង ដើម្បីស្តារមធ្យោបាយចិញ្ចឹមជីវិតរបស់ក្រុមមនុស្សរងផលប៉ះពាល់ឱ្យបានយ៉ាងហោចណាស់ក្នុងកម្រិតមួយដែលស្មើ ឬប្រសើរជាងកម្រិតមុនពេលមានគម្រោងអភិវឌ្ឍន៍។

## ឃ. លក្ខខណ្ឌតម្រូវ

### ១. ការទូទាត់សង ជំនួយ និង អត្ថប្រយោជន៍សម្រាប់អ្នកបាត់បង់លំនៅដ្ឋាន

---

មធ្យោបាយចិញ្ចឹមជីវិត) ដោយសារតែ (១) លទ្ធកម្មដីដោយមិនស្ម័គ្រចិត្ត ឬ (២) ការកម្រិតដោយមិនស្ម័គ្រចិត្តលើការប្រើប្រាស់ដី ឬសិទ្ធិចេញ-ចូលទៅកាន់ឧទ្យានជាតិ និងតំបន់ការពារធម្មជាតិដែលកំណត់ដោយច្បាប់។

៧. អ្នកបាត់បង់លំនៅដ្ឋាននៅក្នុងតំបន់គម្រោង ចែកចេញជាបីប្រភេទ : (១) ក្រុមមនុស្សដែលមានសិទ្ធិកម្មសិទ្ធិស្របច្បាប់លើដីដែលត្រូវបាត់បង់ទាំងស្រុង ឬមួយផ្នែក (២) ក្រុមមនុស្សដែលបាត់បង់ដីដែលខ្លួនកាន់កាប់ទាំងស្រុង ឬមួយផ្នែក តែគ្មានសិទ្ធិកម្មសិទ្ធិស្របច្បាប់លើដីនោះ ប៉ុន្តែមានសិទ្ធិកាន់កាប់ដីនោះ ដែលសិទ្ធិនេះមានការទទួលស្គាល់ដោយច្បាប់ជាតិ និង (៣) ក្រុមមនុស្សដែលបាត់បង់ដីដែលខ្លួនកាន់កាប់ទាំងស្រុង ឬមួយផ្នែក ដែលគ្មានទាំងសិទ្ធិកម្មសិទ្ធិស្របច្បាប់ និងសិទ្ធិកាន់កាប់ ដែលមានការទទួលស្គាល់ដោយច្បាប់ ។ លក្ខខណ្ឌតម្រូវក្នុងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត អនុវត្តចំពោះប្រភេទទាំងបីនៃអ្នកបាត់បង់លំនៅដ្ឋាន ។

៨. អ្នកខ្ចី/អតិថិជន នឹងផ្តល់ដី និងរចនាសម្ព័ន្ធជំនួសគ្រប់គ្រាន់ និងសមរម្យ ឬប្រាក់ទូទាត់សងសោហ៊ុយចំណាយដោះដូរដី និងរចនាសម្ព័ន្ធដែលបាត់បង់ ប្រាក់ទូទាត់សងគ្រប់គ្រាន់សម្រាប់ការខូចខាតដោយផ្នែកចំពោះរចនាសម្ព័ន្ធ និងផ្តល់ជំនួយឧបត្ថម្ភក្នុងការផ្លាស់ទីលំនៅ ប្រសិនបើមាន ដល់ក្រុមមនុស្សដែលមានរៀបរាប់ក្នុងកថាខណ្ឌ ៧ (i) និង ៧ (ii) នៅមុនពេលពួកគាត់ផ្លាស់ទីលំនៅ ។ ចំពោះក្រុមមនុស្សដែលមានរៀបរាប់ក្នុងកថាខណ្ឌ ៧ (iii) អ្នកខ្ចី/អតិថិជន នឹងផ្តល់ការទូទាត់សងដល់ពួកគាត់ចំពោះការបាត់បង់ទ្រព្យសកម្មក្រៅពីដីធ្លី ដូចជា ទីកន្លែងស្នាក់នៅ និងការសាងសង់បន្ថែមណាមួយដែលមាននៅលើដី តាមសោហ៊ុយចំណាយដោះដូរទាំងស្រុង ។ សិទ្ធិរបស់ក្រុមមនុស្សដែលមានរៀបរាប់ក្នុងកថាខណ្ឌ ៧ (iii) ត្រូវបានផ្តល់ឱ្យតែនៅក្នុងករណីដែលពួកគាត់កាន់កាប់ដី ឬរចនាសម្ព័ន្ធនៅក្នុងតំបន់គម្រោង នៅមុនកាលបរិច្ឆេទផុតកំណត់សម្រាប់អ្នកមានសិទ្ធិទទួលបានជំនួយឧបត្ថម្ភក្នុងការតាំងទីលំនៅជាថ្មីតែប៉ុណ្ណោះ ។

៩. អាទិភាពនឹងផ្តល់ឱ្យចំពោះយុទ្ធសាស្ត្រដោះស្រាយការតាំងទីលំនៅជាថ្មីតាមរយៈការផ្តល់ដីធ្លី សម្រាប់ក្រុមមនុស្សដែលមធ្យោបាយចិញ្ចឹមជីវិតរបស់ពួកគាត់ពឹងផ្អែកលើដី ។ យុទ្ធសាស្ត្រទាំងនេះ អាចមានបញ្ចូលនូវការតាំងទីលំនៅនៅលើដីសាធារណៈ ឬដីឯកជនដែលទទួលបានតាមរយៈលទ្ធកម្ម ឬទិញសម្រាប់ការតាំងទីលំនៅ ។ នៅពេលដាក់ស្នើដោះដូរដី អ្នកបាត់បង់លំនៅដ្ឋាននឹងផ្តល់ឱ្យនូវដីដែលមានសក្តានុពលផលិតកម្ម ស្ថិតក្នុងទីតាំងល្អ និងមានកត្តាផ្សេងទៀត ដែលយ៉ាងហោចណាស់មានអត្ថប្រយោជន៍សមមូលទៅនឹងដីដែលបាត់បង់ ។ ប្រសិនបើដីមិនមែនជាជម្រើសអាទិភាពរបស់ក្រុមមនុស្សដែលផ្លាស់ទីលំនៅ ឬក្នុងករណីគ្មានដីដែលមានតម្លៃសមរម្យគ្រប់គ្រាន់ ជម្រើសផ្សេងក្រៅពីការផ្តល់ដី ដូចជា ឱកាសការងារ ឬការងារឯករាជ្យ នឹងត្រូវផ្តល់ឱ្យបន្ថែមលើប្រាក់ទូទាត់សងចំពោះការបាត់បង់ដី និងទ្រព្យសកម្ម ។ កង្វះដី នឹងត្រូវបង្ហាញ និងកត់ត្រាទុកជាឯកសារ តាមការចង់បានរបស់ ADB ។

១០. អត្រាទូទាត់សងចំពោះផ្ទះ ដី និងទ្រព្យសកម្មផ្សេងទៀតដែលបានធ្វើលទ្ធកម្ម នឹងត្រូវគណនាជាសោហ៊ុយចំណាយដោះដូរទាំងស្រុង ។ ការគណនាសោហ៊ុយចំណាយដោះដូរទាំងស្រុង នឹងត្រូវពឹងផ្អែកលើកត្តាដូចតទៅ : (១) តម្លៃទីផ្សារ (២) តម្លៃអំឡុងពេលអន្តរកាល (៣) ការប្រាក់គិតបន្ថែម (៤) សោហ៊ុយរុះរើ និងសាងសង់ឡើងវិញ និង (៥) សោហ៊ុយចំណាយផ្សេងៗទៀត ប្រសិនបើមាន ។ ប្រសិនបើគ្មានតម្លៃទីផ្សារ ឬតម្លៃទីផ្សារស្ថិតក្នុងដំណាក់កាលកំពុងលូតលាស់ អ្នកខ្ចី/អតិថិជន នឹងពិគ្រោះយោបល់ជាមួយអ្នកបាត់បង់លំនៅដ្ឋាន និងប្រជាពលរដ្ឋនៃប្រទេសម្ចាស់ផ្ទះ ដើម្បីស្រង់ព័ត៌មានថ្មីៗឱ្យបានគ្រប់គ្រាន់ពីការជួញដូរដីធ្លី តម្លៃដីតាមប្រភេទ ប័ណ្ណកម្មសិទ្ធដី ការប្រើប្រាស់ដី ការប្រមូលផល និងការដាំដុះ ភាពអាចរកដីបានក្នុងតំបន់គម្រោង និងក្នុងតំបន់ទាំងមូល និងព័ត៌មានពាក់ព័ន្ធផ្សេងៗទៀត ។ អ្នកខ្ចី/អតិថិជន ក៏នឹងប្រមូលទិន្នន័យគោលស្តីពីផ្ទះ ប្រភេទផ្ទះ និងសម្ភារៈសំណង់ផងដែរ ។

អ្នកជំនាញការដែលមានគុណវុឌ្ឍិ និងមានបទពិសោធន៍ នឹងធ្វើការវាយតម្លៃទ្រព្យសកម្មដែលត្រូវបានធ្វើលទ្ធកម្ម។ ក្នុងការអនុវត្ត វិធីសាស្ត្រវាយតម្លៃ ការធ្លាក់ចុះតម្លៃរចនាសម្ព័ន្ធ និងទ្រព្យសកម្ម មិនត្រូវយកមកគិតឡើយ។

១១. ក្នុងករណីអ្នកបាត់បង់លំនៅដ្ឋានរូបវន្ត អ្នកខ្ចី/អតិថិជន នឹងផ្តល់ (១) ជំនួយឧបត្ថម្ភក្នុងការផ្លាស់ទីលំនៅ មានការធានាសិទ្ធិកាន់កាប់ដីថ្មី ផ្ទះសម្បែងនៅតំបន់តាំងទីលំនៅថ្មីដែលមានលក្ខខណ្ឌល្អប្រសើរជាងកន្លែងចាស់ ជាមួយនឹងសិទ្ធិទទួលការងារ និងឱកាសផលិតកម្មដែលអាចប្រៀបធៀបបានជាមួយនឹងកន្លែងចាស់ និង ហេដ្ឋារចនាសម្ព័ន្ធស៊ីវិល និង សេវាសហគមន៍ដែលចាំបាច់ (២) ជំនួយគាំទ្រអន្តរកាល និងជំនួយអភិវឌ្ឍន៍ ដូចជា ការអភិវឌ្ឍន៍ដី ហេដ្ឋារចនាសម្ព័ន្ធឥណទាន ការបណ្តុះបណ្តាល ឬឱកាសការងារ និង (៣) ឱកាសទទួលបានអត្ថប្រយោជន៍សមស្របពីគម្រោងអភិវឌ្ឍន៍។

១២. ក្នុងករណីអ្នកបាត់បង់លំនៅដ្ឋានសេដ្ឋកិច្ច (ដោយមិនគិតថាពួកគាត់ត្រូវ ឬមិនត្រូវផ្លាស់ទីលំនៅរូបវន្តឡើយ) អ្នកខ្ចី/អតិថិជន នឹងធ្វើការទូទាត់សងជាបន្ទាន់ចំពោះការបាត់បង់ប្រាក់ចំណូល ឬមធ្យោបាយចិញ្ចឹមជីវិត ដោយផ្តល់ជូនសោហ៊ុយចំណាយដោះដូរទាំងស្រុង។ អ្នកខ្ចី/អតិថិជន នឹងផ្តល់ជំនួយឧបត្ថម្ភដូចជា ហេដ្ឋារចនាសម្ព័ន្ធឥណទាន ការបណ្តុះបណ្តាល និងឱកាសការងារ ដើម្បីឱ្យពួកគេអាចលើកកម្ពស់ (ឬយ៉ាងហោចណាស់ស្តារ) លទ្ធភាពរកប្រាក់ចំណូល កម្រិតផលិតកម្ម និងកម្រិតជីវភាពរស់នៅក្នុងកម្រិតមួយដែលសមមូលនឹងកម្រិតមុនពេលផ្លាស់ទីលំនៅ។ អ្នកខ្ចី/អតិថិជន ក៏នឹងផ្តល់ឱ្យអ្នកបាត់បង់លំនៅដ្ឋាននូវឱកាសទទួលបានអត្ថប្រយោជន៍សមស្របពីគម្រោងអភិវឌ្ឍន៍។ អ្នកខ្ចី/អតិថិជន នឹងធ្វើសំណងសេដ្ឋកិច្ចដល់អ្នកបាត់បង់លំនៅដ្ឋាន ដែលមានកំណត់ក្នុងកថាខណ្ឌ ៧ (iii) ចំពោះការបាត់បង់ទ្រព្យសកម្ម ដូចជា ដំណាំ ប្រព័ន្ធស្រោចស្រព និងការសាងសង់បន្ថែមផ្សេងទៀតនៅលើដី (ប៉ុន្តែមិនទូទាត់សងចំពោះការបាត់បង់ដីឡើយ) ដោយផ្តល់ជូននូវសោហ៊ុយចំណាយទាំងស្រុងក្នុងការផ្លាស់ទីលំនៅ។ ក្នុងករណីដែលលទ្ធកម្មដីប៉ះពាល់ដល់សំណង់ពាណិជ្ជកម្ម ពាណិជ្ជកររងផលប៉ះពាល់មានសិទ្ធិទទួលបាន (១) សោហ៊ុយចំណាយក្នុងការរៀបចំសកម្មភាពពាណិជ្ជកម្មឡើងវិញនៅទីកន្លែងផ្សេង (២) ចំណូលសុទ្ធដែលត្រូវបាត់បង់នៅអំឡុងពេលអន្តរកាល និង (៣) សោហ៊ុយដឹកជញ្ជូន និងតំឡើងរោងចក្រ គ្រឿងម៉ាស៊ីន និងសម្ភារៈឧបករណ៍ផ្សេងទៀតឡើងវិញ។ ពាណិជ្ជករដែលមានសិទ្ធិកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ដែលច្បាប់ទទួលស្គាល់ លើដីដែលពួកគេធ្វើសកម្មភាពពាណិជ្ជកម្ម មានសិទ្ធិទទួលបានដីជំនួសដែលមានតម្លៃស្មើ ឬលើសតម្លៃដីចាស់ ឬប្រាក់សំណងដែលមានតម្លៃស្មើនឹងសោហ៊ុយចំណាយទាំងស្រុងក្នុងការផ្លាស់ទីលំនៅ។

១៣. ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត គឺជាផ្នែកមួយនៃគម្រោង ឬកម្មវិធីអភិវឌ្ឍន៍។ ក្នុងបរិបទនេះ យុទ្ធសាស្ត្រល្អបំផុតគឺផ្តល់ឱ្យអ្នកបាត់បង់លំនៅដ្ឋាននូវឱកាសចែករំលែកបានអត្ថប្រយោជន៍ពីគម្រោង បន្ថែមលើការផ្តល់នូវការទូទាត់សង និងជំនួយឧបត្ថម្ភក្នុងការតាំងទីលំនៅថ្មី។ ឱកាសនេះ នឹងជួយបង្ការមិនឱ្យមានការធ្លាក់ខ្លួនក្រីក្រក្នុងចំណោមក្រុមមនុស្សរងផលប៉ះពាល់ ហើយក៏ជួយបំពេញសេចក្តីត្រូវការសីលធម៌នៃការអភិវឌ្ឍន៍ ដើម្បីលាតសន្ធឹងអត្ថប្រយោជន៍នៃការអភិវឌ្ឍន៍ឱ្យបានទូលំទូលាយ។ ហេតុនេះ អ្នកខ្ចី/អតិថិជន ត្រូវបានលើកទឹកចិត្តឱ្យធ្វើការអះអាងនូវឱកាសជាក់លាក់ក្នុងការភ្ជាប់ក្រុមមនុស្សរងផលប៉ះពាល់ ឱ្យក្លាយជាអ្នកទទួលអត្ថប្រយោជន៍ពីគម្រោង និងដើម្បីពិភាក្សាពីរបៀបពង្រីងឱកាសនេះឱ្យបានទូលំទូលាយតាមដែលអាចធ្វើនៅបាន ក្នុងចំណោមក្រុមមនុស្សរងផលប៉ះពាល់ នៅក្នុងផែនការតាំងទីលំនៅជាថ្មី។

១៤. អ្នកខ្ចី/អតិថិជន នឹងធានាថា ការផ្លាស់ទីលំនៅរូបវន្ត ឬការផ្លាស់ទីលំនៅសេដ្ឋកិច្ចអាចនឹងកើតមានឡើងបាន លុះត្រាតែ (១) សំណងសោហ៊ុយចំណាយទាំងស្រុងក្នុងការផ្លាស់ទីលំនៅ ត្រូវបានបង់ជូនបុគ្គលដែលត្រូវផ្លាស់ទីលំនៅនីមួយៗ ចំពោះសមាសភាគ ឬផ្នែកនៃគម្រោងដែលបានសាងសង់រួចរាល់ (២) សិទ្ធិផ្សេងទៀតដែលមានកំណត់ក្នុងផែនការតាំងទីលំនៅជាថ្មី ត្រូវបានផ្តល់ជូនអ្នកបាត់បង់លំនៅដ្ឋាន និង (៣) មានកម្មវិធីទូលំទូលាយដើម្បីស្តារប្រភពប្រាក់ចំណូល និងមធ្យោបាយចិញ្ចឹមជីវិត និងមានថវិកាទ្រទ្រង់គ្រប់គ្រាន់ ដើម្បីជួយអ្នកបាត់បង់លំនៅដ្ឋានលើកកម្ពស់ (ឬយ៉ាងហោចណាស់ស្តារ) ប្រភពប្រាក់ចំណូល និងមធ្យោបាយចិញ្ចឹមជីវិតរបស់ពួកគាត់។ បើទោះជាមានការតម្រូវឱ្យបង់ប្រាក់ទូទាត់សងនៅមុនពេលធ្វើការផ្លាស់ទីលំនៅក៏ដោយ ការអនុវត្តផែនការតាំងទីលំនៅជាថ្មីទាំងស្រុង អាចនឹងត្រូវការពេលវេលាយូរជាងនេះ។ ប្រសិនបើសកម្មភាពគម្រោងរឹតត្បិតដល់ការប្រើប្រាស់ដី ឬសិទ្ធិចេញ-ចូលទៅកាន់ឧទ្យានជាតិ ឬតំបន់ការពារធម្មជាតិដែលកំណត់ដោយច្បាប់ ការរឹតត្បិតនេះត្រូវតែអនុវត្តឱ្យស្របតាមកាលវិភាគដែលកំណត់ក្នុងផែនការតាំងទីលំនៅថ្មីដែលបានព្រមព្រៀងគ្នា រវាងអ្នកខ្ចី/អតិថិជន និង ADB។

## ២. ការវាយតម្លៃផលប៉ះពាល់សង្គម

១៥. អ្នកខ្ចី/អតិថិជន នឹងរៀបចំធ្វើការអង្កេតសង្គម-សេដ្ឋកិច្ច និងជំរឿន ដោយមានទូរទិន្នន័យគោលសមស្របអំពីសង្គម-សេដ្ឋកិច្ច ដើម្បីកំណត់អត្តសញ្ញាណបុគ្គលដែលត្រូវផ្លាស់ទីលំនៅដោយសារគម្រោង និងដើម្បីវាយតម្លៃផលប៉ះពាល់សង្គម-សេដ្ឋកិច្ចរបស់គម្រោងចំពោះពួកគាត់។ ក្នុងគោលបំណងនេះ ជាធម្មតា កាលបរិច្ឆេទផុតកំណត់មួយនឹងត្រូវកំណត់ដោយនីតិវិធីរបស់ប្រទេសម្ចាស់ផ្ទះ។ ក្នុងករណីគ្មាននីតិវិធីនេះទេ អ្នកខ្ចី/អតិថិជននឹងកំណត់កាលបរិច្ឆេទផុតកំណត់សម្រាប់អ្នកមានសិទ្ធិ។ ព័ត៌មានពាក់ព័ន្ធនឹងកាលបរិច្ឆេទផុតកំណត់ នឹងត្រូវកត់ត្រាទុកជាឯកសារ និងផ្សព្វផ្សាយនៅក្នុងតំបន់គម្រោង។ របាយការណ៍វាយតម្លៃផលប៉ះពាល់សង្គម (SIA) នឹងមានបញ្ចូល (១) ផលប៉ះពាល់សង្គមដែលអាចកើតមាន និងដែលកំណត់បាននៅពេលអតីតកាល បច្ចុប្បន្ន និងនៅពេលអនាគត (២) បញ្ជីអ្នកបាត់បង់លំនៅដ្ឋាន[២] និងទ្រព្យសកម្មរបស់ពួកគេ[៣] (៣) ការវាយតម្លៃប្រាក់ចំណូល និងមធ្យោបាយចិញ្ចឹមជីវិតរបស់ពួកគេ និង (៤) ព័ត៌មានបែងចែកតាមយេនឌ័រដែលពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ច និងសង្គមវប្បធម៌របស់អ្នកបាត់បង់លំនៅដ្ឋាន។ ផលប៉ះពាល់ និងហានិភ័យសង្គមដែលអាចកើតចេញពីគម្រោង នឹងត្រូវវាយតម្លៃធៀបជាមួយនឹងលក្ខខណ្ឌតម្រូវដែលកំណត់ក្នុងឯកសារនេះ និងច្បាប់ និងបទបញ្ញាពាក់ព័ន្ធនឹងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ដែលនៅជាធរមាននៅក្នុងដែនយុត្តាធិការដែលត្រូវអនុវត្តគម្រោង គិតរួមទាំងកាតព្វកិច្ចដែលប្រទេសម្ចាស់ផ្ទះត្រូវបំពេញស្របតាមច្បាប់អន្តរជាតិផងដែរ។

១៦. ជាផ្នែកមួយនៃការវាយតម្លៃផលប៉ះពាល់សង្គម អ្នកខ្ចី/អតិថិជននឹងកំណត់អត្តសញ្ញាណបុគ្គល និងក្រុមមនុស្សដែលអាច

---

[២] កំណត់ត្រាប្រជាជននៃអ្នកបាត់បង់លំនៅដ្ឋានតាមទីកន្លែងស្នាក់នៅរបស់ពួកគេដែលបានមកពីជំរឿន។ ប្រសិនបើគ្មានការធ្វើជំរឿននៅមុនពេលវាយតម្លៃគម្រោង ហើយផែនការតាំងទីលំនៅជាថ្មីពឹងផ្អែកទៅលើការអង្កេតគំរូ ផែនការតាំងទីលំនៅជាថ្មីដែលត្រូវបានធ្វើបច្ចុប្បន្នភាពនឹងត្រូវរៀបចំឡើងដោយពឹងផ្អែកទៅលើជំរឿនអ្នកបាត់បង់លំនៅដ្ឋាន បន្ទាប់ពីបានបញ្ចប់ការអង្កេតវាស់ស្ទង់លម្អិត ប៉ុន្តែនៅមុនពេលលទ្ធកម្មដីសម្រាប់គម្រោង។

[៣] បញ្ជីទ្រព្យសកម្មគឺជាកំណត់ត្រាបឋមនៃទ្រព្យសកម្មដែលត្រូវរងផលប៉ះពាល់ ឬបាត់បង់ ក្នុងកម្រិតក្រុមគ្រួសារ សហគ្រាស ឬសហគមន៍។

រងផលប៉ះពាល់ពីគម្រោងខុសពី ឬមិនសមមាត្រជាមួយអ្នកដទៃ ដោយសារតែពួកគេជាក្រុមទន់ខ្សោយ ឬងាយរងគ្រោះ។ ប្រសិនបើអត្តសញ្ញាណរបស់បុគ្គល ឬក្រុមមនុស្សប្រភេទនេះត្រូវបានកំណត់ អ្នកខ្ចី/អតិថិជន នឹងស្នើ និងអនុវត្តវិធានផ្តោតលើក្រុមមនុស្សប្រភេទនេះ ដើម្បីបង្ការមិនឱ្យផលប៉ះពាល់អវិជ្ជមានជះឥទ្ធិពលមិនសមមាត្រលើពួកគេ ហើយដើម្បីជួយពួកគាត់មិនឱ្យចាញ់ប្រៀបអ្នកដទៃក្នុងការទទួលបានអត្ថប្រយោជន៍ និងឱកាសដែលកើតចេញពីការអភិវឌ្ឍន៍។

## ៣. ការរៀបចំផែនការតាំងទីលំនៅជាថ្មី

១៧. អ្នកខ្ចី/អតិថិជន នឹងរៀបចំផែនការតាំងទីលំនៅជាថ្មី ប្រសិនបើគម្រោងស្នើសុំមានការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត។ កម្មវត្ថុនៃផែនការតាំងទីលំនៅជាថ្មីគឺដើម្បីធានាថាមធ្យោបាយចិញ្ចឹមជីវិត និងកម្រិតជីវភាពរស់នៅរបស់អ្នកបាត់បង់លំនៅដ្ឋាន (រូបវន្ត និង/ឬ សេដ្ឋកិច្ច) ត្រូវបានលើកកម្ពស់ (ឬយ៉ាងហោចណាស់ស្តារ) ក្នុងកម្រិតមុនពេលមានគម្រោង និងដើម្បីធានាថា កម្រិតជីវ-ភាពរស់នៅរបស់ជនក្រីក្រ និងក្រុមងាយរងគ្រោះផ្សេងទៀតដែលត្រូវផ្លាស់ទីលំនៅ ត្រូវបានលើកកម្ពស់ (មិនមែនគ្រាន់តែស្តារប៉ុណ្ណោះទេ) តាមរយៈការផ្តល់ទីកន្លែងស្នាក់នៅសមរម្យ ការធានាសិទ្ធិកាន់កាប់ដី និងមធ្យោបាយចិញ្ចឹមជីវិត និងប្រភពចំណូលទៀងទាត់។ ផែនការតាំងទីលំនៅជាថ្មី នឹងលើកយកមកអនុវត្តនូវលក្ខខណ្ឌតម្រូវពាក់ព័ន្ធដែលកំណត់ដោយលក្ខខណ្ឌតម្រូវសម្រាប់ការពារ ២ ហើយកម្រិតនៃភាពលម្អិត និងទូលំទូលាយនៃផែនការតាំងទីលំនៅជាថ្មី ត្រូវមានភាពសមាមាត្រទៅនឹងកម្រិតនៃផលប៉ះពាល់ដែលបណ្តាលមកពីការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត។ គ្រោងនៃផែនការតាំងទីលំនៅជាថ្មី មានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធនៃសេចក្តីបន្ថែមនេះ។

១៨. ផែនការតាំងទីលំនៅជាថ្មី នឹងផ្អែកទៅលើការវាយតម្លៃផលប៉ះពាល់សង្គម និងការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយក្រុមមនុស្សរងផលប៉ះពាល់។ ផែនការតាំងទីលំនៅជាថ្មី នឹងដាក់បញ្ចូលនូវវិធានការនានាដើម្បីធានាថាអ្នកបាត់បង់លំនៅដ្ឋាន (១) បានទទួលព័ត៌មានពីជម្រើស និងសិទ្ធិ ដែលពាក់ព័ន្ធនឹងការទូទាត់សង ការផ្លាស់ទីលំនៅ និងការស្តារនីតិសម្បទា (២) បានទទួលការពិគ្រោះយោបល់ពីជម្រើសក្នុងការតាំងទីលំនៅជាថ្មី និង (៣) បានទទួលនូវជម្រើសផ្សេងៗក្នុងការតាំងទីលំនៅជាថ្មី។ នៅអំឡុងពេលកំណត់ពីផលប៉ះពាល់នៃការតាំងទីលំនៅជាថ្មី និងការរៀបចំផែនការតាំងទីលំនៅជាថ្មី និងក្នុងអំឡុងពេលអនុវត្ត អ្នកខ្ចី/អតិថិជន នឹងធ្វើការចាប់អារម្មណ៍ជាពិសេសពីបញ្ហាយេនឌ័រ រួមមានដូចជា វិធានការជាក់លាក់ដើម្បីដោះស្រាយតម្រូវការរបស់ស្ត្រីមេគ្រួសារ ការពិគ្រោះយោបល់ពីបញ្ហាយេនឌ័រ ការផ្តល់ព័ត៌មាន និងយន្តការដោះស្រាយបណ្តឹងតវ៉ា ដើម្បីធានាថា បុរស និងស្ត្រីទទួលបានការទូទាត់សងសមរម្យគ្រប់គ្រាន់ចំពោះការបាត់បង់ទ្រព្យសម្បត្តិ និងជំនួយឧបត្ថម្ភក្នុងការតាំងទីលំនៅជាថ្មី ប្រសិនបើមានព្រមទាំងជំនួយឧបត្ថម្ភក្នុងការស្តារ និងលើកកម្ពស់ប្រភពចំណូល និងកម្រិតជីវភាពរស់នៅរបស់ពួកគេ។

១៩. អ្នកខ្ចី/អតិថិជន នឹងវិភាគ និងសង្ខេបច្បាប់ និងបទបញ្ញត្តិជាតិដែលពាក់ព័ន្ធនឹងលទ្ធកម្មដី ការបង់ប្រាក់ទូទាត់សំណង និងការផ្លាស់ទីលំនៅរបស់ក្រុមមនុស្សរងផលប៉ះពាល់ នៅក្នុងផែនការតាំងទីលំនៅជាថ្មី។ អ្នកខ្ចី/អតិថិជន នឹងប្រៀបធៀបច្បាប់ និងបទបញ្ញត្តិទាំងនេះជាមួយនឹងគោលការណ៍ និងលក្ខខណ្ឌតម្រូវនៃគោលនយោបាយតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តរបស់ ADB។

ប្រសិនបើមានគម្លាតរវាងគោលការណ៍របស់រដ្ឋ និងរបស់ ADB អ្នកខ្ចី/អតិថិជន នឹងស្នើយុទ្ធសាស្ត្រសមស្របដើម្បីបំបាត់គម្លាតនោះ ក្នុងផែនការតាំងទីលំនៅជាថ្មី ដោយពិគ្រោះយោបល់ជាមួយ ADB ។

២០. សោហ៊ុយចំណាយក្នុងការទូទាត់សំណង ការផ្លាស់ទីលំនៅ និងការស្តារនីតិសម្បទាមធ្យោបាយចិញ្ចឹមជីវិត នឹងត្រូវចាត់ទុកជាសោហ៊ុយចំណាយរបស់គម្រោង។ ដើម្បីធានាថាមានធនធានចាំបាច់ទាន់ពេលវេលា លទ្ធកម្មដី និងសោហ៊ុយចំណាយក្នុងការតាំងទីលំនៅជាថ្មី អាចនឹងត្រូវរាប់បញ្ចូលក្នុងការផ្តល់ហិរញ្ញប្បទានរបស់ ADB ។ ការចំណាយក្នុងការតាំងទីលំនៅជាថ្មី មានសិទ្ធិទទួលបានហិរញ្ញប្បទានពី ADB ប្រសិនបើការតាំងទីលំនៅជាថ្មីនោះ ធ្វើឱ្យស្របតាមសេចក្តីថ្លែងការណ៍គោលនយោបាយការពារ និងឯកសាររៀបចំផែនការតាំងទីលំនៅជាថ្មីអនុម័តយល់ព្រមដោយ ADB ។ ប្រសិនបើមូលធិនិ ADB ត្រូវបានប្រើសម្រាប់ការចំណាយក្នុងការតាំងទីលំនៅជាថ្មី ការចំណាយនេះនឹងត្រូវឆ្លុះបញ្ចាំងយ៉ាងច្បាស់ ក្នុងផែនការតាំងទីលំនៅជាថ្មី ។

២១. អ្នកខ្ចី/អតិថិជន នឹងបញ្ចូលវិធានការលម្អិតក្នុងការស្តារប្រភពចំណូល និងការលើកកម្ពស់មធ្យោបាយចិញ្ចឹមជីវិតរបស់ក្រុមមនុស្ស ដែលត្រូវផ្លាស់ទីលំនៅ នៅក្នុងផែនការតាំងទីលំនៅជាថ្មី។ ប្រភពចំណូល និងមធ្យោបាយចិញ្ចឹមជីវិតដែលរងផលប៉ះពាល់ពីសកម្មភាពគម្រោង នឹងត្រូវស្តារទៅរកកម្រិតមុនពេលមានគម្រោងវិញ ហើយ អ្នកខ្ចី/អតិថិជន នឹងព្យាយាមលើកកម្ពស់ប្រភពចំណូលរបស់អ្នកបាត់បង់លំនៅដ្ឋាន ដើម្បីឱ្យពួកគាត់អាចទទួលបានអត្ថប្រយោជន៍ពីគម្រោង។ ចំពោះក្រុមមនុស្ស និងក្រុមគ្រួសារងាយរងគ្រោះដែលទទួលរងផលប៉ះពាល់ ផែនការតាំងទីលំនៅជាថ្មី នឹងបញ្ចូលនូវវិធានការផ្តល់ ជំនួយឧបត្ថម្ភបន្ថែម ដើម្បីឱ្យពួកគាត់អាចលើកកម្ពស់ចំណូលរបស់ពួកគាត់ឱ្យបានប្រហាក់ប្រហែលនឹងកម្រិតនៅមុនពេលមានគម្រោង។ ផែនការតាំងទីលំនៅជាថ្មីនឹងរៀបរាប់ពីយុទ្ធសាស្ត្រស្តារប្រភពចំណូល និងមធ្យោបាយចិញ្ចឹមជីវិត ការរៀបចំស្ថាប័ន ក្របខណ្ឌតាមដាន និងរាយការណ៍ កញ្ចប់ថវិកា និងកម្មវិធីអនុវត្ត។

២២. ព័ត៌មានដែលមានក្នុងផែនការតាំងទីលំនៅជាថ្មី អាចគ្រាន់តែជាព័ត៌មានបណ្តោះអាសន្ន រហូតទាល់តែជំរឿនក្រុមមនុស្សរងផលប៉ះពាល់ត្រូវបានបញ្ចប់។ បន្ទាប់ពីការបញ្ចប់ប្លង់គម្រោងវិស្វកម្មភ្លាម អ្នកខ្ចី/អតិថិជននឹងបញ្ចប់ផែនការតាំងទីលំនៅថ្មី ដោយបញ្ចប់ការធ្វើជំរឿន និងបញ្ជីទ្រព្យសកម្មដែលត្រូវបាត់បង់។ ក្នុងដំណាក់កាលនេះ ការកែប្រែផែនការតាំងទីលំនៅជាថ្មី អាចធ្វើបានតែចំពោះចំនួនអ្នកបាត់បង់លំនៅដ្ឋាន ទំហំនៃលទ្ធកម្មដី កញ្ចប់ថវិកាតាំងទីលំនៅជាថ្មី និងកាលវិភាគអនុវត្តផែនការតាំងទីលំនៅជាថ្មី។ តារាងសិទ្ធិនៃផែនការតាំងពីលំនៅជាថ្មី អាចត្រូវបានធ្វើបច្ចុប្បន្នភាពនៅក្នុងដំណាក់កាលនេះ ដើម្បីឆ្លុះបញ្ចាំងពីការប្រែប្រួលពាក់ព័ន្ធ ប៉ុន្តែបទដ្ឋានដែលបានកំណត់ក្នុងម៉ាទ្រីសសិទ្ធិច្បាប់ដើមមិនអាចបន្ទាបបានឡើយ នៅពេលផែនការតាំងទីលំនៅជាថ្មីត្រូវបានកែប្រែ និងបញ្ចប់។ អ្នកខ្ចី/អតិថិជន នឹងធានាថា ផែនការតាំងទីលំនៅជាថ្មីចុងក្រោយ (១) ដោះស្រាយគ្រប់បញ្ហាតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តដែលកើតចេញពីគម្រោង (២) រៀបរាប់ពីវិធានការកាត់បន្ថយជាក់លាក់ក្នុងការដោះស្រាយបញ្ហា និង (៣) ធានាថាមានធនធានគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហាតាមការចង់បាន។

២៣. គម្រោងដែលមានការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តធ្ងន់ធ្ងរ ត្រូវការមូលនិធិបម្រុងគ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហានៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តដែលបានកំណត់នៅអំឡុងពេលអនុវត្តគម្រោង។ អ្នកខ្ចី/អតិថិជន ធានាថាខ្លួនអាចរកបានមូលនិធិបម្រុងនេះ។ លើសពីនេះ អ្នកខ្ចី/អតិថិជន នឹងពិគ្រោះយោបល់ជាមួយអ្នកបាត់បង់លំនៅដ្ឋានដែលបានកំណត់អត្តសញ្ញាណ

នៅក្រោយការរៀបចំ ផែនការតាំងទីលំនៅជាថ្មី ។ និងជូនដំណឹងដល់ពួកគាត់ពីសិទ្ធិ និងជម្រើសផ្លាស់ទីលំនៅរបស់ពួកគាត់ ។ អ្នកខ្ចី/អតិថិជន នឹងរៀបចំ ការបំពេញបន្ថែមលើផែនការតាំងទីលំនៅជាថ្មី ឬការកែប្រែផែនការតាំងទីលំនៅជាថ្មី ដើម្បីផ្ញើជូន ADB ឱ្យធ្វើការពិនិត្យវាយតម្លៃ នៅមុនពេលចុះកិច្ចសន្យាណាមួយ ។

២៤. អ្នកខ្ចី/អតិថិជន នឹងប្រើប្រាស់អ្នកជំនាញមានគុណវុឌ្ឍិ និងមានបទពិសោធន៍ ដើម្បីរៀបចំការវាយតម្លៃផលប៉ះពាល់សង្គម និងផែនការតាំងទីលំនៅជាថ្មី ។ ចំពោះគម្រោងមានភាពស្មុគស្មាញ និងងាយរងការប៉ះពាល់ខ្លាំង ក្រុមទីប្រឹក្សាឯករាជ្យនៃអ្នកជំនាញ ដែលមិនពាក់ព័ន្ធនឹងគម្រោង នឹងត្រូវប្រើនៅអំឡុងពេលរៀបចំ និងអនុវត្តគម្រោង ។

## ៤. ការទទួលបានដីធ្លីតាមរយៈការចរចារ

២៥. លក្ខខណ្ឌតម្រូវសម្រាប់ការពារ ២ មិនអនុវត្តចំពោះការដោះស្រាយដោយការចរចាគ្នាឡើយ លើកលែងតែក្នុងករណីដែលអាចមានអស្សាមិករណ៍នៅក្រោយការបរាជ័យនៃការចរចា ។ ការដោះស្រាយដោយការចរចាគ្នា ជួយបញ្ចៀសមិនឱ្យមានអស្សាមិ-ករណ៍ និងលប់បំបាត់តម្រូវការប្រើសមត្ថកិច្ចរដ្ឋាភិបាលក្នុងការបណ្តេញប្រជាពលរដ្ឋចេញដោយប្រើកំលាំង ។ អ្នកខ្ចី/អតិថិជន ត្រូវបានលើកទឹកចិត្តឱ្យធ្វើលទ្ធកម្មដី និងទ្រព្យសកម្មផ្សេងទៀតតាមរយៈការដោះស្រាយដោយការចរចាគ្នា ប្រសិនបើអាចធ្វើទៅបាន ដោយផ្អែកលើការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយក្រុមមនុស្សរងផលប៉ះពាល់ រួមទាំងក្រុមមនុស្សដែលគ្មានសិទ្ធិ-កម្មសិទ្ធិលើទ្រព្យសកម្មផង ។ ការដោះស្រាយដោយការចរចាគ្នា នឹងផ្តល់នូវតម្លៃសមស្របគ្រប់គ្រាន់សម្រាប់ដី និង/ឬ ទ្រព្យសកម្មផ្សេងទៀត ។ អ្នកខ្ចី/អតិថិជន នឹងធានាថា រាល់ការចរចាជាមួយអ្នកបាត់បង់លំនៅដ្ឋាន នឹងលើកឡើងដោយបើកចំហពីហានិភ័យនៃអសមមាត្រនៃព័ត៌មាន និងអំណាចចរចារបស់ភាគីពាក់ព័ន្ធនឹងការចរចា ។ ក្នុងគោលបំណងនេះ អ្នកខ្ចី/អតិថិជន នឹងជួលភាគីឯករាជ្យពីខាងក្រៅឱ្យកត់ត្រាដំណើរការចរចា និងដោះស្រាយ ។ អ្នកខ្ចី/អតិថិជន នឹងព្រមព្រៀងជាមួយ ADB ពីដំណើរការពិគ្រោះយោបល់ គោលនយោបាយ និងច្បាប់ដែលអនុវត្តចំពោះការចរចានេះ ការបញ្ជាក់ទទួលស្គាល់ភាគីទី ៣ យន្តការគណនាសោហ៊ុយចំណាយក្នុងការដោះដូរដី និងទ្រព្យសកម្មផ្សេងទៀត និងលក្ខខណ្ឌតម្រូវក្នុងការរក្សាទុកកំណត់ត្រានានា ។

## ៥. ការផ្តល់ព័ត៌មាន

២៦. អ្នកខ្ចី/អតិថិជន នឹងផ្ញើឱ្យ ADB នូវឯកសារដូចខាងក្រោមដើម្បីផ្សព្វផ្សាយនៅលើគេហទំព័ររបស់ ADB :

(i) សេចក្តីព្រាងផែនការតាំងទីលំនៅជាថ្មី និង/ឬ ក្របខណ្ឌតាំងទីលំនៅជាថ្មីដែលឯកភាពទទួលស្គាល់ដោយអ្នកខ្ចី/អតិថិជននៅមុនពេលវាយតម្លៃគម្រោង ។

(ii) ផែនការតាំងទីលំនៅជាថ្មីចុងក្រោយ ដែលឯកភាពទទួលស្គាល់ដោយអ្នកខ្ចី/អតិថិជន នៅក្រោយការបញ្ចប់ការធ្វើជំរឿនក្រុមមនុស្សរងផលប៉ះពាល់ ។

(iii) ផែនការតាំងទីលំនៅជាថ្មី ឬដែលបានធ្វើបច្ចុប្បន្នភាព និងផែនការសកម្មភាពកែតម្រូវដែលបានរៀបចំនៅអំឡុងពេលអនុវត្តគម្រោង ប្រសិនបើមាន ។ និង

(iv) របាយការណ៍តាមដានការតាំងទីលំនៅជាថ្មី ។

២៧. អ្នកខ្ចី/អតិថិជន នឹងផ្តល់ព័តិមានពាក់ព័ន្ធនឹងការតាំងទីលំនៅជាថ្មី រួមទាំងព័តិមានដែលមានក្នុងឯកសារទាំងឡាយនៃកថាខណ្ឌ ២៦ ឱ្យបានទាន់ពេលវេលា និងត្រូវផ្តល់ឱ្យនៅកន្លែង និងក្នុងទម្រង់ និងភាសាដែលក្រុមមនុស្សរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធអាចយល់បាន ។ ចំពោះអ្នកមិនចេះអក្សរ វិធីសាស្ត្រទំនាក់ទំនងសមស្របផ្សេងទៀតនឹងត្រូវយកមកប្រើ ។

## ៦. ការពិគ្រោះយោបល់ និង ការចូលរួម

២៨. អ្នកខ្ចី/អតិថិជន នឹងធ្វើការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយក្រុមមនុស្សរងផលប៉ះពាល់ សហគមន៍របស់ពួកគាត់ និងសង្គមស៊ីវិល ចំពោះរាល់គ្រប់គម្រោង និងអនុគម្រោងដែលកំណត់ថាមានការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ។ ការពិគ្រោះ យោបល់ពោរពេញដោយអត្ថន័យ គឺជាដំណើរការដែល (១) ចាប់ផ្តើមនៅដើមដំណាក់កាលនៃការរៀបចំគម្រោង និងបន្តធ្វើជាប់ជានិច្ចនៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង (២) ធ្វើការផ្តល់ព័តិមានពាក់ព័ន្ធ និងសមស្របទាន់ពេលវេលា និងជាព័តិមានដែលក្រុមមនុស្សរងផលប៉ះពាល់អាចរកបាន និងអាចយល់បានដោយងាយស្រួល (៣) ធ្វើឡើងនៅក្នុងបរិយាកាសដែលគ្មានការគំរាមកំហែង និងបង្ខិតបង្ខំ (៤) មានការគិតគូរពីបញ្ហាយេនឌ័រ និងមានការតម្រែតម្រង់ទៅតាមតម្រូវការក្រុមទន់ខ្សោយ និងងាយរងគ្រោះ និង (៥) អនុញ្ញាតឱ្យមានការបញ្ចូលគំនិតយោបល់របស់ក្រុមមនុស្សរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធក្នុងការធ្វើការសម្រេចចិត្តពីការរៀបចំគម្រោង វិធានការកាត់បន្ថយផលប៉ះពាល់ ការចែករំលែកអត្ថប្រយោជន៍ និងឱកាសដែលបានមកពីការអភិវឌ្ឍន៍ និងបញ្ហាអនុវត្តគម្រោង ។ ទំហំនៃការពិគ្រោះយោបល់ នឹងធ្វើឡើងសមមាត្រទៅនឹងផលប៉ះពាល់ដែលមានទៅលើសហគមន៍រងផលប៉ះពាល់ ។ អ្នកខ្ចី/អតិថិជន នឹងធ្វើការចាប់អារម្មណ៍ជាពិសេសចំពោះតម្រូវការរបស់ក្រុមទន់ខ្សោយ ឬងាយរងគ្រោះ ជាពិសេសក្រុមមនុស្សរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ អ្នកគ្មានដីធ្លី ចាស់ជរា ស្ត្រីមេគ្រួសារ ស្ត្រី និងកុមារ ក្រុមជនជាតិភាគតិច និងអ្នកគ្មានសិទ្ធិកម្មសិទ្ធិដី ។

## ៧. យន្តការដោះស្រាយបណ្តឹងតវ៉ា

២៩. អ្នកខ្ចី/អតិថិជន នឹងបង្កើតយន្តការទទួល និងសម្របសម្រួលដោះស្រាយក្តីបារម្ភ និងពាក្យបណ្តឹងរបស់ក្រុមមនុស្សរងផលប៉ះពាល់ អំពីការផ្លាស់ទីលំនៅរូបវន្ត និងសេដ្ឋកិច្ច និងផលប៉ះពាល់ផ្សេងទៀតរបស់គម្រោង ដោយយកចិត្តទុកដាក់ជាពិសេសចំពោះផលប៉ះពាល់លើក្រុមងាយរងគ្រោះ ។ យន្តការដោះស្រាយបណ្តឹងតវ៉ា ត្រូវមានទំហំសមមាត្រនឹងផលប៉ះពាល់អវិជ្ជមាន និងហានិភ័យរបស់គម្រោង ។ យន្តការនេះ ត្រូវតែអាចដោះស្រាយក្តីបារម្ភ និងបណ្តឹងតវ៉ារបស់ក្រុមមនុស្សរងផលប៉ះពាល់បានឆាប់រហ័ស ដោយប្រើប្រាស់នូវដំណើរការដែលងាយយល់ និងមានតម្លាភាព និងដែលមានការគិតគូរពីយេនឌ័រ មានលក្ខណៈសមស្របខាងវប្បធម៌ និងអាចប្រើប្រាស់បានដោយក្រុមមនុស្សរងផលប៉ះពាល់ ដោយមិនគិតថ្លៃ និងដោយគ្មានសងសឹក ។ យន្តការនេះមិនត្រូវបង្កឱ្យមានឧបសគ្គដល់ការប្រើប្រាស់ដំណើរការដោះស្រាយវិវាទតាមរយៈប្រព័ន្ធយុត្តាធិការ ឬប្រព័ន្ធរដ្ឋបាលរបស់រដ្ឋឡើយ ។ អ្នកខ្ចី/អតិថិជន នឹងផ្តល់ព័តិមានពីយន្តការនេះដល់ក្រុមមនុស្សរងផលប៉ះពាល់ ។

## ៨. ការតាមដាន និង ការរាយការណ៍

៣០. អ្នកខ្ចី/អតិថិជន នឹងធ្វើការតាមដាន និងវាស់ស្ទង់ការវិវត្តការនៃការអនុវត្តផែនការតាំងទីលំនៅជាថ្មី។ ទំហំនៃសកម្មភាពតាមដាន ត្រូវសមមាត្រជាមួយនឹងផលប៉ះពាល់ និងហានិភ័យរបស់គម្រោង។ ក្រៅពីការកត់ត្រាការវិវត្តក្នុងការបង់សំណងទូទាត់ និងសកម្មភាពតាំងទីលំនៅជាថ្មី អ្នកខ្ចី/អតិថិជននឹងរៀបចំរបាយការណ៍តាមដាន ដើម្បីធានាថាការអនុវត្តផែនការតាំងទីលំនៅជាថ្មីផ្តល់នូវផ្លែផ្កាដែលចង់បាន។ សម្រាប់គម្រោងដែលមានការតាំងទីលំនៅជាថ្មីធ្ងន់ធ្ងរ អ្នកខ្ចី/អតិថិជន នឹងជួលអ្នកជំនាញពីខាងក្រៅដែលមានគុណវុឌ្ឍិ និងមានបទពិសោធន៍ ឬ NGO ដែលមានគុណវុឌ្ឍិ ឱ្យធ្វើការបញ្ជាក់លើព័ត៌មានតាមដានរបស់ខ្លួន។ អ្នកជំនាញពីខាងក្រៅដែលអ្នកខ្ចី/អតិថិជនជួលមក នឹងផ្តល់យោបល់លើបញ្ហាអនុវត្តតាមលក្ខខណ្ឌតម្រូវសម្រាប់ការពារ ហើយក្នុងករណីមានបញ្ហាការតាំងទីលំនៅជាថ្មីធ្ងន់ធ្ងរ ផែនការសកម្មភាពកែតម្រូវនឹងត្រូវរៀបចំឡើងដើម្បីដោះស្រាយបញ្ហាទាំងនោះ។ រហូតទាល់តែឯកសាររៀបចំផែនការទាំងនេះត្រូវបានរៀបចំ ផ្សព្វផ្សាយ និងទទួលបានការឯកភាព អ្នកខ្ចី/អតិថិជន នឹងមិនបន្តអនុវត្តសមាសភាគជាក់លាក់ណាមួយរបស់គម្រោងដែលបណ្តាលឱ្យមានការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តឡើយ។

៣១. អ្នកខ្ចី/អតិថិជន នឹងរៀបចំរបាយការណ៍តាមដានប្រចាំឆមាស ដែលនឹងរៀបរាប់ពីការវិវត្តនៃការអនុវត្តសកម្មភាពតាំងទីលំនៅជាថ្មី និងបញ្ហាអនុវត្តតាម និងសកម្មភាពកែតម្រូវផ្សេងទៀត។ របាយការណ៍នេះ នឹងតាមមើលសូចនាករតាមដានការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ដែលបានព្រមព្រៀងនៅពេលឯកភាពទទួលស្គាល់ផែនការតាំងទីលំនៅជាថ្មី។ សោហ៊ុយចំណាយក្នុងការតាមដានទាំងក្នុងទាំងក្រៅ នឹងបញ្ចូលក្នុងកញ្ចប់ថវិកាគម្រោង។

## ៩. ផលប៉ះពាល់ដែលមិនបានគិតទុក

៣២. ប្រសិនបើការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តឥតព្រាងទុកត្រូវបានរកឃើញនៅអំឡុងពេលអនុវត្តគម្រោង អ្នកខ្ចី/អតិថិជន នឹងរៀបចំការរៀបចំវាយតម្លៃផលប៉ះពាល់សង្គម និងធ្វើបច្ចុប្បន្នភាពផែនការតាំងទីលំនៅជាថ្មី ឬរៀបចំផែនការតាំងទីលំនៅថ្មី ដែលមានក្តោបនូវរាល់លក្ខខណ្ឌតម្រូវចាំបាច់ដែលមានកំណត់ក្នុងឯកសារនេះ។

## ១០. ការគិតគូរជាពិសេសចំពោះក្រុមជនជាតិដើមភាគតិច

៣៣. អ្នកខ្ចី/អតិថិជន នឹងព្យាយាមសិក្សាស្វែងរកប្លង់រៀបចំគម្រោងផ្សេងទៀត ដើម្បីបញ្ចៀសការផ្លាស់ទីក្រុមជនជាតិដើមភាគ-តិច ព្រោះថាការផ្លាស់ទីនេះអាចនឹងផ្តល់ផលប៉ះពាល់អវិជ្ជមានចំពោះអត្តសញ្ញាណ វប្បធម៌ និងទំនៀមទំលាប់ចិញ្ចឹមជីវិតរបស់ពួកគេ។ ប្រសិនបើការបញ្ចៀសមិនអាចធ្វើទៅបាន ផែនការចម្រុះរវាងផែនការក្រុមជនជាតិដើមភាគតិច និងផែនការតាំងទីលំនៅជាថ្មី នឹងរៀបចំឡើង ដោយមានការពិគ្រោះយោបល់ជាមួយ ADB ដើម្បីដោះស្រាយបញ្ហាការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និងបញ្ហាក្រុមជនជាតិដើមភាគតិច។ ផែនការចម្រុះនេះ ក៏ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវពាក់ព័ន្ធដែលមានកំណត់ក្នុងលក្ខខណ្ឌតម្រូវសម្រាប់ការពារ ៣ ផងដែរ។

# គ្រោងនៃផែនការតាំងទីលំនៅជាថ្មី

គ្រោងនេះជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវសម្រាប់ការពារ ២។ ផែនការតាំងទីលំនៅជាថ្មីតម្រូវឱ្យមានគ្រប់គម្រោងទាំងអស់ដែលមានការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត។ កម្រិតនៃភាពលម្អិត និងទូលំទូលាយនៃផែនការនេះ ត្រូវតែសមមាត្រជាមួយនឹងទំហំនៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និងហានិភ័យដែលអាចមាន។ ចំណុចសំខាន់ៗនៃគ្រោងនេះ នឹងជួយផ្តល់ជាមគ្គុទេសក៍ក្នុងការរៀបចំផែនការតាំងទីលំនៅជាថ្មី តែមិនតម្រូវថាចាំបាច់ត្រូវតែធ្វើតាមលំដាប់ដែលបានបង្ហាញជូននេះទេ។

## ក. សង្ខេបប្រតិបត្តិ

ផ្នែកនេះផ្តល់នូវការរៀបរាប់ដោយសង្ខេបអំពីទំហំគម្រោង លទ្ធផលអង្កេតសំខាន់ៗ សិទ្ធិ និងសកម្មភាពជាអនុសាសន៍។

## ខ. ការពិពណ៌នាពីគម្រោង

ផ្នែកនេះផ្តល់នូវការពិពណ៌នាជាទូទៅពីគម្រោង ពិភាក្សាពីសមាសភាគគម្រោងដែលនឹងបណ្តាលឱ្យមានលទ្ធកម្មដី ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ឬបញ្ហាទាំងពីរនេះ និងកំណត់តំបន់គម្រោង។ ផ្នែកនេះក៏នឹងរៀបរាប់ពីជម្រើសផ្សេងទៀតដែលត្រូវបានលើកយកមកពិចារណាដើម្បីបញ្ចៀស ឬកាត់បន្ថយការតាំងទីលំនៅជាថ្មី។ ផ្នែកនេះក៏នឹងមានបញ្ចូលផងដែរនូវតារាងទិន្នន័យបរិមាណ និងមូលហេតុនៃការធ្វើការសម្រេចចិត្តចុងក្រោយ។

## គ. ទំហំនៃលទ្ធកម្មដី និង ការតាំងទីលំនៅជាថ្មី

ផ្នែកនេះ នឹង:

(i) ពិភាក្សាពីផលប៉ះពាល់ដែលអាចមានរបស់គម្រោង និងផែនទីនៃតំបន់ ឬបរិវេណនៃផលប៉ះពាល់ដែលអាចបណ្តាលមកពីសមាសភាគ ឬសកម្មភាពគម្រោង។

(ii) ពិភាក្សាពីទំហំនៃលទ្ធកម្មដី (ដោយផ្តល់ផែនទី) និងពន្យល់ពីមូលហេតុនៃភាពចាំបាច់នៃការធ្វើលទ្ធកម្មដី ចំពោះគម្រោងវិនិយោគមេ។

(iii) សង្ខេបពីលទ្ធផលចំបងៗចំពោះទ្រព្យលទ្ធកម្ម និងអ្នកបាត់បង់លំនៅដ្ឋាន។ និង

(iv) ផ្តល់សេចក្តីលម្អិតពីធនធានទ្រព្យរួមដែលនឹងត្រូវធ្វើលទ្ធកម្ម។

## ឃ. ព័ត៌មាន និង ទម្រង់ទូទៅនៃសង្គម-សេដ្ឋកិច្ច

ផ្នែកនេះរៀបរាប់ត្រួសៗពីលទ្ធផលនៃការវាយតម្លៃផលប៉ះពាល់សង្គម ការធ្វើជំរឿន និងការសិក្សាផ្សេងទៀត ដោយមានទិន្នន័យ និង/ឬ ព័ត៌មានបែកចែកទៅតាមយេនឌ័រ ភាពងាយរងគ្រោះ និងក្រុមសង្គមផ្សេងទៀត ដូចជា :

(i) ផ្តល់និយមន័យ កំណត់អត្តសញ្ញាណ និងរៀបរាប់ពីមនុស្ស និងសហគមន៍ដែលនឹងត្រូវរងការប៉ះពាល់ ។

(ii) ពិពណ៌នាពីផលប៉ះពាល់នៃលទ្ធកម្មដី និងទ្រព្យសកម្មចំពោះមនុស្ស និងសហគមន៍រងផលប៉ះពាល់ ដោយពិចារណាទៅលើប៉ារ៉ាម៉ែត្រសង្គម វប្បធម៌ និងសេដ្ឋកិច្ច ។

(iii) ពិភាក្សាពីផលប៉ះពាល់របស់គម្រោងចំពោះជនក្រីក្រ ក្រុមជនជាតិដើមភាគតិច និងក្រុមងាយរងគ្រោះផ្សេងទៀត ។ និង

(iv) កំណត់អត្តសញ្ញាណយេនឌ័រ និងការតាំងទីលំនៅជាថ្មី និងស្ថានភាពសង្គម-សេដ្ឋកិច្ច ផលប៉ះពាល់ តម្រូវការ និងអាទិភាពរបស់ស្ត្រី ។

## ខ. ការផ្តល់ព័ត៌មាន ការពិគ្រោះយោបល់ និង ការចូលរួម

ផ្នែកនេះ នឹង:

(i) កំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធនឹងគម្រោង ជាពិសេស អ្នកពាក់ព័ន្ធបឋម ។

(ii) រៀបរាប់ពីយន្តការនៃការពិគ្រោះយោបល់ និងការចូលរួមដែលត្រូវយកមកប្រើ នៅក្នុងដំណាក់កាលផ្សេងៗនៃវដ្តគម្រោង ។

(iii) រៀបរាប់ពីសកម្មភាពដែលត្រូវធ្វើដើម្បីផ្សព្វផ្សាយព័ត៌មានពីគម្រោង និងការតាំងទីលំនៅជាថ្មី នៅអំឡុងពេលរៀបចំគម្រោង និងការរៀបចំត្រៀមជួបជាមួយអ្នកពាក់ព័ន្ធ ។

(iv) សង្ខេបលទ្ធផលនៃការពិគ្រោះយោបល់ជាមួយក្រុមមនុស្សរងផលប៉ះពាល់ (រួមទាំងសហគមន៍ម្ចាស់ផ្ទះ) និងពិភាក្សាពីរបៀបដោះស្រាយក្តីបារម្ភ និងអនុសាសន៍ដែលបានលើកឡើង នៅក្នុងផែនការតាំងទីលំនៅជាថ្មី ។

(v) អះអាងពីការផ្សព្វផ្សាយសេចក្តីព្រាងផែនការតាំងទីលំនៅជាថ្មីប្រាប់ដល់ក្រុមមនុស្សរងផលប៉ះពាល់ និងដាក់បញ្ចូលនូវការរៀបចំផ្សព្វផ្សាយនូវផែនការបន្តបន្ទាប់ទៀត ។ និង

(vi) រៀបរាប់ពីវិធានការផ្តល់ព័ត៌មានដែលបានគ្រោងទុក (រួមមានដូចជា ប្រភេទព័ត៌មានដែលត្រូវផ្សព្វផ្សាយ និងវិធីសាស្ត្រផ្សព្វផ្សាយ) និងដំណើរការក្នុងការធ្វើការពិគ្រោះយោបល់ជាមួយក្រុមមនុស្សរងផលប៉ះពាល់នៅអំឡុងពេលអនុវត្តគម្រោង ។

## គ. យន្តការដោះស្រាយបណ្តឹងតវ៉ា

ផ្នែកនេះរៀបរាប់ពីយន្តការទទួល និងសម្របសម្រួលដោះស្រាយក្តីបារម្ភ និងពាក្យបណ្តឹងតវ៉ារបស់ក្រុមមនុស្សរងផលប៉ះពាល់ ។ ផ្នែកនេះរៀបរាប់ពីរបៀបដែលក្រុមមនុស្សរងផលប៉ះពាល់ និងក្រុមយេនឌ័រ អាចប្រើប្រាស់នីតិវិធីដោះស្រាយបណ្តឹងតវ៉ានេះ ។

## ឆ. ក្របខណ្ឌច្បាប់

ផ្នែកនេះ នឹង:

(i) រៀបរាប់ពីច្បាប់ និងបទបញ្ជាថ្នាក់ជាតិ និងថ្នាក់តំបន់ ដែលអនុវត្តចំពោះគម្រោង និងកំណត់នូវគម្លាតរវាងច្បាប់ជាតិ និងគោលនយោបាយរបស់ ADB និងពិភាក្សាពីរបៀបលប់បំបាត់គម្លាតនេះ ។

(ii) រៀបរាប់ពីការប្ដេជ្ញាច្បាប់ និងគោលនយោបាយរបស់ទីភ្នាក់ងារប្រតិបត្តិចំពោះអ្នកបាត់បង់លំនៅដ្ឋានគ្រប់ប្រភេទទាំងអស់ ។

(iii) រៀបរាប់ត្រួសៗពីគោលការណ៍ និងវិធីសាស្ត្រដែលត្រូវប្រើក្នុងការកំណត់តម្លៃ និងអត្រាទូទាត់សង ដោយគិតសោហ៊ុយចំណាយដោះដូរ ចំពោះទ្រព្យសកម្ម ប្រភពចំណូល និងមធ្យោបាយចិញ្ចឹមជីវិត និងកំណត់ពីលក្ខណៈវិនិច្ឆ័យនៃអ្នកមានសិទ្ធិទទួលបានប្រាក់ទូទាត់សង និងជំនួយឧបត្ថម្ភ និងកំណត់ពីរបៀប និងពេលវេលាដែលផ្ដល់ប្រាក់ទូទាត់សង និងជំនួយឧបត្ថម្ភនោះ ។

(iv) រៀបរាប់ពីដំណើរការលទ្ធកម្មដី និងរៀបចំកាលវិភាគដើម្បីសម្រេចឱ្យបាននូវលក្ខខណ្ឌតម្រូវផ្នែកនីតិវិធីចំបងៗ ។

## ជ. សិទ្ធិ ជំនួយឧបត្ថម្ភ និង អត្ថប្រយោជន៍

ផ្នែកនេះ នឹង :

(i) កំណត់សិទ្ធិ និងគុណវុឌ្ឍិរបស់អ្នកបាត់បង់លំនៅដ្ឋាន និងរៀបរាប់ពីវិធានការផ្ដល់ជំនួយឧបត្ថម្ភក្នុង ការតាំងទីលំនៅជាថ្មី (រួមទាំង តារាងសិទ្ធិ) ។

(ii) កំណត់ជាក់លាក់នូវជំនួយឧបត្ថម្ភចំពោះក្រុមងាយរងគ្រោះ ដូចជា ស្ត្រី និងក្រុមពិសេសផ្សេងទៀត ។ និង

(iii) រៀបរាប់ត្រួសៗពីឱកាសដែលក្រុមមនុស្សរងផលប៉ះពាល់អាចទាញយកអត្ថប្រយោជន៍ពីគម្រោង ។

## ឈ. ការផ្លាស់ទីលំនៅ និង ការតាំងទីលំនៅ

ផ្នែកនេះ នឹង :

(i) រៀបរាប់ពីជម្រើសក្នុងការផ្លាស់ទីលំនៅ និងរចនាសម្ព័ន្ធផ្សេងទៀត ដូចជា ការដោះដូរយកផ្ទះ ការដោះដូរយកសំណងទូទាត់ជាសាច់ប្រាក់ និង/ឬ ការជ្រើសរើសដោយខ្លួនឯង (ដោយធានាថា បញ្ហាយេនឌ័រ និងការគាំទ្រដល់ក្រុមងាយរងគ្រោះត្រូវបានកំណត់) ។

(ii) រៀបរាប់ពីការពិចារណាពីតំបន់ផ្លាស់ទីលំនៅផ្សេងទៀត ការពិគ្រោះយោបល់ជាមួយសហគមន៍ និងផ្តល់មូលហេតុនៃការសម្រេចយកតំបន់ដែលបានជ្រើសរើស រួមទាំង សេចក្តីលម្អិតពីទីតាំង ការវាយតម្លៃបរិស្ថានទីតាំង និងតម្រូវការក្នុងការអភិវឌ្ឍន៍ ។

(iii) ផ្តល់នូវកាលវិភាគក្នុងការរៀបចំ និងផ្ទេរទីតាំង ។

(iv) រៀបរាប់ពីការរៀបចំផ្នែកច្បាប់ដើម្បីផ្តល់ និងផ្ទេរសិទ្ធិកម្មសិទ្ធិដល់ក្រុមមនុស្សដែលត្រូវតាំងទីលំនៅជាថ្មី ។

(v) រៀបរាប់គ្រួស១ពីវិធានការជួយដល់អ្នកបាត់បង់លំនៅដ្ឋានក្នុងការផ្លាស់ទីលំនៅ និងសាងសង់ទីលំនៅនៅតំបន់ថ្មី ។

(vi) រៀបរាប់ពីផែនការផ្តល់ហេដ្ឋានរចនាសម្ព័ន្ធស៊ីវិល ។ និង

(vii) ពន្យល់ពីរបៀបធ្វើសមាហរណកម្មជាមួយប្រជាជនម្ចាស់ផ្ទះ ។

## ៧. ការស្តារ និង នីតិសម្បទានប្រភពចំណូល

ផ្នែកនេះ នឹង :

(i) កំណត់ហានិភ័យមធ្យោបាយចិញ្ចឹមជីវិត និងរៀបចំតារាងបែងចែកតាមទិន្នន័យប្រជាសាស្ត្រ និងប្រភពមធ្យោ-បាយចិញ្ចឹមជីវិត ។

(ii) រៀបរាប់ពីកម្មវិធីស្តារប្រភពចំណូល រួមទាំង ពហុជម្រើសក្នុងការស្តារមធ្យោបាយចិញ្ចឹមជីវិតគ្រប់ប្រភេទ ( ឧ. ការចែករំលែកអត្ថប្រយោជន៍គម្រោង ផែនការចែករំលែកផលលាភ ស្តុករួមសម្រាប់ការបែងចែកសមធម៌ ដូចជា ដី និងពិភាក្សាពីនិរន្តរភាព និងផែនការបម្រុងសុវត្ថិភាព ។)

(iii) រៀបរាប់គ្រួស១ពីវិធានការផ្តល់ផែនការបម្រុងសុវត្ថិភាពសង្គមតាមរយៈការធានារ៉ាប់រងសង្គម និង/ឬ មូលនិធិពិសេសរបស់គម្រោង ។

(iv) រៀបរាប់ពីវិធានការពិសេសក្នុងការគាំទ្រដល់ក្រុមងាយរងគ្រោះ ។

(v) ពន្យល់ពីការគិតគូរដល់បញ្ហាយេនឌ័រ ។ និង

(vi) រៀបរាប់ពីកម្មវិធីបណ្តុះបណ្តាល ។

## ៨. កញ្ចប់ថវិកាសម្រាប់ការតាំងទីលំនៅជាថ្មី និង ផែនការហិរញ្ញប្បទាន

ផ្នែកនេះ នឹង :

(i) ផ្តល់នូវខ្ទង់ថវិកាសម្រាប់ចំណុចនីមួយ១នៃសកម្មភាពតាំងទីលំនៅជាថ្មី រួមទាំង ថវិកាសម្រាប់អង្គភាពតាំងទី

លំនៅជាថ្មី ការបណ្តុះបណ្តាលបុគ្គលិក ការតាមដាន និងវាយតម្លៃ និងការរៀបចំផែនការតាំងទីលំនៅជាថ្មី នៅអំឡុងពេលអនុវត្តប្រាក់កម្ចី ។

(ii) រៀបរាប់ពីលំហូរមូលនិធិ (កញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់ការតាំងទីលំនៅជាថ្មី ត្រូវមានបង្ហាញពីផែនការចំណាយសម្រាប់ចំណុចសំខាន់ៗ) ។

(iii) ផ្តល់មូលហេតុនៃការសន្មតដែលប្រើសម្រាប់ការគណនាអត្រាទូទាត់សង និងសោហ៊ុយចំណាយប៉ាន់ស្មានដទៃទៀត (ដោយគិតទាំងប្រាក់បម្រុងរូបវន្ត និងសោហ៊ុយចំណាយបម្រុង) ព្រមទាំងសោហ៊ុយចំណាយដោះដូរ ។

(iv) ផ្តល់នូវព័ត៌មានអំពីប្រភពមូលនិធិនៃកញ្ចប់ថវិកាសម្រាប់ផែនការតាំងទីលំនៅជាថ្មី ។

## ថ. ការរៀបចំស្ថាប័ន

ផ្នែកនេះ នឹង :

(i) រៀបរាប់ពីការរៀបចំស្ថាប័ន ការទទួលខុសត្រូវ និងយន្តការអនុវត្តវិធានការដែលកំណត់ដោយផែនការតាំងទីលំនៅជាថ្មី ។

(ii) រៀបរាប់ពីកម្មវិធីកសាងសមត្ថភាពស្ថាប័ន រួមទាំង ការផ្តល់ជំនួយបច្ចេកទេស ប្រសិនបើចាំបាច់ ។

(iii) រៀបរាប់ពីតួនាទីរបស់ NGO ប្រសិនបើមានពាក់ព័ន្ធ និងអង្គការនៃក្រុមមនុស្សរងផលប៉ះពាល់ នៅក្នុងការរៀបចំ និងគ្រប់គ្រងផែនការតាំងទីលំនៅជាថ្មី ។ និង

(iv) រៀបរាប់ពីរបៀបដែលក្រុមស្ត្រីអាចចូលរួមក្នុងការរៀបចំ និងគ្រប់គ្រងផែនការតាំងទីលំនៅជាថ្មី ។

## ឱ. កម្មវិធីអនុវត្ត

ផ្នែកនេះរៀបរាប់ពីកម្មវិធីលម្អិតក្នុងការអនុវត្តសកម្មភាពសំខាន់ៗក្នុងការស្តារនីតិសម្បទាន និងការតាំងទីលំនៅជាថ្មី ។ កម្មវិធីអនុវត្តនេះ ត្រូវក្តោបគ្រប់ទិដ្ឋភាពទាំងអស់នៃសកម្មភាពតាំងទីលំនៅជាថ្មី ដោយធ្វើសមកាលកម្មជាមួយកម្មវិធីការងារសាងសង់ស៊ីវិលរបស់គម្រោង និងផ្តល់នូវដំណើរការលទ្ធកម្មដី និងបន្ទាត់ពេលវេលា ។

## ឍ. ការតាមដាន និង ការរាយការណ៍

ផ្នែកនេះរៀបរាប់ពីយន្តការ និងកម្រិតគោលសមស្រប ក្នុងការតាមដាន និងវាយតម្លៃការអនុវត្តផែនការតាំងទីលំនៅជាថ្មី ។ ផ្នែកនេះកំណត់ជាក់លាក់ពីផែនការចូលរួមរបស់ក្រុមមនុស្សរងផលប៉ះពាល់ក្នុងដំណើរការតាមដាន ។ ផ្នែកនេះក៏នឹងរៀបរាប់ផងដែរពីនីតិវិធីក្នុងការរាយការណ៍ ។

# លក្ខខណ្ឌតម្រូវសម្រាប់ការពារ ៣ : ក្រុមជនជាតិដើមភាគតិច

## ក. សេចក្តីផ្តើម

១. សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិក្រុមជនជាតិដើមភាគតិច ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅខែ កញ្ញា ឆ្នាំ ២០០៧។ ប្រទេសជាច្រើននៅអាស៊ី និងប៉ាស៊ីហ្វិក បានបោះឆ្នោតគាំទ្រដល់សេចក្តីប្រកាសឥតភ្ជាប់កាតព្វកិច្ចនេះ។ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ទទួលស្គាល់សិទ្ធិរបស់ក្រុមជនជាតិដើមភាគតិចក្នុងតម្រង់ទិសដៅអភិវឌ្ឍន៍របស់ពួកគេ។ ជាធម្មតា ក្រុមជនជាតិដើមភាគតិច មិនបានទទួលអត្ថប្រយោជន៍ដោយស្វ័យប្រវត្តិពីការអភិវឌ្ឍន៍ ដែលជាទូទៅត្រូវបានរៀបចំផែនការ និងអនុវត្តដោយក្រុមជនជាតិភាគច្រើន ឬមានឧត្តមភាព នៅក្នុងប្រទេសដែលពួកគេរស់នៅ។ កិច្ចខិតខំប្រឹងប្រែងជាពិសេសជាការចាំបាច់ដើម្បីភ្ជាប់ក្រុមជនជាតិដើមភាគតិចក្នុងការរៀបចំកម្មវិធីអភិវឌ្ឍន៍ដែលមានឥទ្ធិពលចំពោះពួកគេ ជាពិសេសកម្មវិធីអភិវឌ្ឍន៍ដែលរៀបចំឡើងដើម្បីបំពេញសេចក្តីត្រូវការ និងសេចក្តីប្រាថ្នាជាក់លាក់របស់ពួកគេ។ ក្រុមជនជាតិដើមភាគតិចកំពុងរងគ្រោះកាន់តែខ្លាំងឡើងៗ ដោយសារតែកម្មវិធីអភិវឌ្ឍន៍ចេះតែទន្រ្ទានចូលតំបន់ដែលពួកគេកាន់កាប់ រស់នៅ ប្រើប្រាស់ជាប្រពៃណី និងចាត់ទុកថាជាដីកេរតំណែលរបស់ដូនតា។

២. លក្ខខណ្ឌតម្រូវសម្រាប់ការពារ ៣ កំណត់ពីលក្ខខណ្ឌតម្រូវដែលអ្នកខ្ចី/អតិថិជនត្រូវបំពេញ ដើម្បីផ្តល់នូវការការពារដល់ក្រុមជនជាតិដើមភាគតិច ចំពោះគម្រោងដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ លក្ខខណ្ឌតម្រូវនេះ ពិភាក្សាពីកម្មវត្ថុ និងទំហំនៃការអនុវត្ត និងគូសបញ្ជាក់ពីលក្ខខណ្ឌតម្រូវដែលពាក់ព័ន្ធនឹង (១) ដំណើរការវាយតម្លៃផលប៉ះពាល់សង្គម និងការរៀបចំផែនការ (២) ការរៀបចំរបាយការណ៍វាយតម្លៃផលប៉ះពាល់សង្គម និងឯកសាររៀបចំផែនការ (៣) ការផ្សព្វផ្សាយព័ត៌មាន និងការពិគ្រោះយោបល់ រួមទាំង ការបញ្ជាក់ពីការយល់ព្រមរបស់សហគមន៍ជនជាតិដើមភាគតិចចំពោះសកម្មភាពគម្រោងជាក់លាក់ណាមួយ (៤) ការបង្កើតយន្តការដោះស្រាយបណ្តឹងតវ៉ា និង (៥) ការតាមដាន និងការរាយការណ៍។ បណ្តុំនៃលក្ខខណ្ឌតម្រូវគោលនយោបាយទាំងនេះ នឹងការពារសិទ្ធិក្រុមជនជាតិដើមភាគតិចក្នុងការរក្សា និងការពារអត្តសញ្ញាណវប្បធម៌ ទម្លាប់អនុវត្ត និងទីជំរករបស់ពួកគេ និងដើម្បីធានាថាគម្រោងដែលប៉ះពាល់ដល់ពួកគេ នឹងចាត់វិធានការចាំបាច់នានាដើម្បីការពារសិទ្ធិទាំងនេះ។

## ខ. កម្មវត្ថុ

៣. កម្មវត្ថុ គឺដើម្បីរៀបចំ និងអនុវត្តគម្រោងក្នុងវិធីសាស្រ្តដែលជម្រុញការគោរពអត្តសញ្ញាណ សេចក្តីថ្លៃថ្នូរ សិទ្ធិមនុស្ស មធ្យោបាយចិញ្ចឹមជីវិត និងវប្បធម៌របស់ក្រុមជនជាតិដើមភាគតិច ដែលកំណត់ដោយក្រុមជនជាតិដើមភាគតិចដោយខ្លួនឯង ដើម្បីឱ្យពួកគេ (១) អាចទទួលបានអត្ថប្រយោជន៍សង្គម និងសេដ្ឋកិច្ចតាមវប្បធម៌របស់ពួកគេ (២) មិនរងផលប៉ះពាល់អវិជ្ជមានដែលកើតចេញពីគម្រោង និង (៣) អាចចូលរួមយ៉ាងសកម្មក្នុងគម្រោងដែលជះឥទ្ធិពលមកលើពួកគេ។

## គ. ទំហំនៃការអនុវត្ត

៤. លក្ខខណ្ឌទាំងនេះ អនុវត្តចំពោះរាល់គ្រប់គម្រោងដែលផ្ដល់ហិរញ្ញប្បទានដោយ ADB និង/ឬ គម្រោងដែលស្ថិត និងមិនស្ថិតនៅក្រោមការគ្រប់គ្រងរដ្ឋបាលដោយ ADB រួមទាំងសមាសភាគគម្រោងទាំងនោះផង ដោយមិនគិតពីប្រភពនៃហិរញ្ញប្បទាន ព្រមទាំងគម្រោងវិនិយោគដែលផ្ដល់ហិរញ្ញប្បទានដោយប្រាក់កម្ចី និង/ឬ ជំនួយឥតសំណង និង/ឬ ដោយវិធីសាស្ត្រផ្សេងទៀត ដូចជា ការវិនិយោគភាគហ៊ុន និង/ឬ ការធានា (ហៅកាត់ជារួមថាគម្រោង)។លក្ខខណ្ឌតម្រូវនេះ ក៏គ្របដណ្ដប់ផងដែរទៅលើសកម្ម-ភាពដែលធ្វើឡើងដោយអ្នកខ្ចី/អតិថិជន ក្នុងគម្រោងដែលគាំទ្រដោយ ADB ។

៥. នៅតំបន់អាស៊ី និងបាស៊ីហ្វិក សហគមន៍ជនជាតិដើមភាគតិចនីមួយៗ មានវប្បធម៌ ប្រវត្តិសាស្ត្រ និងស្ថានភាពបច្ចុប្បន្នខុសប្លែកគ្នាយ៉ាងខ្លាំង។ បរិបទដែលពួកគេរស់នៅ មានភាពខុសប្លែកគ្នា និងប្រែប្រួលមិនដូចគ្នា ហើយគ្មាននិយមន័យដែលទទួលស្គាល់ជាសកលចំពោះពាក្យថា "ក្រុមជនជាតិដើមភាគតិច" ឡើយ។ ក្រុមជនជាតិដើមភាគតិច ត្រូវបានស្គាល់នៅក្នុងប្រទេសផ្សេងៗថា ជាក្រុមជនអន្តោគ្រាមដើមភាគតិច សហគមន៍វប្បធម៌ដើមភាគតិច អ្នកស្រុកដើម កុលសម្ព័ន្ធភ្នំ ជនជាតិភាគតិច ក្រុមកុលសម្ព័ន្ធងាយរងគ្រោះ ឬក្រុមកុលសម្ព័ន្ធ។ ក្នុងគោលបំណងប្រតិបត្តិ ក្រុមមនុស្សទាំងនេះ ត្រូវសន្មតហៅថា "ក្រុមជនជាតិដើមភាគតិច" ប្រសិនបើពួកគេមានភិនភាគសម្គាល់ ដូចមានចែងក្នុងកថាខណ្ឌ ៦។

៦. ក្នុងគោលបំណងប្រតិបត្តិ ពាក្យថា "ក្រុមជនជាតិដើមភាគតិច" ត្រូវបានប្រើជាទូទៅ សំដៅលើក្រុមវប្បធម៌ សង្គម និងក្រុមងាយរងគ្រោះខុសៗគ្នា ដែលមានភិនភាគសម្គាល់ដូចខាងក្រោម ៖

(i) ការទទួលស្គាល់ដោយខ្លួនឯងថាជាសមាជិកនៃក្រុមវប្បធម៌ជនជាតិដើម ហើយការទទួលស្គាល់អត្តសញ្ញាណនេះត្រូវបានទទួលស្គាល់ពីអ្នកដទៃ។

(ii) ភ្ជាប់រួមគ្នានឹងតំបន់ភូមិសាស្ត្ររស់នៅ ឬដែនដីដូនតាដែលស្ថិតនៅក្នុងតំបន់គម្រោង និងធនធានធម្មជាតិក្នុងតំបន់ជំរក និងដែនដីទាំងនោះ។

(iii) មានស្ថាប័ននយោបាយ សង្គម សេដ្ឋកិច្ច ឬវប្បធម៌ដាច់ដោយឡែកពីសង្គម និងវប្បធម៌ជនជាតិភាគច្រើន។

(iv) ប្រើភាសាដោយឡែកដែលជាទូទៅខុសពីភាសាផ្លូវការរបស់ប្រទេស ឬតំបន់។

៧. ក្នុងការពិចារណាពីភិនភាគសម្គាល់ទាំងនេះ ច្បាប់ជាតិ ទម្លាប់អនុវត្ត និងអនុសញ្ញាអន្តរជាតិផ្សេងទៀតដែលរដ្ឋជាភាគីនឹងត្រូវលើកយកមកពិចារណាផងដែរ។

៨. ក្រុមដែលបាត់បង់ការភ្ជាប់រួមគ្នានឹងតំបន់ភូមិសាស្ត្ររស់នៅ ឬផែនដីដូនតាដែលស្ថិតនៅក្នុងតំបន់គម្រោង ដោយសារតែការផ្ដាច់ចេញដោយមិនស្ម័គ្រចិត្ត នៅតែមានសិទ្ធិទទួលបាន នៅក្រោមគោលនយោបាយនេះ។

៩. លក្ខខណ្ឌតម្រូវសម្រាប់ការពារក្រុមជនជាតិដើមភាគតិច នឹងត្រូវលើកយកមកអនុវត្ត ប្រសិនបើគម្រោងមានការប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោល ចំពោះសេចក្ដីថ្លៃថ្នូរ សិទ្ធិមនុស្ស មធ្យោបាយចិញ្ចឹមជីវិត ឬវប្បធម៌របស់ក្រុមជនជាតិដើមភាគតិច ឬប៉ះពាល់ដល់ទឹកដី ឬធនធានធម្មជាតិ ឬវប្បធម៌ដែលក្រុមជនជាតិដើមភាគតិចកាន់កាប់ ប្រើប្រាស់ រស់នៅ ឬអះអាងថាជាទឹកដីដូនតារបស់ពួកគេ។

## ឃ. លក្ខខណ្ឌតម្រូវទូទៅ

### ១. ការពិគ្រោះយោបល់ និង ការចូលរួម

១០. អ្នកខ្ចី/អតិថិជន នឹងធ្វើការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយក្រុមជនជាតិដើមភាគតិចរងផលប៉ះពាល់ ដើម្បីធានានូវការចូលរួមរបស់ពួកគេក្នុងការ (១) រៀបចំ អនុវត្ត និងតាមដាន ដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមានចំពោះពួកគេ ឬ (ក្នុងករណីមិនបញ្ចៀសបាន) បន្ធូរបន្ថយ កាត់បន្ថយ និងទូទាត់សងផលប៉ះពាល់ទាំងនោះ និង (២) កែតម្រូវអត្ថប្រយោជន៍គម្រោងឱ្យស្របតាមវប្បធម៌របស់ពួកគេ។ ការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យ គឺជាដំណើរការដែល (១) ចាប់ផ្ដើមនៅដើមដំណាក់កាលនៃការរៀបចំគម្រោង និងបន្តធ្វើជាប់ជានិច្ចនៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង (២) ធ្វើការផ្ដល់ព័ត៌មានពាក់ព័ន្ធ និងសមស្របទាន់ពេលវេលា និងជាព័ត៌មានដែលក្រុមមនុស្សរងផលប៉ះពាល់អាចរកបាន និងអាចយល់បានដោយងាយស្រួល (៣) ធ្វើឡើងនៅក្នុងបរិយាកាសដែលគ្មានការគំរាមកំហែង និងបង្ខិតបង្ខំ (៤) មានការគិតគូរពីបញ្ហាយេនឌ័រ និងមានការតម្រែតម្រង់ទៅតាមតម្រូវការក្រុមទន់ខ្សោយ និងងាយរងគ្រោះ និង (៥) អនុញ្ញាតឱ្យមានការបញ្ចូលគំនិតយោបល់របស់ក្រុមមនុស្សរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធ ក្នុងការធ្វើការសម្រេចចិត្តពីការរៀបចំគម្រោង វិធានការកាត់បន្ថយផលប៉ះពាល់ ការចែករំលែកអត្ថប្រយោជន៍ និងឱកាសដែលបានមកពីការអភិវឌ្ឍន៍ និងបញ្ហាអនុវត្តគម្រោង។ ទំហំនៃការពិគ្រោះយោបល់ នឹងធ្វើឡើងសមមាត្រទៅនឹងផលប៉ះ-ពាល់ដែលមានទៅលើសហគមន៍រងផលប៉ះពាល់។ ដំណើរការពិគ្រោះយោបល់ និងលទ្ធផលនៃការពិគ្រោះយោបល់ នឹងត្រូវកត់ត្រាទុកជាឯកសារ និងត្រូវឆ្លុះបញ្ចាំងក្នុងរបាយការណ៍ក្រុមជនជាតិដើមភាគតិច (IPP)។

១១. ដើម្បីធ្វើការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយក្រុមជនជាតិដើមភាគតិចរងផលប៉ះពាល់ អ្នកខ្ចី/អតិថិជន នឹងបង្កើតនូវយុទ្ធសាស្ត្រផ្អែកតាមបរិបទសម្រាប់ការពិគ្រោះយោបល់មានការចូលរួមទូលំទូលាយ រួមមាន វិធីសាស្ត្រកំណត់អត្តសញ្ញាណអ្នកតំណាងក្រុមជនជាតិដើមភាគតិច និងវិធីសាស្ត្រពិគ្រោះយោបល់ដែលសមស្របនឹងសង្គម និងវប្បធម៌របស់ សហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់។ អ្នកខ្ចី/អតិថិជន នឹងយកចិត្តទុកដាក់ជាពិសេសចំពោះក្ដីបារម្ភរបស់ស្ត្រី និងយុវជនជនជាតិដើមភាគតិច។

១២. ប្រសិនបើអ្នកខ្ចី/អតិថិជន និងក្រុមជនជាតិដើមភាគតិចរងផលប៉ះពាល់យល់ឃើញផ្សេងគ្នា ឬគ្មានការឯកភាពគ្នាពីគម្រោង សមាសភាគគម្រោង ឬ IPP អ្នកខ្ចី/អតិថិជន នឹងធ្វើការចរចាដោយសុទ្ធចិត្ត ដើម្បីដោះស្រាយការយល់ឃើញខុសគ្នា និងការមិនឯកភាពគ្នានោះ។

### ២. ការវាយតម្លៃផលប៉ះពាល់សង្គម

១៣. ប្រសិនបើការពិនិត្យរបស់ ADB បញ្ជាក់នូវផលប៉ះពាល់ដែលអាចមានចំពោះក្រុមជនជាតិដើមភាគតិច អ្នកខ្ចី/អតិថិជន នឹងជួលអ្នកជំនាញដែលមានគុណវុឌ្ឍិ និងមានបទពិសោធន៍ ឱ្យធ្វើការវាយតម្លៃផលប៉ះពាល់សង្គម (SIA) ពេញលេញ ហើយប្រសិនបើផលប៉ះពាល់ចំពោះក្រុមជនជាតិដើមភាគតិចត្រូវបានកំណត់ អ្នកខ្ចី/អតិថិជន នឹងរៀបចំ IPP រួមជាមួយនឹងការសិក្សា

សមិទ្ធិលទ្ធភាព។ ផលប៉ះពាល់ និងហានិភ័យសង្គមដែលអាចកើតចេញពីគម្រោង នឹងត្រូវវាយតម្លៃធៀបជាមួយនឹងលក្ខខណ្ឌតម្រូវដែលកំណត់ក្នុងឯកសារនេះ និងច្បាប់ និងបទបញ្ជា ពាក់ព័ន្ធនឹងបញ្ហាក្រុមជនជាតិដើមភាគតិច ដែលនៅជាធរមាននៅក្នុងដែនយុត្តាធិការដែលត្រូវអនុវត្តគម្រោង គិតរួមទាំង កាតព្វកិច្ចដែលប្រទេសម្ចាស់ផ្ទះត្រូវបំពេញស្របតាមច្បាប់អន្តរជាតិផងដែរ។

១៤. ផ្អែកលើការពិនិត្យ ការធ្វើ SIA នៅមូលដ្ឋាន នឹងត្រូវរៀបចំធ្វើឡើងជាផ្នែកមួយនៃការសិក្សាសមិទ្ធិលទ្ធភាព ឬជាសកម្មភាពសិក្សាឯករាជ្យ។ SIA នឹងពិគ្រោះយោបល់ជាមួយសហគមន៍ជនជាតិដើមភាគតិច កំណត់អត្តសញ្ញាណក្រុមជនជាតិដើមភាគតិចដែលត្រូវរងផលប៉ះពាល់ពីគម្រោង និងផលប៉ះពាល់របស់គម្រោងដែលអាចកើតមានចំពោះពួកគេ ដោយក្នុងនោះនឹងមានគិតគូរពីបញ្ហាយេនឌ័រផងដែរ។ SIA នឹងផ្ដល់នូវទិន្នន័យសង្គម-សេដ្ឋកិច្ចគោលរបស់ក្រុមជនជាតិដើមភាគតិចដែលរស់នៅក្នុងតំបន់គម្រោង និងតំបន់រងផលប៉ះពាល់របស់គម្រោង។ វាយតម្លៃសិទ្ធិ និងឱកាសទទួលបានសេវាសេដ្ឋកិច្ច និងសង្គមមូលដ្ឋាន។ វាយតម្លៃផលប៉ះពាល់រយៈពេលខ្លី និងរយៈពេលវែង ដោយផ្ទាល់ និងដោយប្រយោល វិជ្ជមាន និងអវិជ្ជមាន របស់គម្រោងចំពោះក្រុមសង្គម-សេដ្ឋកិច្ច និងវប្បធម៌នីមួយៗ។ វាយតម្លៃ និងបញ្ជាក់អះអាងនូវក្រុមជនជាតិដើមភាគតិចដែលនឹងធ្វើឱ្យមានការអនុវត្តគោលនយោបាយក្រុមជនជាតិដើមភាគតិច។ វាយតម្លៃវិធីសាស្ត្រសម្រាប់ជំហានបន្ទាប់ និងធនធានដែលចាំបាច់សម្រាប់ដោះស្រាយក្ដីបារម្ភ និងបញ្ហានានាដែលប៉ះពាល់ដល់ពួកគេ។

១៥. កម្រិតនៃភាពលម្អិត និងទូលំទូលាយនៃ ISA ត្រូវតែសមមាត្រជាមួយនឹងភាពស្មុគស្មាញនៃគម្រោងដែលបានស្នើសុំ និងលក្ខណៈ និងទំហំនៃផលប៉ះពាល់ដែលអាចមានចំពោះក្រុមជនជាតិដើមភាគតិច ទោះវិជ្ជមានក្ដី ឬអវិជ្ជមានក្ដី របស់គម្រោងដែលបានស្នើសុំ។

## ៣. ការរៀបចំផែនការក្រុមជនជាតិដើមភាគតិច

១៦. ប្រសិនបើការពិនិត្យ និង ISA ចង្អុលបង្ហាញថា គម្រោងដែលបានស្នើសុំនឹងមានផលប៉ះពាល់ (វិជ្ជមាន និង/ឬ អវិជ្ជមាន) ចំពោះក្រុមជនជាតិដើមភាគតិច អ្នកខ្ចី/អតិថិជន នឹងរៀបចំ IPP ក្នុងបរិបទនៃ SIA និងតាមរយៈការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយសហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់។ IPP នឹងកំណត់នូវវិធានការដែលអ្នកខ្ចី/អតិថិជននឹងធានាថា (១) ក្រុមជនជាតិដើមភាគតិចរងផលប៉ះពាល់ទទួលបានអត្ថប្រយោជន៍សង្គម និងសេដ្ឋកិច្ចដែលសមស្របនឹងវប្បធម៌របស់ពួកគេ (២) ប្រសិនបើកំណត់បាននូវផលប៉ះពាល់អវិជ្ជមានចំពោះក្រុមជនជាតិដើមភាគតិច ផលប៉ះពាល់ទាំងនេះនឹងត្រូវបញ្ចៀសតាមលទ្ធផល ដែលអាចធ្វើទៅបាន។ ប្រសិនបើការបញ្ចៀសមិនអាចធ្វើទៅបាន IPP នឹងរៀបរាប់ត្រួសៗពីវិធានការបន្ធូរបន្ថយ កាត់បន្ថយ និងទូទាត់សងចំពោះផលប៉ះពាល់អវិជ្ជមាននោះ ផ្អែកតាមការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយសហគមន៍ជនជាតិដើមភាគតិច។ កម្រិតនៃភាពលម្អិត និងទូលំទូលាយនៃ IPP (ឧបសម្ព័ន្ធនៃសេចក្ដីបន្ថែមនេះ) នឹងប្រែប្រួលទៅតាមគម្រោងនីមួយៗ និងលក្ខណៈនៃផលប៉ះពាល់ដែលត្រូវដោះស្រាយ។ អ្នកខ្ចី/អតិថិជន នឹងបញ្ចូលសមាសធាតុនៃ IPP ទៅក្នុងការរៀបចំគម្រោង។

១៧. ប្រសិនបើក្រុមជនជាតិដើមភាគតិចជាអ្នកទទួលអត្ថប្រយោជន៍តែម្នាក់គត់ ឬភាគច្រើនលើសលប់ពីគម្រោង[១] ហើយមានតែផលប៉ះពាល់វិជ្ជមានត្រូវបានកំណត់ សមាសធាតុនៃ IPP នឹងត្រូវដាក់បញ្ចូលទាំងស្រុងក្នុងប្លង់រៀបចំគម្រោងទាំងមូល ជំនួសឱ្យការរៀបចំ IPP ដាច់ដោយឡែក។ ក្នុងករណីនេះ ឯកសារគម្រោង នឹងមាននូវការសង្ខេបអំពីរបៀបដែលគម្រោងគោរពតាមលក្ខ-ខណ្ឌតម្រូវសម្រាប់ការពារក្រុមជនជាតិដើមភាគតិច។ ជាពិសេស នឹងមានការពន្យល់ពីរបៀបដែលលក្ខខណ្ឌតម្រូវឱ្យមានការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យត្រូវបានបំពេញ និងរបៀបដែលការទទួលបានអត្ថប្រយោជន៍ ត្រូវបានដាក់បញ្ចូលក្នុងប្លង់រចនាគម្រោង។

១៨. អ្នកខ្ចី/អតិថិជន នឹងធ្វើបច្ចុប្បន្នភាព IPP នៅក្រោយការបញ្ចប់ការបញ្ចប់ប្លង់រចនាវិស្វកម្មលម្អិត និងការអង្កេតរកមើលវិធានការលម្អិត។ IPP ដែលបានធ្វើបច្ចុប្បន្នភាព នឹងតាមដានយ៉ាងជិតដល់ចំពោះការចុះកិច្ចសន្យា និងការអនុវត្តតាមកាលវិភាគនៃសមាសភាគគម្រោង ឬអនុគម្រោងនីមួយៗ។ វិធានការកាត់បន្ថយផលប៉ះពាល់ នឹងបញ្ចៀសផលប៉ះពាល់អវិជ្ជមានចំពោះក្រុមជនជាតិដើមភាគតិច ហើយវិធានការលើកស្ទួយអត្ថប្រយោជន៍គម្រោងឱ្យសមស្របនឹងវប្បធម៌របស់ក្រុមជនជាតិដើមភាគតិច នឹងត្រូវកែសម្រួល ប៉ុន្តែលទ្ធផលដែលបានព្រមព្រៀងគ្នាក្នុងសេចក្តីព្រាង IPP មិនអាចបន្ទាប ឬកាត់បន្ថយបានឡើយ។ ប្រសិនបើក្រុមជនជាតិដើមភាគតិចថ្មីត្រូវបានកំណត់អត្តសញ្ញាណនៅមុនពេលបញ្ជូន IPP ចុងក្រោយឱ្យ ADB ការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យ ក៏នឹងត្រូវធ្វើជាមួយក្រុមថ្មីនេះផងដែរ។

១៩. អ្នកខ្ចី/អតិថិជន នឹងប្រើប្រាស់អ្នកជំនាញមានគុណវុឌ្ឍិ និងមានបទពិសោធន៍ដើម្បីរៀបចំការវាយតម្លៃផលប៉ះពាល់សង្គម និង IPP។ ចំពោះគម្រោងមានភាពស្មុគស្មាញ និងងាយរងការប៉ះពាល់ខ្លាំង ក្រុមទីប្រឹក្សាឯករាជ្យនៃអ្នកជំនាញដែលមិនពាក់ព័ន្ធនឹងគម្រោង នឹងត្រូវប្រើនៅអំឡុងពេលរៀបចំ និងអនុវត្តគម្រោង។ គម្រោងមានភាពស្មុគស្មាញ និងងាយរងការប៉ះពាល់ខ្លាំងដែលអាចផ្តល់ផលប៉ះពាល់ចំពោះក្រុមជនជាតិដើមភាគតិច ត្រូវតែមានអ្នកជំនាញក្រុមជនជាតិដើមភាគតិច ជាសមាជិកក្រុមទីប្រឹក្សា។

## ៤. ការផ្តល់ព័ត៌មាន

២០. អ្នកខ្ចី/អតិថិជន នឹងផ្តើឱ្យ ADB នូវឯកសារដូចខាងក្រោមដើម្បីផ្សព្វផ្សាយនៅលើគេហទំព័ររបស់ ADB ៖

(i) សេចក្តីព្រាង IPP និង/ឬ ក្របខណ្ឌផែនការក្រុមជនជាតិដើមភាគតិច ព្រមទាំង ការវាយតម្លៃផលប៉ះពាល់សង្គម ដែលឯកភាពទទួលស្គាល់ដោយអ្នកខ្ចី/អតិថិជននៅមុនពេលវាយតម្លៃគម្រោង។

(ii) IPP ចុងក្រោយ នៅក្រោយពេលបញ្ចប់។

(iii) IPP ថ្មី ឬដែលបានធ្វើបច្ចុប្បន្នភាព និងផែនការសកម្មភាពកែតម្រូវដែលបានរៀបចំធ្វើនៅអំឡុងពេលអនុវត្តគម្រោង ប្រសិនបើមាន។ និង

(iv) របាយការណ៍តាមដាន។

---

[១] ដូចជាក្នុងករណីប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនដូចជាបណ្តាកោះនៅតំបន់ប៉ាស៊ីហ្វិកជាដើម។

២១. អ្នកខ្ចី/អតិថិជន នឹងផ្តល់ព័ត៌មានពាក់ព័ន្ធ រួមទាំងព័ត៌មានដែលមានក្នុងឯកសារទាំងឡាយនៃកថាខណ្ឌខាងលើ ឱ្យបានទាន់ពេលវេលា និងត្រូវផ្តល់ឱ្យនៅកន្លែង និងក្នុងទម្រង់ និងភាសាដែលក្រុមជនជាតិដើមភាគតិចរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធអាចយល់បាន។ ចំពោះក្រុមជនជាតិដើមភាគតិចដែលមិនចេះអក្សរ វិធីសាស្ត្រទំនាក់ទំនងសមស្របផ្សេងទៀតនឹងត្រូវយកមកប្រើ។

### ៥. យន្តការដោះស្រាយបណ្តឹងតវ៉ា

២២. អ្នកខ្ចី/អតិថិជន នឹងបង្កើតឱ្យមាននូវយន្តការមួយដើម្បីទទួល និងសម្របសម្រួលដំណោះស្រាយចំពោះក្តីបារម្ភ បណ្តឹង និងការតវ៉ារបស់ក្រុមជនជាតិដើមភាគតិចរងផលប៉ះពាល់។ យន្តការដោះស្រាយបណ្តឹងតវ៉ា ត្រូវមានទំហំសមមាត្រនឹងផលប៉ះពាល់របស់គម្រោង។ យន្តការនេះ ត្រូវតែអាចដោះស្រាយក្តីបារម្ភ និងបណ្តឹងតវ៉ាបានឆាប់រហ័ស ដោយប្រើប្រាស់នូវដំណើរការដែលងាយយល់ និងមានតម្លាភាព មានលក្ខណៈសមស្របខាងវប្បធម៌ មានការគិតគូរពីយេនឌ័រ និងអាចប្រើប្រាស់បានដោយសហគមន៍ជន-ជាតិដើមភាគតិចរងប៉ះពាល់ ដោយមិនគិតថ្លៃ និងដោយគ្មានសងសឹក។ យន្តការនេះមិនត្រូវបង្កឱ្យមានឧបសគ្គដល់ការប្រើប្រាស់ដំណើរការដោះស្រាយវិវាទតាមរយៈប្រព័ន្ធយុត្តាធិការ ឬប្រព័ន្ធរដ្ឋបាលរបស់រដ្ឋឡើយ។ សហគមន៍ក្រុមជនជាតិដើមភាគតិចរងផលប៉ះពាល់ត្រូវតែអាចទទួលបានព័ត៌មានពីយន្តការនេះឱ្យបានសមស្រប។

### ៦. ការតាមដាន និង ការរាយការណ៍

២៣. អ្នកខ្ចី/អតិថិជន នឹងធ្វើការតាមដាន និងវាស់ស្ទង់ការវិវត្តការនៃការអនុវត្ត IPP។ ទំហំនៃសកម្មភាពតាមដាន ត្រូវសម-មាត្រជាមួយនឹងផលប៉ះពាល់ និងហានិភ័យរបស់គម្រោង។ បន្ថែមលើការកត់ត្រាព័ត៌មានដើម្បីតាមដានលទ្ធផល អ្នកខ្ចី/អតិថិជន ត្រូវប្រើប្រាស់យន្តការឌីណាមិច ដូចជា ការអង្កេត និងសវនកម្ម ដើម្បីបញ្ជាក់ពីការអនុលោមតាមលក្ខខណ្ឌតម្រូវ និងការវិវត្តឆ្ពោះទៅលទ្ធផលរំពឹងទុក។ ចំពោះគម្រោងដែលអាចនឹងមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរចំពោះក្រុមជនជាតិដើមភាគតិច អ្នកខ្ចី/អតិ-ថិជន នឹងជួលអ្នកជំនាញពីខាងក្រៅដែលមានគុណវុឌ្ឍិ និងមានបទពិសោធន៍ ឬ NGO ដែលមានគុណវុឌ្ឍិ ឱ្យធ្វើការបញ្ជាក់លើព័ត៌មានតាមដានរបស់ខ្លួន។ អ្នកជំនាញពីខាងក្រៅដែលអ្នកខ្ចី/អតិថិជនបានជួលមក នឹងផ្តល់យោបល់លើបញ្ហាអនុវត្តតាមលក្ខខណ្ឌតម្រូវសម្រាប់ការពារ ហើយក្នុងករណីរកឃើញមានបញ្ហាធ្ងន់ធ្ងរចំពោះក្រុមជនជាតិដើមភាគតិច អ្នកខ្ចី/អតិថិជន នឹងរៀបចំផែនការសកម្មភាពកែតម្រូវ ឬធ្វើបច្ចុប្បន្នភាព IPP ដែលបានឯកភាព។ អ្នកខ្ចី/អតិថិជន នឹងអនុវត្តសកម្មភាពកែតម្រូវទាំងនេះ និងតាមដានការអនុវត្តសកម្មភាពទាំងនេះ ដើម្បីធានានូវប្រសិទ្ធភាពនៃការអនុវត្ត។

២៤. អ្នកខ្ចី/អតិថិជន នឹងរៀបចំរបាយការណ៍តាមដានសាមាយិក ដែលនឹងរៀបរាប់ពីការវិវត្តនៃការអនុវត្ត IPP គូសបញ្ជាក់ពីបញ្ហាអនុវត្តតាម និងសកម្មភាពកែតម្រូវ ប្រសិនបើមាន។ អ្នកខ្ចី/អតិថិជន នឹងផ្ញើរបាយការណ៍តាមដានប្រចាំឆមាសផងដែរ។ សោហ៊ុយចំណាយក្នុងការតាមដាន នឹងបញ្ចូលក្នុងកញ្ចប់ថវិកាគម្រោង។

### ៧. ផលប៉ះពាល់ឥតព្រាងទុក

២៥. ប្រសិនបើមានផលប៉ះពាល់ឥតព្រាងទុកកើតមានចំពោះក្រុមជនជាតិដើមភាគតិច ត្រូវបានរកឃើញនៅអំឡុងពេលអនុវត្ត

គម្រោង ដូចជា ការប្រែប្រួលតំបន់គម្រោង អ្នកខ្ចី/អតិថិជននឹងរៀបចំធ្វើការវាយតម្លៃផលប៉ះពាល់សង្គម និងធ្វើបច្ចុប្បន្នភាព IPP ឬរៀបចំ IPP ជាថ្មី ដែលមានក្តោបនូវរាល់លក្ខខណ្ឌតម្រូវចាំបាច់ដែលមានកំណត់ក្នុងឯកសារនេះ។

## ខ. លក្ខខណ្ឌតម្រូវពិសេស

### ១. ដីដូនតា និង ធនធានធម្មជាតិពាក់ព័ន្ធ

២៦. ក្រុមជនជាតិដើមភាគតិច មានចំណងទាក់ទងយ៉ាងជិតដិតជាមួយនឹងដី ព្រៃឈើ ទឹក សត្វព្រៃ និងធនធានធម្មជាតិផ្សេងទៀត ហេតុនេះចាំបាច់ត្រូវមានការគិតគូរជាពិសេស ប្រសិនបើមានការប៉ះពាល់ដល់ចំណងទាក់ទងនេះ។ ក្នុងករណីនេះ នៅពេលធ្វើការវាយតម្លៃផលប៉ះពាល់សង្គម និងរៀបចំ IPP អ្នកខ្ចី/អតិថិជន នឹងចាប់អារម្មណ៍ជាពិសេសចំពោះ :

(i) សិទ្ធិប្រពៃណីរបស់ក្រុមជនជាតិដើមភាគតិច ទាំងសិទ្ធិបុគ្គល និងសិទ្ធិរួម ដែលទាក់ទងទៅនឹងដីដូនតា ទឹកដី និងដែនដីដែលពួកគេកាន់កាប់ ឬប្រើប្រាស់ ឬតាំងទីលំនៅជាប្រពៃណី ហើយធនធានធម្មជាតិមានសារៈសំខាន់ចំពោះការរស់រាននៃវប្បធម៌ និងមធ្យោបាយចិញ្ចឹមជីវិតរបស់ពួកគេ។

(ii) តម្រូវការក្នុងការការពារដីដូនតា ទឹកដី និងធនធានទាំងនោះពីការរំលោភ និងទន្ទ្រានយកដោយខុសច្បាប់។

(iii) តម្លៃវប្បធម៌ និងតម្លៃខាងផ្លូវចិត្តដែលក្រុមជនជាតិដើមភាគតិចមានចំពោះទឹកដី និងធនធានទាំងនោះ។

(iv) របៀបគ្រប់គ្រងធនធានធម្មជាតិទាំងនោះរបស់ក្រុមជនជាតិដើមភាគតិច និងនិរន្តរភាពរយៈពេលពេលវែងនៃរបៀបគ្រប់គ្រងនោះ។ និង

(v) តម្រូវការក្នុងការស្តារមធ្យោបាយចិញ្ចឹមជីវិតរបស់ក្រុមជនជាតិដើមភាគតិច ដែលត្រូវបណ្តេញចេញពីដីរបស់ពួកគេ។

២៧. ប្រសិនបើគម្រោងពាក់ព័ន្ធទៅនឹងសកម្មភាពដែលពឹងផ្អែកលើការបង្កើតសិទ្ធិស្របច្បាប់ទទួលស្គាល់ទឹកដី និងដែនដីដែលក្រុមជនជាតិដើមភាគតិចកាប់កាន់ ឬប្រើប្រាស់ ឬតាំងទីលំនៅជាប្រពៃណី ដូចជា គម្រោងផ្តល់កម្មសិទ្ធិដី ឬលទ្ធកម្មដី អ្នកខ្ចី/អតិថិជននឹងបញ្ចូលផែនការសកម្មភាពដើម្បីទទួលស្គាល់សិទ្ធិប្រពៃណីដែលពួកគេមានចំពោះទឹកដី ដែនដី និងដីដូនតា នៅក្នុង IPP។ ជាធម្មតា ផែនការសកម្មភាពត្រូវធ្វើនៅមុនការអនុវត្តគម្រោង ប៉ុន្តែក្នុងករណីខ្លះចាំបាច់ត្រូវរៀបចំធ្វើក្នុងពេលជាមួយនឹងគម្រោងតែម្តង។ ការទទួលស្គាល់តាមផ្លូវច្បាប់នេះ អាចមានទម្រង់ដូចខាងក្រោម :

(i) ការទទួលស្គាល់តាមផ្លូវច្បាប់ទាំងស្រុងនូវប្រព័ន្ធសិទ្ធិកម្មសិទ្ធិដីរបស់ក្រុមជនជាតិដើមភាគតិច។ ឬ

(ii) ការបម្លែងសិទ្ធិប្រើប្រាស់ប្រពៃណីឱ្យក្លាយទៅជាសិទ្ធិកម្មសិទ្ធិសហគមន៍ និង/ឬ បុគ្គល។

២៨. ប្រសិនបើគ្មានជម្រើសណាមួយអាចធ្វើបានស្របតាមច្បាប់ជាតិ IPP នឹងបញ្ចូលនូវផែនការសកម្មភាពក្នុងការទទួលស្គាល់តាមផ្លូវច្បាប់នូវសិទ្ធិប្រើប្រាស់ ឬគ្រប់គ្រងអចិន្ត្រៃយ៍ ឬរយៈពេលវែងដែលអាចស្នើសុំជាថ្មីបាន។

២៩. លើសពីនេះទៀត ចំពោះគម្រោងដែលអាចមានផលប៉ះពាល់ចំពោះក្រុមជនជាតិដើមភាគតិច អ្នកខ្ចី/អតិថិជន នឹងធានាឱ្យមាននូវការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យ និងជួយសម្របសម្រួលដល់ការចូលរួមរបស់ពួកគេក្នុងបញ្ហាដែលជះឥទ្ធិពលមកលើពួកគេដោយផ្ទាល់ ដូចជា វិធានការកាត់បន្ថយផលប៉ះពាល់ ការបែងចែកផលប្រយោជន៍ និងឱកាសដែលកើតចេញពីគម្រោង និងផែនការអនុវត្ត។

## ២. ការយល់ព្រមរបស់សហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់

៣០. ក្រុមជនជាតិដើមភាគតិច អាចនឹងងាយរងគ្រោះជាពិសេស ប្រសិនបើគម្រោងមានសកម្មភាព (១) អភិវឌ្ឍន៍ពាណិជ្ជកម្មលើធនធានវប្បធម៌ និងចំណេះដឹងរបស់ក្រុមជនជាតិដើមភាគតិច (២) ផ្លាស់ទីលំនៅរូបវន្តចេញពីទឹកដីប្រពៃណី និង (៣) សកម្ម-ភាពអភិវឌ្ឍន៍ពាណិជ្ជកម្មលើធនធានធម្មជាតិក្នុងទឹកដីប្រពៃណី ដោយមានការប្រើប្រាស់ដែលអាចនឹងប៉ះពាល់ដល់មធ្យោបាយចិញ្ចឹមជីវិត ឬការប្រើប្រាស់ខាងវប្បធម៌ ការប្រើប្រាស់បម្រើឱ្យពិធីបុណ្យ ឬជំនឿសាសនា ដែលជាអត្តសញ្ញាណនៃសហគមន៍ជនជាតិដើមភាគតិច។ ក្នុងការសម្រេចថាគួរ ឬមិនគួរដំណើរការគម្រោងដែលមានសកម្មភាពទាំងនេះ អ្នកខ្ចី/អតិថិជន នឹងស្នើសុំការយល់ព្រមពីសហគមន៍ជនជាតិដើមភាគតិចរងប៉ះពាល់។

៣១. នៅក្នុងការអនុវត្តគោលនយោបាយ ការយល់ព្រមរបស់សហគមន៍ជនជាតិដើមភាគតិច សំដៅលើការបញ្ជាក់ជារួមរបស់សហគមន៍ជនជាតិដើមភាគតិច តាមរយៈបុគ្គលណាមួយ និង/ឬ តំណាងរបស់ពួកគេ ក្នុងការគាំទ្រជារួមពីសហគមន៍ចំពោះសកម្ម-ភាពគម្រោងដែលមានក្នុងកថាខណ្ឌ ៣០។ ការគាំទ្រជារួមពីសហគមន៍ ក៏អាចនឹងមានផងដែរ បើទោះជាមានការជំទាស់ចំពោះសកម្មភាពគម្រោងពីសំណាក់បុគ្គល ឬក្រុមមួយចំនួនក៏ដោយ។

៣២. នៅក្រោយពេលបានទទួលការគាំទ្រជារួមពីសហគមន៍ អ្នកខ្ចី/អតិថិជន នឹងផ្ដល់នូវឯកសារដែលលម្អិតពីដំណើរការ និងលទ្ធផលនៃ ការពិគ្រោះយោបល់ជាមួយក្រុមជនជាតិដើមភាគតិច និងអង្គការរបស់ក្រុមជនជាតិដើមភាគតិច រួមទាំង (១) លទ្ធផល SIA (២) ដំណើរការនៃការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយសហគមន៍ជនជាតិដើមភាគតិច (៣) វិធានការបន្ថែម ដូចជា ការកែប្រែប្លង់រៀបចំគម្រោង ដែលចាំបាច់សម្រាប់ដោះស្រាយផលប៉ះពាល់អវិជ្ជមានដែលកើតមានចំពោះក្រុមជនជាតិដើមភាគតិច និងដើម្បីផ្ដល់ឱ្យពួកគេនូវអត្ថប្រយោជន៍គម្រោងដែលសមស្របនឹងវប្បធម៌របស់ពួកគេ (៤) អនុសាសន៍ក្នុងការធ្វើការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យ និងការចូលរួមរបស់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងអំឡុងពេលអនុវត្ត តាមដាន និងវាយតម្លៃគម្រោង និង (៥) ខ្លឹមសារនៃការព្រមព្រៀងជាផ្លូវការជាមួយសហគមន៍ជនជាតិដើមភាគតិច និង/ឬ អង្គការរបស់ជនជាតិដើមភាគតិច។ អ្នកខ្ចី/អតិថិជន នឹងផ្ញើឯកសារនៃដំណើរការជួបប្អានេះ ទៅឱ្យ ADB ពិនិត្យ និងស៊ើបអង្កេត ដើម្បីធានាថាពិតជាមានការគាំទ្រជារួមពីសហគមន៍ជនជាតិដើមភាគតិចចំពោះសកម្មភាពគម្រោងប្រាកដមែន។ ADB នឹងមិនផ្ដល់ហិរញ្ញប្បទានចំពោះគម្រោងឡើយ ប្រសិនបើគ្មានការគាំទ្រជារួមពីសហគមន៍ជនជាតិដើមភាគតិចនោះទេ។

៣៣. ប្រសិនបើអ្នកខ្ចី/អតិថិជន និងក្រុមជនជាតិដើមភាគតិចរងផលប៉ះពាល់ គ្មានការឯកភាពគ្នាធ្ងន់ធ្ងរ ពីប្លង់រៀបចំ IPP ការអនុវត្តសកម្មភាពដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ពាណិជ្ជកម្មលើធនធានវប្បធម៌ ការផ្លាស់ទីលំនៅរូបវន្តរបស់ក្រុមជនជាតិដើមភាគតិច

និង/ឬ សកម្មភាពអភិវឌ្ឍន៍ពាណិជ្ជកម្មលើធនធានធម្មជាតិ អ្នកខ្ចី/អតិថិជន នឹងប្រកាន់យកនូវដំណើរការចរចាដោយសុទ្ធចិត្ត ដើម្បីដោះស្រាយការយល់ឃើញខុសគ្នា និងការមិនឯកភាពគ្នានោះ ។

៣៤. **ការអភិវឌ្ឍន៍ពាណិជ្ជកម្មលើធនធានវប្បធម៌ :** ប្រសិនបើគម្រោងមានពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ពាណិជ្ជកម្មលើធនធានវប្បធម៌ និងចំណេះដឹងរបស់ក្រុមជនជាតិដើមភាគតិច អ្នកខ្ចី/អតិថិជន នឹងធានាថា សហគមន៍រងផលប៉ះពាល់បានទទួលដឹងពី (១) សិទ្ធិដែលពួកគេមានចំពោះធនធានទាំងនោះស្របតាមច្បាប់ និងទំនៀមទំលាប់ (២) ទំហំ និងលក្ខណៈនៃការអភិវឌ្ឍន៍ពាណិជ្ជកម្មដែលបានស្នើសុំ និងភាគីពាក់ព័ន្ធនឹងការអភិវឌ្ឍន៍នោះ និង (៣) ផលប៉ះពាល់របស់គម្រោងដែលអាចកើតមានចំពោះមធ្យោបាយចិញ្ចឹមជីវិត បរិស្ថាន និងការប្រើប្រាស់ធនធានទាំងនោះដោយក្រុមជនជាតិដើមភាគតិច ។ IPP នឹងឆ្លុះបញ្ចាំងលក្ខណៈ និងខ្លឹមសារនៃការព្រមព្រៀង ហើយនឹងបញ្ចូលនូវផែនការធានាថាក្រុមជនជាតិដើមភាគតិចនឹងអាចទទួលបាននូវចំណែកសមស្របនៃអត្ថប្រយោជន៍ដែលកើតចេញពីការអភិវឌ្ឍន៍ពាណិជ្ជកម្មនោះ ដែលមានលក្ខណៈសមស្របតាមវប្បធម៌របស់ពួកគេ ។

៣៥. **ការផ្លាស់ទីលំនៅរូបវន្តរបស់ក្រុមជនជាតិដើមភាគតិច :** អ្នកខ្ចី/អតិថិជន នឹងព្យាយាមសិក្សាស្វែងរកប្លង់រៀបចំគម្រោងផ្សេងទៀត ដើម្បីបញ្ចៀសការផ្លាស់ទីក្រុមជនជាតិដើមភាគតិច ព្រោះថាការផ្លាស់ទីនេះ អាចនឹងផ្តល់ផលប៉ះពាល់អវិជ្ជ-មានចំពោះអត្តសញ្ញាណ វប្បធម៌ និងទំនៀមទំលាប់ចិញ្ចឹមជីវិតរបស់ពួកគេ ។ ក្នុងករណីលើកលែង ប្រសិនបើការបញ្ចៀសមិនអាចធ្វើទៅបាន អ្នកខ្ចី/អតិថិជននឹងរៀបចំ IPP ដែលអាចបញ្ចូលគ្នាជាមួយនឹងផែនការតាំងទីលំនៅថ្មី ។ ផែនការរួមគ្នានេះ ចាំបាច់ត្រូវតែស្របជាមួយនឹងវប្បធម៌របស់ក្រុមជនជាតិដើមភាគតិច ហើយត្រូវតែមានបញ្ចូលនូវយុទ្ធសាស្ត្រ តាំងទីលំនៅជាថ្មីដោយការផ្តល់ដី ។ ប្រសិនបើអាច ផែនការនេះ ត្រូវអនុញ្ញាតឱ្យក្រុមជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ត្រឡប់ទៅកាន់ទឹកដី និងដែនដីដែលពួកគេធ្លាប់បានកាន់កាប់ ប្រើប្រាស់ និងតាំងទីលំនៅជាប្រពៃណី ប្រសិនបើមូលហេតុនៃការផ្លាស់ទីលំនៅពួកគាត់លែងមានអត្ថិភាព ។ ផែនការ ក៏គួរតែមានបញ្ចូលនូវបទបញ្ញត្តិស្តារសម្បទានដីទាំងនោះផង ប្រសិនបើចាំបាច់ ។

៣៦. **ការអភិវឌ្ឍន៍ពាណិជ្ជកម្មលើធនធានធម្មជាតិ :** ប្រសិនបើគម្រោងមានពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ពាណិជ្ជកម្មលើធនធានធម្មជាតិ (ដូចជា រ៉ែ អ៊ីដ្រូកាបូន ព្រៃឈើ ទឹក ឬតំបន់ប្រមាញ់ និងនេសាទ) នៅក្នុងទឹកដីដែលប្រើប្រាស់ជាប្រពៃណីដោយក្រុមជនជាតិដើមភាគតិច អ្នកខ្ចី/អតិថិជន នឹងធានាថាសហគមន៍រងផលប៉ះពាល់បានទទួលដឹងពី (១) សិទ្ធិដែលពួកគេមានចំពោះធនធានទាំងនោះស្របតាមច្បាប់ និងទំនៀមទំលាប់ (២) ទំហំ និងលក្ខណៈនៃការអភិវឌ្ឍន៍ពាណិជ្ជកម្មដែលបានស្នើសុំ និងភាគីពាក់ព័ន្ធនឹងការអភិវឌ្ឍន៍នោះ និង (៣) ផលប៉ះពាល់របស់គម្រោងដែលអាចកើតមានចំពោះមធ្យោបាយចិញ្ចឹមជីវិត បរិស្ថាន និងការប្រើប្រាស់ធនធានទាំងនោះដោយក្រុមជនជាតិដើមភាគតិច ។ អ្នកខ្ចី/អតិថិជន នឹងបញ្ចូលក្នុង IPP នូវផែនការដែលអនុញ្ញាតឱ្យក្រុមជនជាតិដើមភាគតិចអាចទទួលបាននូវចំណែកសមស្របនៃអត្ថប្រយោជន៍ដែលកើតចេញពីការអភិវឌ្ឍន៍ពាណិជ្ជកម្មនោះ ដែលមានលក្ខណៈសមស្របតាមវប្បធម៌របស់ពួកគេ និង យ៉ាងហោចណាស់មានកម្រិតស្មើនឹង ឬប្រសើរជាងផលប្រយោជន៍ដែលម្ចាស់ដីរងផលប៉ះពាល់ផ្សេងទៀតទទួលបាន ។

## ៣. ក្រុមជនជាតិដើមភាគតិច និង ការអភិវឌ្ឍន៍

៣៧. ក្នុងការលើកកម្ពស់កម្មវត្ថុផ្ដល់អត្ថប្រយោជន៍ដល់ក្រុមជនជាតិដើមភាគតិច ប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក អាចស្នើសុំ ADB គាំទ្រពួកគេក្នុងការរៀបចំ ផែនការអភិវឌ្ឍន៍ និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ តាមរយៈការផ្ដល់ជំនួយហិរញ្ញវត្ថុដល់គំនិតផ្ដួចផ្ដើមនានា ដូចជា :

(i) ពង្រឹងច្បាប់ជាតិក្នុងការបង្កើតការទទួលស្គាល់តាមផ្លូវច្បាប់នូវប្រព័ន្ធសិទ្ធិកម្មសិទ្ធិដីប្រពៃណី ឬទំនៀមទម្លាប់របស់ក្រុមជនជាតិដើមភាគតិច ។

(ii) លើកកម្ពស់ការចូលរួមរបស់ក្រុមជនជាតិដើមភាគតិចក្នុងដំណើរការអភិវឌ្ឍន៍ តាមរយៈការបញ្ចូលការយល់ឃើញរបស់ពួកគាត់ក្នុងប្លង់រៀបចំនៃកម្មវិធីអភិវឌ្ឍន៍ និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងផ្ដល់ឱ្យពួកគាត់នូវឱកាសទទួលបានអត្ថប្រយោជន៍បានប្រសើរជាងមុនពីកម្មវិធីអភិវឌ្ឍន៍ តាមរយៈកំណែទម្រង់គោលនយោបាយ និងច្បាប់ ការកសាងសមត្ថភាព និងការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យ ការចូលរួម និងការផ្ដល់អំណាច ។

(iii) គាំទ្រអាទិភាពអភិវឌ្ឍន៍ក្រុមជនជាតិដើមភាគតិច តាមរយៈកម្មវិធីដែលរៀបចំដោយរដ្ឋាភិបាលសហការជាមួយក្រុមជនជាតិដើមភាគតិច ។

(iv) ដោះស្រាយបញ្ហាយេនឌ័រ និងចម្រុះជំនាន់ ដែលកើតមានក្នុងចំណោមក្រុមជនជាតិដើមភាគតិចជាច្រើន ដូចជា តម្រូវការពិសេសរបស់ស្ត្រី យុវវ័យ និងកុមារ ។

(v) រៀបចំប្រវត្តិចូលរួមរបស់ក្រុមជនជាតិដើមភាគតិច ដើម្បីកត់ត្រាពីវប្បធម៌ រចនាសម្ព័ន្ធប្រជាសាស្ត្រ យេនឌ័រ និងទំនាក់ទំនងអន្តរជំនាន់ អង្គការសង្គម ស្ថាប័ន ប្រព័ន្ធផលិតកម្ម ជំនឿសាសនា និងទម្រង់នៃការប្រើប្រាស់ធនធាន ។

(vi) ពង្រឹងសមត្ថភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងអង្គការរបស់ក្រុមជនជាតិដើមភាគតិច ក្នុងការរៀបចំ អនុវត្ត តាមដាន និងវាយតម្លៃកម្មវិធីអភិវឌ្ឍន៍ ។

(vii) ពង្រឹងសមត្ថភាពរបស់ទីភ្នាក់ងាររដ្ឋាភិបាលដែលទទួលខុសត្រូវផ្ដល់សេវាអភិវឌ្ឍន៍ដល់ក្រុមជនជាតិដើមភាគតិច ។

(viii) អភិរក្ស និងគោរពចំណេះដឹងរបស់ជនជាតិដើមភាគតិច រួមទាំងការពង្រឹងសិទ្ធិកម្មសិទ្ធបញ្ញា ។ និង

(ix) សម្របសម្រួលភាពជាដៃគូរវាងរដ្ឋាភិបាល អង្គការរបស់ក្រុមជនជាតិដើមភាគតិច អង្គការសង្គមស៊ីវិល និងវិស័យឯកជន ក្នុងការជម្រុញកម្មវិធីអភិវឌ្ឍន៍ក្រុមជនជាតិដើមភាគតិច ។

# គ្រោងនៃផែនការក្រុមជនជាតិដើមភាគតិច

គ្រោងនេះជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវសម្រាប់ការពារ ៣។ ផែនការក្រុមជនជាតិដើមភាគតិច (IPP) តម្រូវឱ្យមានគ្រប់គម្រោងទាំងអស់ដែលមានផលប៉ះពាល់ចំពោះក្រុមជនជាតិដើមភាគតិច។ កម្រិតនៃភាពលម្អិត និងទូលំទូលាយនៃរបាយការណ៍នេះ ត្រូវតែសមមាត្រជាមួយនឹងទំហំនៃផលប៉ះពាល់ដែលអាចកើតមានចំពោះក្រុមជនជាតិដើមភាគតិច។ ចំណុចសំខាន់ៗនៃគ្រោងនេះនឹងជួយផ្តល់ជាមគ្គុទេសក៏ក្នុងការរៀបចំ IPP តែមិនតម្រូវថាចាំបាច់ត្រូវតែធ្វើតាមលំដាប់ដែលបានបង្ហាញជូននេះទេ។

## ក. សង្ខេបប្រតិបត្តិនៃផែនការក្រុមជនជាតិដើមភាគតិច

ផ្នែកនេះរៀបរាប់យ៉ាងជាក់ច្បាស់ពីដំណើររឿងពិតចំបងៗ លទ្ធផលសំខាន់ៗ និងសកម្មភាពជាអនុសាសន៍។

## ខ. ការពិពណ៌នាពីគម្រោង

ផ្នែកនេះផ្តល់នូវការពិពណ៌នាជាទូទៅពីគម្រោង ពិភាក្សាពីសមាសភាគ និងសកម្មភាពគម្រោងដែលអាចនឹងបង្កផលប៉ះពាល់ដល់ក្រុមជនជាតិដើមភាគតិច និងកំណត់តំបន់គម្រោង។

## គ. ការវាយតម្លៃផលប៉ះពាល់សង្គម

ផ្នែកនេះ នឹង :

(i) ពិនិត្យក្របខណ្ឌច្បាប់ និងស្ថាប័ន ដែលអនុវត្តចំពោះក្រុមជនជាតិដើមភាគតិច ក្នុងបរិបទគម្រោង។

(ii) ផ្តល់ព័ត៌មានគោលអំពីលក្ខណៈប្រជាសាស្ត្រ សង្គម វប្បធម៌ និងនយោបាយរបស់សហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ ទឹកដី និងដែនដីដែលពួកគេកាន់កាប់ ប្រើប្រាស់ ឬតាំងទីលំនៅជាប្រពៃណី និងធនធានធម្មជាតិដែលពួកគេត្រូវពឹងអាស្រ័យលើ។

(iii) កំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធចំបងៗរបស់គម្រោង និងបង្កើតឱ្យមាននូវដំណើរការមួយដែលមានលក្ខណៈសមស្របនឹងវប្បធម៌ និងដែលមានការគិតគូរពីបញ្ហាយេនឌ័រ សម្រាប់ផ្តល់ការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយក្រុមជនជាតិដើមភាគតិចនៅគ្រប់ដំណាក់កាលនៃការរៀបចំ និងអនុវត្តគម្រោង ដោយពិនិត្យពិចារណាផងដែរនូវការពិនិត្យវាយតម្លៃ និងទិន្នន័យគោល។

(iv) វាយតម្លៃ (ដោយពឹងផ្អែកលើការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយសហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់) ផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានដែលអាចមានរបស់គម្រោង។ ចំណុចសំខាន់នៃការកំណត់ផលប៉ះពាល់អវិជ្ជមានដែលអាចមាន គឺការវិភាគដែលមានការគិតគូរពីបញ្ហាយេនឌ័រពីភាពងាយរងគ្រោះ (និងហានិភ័យដែលអាចកើតមានចំពោះ) របស់សហគមន៍ជនជាតិដើមភាគតិច ដោយសារតែស្ថានភាពរបស់ពួកគេ

និងចំណងទាក់ទងជិតដិតរវាងពួកគេនឹងទឹកដី និងធនធានធម្មជាតិ ព្រមទាំងកង្វះលទ្ធភាពក្នុងការទទួលបានឱកាសនានា បើធៀបជាមួយក្រុមសង្គមផ្សេងទៀតដែលរស់នៅក្នុងសហគមន៍ តំបន់ ឬសង្គមជាតិទាំងមូល។

(v) ដាក់បញ្ចូលនូវការវាយតម្លៃដែលមានការគិតគូរពីបញ្ហាយេនឌ័រពីការយល់ឃើញរបស់ក្រុមជនជាតិដើមភាគតិចរងផលប៉ះពាល់ ចំពោះគម្រោង និងផលប៉ះពាល់របស់គម្រោងមកលើសង្គម សេដ្ឋកិច្ច និងវប្បធម៌។

(vi) កំណត់ និងផ្តល់អនុសាសន៍ (ដោយពឹងផ្អែកលើការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយសហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់) ពីវិធានការចាំបាច់ក្នុងការបញ្ចៀសផលប៉ះពាល់អវិជ្ជមាន ឬ (ក្នុងករណីមិនបញ្ចៀសបាន) កំណត់នូវវិធានការបន្ធូរបន្ថយ កាត់បន្ថយ និង/ឬ ទូទាត់សងផលប៉ះពាល់ទាំងនោះ និងដើម្បីធានាថា ក្រុមជនជាតិដើមភាគតិចទទួលបានអត្ថប្រយោជន៍ពីគម្រោងស្របតាមវប្បធម៌របស់ពួកគេ។

## ឃ. ការផ្តល់ព័ត៌មាន ការពិគ្រោះយោបល់ និង ការចូលរួម

ផ្នែកនេះ នឹង ៖

(i) រៀបរាប់ពីដំណើរការផ្តល់ព័ត៌មាន ការពិគ្រោះយោបល់ និងការចូលរួមរបស់សហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ ដែលបានធ្វើនៅអំឡុងពេលរៀបចំគម្រោង។

(ii) សង្ខេបគំនិតយោបល់របស់ពួកគេពីលទ្ធផលនៃការវាយតម្លៃផលប៉ះពាល់សង្គម និងកំណត់នូវក្តីបារម្ភនានាដែលបានលើកឡើងនៅអំឡុងពេលពិគ្រោះយោបល់ និងរបៀបដោះស្រាយក្តីបារម្ភទាំងនោះ នៅក្នុងប្លង់រៀបចំគម្រោង។

(iii) ចំពោះគម្រោងដែលទាមទារឱ្យមាននូវការគាំទ្រជារួមពីសហគមន៍ កត់ត្រាទុកជាឯកសារនូវដំណើរការ និងលទ្ធផលនៃការពិគ្រោះយោបល់ជាមួយសហគមន៍ក្រុមជនជាតិដើមភាគតិចរងផលប៉ះពាល់ និងការព្រមព្រៀងនានាដែលកើតចេញពីការពិគ្រោះយោបល់នោះអំពីសកម្មភាពគម្រោង និងវិធានការការពារដែលអាចដោះស្រាយផលប៉ះពាល់នៃសកម្មភាពទាំងនោះ។

(iv) រៀបរាប់ពីយន្តការនៃការពិគ្រោះយោបល់ និងការចូលរួមដែលត្រូវយកមកប្រើនៅក្នុងពេលអនុវត្តគម្រោង ដើម្បីធានានូវការចូលរួមរបស់ក្រុមជនជាតិដើមភាគតិច នៅអំឡុងពេលអនុវត្តគម្រោង។ និង

(v) អះអាងបញ្ជាក់ពីការផ្សព្វផ្សាយសេចក្តីព្រាង និងអត្ថបទចុងក្រោយនៃ IPP ប្រាប់ដល់សហគមន៍ជនជាតិដើមភាគតិច។

## ង. វិធានការបែងចែកអត្ថប្រយោជន៍

ផ្នែកនេះកំណត់ពីវិធានការក្នុងការធានាថា ក្រុមជនជាតិដើមភាគតិចទទួលបានអត្ថប្រយោជន៍សង្គម និងសេដ្ឋកិច្ច ដែលសមស្របនឹងវប្បធម៌របស់ពួកគេ និងដែលបានគិតគូរពីបញ្ហាយេនឌ័រ។

## ច. វិធានការកាត់បន្ថយផលប៉ះពាល់

ផ្នែកនេះ កំណត់វិធានការក្នុងការបញ្ចៀសផលប៉ះពាល់អវិជ្ជមានចំពោះក្រុមជនជាតិដើមភាគតិច និង (ប្រសិនបើការបញ្ចៀសមិនអាចធ្វើទៅបាន) កំណត់វិធានការបន្ធូរបន្ថយ កាត់បន្ថយ និងទូទាត់សងនូវផលប៉ះពាល់អវិជ្ជមានដែលបានកំណត់ចំពោះក្រុមជន-ជាតិដើមភាគតិចរងផលប៉ះពាល់នីមួយៗ ។

## ឆ. ការកសាងសមត្ថភាព

ផ្នែកនេះ កំណត់ពីវិធានការក្នុងការពង្រឹងសមត្ថភាពសង្គម ច្បាប់ និងបច្ចេកទេសរបស់ (ក) ស្ថាប័នរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាក្រុមជនជាតិដើមភាគតិចនៅក្នុងតំបន់គម្រោង និង (ខ) អង្គការរបស់ក្រុមជនជាតិដើមភាគតិចនៅក្នុងតំបន់គម្រោង ដើម្បីឱ្យពួកគេអាចមានលទ្ធភាពតំណាងក្រុមជនជាតិដើមភាគតិចរងផលប៉ះពាល់បានយ៉ាងមានប្រសិទ្ធភាព ។

## ជ. យន្តការដោះស្រាយបណ្តឹងតវ៉ា

ផ្នែកនេះ រៀបរាប់ពីនីតិវិធីក្នុងការដោះស្រាយបណ្តឹងតវ៉ារបស់សហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ ។ ផ្នែកនេះក៏នឹងរៀបរាប់ផងដែរ ពីរបៀបដែលនីតិវិធីដោះស្រាយបណ្តឹងតវ៉ានេះ អាចប្រើប្រាស់បានដោយក្រុមជនជាតិដើមភាគតិចរងផលប៉ះពាល់ មានលក្ខណៈស្របនឹងវប្បធម៌របស់ក្រុមជនជាតិដើមភាគតិច និងដែលបានគិតគូរពីបញ្ហាយេនឌ័រ ។

## ឈ. ការតាមដាន ការរាយការណ៍ និង ការវាយតម្លៃ

ផ្នែកនេះរៀបរាប់ពីយន្តការ និងកម្រិតគោល ដែលសមស្របនឹងគម្រោង ក្នុងការតាមដាន និងវាយតម្លៃការអនុវត្ត IPP ។ ផ្នែកនេះ ក៏កំណត់យ៉ាងជាក់លាក់ពីផែនការចូលរួមរបស់ក្រុមជនជាតិដើមភាគតិចរងផលប៉ះពាល់ ក្នុងការរៀបចំ និងបញ្ជាក់ការតាមដាន និងការវាយតម្លៃរបាយការណ៍ ។

## ញ. ការរៀបចំស្ថាប័ន

ផែននេះ រៀបរាប់ពីការរៀបចំស្ថាប័ន ការទទួលខុសត្រូវ និងយន្តការអនុវត្តវិធានការនានាដែលមានកំណត់នៅក្នុង IPP ។ ផែនការនេះ ក៏មានរៀបរាប់ពីដំណើរការបញ្ចូលអង្គការមូលដ្ឋាន និង NGO ពាក់ព័ន្ធ ក្នុងការអនុវត្តវិធានការនានាដែលមានកំណត់នៅក្នុង IPP ។

## ដ. កញ្ចប់ថវិកា និង ហិរញ្ញប្បទាន

ផ្នែកនេះ ចែងពីកញ្ចប់ថវិកាសម្រាប់ចំណុចនីមួយៗនៃសកម្មភាពដែលមាននៅក្នុង IPP ។

# លក្ខខណ្ឌតម្រូវសម្រាប់ការពារ ៤ : លក្ខខណ្ឌតម្រូវពិសេសសម្រាប់ទម្រង់ហិរញ្ញវត្ថុផ្សេងៗ

## ក. សេចក្តីផ្តើម

១. ទម្រង់ផ្សេងៗនៃការផ្តល់ប្រាក់កម្ចី និងផលិតផលហិរញ្ញវត្ថុ គឺជាឧបករណ៍គន្លឹះរបស់ ADB ក្នុងការជម្រុញការរីកចម្រើន និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក។ ក្រៅពីគម្រោងប្រាក់កម្ចីស្តង់ដារ ADB ផ្តល់នូវឧបករណ៍វិនិយោគផ្សេងៗ ដូចជា កម្មវិធីផ្តល់ប្រាក់កម្ចី កម្មវិធីហិរញ្ញប្បទានតាមវិស័យ ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញប្បទានពហុភាគ (MFF) ជំនួយប្រាក់កម្ចីក្នុងគ្រាបន្ទាន់ អន្តរការីហិរញ្ញវត្ថុ និងហិរញ្ញវត្ថុសហគ្រាស។ លក្ខខណ្ឌតម្រូវ ៤ កំណត់ពីលក្ខខណ្ឌតម្រូវពិសេសសម្រាប់ទម្រង់ផ្សេងៗនៃការផ្តល់ហិរញ្ញប្បទានដែលអ្នកខ្ចី/អតិថិជនត្រូវបំពេញ។

## ខ. កម្មវិធីផ្តល់ប្រាក់កម្ចី

២. អ្នកខ្ចី/អតិថិជន នឹងធ្វើការវាយតម្លៃផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលដែលអាចកើតមានចំពោះបរិស្ថាន ឬការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ឬផលប៉ះពាល់ចំពោះក្រុមជនជាតិដើមភាគតិច ដែលពាក់ព័ន្ធនឹងគោលនយោបាយដែលគាំទ្រដោយកម្មវិធីផ្តល់ប្រាក់កម្ចី កំណត់នូវវិធានការកាត់បន្ថយសមស្របដើម្បីដោះស្រាយផលប៉ះពាល់ទាំងនោះ និងបញ្ចូលវិធានការទាំងនោះក្នុងប្លង់រៀបចំគម្រោង។ តារាងនៃផលប៉ះពាល់ដែលអាចបណ្តាមកពីសកម្មភាពគោលនយោបាយនីមួយៗ រួមនឹងវិធានការកាត់បន្ថយផលប៉ះពាល់ នឹងត្រូវរៀបចំឡើងដោយមាននូវសូចនាករបរិមាណនៃទំហំនៃផលប៉ះពាល់នីមួយៗ និងមូលហេតុសង្ខេបនៃការយល់ឃើញ។ ការវាយតម្លៃផលប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្រ (SEA) អាចនឹងចាំបាច់ត្រូវធ្វើ ប្រសិនបើសមស្រប។

## គ. កម្មវិធីហិរញ្ញប្បទានតាមវិស័យ

៣. ចំពោះការវិនិយោគតាមវិស័យដែលអាចបណ្តាលឱ្យមានផលប៉ះពាល់ចំពោះបរិស្ថាន ឬការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ឬផលប៉ះពាល់ចំពោះក្រុមជនជាតិដើមភាគតិច នៅមុនពេលដែល ADB អនុម័តយល់ព្រមលើគម្រោង អ្នកខ្ចី/អតិថិជន ត្រូវព្រមព្រៀងជាមួយ ADB ពីក្របខណ្ឌពិនិត្យ និងវាយតម្លៃបរិស្ថាន ក្របខណ្ឌនៃការតាំងទីលំនៅជាថ្មី ឬក្របខណ្ឌក្នុងការរៀបចំផែនការក្រុមជនជាតិដើមភាគតិច (IPPF) ដើម្បីផ្តល់ជាមគ្គុទេសក៍ក្នុងការជ្រើសរើសអនុគម្រោង ការពិនិត្យ និងចាត់ចំណាត់ថ្នាក់ ការវាយតម្លៃបរិស្ថាន និងសង្គម និងការរៀបចំ និងអនុវត្តផែនការការពាររបស់អនុគម្រោង និងដើម្បីជួយសម្របសម្រួលក្នុងការអនុវត្តតាមលក្ខខណ្ឌតម្រូវសម្រាប់ការពារ ១-៣។

៤. ក្របខណ្ឌពិនិត្យ និងវាយតម្លៃបរិស្ថាន ក្របខណ្ឌនៃការតាំងទីលំនៅជាថ្មី ឬ IPPF នឹង (១) ពិពណ៌នាពីគម្រោង និងអនុគម្រោង និង/ឬ សមាសភាគគម្រោង (២) ពន្យល់ពីផលប៉ះពាល់បរិស្ថាន និង/ឬ សង្គមដែលរំពឹងថានឹងអាចកើតមានចេញពីសមាសភាគ ឬអនុគម្រោងនៃគម្រោងដែលបានស្នើសុំ (៣) កំណត់ពីលក្ខខណ្ឌតម្រូវដែលត្រូវបំពេញក្នុងការពិនិត្យ និងចាត់ចំណាត់ថ្នាក់អនុគម្រោង ការវាយតម្លៃ និងការរៀបចំផែនការ ដូចជា ផែនការរៀបចំការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយ

ក្រុមមនុស្សរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធផ្សេងទៀត និងលក្ខខណ្ឌតម្រូវក្នុងការផ្ដល់ព័ត៌មាន និង (ប្រសិនបើអាច) លក្ខណៈ-វិនិច្ឆ័យការពារដែលត្រូវប្រើក្នុងការជ្រើសរើសអនុគម្រោង និង/ឬ សមាសភាគគម្រោង (៤) វាយតម្លៃសមត្ថភាពរបស់អ្នកខ្ចី/អតិថិជនក្នុងការអនុវត្តច្បាប់ជាតិ និងលក្ខខណ្ឌតម្រូវរបស់ ADB និងកំណត់នូវតម្រូវការនៃការកសាងសមត្ថភាព (៥) កំណត់នីតិ-វិធីអនុវត្ត រួមទាំង កញ្ចប់ថវិកា ការរៀបចំស្ថាប័ន និងការកសាងសមត្ថភាព និង (៦) កំណត់លក្ខខណ្ឌតម្រូវក្នុងការតាមដាន និងរាយការណ៍ និង (៧) ពិពណ៌នាពីការទទួលខុសត្រូវរបស់អ្នកខ្ចី/អតិថិជន និងរបស់ ADB ក្នុងការរៀបចំ អនុវត្ត និងពិនិត្យវាយ-តម្លៃឯកសារការពាររបស់អនុគម្រោង។

៥. ក្រៅពីចំណុចដែលមានក្នុងកថាខណ្ឌ ៤ ក្របខណ្ឌនៃការតាំងទីលំនៅជាថ្មី នឹងកំណត់ផងដែរពីវិធីសាស្ត្រក្នុងការវាយតម្លៃផលប៉ះពាល់សង្គម និងក្នុងការធ្វើជំរឿន។ ប្រសិនបើអាច IPPF នឹងកំណត់នូវដំណើរការ និងឯកសារចាំបាច់ក្នុងការអះអាងពីការគាំទ្រជារួមពីសហគមន៍រងផលប៉ះពាល់ពីសកម្មភាពគម្រោង ដូចមានចែងក្នុងផ្នែក ង (២) នៃលក្ខខណ្ឌតម្រូវ ៣។ ឧបសម្ព័ន្ធ ១, ២ និង ៣ នៃសេចក្ដីបន្ថែមនេះ រៀបរាប់ត្រួសៗពីខ្លឹមសារជាអនុសាសន៍នៃក្របខណ្ឌពិនិត្យ និងវាយតម្លៃបរិស្ថាន ក្របខណ្ឌនៃការតាំងទីលំនៅជាថ្មី និង IPPF។ សូមកត់សម្គាល់ថា ខ្លឹមសារជាអនុសាសន៍នេះ គ្រាន់តែជាមគ្គុទេសក៍ក្នុងការរៀបចំរបាយការណ៍ប៉ុណ្ណោះ។ កម្រិតនៃកិច្ចខិតខំប្រឹងប្រែង ទំហំនៃការវិភាគ និងភាពទូលំទូលាយ និងកម្រិតនៃភាពលម្អិត នឹងប្រែប្រួលទៅតាមទំហំ និងលក្ខណៈនៃផលប៉ះពាល់ និងហានិភ័យដែលអាចមានរបស់គម្រោងនីមួយៗ។

៦. អនុគម្រោងគំរូមួយ ឬច្រើន នឹងត្រូវកំណត់ និងវាយតម្លៃនៅមុនពេលមានការអនុម័តយល់ព្រមលើគម្រោងវិនិយោគតាមវិស័យណាមួយ។ ចំពោះអនុគម្រោងនេះ អ្នកខ្ចី/អតិថិជន នឹងរៀបចំឯកសារពាក់ព័ន្ធនានា ដូចជា របាយការណ៍វាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាន ផែនការគ្រប់គ្រងបរិស្ថាន ផែនការតាំងទីលំនៅជាថ្មី និងផែនការក្រុមជនជាតិដើមភាគតិច។

៧. លក្ខខណ្ឌតម្រូវដែលមានចែងក្នុងលក្ខខណ្ឌតម្រូវសម្រាប់ការពារ ១-៣ អនុវត្តចំពោះគ្រប់អនុគម្រោង និងសមាសភាគគម្រោងដែលកំណត់នៅអំឡុងពេលអនុវត្តគម្រោង។

៨. ប្រសិនបើគម្រោងវិនិយោគតាមវិស័យមានពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ ឬការកែប្រែគោលនយោបាយ ផែនការ ឬកម្មវិធីដែលអាចនឹងបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ឬផលប៉ះពាល់ចំពោះក្រុមជនជាតិដើមភាគតិច លក្ខខណ្ឌតម្រូវដែលមានក្នុងកថាខណ្ឌ ២ នឹងត្រូវយកមកអនុវត្ត។

## ឃ. ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញប្បទានពហុភាគ

៩. ចំពោះ MFF ដែលអាចមានផលប៉ះពាល់បរិស្ថាន ឬការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត ឬផលប៉ះពាល់ចំពោះក្រុមជនជាតិដើមភាគតិច អ្នកខ្ចី/អតិថិជន នឹងព្រមព្រៀងជាមួយ ADB ពីក្របខណ្ឌវាយតម្លៃ និងត្រួតពិនិត្យបរិស្ថានក្របខណ្ឌនៃការតាំងទីលំនៅជាថ្មី និង IPPF នៅមុនពេល ADB អនុម័តយល់ព្រមលើ MFF។ ក្របខណ្ឌទាំងនេះ នឹងបញ្ជាក់ពីគោលការណ៍ និងលក្ខខណ្ឌតម្រូវ សម្រាប់ការពារដែលត្រូវបំពេញក្នុងការពិនិត្យ និងចាត់ចំណាត់ថ្នាក់ ការវាយតម្លៃសង្គម និងបរិស្ថាន និងការរៀបចំ

និងអនុវត្តផែនការ ការពារ របស់គម្រោង សមាសភាគគម្រោង និងអនុគម្រោង ដែលនឹងត្រូវរៀបចំនៅក្រោយការអនុម័ត MMF ។ ក្របខណ្ឌទាំងនេះ នឹងត្រូវរៀបចំតាមលក្ខខណ្ឌដែលមានកំណត់ក្នុងកថាខណ្ឌ ៤ និង ៥ ។

១០. លក្ខខណ្ឌតម្រូវរបស់ ADB ដែលមានចែងក្នុងលក្ខខណ្ឌតម្រូវសម្រាប់ការពារ ១-៣ អនុវត្តចំពោះគ្រប់សមាសភាគគម្រោង អនុគម្រោង និងគម្រោងទាំងអស់ ដែលកំណត់នៅអំឡុងពេលរៀបចំ និងអនុវត្ត MFF ។

## ខ. ជំនួយប្រាក់កម្ចីក្នុងគ្រាមានអាសន្ន

១១. ចំពោះជំនួយប្រាក់កម្ចីក្នុងគ្រាមានអាសន្ន ការបញ្ចប់ការវាយតម្លៃផលប៉ះពាល់បរិស្ថានស្តង់ដារ ផែនការគ្រប់គ្រងបរិស្ថាន ផែនការតាំងទីលំនៅជាថ្មី និងផែនការក្រុមជនជាតិដើមភាគតិច អាចនឹងមិនអាចធ្វើទៅបានឡើយ នៅមុនពេលក្រុមប្រឹក្សាភិបាលអនុម័តយល់ព្រម។ ក្នុងករណីនេះ ក្របខណ្ឌពិនិត្យ និងវាយតម្លៃបរិស្ថាន ក្របខណ្ឌនៃការតាំងទីលំនៅថ្មី និង IPPF ដូចមានចែងក្នុងកថាខណ្ឌ ៤ និង ៥ នឹងត្រូវរៀបចំឡើង។ សមាសភាគគម្រោង និងអនុគម្រោង ដែលបានកំណត់នៅអំឡុងពេលអនុវត្តគម្រោងត្រូវគោរពតាមលក្ខខណ្ឌតម្រូវដែលមានចែងក្នុងលក្ខខណ្ឌតម្រូវសម្រាប់ការពារ ១-៣។ ចំពោះគម្រោងនៅក្នុងតំបន់វិវាទដែលការបញ្ចប់ការវាយតម្លៃផលប៉ះពាល់បរិស្ថានស្តង់ដារ ផែនការគ្រប់គ្រងបរិស្ថាន ផែនការតាំងទីលំនៅជាថ្មី និង IPP មិនអាចធ្វើទៅបានមុនពេលក្រុមប្រឹក្សាភិបាលអនុម័តយល់ព្រម ក្របខណ្ឌការពារ អាចនឹងត្រូវយកមកអនុវត្ត។

## ច. ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់

១២. ចំពោះគម្រោងដែលមានស្រាប់ ឬកំពុងតែធ្វើការសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធ និង/ឬ សកម្មភាពអាជីវកម្ម អ្នកខ្ចី/អតិថិជន នឹងធ្វើសវនកម្មការអនុវត្តតាមលក្ខខណ្ឌតម្រូវបរិស្ថាន និងសង្គម រួមទាំង ការវាយតម្លៃនៅការដ្ឋាន និងកំណត់ក្តីបារម្ភអតីតកាល ឬបច្ចុប្បន្ន ពាក់ព័ន្ធនឹងផលប៉ះពាល់ចំពោះបរិស្ថាន ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និងក្រុមជនជាតិដើមភាគតិច។ កម្មវត្ថុនៃសវនកម្មការអនុវត្តតាម គឺដើម្បីកំណត់ថាតើសកម្មភាពត្រូវបានធ្វើស្រប ឬមិនស្របតាមគោលការណ៍ និងលក្ខខណ្ឌតម្រូវសម្រាប់ការពាររបស់ ADB ដែលអ្នកខ្ចី/អតិថិជនត្រូវបំពេញ និងដើម្បីកំណត់ និងរៀបចំផែនការចាត់វិធានការសមស្រប ដើម្បីដោះស្រាយបញ្ហាដែលនៅមិនទាន់បានដោះស្រាយ។ ប្រសិនបើកំណត់បាននូវការមិនអនុវត្តតាម ផែនការសកម្មភាពកែតម្រូវដែលព្រមព្រៀងរវាង ADB និង អ្នកខ្ចី/អតិថិជន នឹងត្រូវរៀបចំឡើង។ ផែនការនេះ នឹងកំណត់នូវសកម្មភាពកែតម្រូវ ចាំបាច់កញ្ចប់ថវិកាសម្រាប់សកម្មភាពទាំងនោះ និងកាលវិភាគពេលវេលាដែលត្រូវដោះស្រាយបញ្ហានោះ។ របាយការណ៍សវនកម្ម (រួមទាំងផែនការសកម្មភាពកែតម្រូវប្រសិនបើមាន) នឹងត្រូវផ្សព្វផ្សាយជាសាធារណៈ ស្របតាមលក្ខខណ្ឌតម្រូវក្នុងការផ្តល់ព័ត៌មាននៃលក្ខខណ្ឌតម្រូវសម្រាប់ការពារ ១-៣។ ចំពោះគម្រោងបរិស្ថានប្រភេទ A ដែលមាន ឬកំពុងតែមានការសាងសង់ហេដ្ឋារចនា-សម្ព័ន្ធ និង/ឬ សកម្មភាពអាជីវកម្ម អ្នកខ្ចី/អតិថិជន នឹងផ្ញើរបាយការណ៍សវនកម្មឱ្យ ADB ដើម្បីផ្សព្វផ្សាយលើគេហទំព័ររបស់ ADB យ៉ាងតិច ១២០ ថ្ងៃ មុននឹងការអនុម័តយល់ព្រមរបស់ ADB។ ប្រសិនបើគម្រោងមានការពាក់ព័ន្ធទៅនឹងការកែលម្អ ឬពង្រីកហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ដែលអាចមានផលប៉ះពាល់ចំពោះបរិស្ថាន ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និង/ឬ ក្រុមជនជាតិ

ដើមភាគតិច លក្ខខណ្ឌតម្រូវក្នុងការធ្វើការវាយតម្លៃផលប៉ះពាល់ និងរៀបចំផែនការសង្គម និងបរិស្ថាន ដូចមានចែងក្នុងលក្ខខណ្ឌតម្រូវសម្រាប់ការពារ ១-៣ នឹងត្រូវយកមកអនុវត្ត បន្ថែមលើសវនកម្មការអនុវត្តតាម ។

## ឆ. អន្តរការីហិរញ្ញវត្ថុ

១៣. ប្រសិនបើការវិនិយោគរបស់អន្តរការីហិរញ្ញវត្ថុ (FI) មានផលប៉ះពាល់ចំពោះសង្គម និងបរិស្ថានតិចតួច ឬគ្មានផលប៉ះពាល់អវិជ្ជមាន គម្រោង FI នឹងត្រូវចាត់ទុកជាគម្រោងប្រភេទ C ហើយមិនចាំបាច់អនុវត្តលក្ខខណ្ឌតម្រូវជាក់លាក់ផ្សេងទៀតឡើយ ។ គម្រោង FI ផ្សេងទៀត ចាំបាច់ត្រូវមាន ឬបង្កើតឱ្យមានប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) សមស្រប ដែលជាផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រងទាំងមូល ដើម្បីអាចបំពេញបានតាមលក្ខខណ្ឌតម្រូវរបស់ច្បាប់ជាតិ និង/ឬ ADB សម្រាប់គម្រោង FI ។ ESMS មានធាតុដូចតទៅ : (១) គោលនយោបាយបរិស្ថាន និងសង្គម (២) នីតិវិធីពិនិត្យ ចាត់ចំណាត់ថ្នាក់ និងវាយតម្លៃ (៣) រចនាសម្ព័ន្ធអង្គការ និងបុគ្គលិក ព្រមទាំងជំនាញ និងសមត្ថភាពពាក់ព័ន្ធនឹងបរិស្ថាន និងសង្គម (៤) លក្ខខណ្ឌតម្រូវក្នុងការបណ្តុះបណ្តាល និង (៥) ការតាមដាន និងការរាយការណ៍ ។ ESMS នឹងចងក្រងជាឯកសារ និងដាក់សុំការព្រមព្រៀងរវាង ADB និង FI ។

១៤. នីតិវិធីពិនិត្យដែលបង្កើតឡើងដោយ ESMS នឹងធានាថា អនុគម្រោងទាំងអស់នឹងត្រូវពិនិត្យធៀបជាមួយបញ្ជីសកម្មភាពវិនិយោគដែលត្រូវបានហាមឃាត់ (សេចក្តីបន្ថែម ៥) ។ អនុគម្រោងដែលមានធ្វើសកម្មភាពដែលមានក្នុងបញ្ជីសកម្មភាពវិនិយោគដែលត្រូវបានហាមឃាត់ គ្មានគុណវុឌ្ឍិដែលអាចទទួលបានការគាំទ្រពី FI ដោយប្រើប្រាស់មូលនិធិ ADB ឡើយ ហើយរាល់ពាក្យសុំដែលមានពាក់ព័ន្ធនឹងសកម្មភាពទាំងនេះ នឹងត្រូវបដិសេធចោល ។ អាស្រ័យទៅតាមទំហំនៃ FI និងសកម្មភាពអាជីវកម្មរបស់អន្តរការីនោះ FI គួរតែតែងតាំងសមាជិកថ្នាក់ដឹកនាំរបស់ខ្លួន ឬបុគ្គលិកម្នាក់ ឬច្រើននាក់ ឱ្យទទួលខុសត្រូវការអនុវត្តប្រចាំថ្ងៃនៃ ESMS ដើម្បីឱ្យមានការទទួលខុសត្រូវជារួមចំពោះបញ្ហាបរិស្ថាន និងសង្គម ។

១៥. ប្រសិនបើអនុគម្រោងដែលទទួលបានហិរញ្ញប្បទានពី FI ដោយប្រើប្រាស់មូលនិធិ ADB តាមរយៈ ឥណទានអតិបរមា ប្រាក់កម្ចីផ្សេងទៀត ការវិនិយោគភាគហ៊ុន ការធានា ឬលិខិតុបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ហើយដែលអនុគម្រោងនោះអាចមានផលប៉ះពាល់ធ្ងន់ធ្ងរចំពោះបរិស្ថាន និងសង្គម FI ត្រូវតែធានាថាអនុគម្រោងនោះបំពេញតាមលក្ខខណ្ឌតម្រូវរបស់ ADB ដែលមានចែងក្នុងលក្ខខណ្ឌតម្រូវសម្រាប់ការពារ ១-៣ ព្រមទាំងការផ្តល់ព័ត៌មាន និងការពិគ្រោះយោបល់ ។ ក្នុងករណីនេះ FI នឹងបញ្ជូនអនុគម្រោងទាំងនេះឱ្យ ADB នៅដើមដំណាក់កាលនៃដំណើរការអង្កេតលម្អិតរបស់ខ្លួន ។ ADB នឹងជួយ FI ក្នុងការវាយតម្លៃអនុ-គម្រោងទាំងនេះ ។ ADB នឹងពិនិត្យវាយតម្លៃព័ត៌មាននៃការអង្កេតលម្អិតដែល FI ប្រមូលបាន កំណត់ព័ត៌មានបន្ថែមដែលចាំបាច់ និងជួយកំណត់វិធានការកាត់បន្ថយផលប៉ះពាល់សមស្រប និងកំណត់លក្ខខណ្ឌដែលអនុគម្រោងត្រូវគោរពតាមដើម្បីអាចបន្តអនុវត្តទៅបាន ។ ចំពោះអនុគម្រោងប្រភេទនេះ អ្នកខ្ចី/អតិថិជននឹងធ្វើ EIA ផែនការតាំងទីលំនៅជាថ្មី និង/ឬ IPP ឱ្យ ADB ពិនិត្យសម្រេច មុនពេលអនុម័តអនុគម្រោង ។ ADB ក៏អាចនឹងកំណត់លក្ខខណ្ឌតម្រូវបន្ថែមសម្រាប់សកម្មភាពរបស់ FI ដែលជាទូទៅអាស្រ័យលើទំហំនៃការវិនិយោគរបស់ FI និងប្រព័ន្ធការពាររបស់ប្រទេសម្ចាស់ផ្ទះ ។ ADB នឹងតាមដានការអនុវត្តរបស់ FI ដោយផ្អែកលើប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គមរបស់ FI ។

១៦. លើកលែងតែចំពោះ FI ដែលមានអនុគម្រោងដែលមានផលប៉ះពាល់ ឬហានិភ័យចំពោះសង្គម និងបរិស្ថានតិចតួច ឬគ្មានផលប៉ះពាល់អវិជ្ជមាន FI ត្រូវរៀបចំ និងផ្ញើរបាយការណ៍សាមាយិក យ៉ាងហោចណាស់មួយឆ្នាំម្តង ពីស្ថានភាពអនុវត្ត ESMS ។ ប្រសិនបើរបាយការណ៍ ឬការវាយតម្លៃរបស់ ADB សន្និដ្ឋានថា ESMS មិនដំណើរការ FI នឹងរៀបចំ និងផ្ញើផែនការសកម្មភាពកែតម្រូវ ដែលបានព្រមព្រៀងជាមួយ ADB ហើយអនុវត្តផែនការនោះ ។

## ៥. ហិរញ្ញវត្ថុសហគ្រាសទូទៅ

១៧. ប្រសិនបើមានអតិថិជនដែលមានប្រតិបត្តិការពហុតំបន់ ស្នើសុំហិរញ្ញវត្ថុសហគ្រាសទូទៅ[១] ទុនបង្វិល ឬការវិនិយោគភាគហ៊ុនពី ADB អ្នកខ្ចី/អតិថិជន នឹងជួលអ្នកជំនាញពីខាងក្រៅដែលមានគុណវុឌ្ឍិ និងមានបទពិសោធន៍ ឱ្យធ្វើសវនកម្ម ESMS និងការអនុវត្តកន្លងមក និងនៅពេលបច្ចុប្បន្នរបស់ក្រុមហ៊ុន ធៀបជាមួយនឹងកម្មវត្ថុ គោលការណ៍ និងលក្ខខណ្ឌតម្រូវនៃសេចក្តីថ្លែង-ការណ៍គោលនយោបាយការពាររបស់ ADB ។ សវនកម្ម នឹង :

(i) វាយតម្លៃលទ្ធភាពរបស់អតិថិជនក្នុងការគ្រប់គ្រង និងដោះស្រាយផលប៉ះពាល់ និងហានិភ័យសង្គម និងបរិស្ថានដែលពាក់ព័ន្ធនឹងអាជីវកម្ម និងប្រតិបត្តិការរបស់អតិថិជន ជាពិសេស បញ្ហាដែលបានកំណត់នៅក្នុងលក្ខខណ្ឌតម្រូវសម្រាប់ការពារ ១-៣ ។

(ii) វាយតម្លៃប្រវត្តិរបស់អតិថិជនក្នុងការអនុវត្តតាមច្បាប់ និងបទបញ្ជាដែលពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន និងសង្គមដែលនៅជាធរមាននៅក្នុងដែនយុត្តាធិការដែលត្រូវអនុវត្តគម្រោង គិតរួមទាំង កាតព្វកិច្ចដែលប្រទេសម្ចាស់ផ្ទះត្រូវបំពេញស្របតាមច្បាប់អន្តរជាតិផងដែរ ។ និង

(iii) កំណត់នូវក្រុមពាក់ព័ន្ធចំបងៗរបស់ក្រុមហ៊ុន និងការចូលរួមសកម្មភាពរបស់អ្នកពាក់ព័ន្ធបច្ចុប្បន្ន ។

១៨. ទំហំពិតប្រាកដនៃសវនកម្មក្រុមហ៊ុន នឹងត្រូវព្រមព្រៀងជាមួយ ADB តាមករណីជាក់ស្តែងនីមួយៗ ។

១៩. ផែនការសកម្មភាពកែតម្រូវ នឹងដោះស្រាយរាល់បញ្ហាដែលកំណត់នៅអំឡុងពេលធ្វើសវនកម្មក្រុមហ៊ុន ដោយកំណត់នូវកាលវិភាគចាត់វិធានការ ដើម្បីសម្រេច និងរក្សាឱ្យបាននូវការអនុវត្តតាមកម្មវត្ថុ គោលការណ៍ និងលក្ខខណ្ឌតម្រូវនៃសេចក្តីថ្លែង-ការណ៍គោលនយោបាយការពាររបស់ ADB នៅក្នុងអំឡុងពេលសមស្របមួយ ។ ផែនការសកម្មភាពនេះ នឹងត្រូវដាក់បញ្ចូលទៅក្នុង ESMS របស់អតិថិជន ។

២០. ប្រសិនបើការវិនិយោគមានការស្តារនីតិសម្បទាន ទំនើបកម្ម ឬពង្រីកនូវហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ លក្ខខណ្ឌតម្រូវសម្រាប់សកម្មភាពដែលមានស្រាប់ ដែលមានចែងក្នុងកថាខណ្ឌ ១២ នឹងត្រូវយកមកអនុវត្ត ។

[១] នៅក្នុងលក្ខខណ្ឌតម្រូវនេះ ហិរញ្ញវត្ថុសហគ្រាសទូទៅ សំដៅលើប្រាក់កម្ចី និង/ឬ ការវិនិយោគក្នុងក្រុមហ៊ុនដែលគ្មានគោលដៅដើម្បីអនុវត្តអនុគម្រោងជាក់លាក់ណាមួយ ។ ចំពោះហិរញ្ញវត្ថុសហគ្រាសដែលមានគោលដៅដើម្បីអនុវត្តអនុគម្រោងជាក់លាក់ណាមួយ លក្ខខណ្ឌតម្រូវសម្រាប់ការពារ ១-៣ នឹងត្រូវយកមកអនុវត្ត បន្ថែមលើការបង្កើត និងអនុវត្ត ESMS ។

# គ្រោងនៃក្របខណ្ឌពិនិត្យ និងវាយតម្លៃបរិស្ថាន

## ក. សេចក្តីផ្តើម

ផ្នែកនេះ ធ្វើការពិពណ៌នាដោយសង្ខេបពីគម្រោង អនុគម្រោង និង/ឬ សមាសភាគគម្រោង និងពន្យល់ពីមូលហេតុដែលផែនការ និងការវាយតម្លៃបរិស្ថាន សម្រាប់អនុគម្រោង និង/ឬ សមាសភាគគម្រោងមួយចំនួន មិនរៀបចំធ្វើទៅបាន នៅមុនពេលអនុម័តគម្រោង។

## ខ. ការវាយតម្លៃក្របខណ្ឌច្បាប់ និងសមត្ថភាពស្ថាប័ន

ផ្នែកនេះវាយតម្លៃពីភាពគ្រប់គ្រាន់នៃច្បាប់ បទបញ្ញា និងស្តង់ដារថ្នាក់ជាតិ និងថ្នាក់តំបន់ស្តីពីការវាយតម្លៃ និងការគ្រប់-គ្រងបរិស្ថាន រួមទាំង កិច្ចព្រមព្រៀងបរិស្ថានអន្តរជាតិដែលនៅជាធរមាន។ ផ្នែកនេះបញ្ជាក់ពីកម្មវត្ថុ និងគោលការណ៍ពាក់ព័ន្ធដែលគ្រប់គ្រងការរៀបចំ និងការអនុវត្តអនុគម្រោង និង/ឬ សមាសភាគគម្រោង។ ផ្នែកនេះ ក៏នឹងវាយតម្លៃពីភាពគ្រប់គ្រាន់នៃសមត្ថ-ភាពស្ថាប័នរបស់អ្នកខ្ចី/អតិថិជន ក្នុងការអនុវត្តច្បាប់ជាតិ និងលក្ខខណ្ឌតម្រូវរបស់ ADB និងកំណត់នូវការអភិវឌ្ឍន៍សមត្ថភាពដែលចាំបាច់។

## គ. ផលប៉ះពាល់បរិស្ថានរំពឹងទុក

ផ្នែកនេះផ្តល់នូវព័ត៌មានអំពីសកម្មភាពគម្រោងដែលនឹងត្រូវគាំទ្រ និងផលប៉ះពាល់បរិស្ថានដែលបានរំពឹងទុក។

## ឃ. ការវាយតម្លៃបរិស្ថានសម្រាប់អនុគម្រោង និង/ឬ សមាសភាគគម្រោង

ផ្នែកនេះផ្តល់នូវផែនការក្នុងការវាយតម្លៃ និងរៀបចំផែនការបរិស្ថាន សម្រាប់អនុគម្រោង និង/ឬ សមាសភាគគម្រោង រួមទាំង លក្ខខណ្ឌតម្រូវ និងកាលវិភាគសម្រាប់ធ្វើការ (១) ពិនិត្យ និងចាត់ចំណាត់ថ្នាក់ និង (២) រៀបចំការវាយតម្លៃបរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន (សូមមើលឧបសម្ព័ន្ធនៃសេចក្តីបន្ថែម ១)។ ផ្នែកនេះ ក៏នឹងរៀបរាប់ត្រួសៗពីលក្ខណៈវិនិច្ឆ័យបរិស្ថានដែលនឹងត្រូវយកមកប្រើក្នុងការជ្រើសរើសអនុគម្រោង ឧ. ការបដិសេធ តំបន់វេទយិតបរិស្ថាន ឬបញ្ជីហាមឃាត់ចូលដេញថ្លៃ។

## ង. ការពិគ្រោះយោបល់ ការផ្តល់ព័ត៌មាន និង យន្តការដោះស្រាយបណ្តឹងតវ៉ា

ផ្នែកនេះ នឹងបង្កើតក្របខណ្ឌធានាឱ្យមាននូវការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយក្រុមមនុស្សរងផលប៉ះពាល់នៅអំឡុងពេលរៀបចំ និងអនុវត្តគម្រោង។ ផ្នែកនេះ នឹងពិភាក្សាពីផែនការផ្សព្វផ្សាយ រួមទាំងការផ្សព្វផ្សាយ EIA របស់អនុគម្រោងដែលនឹងត្រូវរៀបចំស្របតាមក្របខណ្ឌនេះ។ ផ្នែកនេះ ក៏នឹងពិភាក្សាពីផែនការរៀបចំដោះស្រាយបណ្តឹងតវ៉ាផងដែរ។

## ច. ការរៀបចំស្ថាប័ន និង ការទទួលខុសត្រូវ

ផ្នែកនេះ កំណត់ជាក់លាក់ពីការទទួលខុសត្រូវ និងសិទ្ធិអំណាចរបស់អ្នកខ្ចី/អតិថិជន ADB និងទីភ្នាក់ងាររដ្ឋាភិបាល ក្នុងការរៀបចំ បញ្ជូន ពិនិត្យ និងវាយតម្លៃរបាយការណ៍វាយតម្លៃបរិស្ថានរបស់អនុគម្រោង និង/ឬ សមាសភាគគម្រោង។ ផ្នែកនេះ ធ្វើការប៉ាន់ស្មានពីលក្ខខណ្ឌជ្រើសរើសបុគ្គល និងផ្តល់អនុសាសន៍ពីកម្មវិធីអភិវឌ្ឍន៍សមត្ថភាព ប្រសិនបើចាំបាច់។ ផ្នែកនេះ ក៏នឹងធ្វើការប៉ាន់ស្មានសោហ៊ុយចំណាយក្នុងការអនុវត្តក្របខណ្ឌពិនិត្យ និងវាយតម្លៃបរិស្ថាន និងលក្ខខណ្ឌតម្រូវកញ្ចប់ថវិកា។

## ឆ. ការតាមដាន និង ការរាយការណ៍

ផ្នែកនេះ កំណត់ជាក់លាក់ពីផែនការតាមដាន និងរាយការណ៍ (រួមទាំងយន្តការ និងការបញ្ជូនរបាយការណ៍ឱ្យ ADB) ដែលសមស្របនឹងគម្រោង។

# គ្រោងនៃក្របខណ្ឌតាំងទីលំនៅជាថ្មី

## ក. សេចក្ដីផ្ដើម

ផ្នែកនេះ ធ្វើការពិពណ៌នាដោយសង្ខេបពីគម្រោង អនុគម្រោង និង/ឬ សមាសភាគគម្រោង និងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តដែលរំពឹងថានឹងអាចកើតមានពីអនុគម្រោង និង/ឬ សមាសភាគគម្រោង ដែលទទួលបានហិរញ្ញប្បទានពីគម្រោងដែលបានស្នើសុំ និងពន្យល់ពីមូលហេតុដែលផែនការតាំងទីលំនៅជាថ្មីសម្រាប់អនុគម្រោងមួយចំនួនមិនអាចរៀបចំធ្វើទៅបាន នៅមុនពេលវាយតម្លៃគម្រោង។

## ខ. កម្មវត្ថុ ក្របខណ្ឌគោលនយោបាយ និង សិទ្ធិ

ផ្នែកនេះ នឹង :

(i) ចែងពីគោលការណ៍ និងកម្មវត្ថុដែលគ្រប់គ្រងការរៀបចំ និងការអនុវត្តផែនការតាំងទីលំនៅជាថ្មី ដែលស្របគ្នាជាមួយនឹងលក្ខខណ្ឌតម្រូវគោលនយោបាយរបស់ ADB។ ធ្វើការប្រៀបធៀបច្បាប់ និងបទបញ្ជាជាតិដែលនៅជាធរមាន ជាមួយនឹងសេចក្ដីថ្លែងការណ៍គោលនយោបាយការពារ ហើយធ្វើការចាត់វិធានការបំបាត់គម្លាត ប្រសិនបើមាន។

(ii) ពិពណ៌នាពីលក្ខណៈវិនិច្ឆ័យក្នុងការពិនិត្យ និងជ្រើសរើសអនុគម្រោង និង/ឬ សមាសភាគគម្រោង រួមទាំងវិធានការបញ្ជៀស និងកាត់បន្ថយការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត។

(iii) ប៉ាន់ស្មានចំនួនមនុស្សរងផលប៉ះពាល់ និងចំណាត់ថ្នាក់នៃអ្នកបាត់បង់លំនៅដ្ឋានរូបវន្ត និងសេដ្ឋកិច្ច។

(iv) ពិពណ៌នាពីលក្ខណៈវិនិច្ឆ័យនៃអ្នកមានសិទ្ធិទទួលបាន សម្រាប់ប្រភេទទាំងបីនៃអ្នកបាត់បង់លំនៅដ្ឋាន។

## គ. ព័ត៌មានសង្គម-សេដ្ឋកិច្ច

ផ្នែកនេះ នឹង :

(i) ពិពណ៌នាពីវិធីសាស្ត្រដែលនឹងត្រូវប្រើក្នុងការអង្កេតសង្គម-សេដ្ឋកិច្ច ក្នុងការធ្វើជំរឿន ក្នុងការរៀបចំបញ្ជីទ្រព្យសកម្មដែលត្រូវបាត់បង់ និងក្នុងការវាយតម្លៃការបាត់បង់ដី។

(ii) ពន្យល់ពីវិធីសាស្ត្រក្នុងការវាយតម្លៃទ្រព្យសកម្មដែលត្រូវបាត់បង់។ និង

(iii) ពិពណ៌នាពីវិធីសាស្ត្រក្នុងការកំណត់សោហ៊ុយចំណាយក្នុងការដោះដូរទ្រព្យសកម្មដែលត្រូវបានធ្វើលទ្ធកម្ម។

## ឃ. ការពិគ្រោះយោបល់ ការចូលរួម និង ការផ្តល់ព័ត៌មាន

ផ្នែកនេះ នឹង :

(i) រៀបរាប់ត្រួសៗពីយន្តការដែលនឹងប្រើនៅក្នុងការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយក្រុមមនុស្សរងផលប៉ះពាល់ និងដើម្បីអនុញ្ញាតឱ្យពួកគាត់អាចចូលរួមក្នុងការរៀបចំ អនុវត្ត និងតាមដានផែនការតាំងទី-លំនៅជាថ្មី ។

(ii) រៀបរាប់ត្រួសៗពីការទទួលខុសត្រូវស្ថាប័ន ។ និង

(iii) រៀបរាប់ពីផែនការផ្សព្វផ្សាយ ដូចជា ព័ត៌មានដែលត្រូវផ្សព្វផ្សាយ និងវិធីសាស្ត្រផ្សព្វផ្សាយ ។

## ង. ការទូទាត់សង ការស្តារប្រភពចំណូល និង ការផ្លាស់ទីលំនៅ

ផ្នែកនេះ នឹង :

(i) រៀបរាប់ពីសំណើវិធានការស្តារប្រភពចំណូល រួមទាំងការទូទាត់សង និងវិធានការពិសេសក្នុងការជួយក្រុមគ្រួសារងាយរងគ្រោះលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេ ។

(ii) ពន្យល់ពីវិធានការផ្តល់ដីដោះដូរ ប្រសិនបើមានគ្រោង ។ និង

(iii) ពិពណ៌នាពីការគាំទ្រដែលនឹងត្រូវផ្តល់ជូនប្រជាពលរដ្ឋម្ចាស់ផ្ទះ ។

## ច. យន្តការដោះស្រាយបណ្តឹងតវ៉ា

ផ្នែកនេះ ពិភាក្សាពីវិធានការបង្កើតយន្តការដោះស្រាយបណ្តឹងតវ៉ានៅថ្នាក់មូលដ្ឋាន និងរៀបរាប់ត្រួសៗពីសមាសភាព ដែនយុត្តាធិការ ផែនការពិគ្រោះយោបល់ ការរក្សាទុកកំណត់ហេតុ និងវិធីសាស្ត្រផ្សព្វផ្សាយព័ត៌មានរបស់យន្តការ ។

## ឆ. ការរៀបចំស្ថាប័ន និង ការអនុវត្ត

ផ្នែកនេះ នឹង :

(i) ផ្តល់នូវការវាយតម្លៃទូលំទូលាយពីសមត្ថភាពស្ថាប័ន និងលទ្ធភាពធនធានក្នុងការរៀបចំ អនុវត្ត និងតាមដានសកម្មភាពតាំងទីលំនៅជាថ្មី និងរៀបរាប់ពីវិធានការបន្ថែមដែលចាំបាច់ក្នុងការពង្រឹងសមត្ថភាពស្ថាប័ន និងលទ្ធ-ភាពចេញចំណាយ ។

(ii) រៀបរាប់ពីដំណើរការអង្គការក្នុងការផ្តល់សិទ្ធិ ។ និង

(iii) រៀបរាប់ពីដំណើរការអនុវត្ត ដូចជា របៀបដែលការរៀបចំការតាំងទីលំនៅជាថ្មី ការអនុម័តយល់ព្រម និងការអនុវត្ត នឹងត្រូវភ្ជាប់ជាមួយនឹងការចុះកិច្ចសន្យា និងការចាប់ផ្តើមនៃការងារស៊ីវិលរបស់គម្រោង។

## ជ. កញ្ចប់ថវិកា និង ហិរញ្ញប្បទាន

ផ្នែកនេះ ផ្តល់នូវកញ្ចប់ថវិកាសន្មតស្សន៍ រួមទាំង លំហូរថវិកា និងកំណត់ប្រភពថវិកា និងការទទួលខុសត្រូវក្នុងការចាត់ចែង អនុម័ត និងបែងចែកថវិកា រួមទាំង ផែនការបម្រុង។

## ឈ. ការតាមដាន និង ការរាយការណ៍

ផ្នែកនេះ កំណត់ពីជំហានក្នុងការបង្កើតឱ្យមានការតាមដានខាងក្នុង និងខាងក្រៅ និងការវាយតម្លៃការតាំងទីលំនៅជាថ្មី និងផ្តល់នូវសូចនាករតាមដាន ក្នុងការតាមដានខាងក្នុង និងខាងក្រៅ។

# គ្រោងនៃក្របខណ្ឌផែនការក្រុមជនជាតិដើមភាគតិច

## ក. សេចក្តីផ្តើម

ផ្នែកនេះ ធ្វើការពិពណ៌នាដោយសង្ខេបពីគម្រោង អនុគម្រោង និង/ឬ សមាសភាគគម្រោង ដែលអាចនឹងស្នើសុំហិរញ្ញ-ប្បទាន និងពន្យល់ពីមូលហេតុនៃផែនការក្រុមជនជាតិដើមភាគតិចសម្រាប់អនុគម្រោងមួយចំនួន មិនអាចរៀបចំធ្វើទៅបាន នៅមុនពេលវាយតម្លៃគម្រោង។

## ខ. កម្មវត្ថុ និង ក្របខណ្ឌគោលនយោបាយ

ផ្នែកនេះ នឹង :

(i) បញ្ជាក់ពីគោលការណ៍ និងកម្មវត្ថុដែលគ្រប់គ្រងការរៀបចំ និងការអនុវត្តផែនការក្រុមជនជាតិដើមភាគតិច និងបង្ហាញភាពស្របគ្នារវាងគោលការណ៍ និងកម្មវត្ថុនេះ ជាមួយនឹងលក្ខខណ្ឌតម្រូវរបស់ ADB ។

(ii) ប្រៀបធៀបច្បាប់ និងបទបញ្ញាថ្នាក់ជាតិ ជាមួយនឹងសេចក្តីថ្លែងការណ៍គោលនយោបាយការពារ និងរៀបរាប់ពីវិធានការបំបាត់គម្លាត ប្រសិនបើមាន។ និង

(iii) រៀបរាប់ពីលក្ខណៈវិនិច្ឆ័យក្នុងការពិនិត្យ និងជ្រើសរើសសមាសភាគគម្រោង និង/ឬ អនុគម្រោង។

## គ. ការកំណត់អត្តសញ្ញាណក្រុមជនជាតិដើមភាគតិចរងផលប៉ះពាល់

ផ្នែកនេះ នឹង :

(i) រៀបរាប់ពីរបៀបដែល SPS របស់ ADB សម្រាប់ធ្វើការកំណត់អត្តសញ្ញាណក្រុមជនជាតិដើមភាគតិច ត្រូវបានយកប្រើនៅក្នុងគម្រោង។

(ii) ផ្តល់ព័ត៌មានពីក្រុមជនជាតិដើមភាគតិចដែលងាយរងគ្រោះបំផុតពីគម្រោង ឬអនុគម្រោង។ និង

(iii) រៀបរាប់ពីផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានរបស់គម្រោង ឬអនុគម្រោង ដែលអាចកើតមានចំពោះក្រុមជនជាតិដើមភាគតិច។

## ឃ. ការវាយតម្លៃផលប៉ះពាល់សង្គម និង IPP សម្រាប់អនុគម្រោង និង/ឬ សមាសភាគគម្រោង

ផ្នែកនេះកំណត់ផែនការក្នុងការវាយតម្លៃផលប៉ះពាល់សង្គម សម្រាប់អនុគម្រោង និង/ឬ សមាសភាគគម្រោង (សូមមើលផ្នែក គ នៃឧបសម្ព័ន្ធរបស់សេចក្តីបន្ថែម ៣) និងលក្ខខណ្ឌតម្រូវ និងកាលវិភាគសម្រាប់ (១) ការពិនិត្យ និងចាត់ចំណាត់ថ្នាក់ និង (២) ការរៀបចំ IPP ។

## ខ. ការពិគ្រោះយោបល់ និង ការចូលរួម

ផ្នែកនេះ រៀបរាប់ត្រួសៗពីយន្តការ និងយុទ្ធសាស្រ្តដែលនឹងត្រូវប្រើនៅក្នុងការរៀបចំការពិគ្រោះយោបល់ពោរពេញដោយអត្ថន័យជាមួយក្រុមជនជាតិដើមភាគតិចរងផលប៉ះពាល់ នៅដំណាក់កាលនីមួយៗនៃការរៀបចំ និងអនុវត្តអនុគម្រោង។ ចំពោះសកម្មភាពគម្រោងដែលទាមទារឱ្យមានការគាំទ្រជារួមពីសហគមន៍ ផ្នែកនេះក៏នឹងរៀបរាប់ត្រួសៗពីយន្តការ និងនីតិវិធីក្នុងការកត់ត្រាដំណើរការពិគ្រោះយោបល់ ដែលអាចបញ្ជាក់នូវការគាំទ្រជារួមនេះពីសហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់។

## ង. ការផ្សព្វផ្សាយ

ផ្នែកនេះរៀបរាប់ត្រួសៗពីផែនការផ្សព្វផ្សាយ ដូចជា ព័ត៌មានដែលត្រូវផ្សព្វផ្សាយ និងវិធីសាស្រ្ត និងទម្រង់នៃការផ្សព្វផ្សាយ ប្រាប់ដល់ក្រុមជនជាតិដើមភាគតិចរងផលប៉ះពាល់ និងសាធារណៈជន។

## ឆ. យន្តការដោះស្រាយបណ្ដឹងតវ៉ា

ផ្នែកនេះ ពិភាក្សាពីវិធានការបង្កើតយន្តការដោះស្រាយបណ្ដឹងតវ៉ាដែលមានលក្ខណៈសមស្របនឹងវប្បធម៌របស់ ក្រុមជនជាតិដើមភាគតិច និងដែលបានគិតគូរពីបញ្ហាយេនឌ័រ។

## ជ. ការរៀបចំស្ថាប័ន និង ការអនុវត្ត

ផ្នែកនេះរៀបរាប់ពីការរៀបចំស្ថាប័ន ដូចជា ការកសាងសមត្ថភាពដែលចាំបាច់ក្នុងការពិនិត្យ និងចាត់ចំណាត់ថ្នាក់ ការវាយតម្លៃផលប៉ះពាល់សង្គម ការរៀបចំ IPP និងការតាមដាន។

## ឈ. ការតាមដាន និង ការរាយការណ៍

ផ្នែកនេះកំណត់នូវជំហានក្នុងការបង្កើតយន្តការ និងកម្រិតគោលដែលសមស្របសម្រាប់ការតាមដាន និងរាយការណ៍។

## ញ. កញ្ចប់ថវិកា និង ហិរញ្ញប្បទាន

ផ្នែកនេះ ផ្ដល់នូវកញ្ចប់ថវិកាសន្ទស្សន៍ និងកំណត់ប្រភពថវិកា និងការទទួលខុសត្រូវក្នុងការចាត់ចែង អនុម័ត និងបែងចែកថវិកា រួមទាំង ផែនការបម្រុង។

## បញ្ជីសកម្មភាពវិនិយោគដែលត្រូវបានហាមឃាត់ដោយ ADB

សកម្មភាពវិនិយោគដែលគ្មានគុណវុឌ្ឍិក្នុងការទទួលបានហិរញ្ញប្បទានពី ADB មានដូចតទៅ :

(i) ផលិតកម្ម ឬធ្វើសកម្មភាពដែលពាក់ព័ន្ធនឹងរាល់ទម្រង់កេងប្រវ័ញ្ចនៃការងារដោយបង្ខំ[១] និងពលកម្មកុមារ[២] ។

(ii) ផលិតកម្ម ឬការជួញដូរផលិតផល ឬធ្វើសកម្មភាពដែលហាមឃាត់ដោយច្បាប់ និងបទបញ្ជារបស់ប្រទេសម្ចាស់ផ្ទះ ឬអនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ ឬដែលត្រូវកាត់បន្ថយការប្រើប្រាស់ ឬត្រូវបានហាមឃាត់ជាអន្តរ-ជាតិ ដូចជា (ក) ឱសថ[៣] ថ្នាំសម្លាប់សត្វល្អិត ថ្នាំកំចាត់ស្មៅ[៤] (ខ) សារធាតុបំផ្លាញស្រទាប់អូហ្សូន[៥] (គ) សារធាតុ Polychlorinated Biphenyls[៦] និងសារធាតុគីមីគ្រោះថ្នាក់ផ្សេងទៀត[៧] (ឃ) សត្វព្រៃ ឬផលិតផលសត្វព្រៃ ដែលមានចែងក្នុងអនុសញ្ញាស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់[៨] និង (ង) ការធ្វើពាណិជ្ជកម្មកាកសំណល់ និងផលិតផលសំណល់ឆ្លងដែន[៩] ។

(iii) ផលិតកម្ម ឬការជួញដូរអាវុធ និងគ្រាប់រំសេវ រួមទាំងសម្ភារៈទាហានប៉ារ៉ា ។

(iv) ផលិតកម្ម ឬការជួញដូរគ្រឿងស្រវឹង លើកលែងស្រាបៀរ និងស្រា[១០] ។

(v) ផលិតកម្ម ឬការជួញដូរថ្នាំជក់[១០] ។

---

[១] ការងារដោយបង្ខំ សំដៅលើការងារ ឬសេវាកម្មដែលមិនមែនធ្វើឡើងដោយការស្ម័គ្រចិត្ត ពោលគឺ ការងារ ឬសេវាកម្មដែលបំពេញដោយបុគ្គលដែលស្ថិតនៅក្រោមការបង្ខិតបង្ខំ ឬទណ្ឌកម្ម ។

[២] ពលកម្មកុមារ សំដៅលើការជួលកុមារដែលមានអាយុទាបជាងអាយុអប្បបរមាអនុញ្ញាតឱ្យចូលបម្រើការងាររបស់ប្រទេសម្ចាស់ផ្ទះ ឬការជួលកុមារដែលធ្វើឡើងផ្ទុយទៅនឹងអនុសញ្ញាលេខ ១៣៨ ស្តីពីការកម្រិតអាយុអប្បបរមាសម្រាប់ការចូលធ្វើការងារ របស់អង្គការពលកម្មអន្តរ-ជាតិ (www.ilo.org) ។

[៣] បញ្ជីផលិតផលឱសថដែលត្រូវកាត់បន្ថយការប្រើប្រាស់ ឬហាមឃាត់ អាចរកបាននៅ : http://www.who.int

[៤] បញ្ជីថ្នាំសម្លាប់សត្វល្អិត និងថ្នាំកំចាត់ស្មៅដែលត្រូវកាត់បន្ថយការប្រើប្រាស់ ឬហាមឃាត់ អាចរកបាននៅ : http://www.pic.int

[៥] បញ្ជីសមាសធាតុគីមីដែលមានប្រតិកម្ម និងបំផ្លាញស្រទាប់អូហ្សូន ដែលបណ្តាលឱ្យរន្ធអូហ្សូនកាន់តែរីកធំទៅៗ និងគោលដៅកាត់បន្ថយការប្រើប្រាស់ មានចែងនៅក្នុងពិធីសារម៉ុងរ៉េអាល់ ។ ព័ត៌មាននេះ អាចរកបាននៅ : http://www.unep.org/ozone/montreal.shtml

[៦] Polychlorinated Biphenyls ជាក្រុមនៃសារធាតុគីមីដែលមានជាតិពុលខ្ពស់ ដែលច្រើនតែមាននៅក្នុងត្រង់ស្វូម៉ាទ័រដែលប្រើប្រេង កុងដង់ និងកុងតាក់ដែលផលិតនៅចន្លោះពីឆ្នាំ ១៩៥០ ដល់ ១៩៨៥ ។

[៧] បញ្ជីសារធាតុគីមីគ្រោះថ្នាក់ អាចរកបាននៅ : http://www.pic.int

[៨] បញ្ជីអាចរកបាននៅ : http://www.cites.org

[៩] ដូចមានកំណត់ដោយអនុសញ្ញាទីក្រុងបាសែល http://www.basel.int

[១០] មិនអនុវត្តចំពោះអ្នកផ្តួចផ្តើមគម្រោងដែលមិនពាក់ព័ន្ធខ្លាំងក្នុងសកម្មភាពទាំងនេះឡើយ ។ ឃ្លាថា "មិនពាក់ព័ន្ធខ្លាំង" មានន័យថា សកម្មភាពទាំងនោះជាសកម្មភាពបន្ទាប់បន្សំនៃប្រតិបត្តិការចំបងរបស់អ្នកផ្តួចផ្តើមគម្រោង ។

(vi) ល្បែងស៊ីសង កាស៊ីណូ និងសហគ្រាសប្រហាក់ប្រហែល[១០] ។

(vii) ផលិតកម្ម ឬការជួញដូរឧបករណ៍មានធាតុវិទ្យុសកម្ម[១១] រួមទាំង រ៉ែអាទ័រនុយក្លេអ៊ែរ និងសមាសភាគរបស់វា ។

(viii) ផលិតកម្ម ឬការជួញដូរ ឬប្រើប្រាស់សារធាតុ Asbestos ដែលមិនចងសម្ព័ន្ធ[១២] ។

(ix) ប្រតិបត្តិការកាប់ឈើធ្វើពាណិជ្ជកម្ម ឬទិញឧបករណ៍កាប់ឈើដើម្បីប្រើប្រាស់ជាចំបងក្នុងការកាប់ព្រៃសំណើម ឬព្រៃដែលមានដើមឈើចាស់ៗ នៅតំបន់ត្រូពិច ។

(x) ការនេសាទនៅសមុទ្រ និងនៅតាមឆ្នេរសមុទ្រ ដោយប្រើសំណាញ់អូសខ្នាតធំ និងសំណាញ់ក្រឡាល្អិត ដែលបង្កឱ្យមានគ្រោះថ្នាក់ក្នុងបរិមាណច្រើនដល់ប្រភេទពូជសត្វសមុទ្រដែលងាយរងគ្រោះ និងដែលត្រូវបានការពារ និងបង្កឱ្យមានការ ខូចខាតដល់ជីវៈចម្រុះ និងទីជម្រកសត្វសមុទ្រ ។

---

[១១] មិនអនុវត្តចំពោះការទិញឧបករណ៍វេជ្ជសាស្ត្រ ឧបករណ៍គ្រប់គ្រង (វាស់វែង) គុណភាព និងឧបករណ៍ផ្សេងទៀត ដែល ADB ចាត់ទុកថាមានធាតុវិទ្យុសកម្មតិចតួច ឬត្រូវបានផ្ទិតត្រឹមត្រូវ ។

[១២] មិនអនុវត្តចំពោះការទិញ និងប្រើប្រាស់សន្លឹកសារធាតុ Asbestos ដែលចងសម្ព័ន្ធ ប្រសិនបើបរិមាណ Asbestos មានតិចជាង ២០% ។

# ការពង្រឹង និង ការប្រើប្រាស់ប្រព័ន្ធការពារក្នុងប្រទេសដើម្បីដោះស្រាយបញ្ហាការពារបរិស្ថាន និងសង្គម

## ក. សេចក្ដីផ្ដើម

១. គោលនយោបាយការពាររបស់ ADB មានគោលដៅសម្រេចឱ្យបានទូវនិរន្តរភាពបរិស្ថាន និងសង្គម និងការកាត់បន្ថយភាពក្រីក្រ ដែលជាគោលដៅអភិវឌ្ឍន៍ចំបងរបស់ ADB ។ ADB ទទួលស្គាល់ថា ប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក (DMC) មានក្របខណ្ឌច្បាប់ ការរៀបចំស្ថាប័ន និងនីតិវិធីរដ្ឋបាលរបស់ខ្លួនក្នុងការធ្វើការការពារ ហើយក៏ទទួលស្គាល់ផងដែរថា ការអភិវឌ្ឍន៍សមត្ថភាព និងការតាមដានការអនុវត្តរបស់រដ្ឋាភិបាល អ្នកផ្ដួចផ្ដើមគម្រោង ទីភ្នាក់ងារប្រតិបត្តិ និងអ្នកពាក់ព័ន្ធផ្សេងទៀត មានសារៈសំខាន់ក្នុងការអនុវត្តគោលនយោបាយ និងក្របខណ្ឌទាំងនោះឱ្យមានប្រសិទ្ធភាព។ ADB ក៏ទទួលស្គាល់ផងដែរថា ការអភិវឌ្ឍន៍បន្ថែមនៃប្រព័ន្ធការពារក្នុងប្រទេស (CSS) នឹងជួយជម្រុញដល់ការអភិវឌ្ឍន៍បរិស្ថាន និងសង្គមប្រកបដោយនិរន្តរភាពនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក។

## ខ. ពាក្យបច្ចេកទេស និង សនិទានភាព

២. **និយមន័យ :** ប្រព័ន្ធការពារក្នុងប្រទេស សំដៅលើក្របខណ្ឌច្បាប់ និងស្ថាប័នរបស់ប្រទេស ដែលរួមមានដូចជាស្ថាប័នអនុវត្តថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និង តាមវិស័យ និងច្បាប់ បទបញ្ជា វិធាន និងនីតិវិធីដែលពាក់ព័ន្ធនឹងគោលនយោបាយការពារបរិស្ថាន និងសង្គម[១] ។

៣. ***សនិទានភាព :*** បទពិសោធន៍ប្រតិបត្តិការ ការវាយតម្លៃ និងការសិក្សារបស់ ADB និងទីភ្នាក់ងារអភិវឌ្ឍន៍ផ្សេងទៀត បង្ហាញថាភាពជោគជ័យនៃគោលនយោបាយការពាររបស់ទីភ្នាក់ងារអភិវឌ្ឍន៍ ពឹងផ្អែកស្ទើតែទាំងស្រុងទៅលើកម្រិតដែលគោលការណ៍ និងលក្ខខណ្ឌតម្រូវនៃគោលនយោបាយការពារ ចាក់ឫសនៅក្នុងដំណើរការសម្រេចចិត្តក្នុងបរិបទវប្បធម៌ និងសង្គម-សេដ្ឋកិច្ចរបស់ DMC ។ ការសិក្សាទាំងនោះ ក៏បង្ហាញផងដែរថា ទីភ្នាក់ងារអភិវឌ្ឍន៍អាចបង្កើតឥទ្ធិពលរបស់ជំនួយអភិវឌ្ឍន៍ ប្រសិនបើពួកគេគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងពង្រឹងក្របខណ្ឌច្បាប់ គោលនយោបាយ និងស្ថាប័នរបស់ DMC ដែលមានរួចហើយ និងធ្វើការងារដោយផ្ទាល់ឱ្យបានច្រើនជាមុនជាមួយ DMC ។

៤. ក្នុងអំឡុងពេលមួយទសវត្សរ៍ចុងក្រោយនេះ DMC ជាច្រើន បានកែលម្អ និង/ឬ អនុម័តគោលនយោបាយថ្នាក់ជាតិ ច្បាប់ និងនីតិវិធីថ្មី ក្នុងការវាយតម្លៃបរិស្ថាន ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និងក្រុមជនជាតិដើមភាគតិច។ នៅក្នុង DMC មួយចំនួន ក្របខណ្ឌច្បាប់ និងនីតិវិធី អាចនឹងមានកម្រិតសមមូលនឹងគោលការណ៍ និងលក្ខខណ្ឌតម្រូវនៃគោលនយោបាយការពាររបស់ ADB ។ នៅក្នុង DMC ផ្សេងទៀត ក្របខណ្ឌច្បាប់ និងសមត្ថភាពស្ថាប័ន នៅមានលក្ខណៈទន់ខ្សោយនៅឡើយ និងតម្រូវឱ្យមានការកែលម្អជាច្រើន និងការអភិវឌ្ឍន៍សមត្ថភាព។ ការបង្កើតភាពជាដៃគូជាមួយ DMC ក្នុងការពង្រឹង និងប្រើប្រាស់ CSS អាចនឹងជួយពង្រឹងនូវភាពជាម្ចាស់របស់ DMC ចំពោះលក្ខខណ្ឌតម្រូវសម្រាប់ការពារ និងបង្កើននូវឥទ្ធិពលនៃការអភិវឌ្ឍន៍។

[១] និយមន័យនេះ ស្របគ្នាជាមួយនឹងនិយមន័យដែលផ្ដល់ដោយធនាគារពិភពលោកចំពោះពាក្យ "ប្រព័ន្ធការពារបរិស្ថាន និងសង្គមក្នុងប្រទេស" ។

ប្រសិនបើប្រើអមជាមួយ នឹងវិធានការអភិវឌ្ឍន៍សមត្ថភាពសមស្រប ការប្រើប្រាស់ CSS អាចជួយកាត់បន្ថយហានិភ័យនានាតាមរយៈការបង្កើនគុណភាព និងភាពទៀងទាត់ពេលវេលានៃការអនុវត្តគម្រោង។

៥. ការសិក្សាវាយតម្លៃពិសេសចំពោះគោលនយោបាយការពារ ៣ របស់ ADB ដែលរៀបចំធ្វើឡើងដោយនាយកដ្ឋានវាយតម្លៃប្រតិបត្តិការ បានបង្ហាញឱ្យឃើញថា នីតិវិធីអនុវត្ត និងគោលនយោបាយការពារអត្ថិភាពរបស់ ADB បានប្រើប្រាស់វិធីសាស្ត្រ "ត្រូវមួយត្រូវទាំងអស់" ហើយមិនបានញែកឱ្យឃើញនូវភាពខុសប្លែកគ្នានៃក្របខណ្ឌច្បាប់ និងស្ថាប័ន លទ្ធភាពអនុវត្ត និងប្រវត្តិអនុវត្តរបស់ DMC ឡើយ។ នាយកដ្ឋានវាយតម្លៃប្រតិបត្តិការ បានផ្តល់អនុសាសន៍ឱ្យធ្វើបច្ចុប្បន្នភាពគោលនយោបាយការពារ និងរកឱកាសបង្កើតវិធីសាស្ត្រជាយុទ្ធសាស្ត្រ ក្នុងការបង្កើនលទ្ធភាព និងភាពអាចទុកចិត្តបានរបស់ CSS ក្នុងការការពារបរិស្ថាន និងសង្គម។

៦. ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អន្តរអាមេរិក បាននឹងកំពុងខិតខំប្រឹងប្រែងប្រើប្រាស់ CSS[២]។ ការអភិវឌ្ឍន៍វិធីសាស្ត្រជាយុទ្ធសាស្ត្រក្នុងការវាយតម្លៃ CSS របស់ ADB នឹងជួយសម្រួលឱ្យមានភាពស៊ីគ្នារវាង ADB និងដៃគូអភិវឌ្ឍន៍ ជួយធ្វើឱ្យនីតិវិធីលើកកម្ពស់សេវាវិនិយោគកាន់តែមានប្រសិទ្ធភាព និងឆាប់រហ័ស និងជួយកាត់បន្ថយសោហ៊ុយចំណាយ ព្រោះថា អ្នកខ្ចី/អតិថិជនមិនចាំបាច់ធ្វើប្រតិបត្តិពីរក្នុងពេលតែមួយ ឬធ្វើការងារជាន់គ្នាទៀតឡើយ។

៧. **បទពិសោធន៍របស់ ADB ក្នុងការវាយតម្លៃ និងប្រើប្រាស់ប្រព័ន្ធការពារក្នុងប្រទេស** : ADB ធ្លាប់បានធ្វើការវាយតម្លៃលក្ខខណ្ឌតម្រូវផ្នែកច្បាប់ និងលទ្ធភាពស្ថាប័នរបស់ DMC ក្នុងការអនុវត្តគម្រោងដែរ ប៉ុន្តែមិនបានធ្វើឱ្យបានស៊ីជម្រៅឡើយ។ ឧ. នៅក្នុងការរៀបចំ និងវាយតម្លៃគម្រោងជាធម្មតាមួយ ADB ធ្វើការអង្កេតលម្អិត ដើម្បីកំណត់នូវគម្លាតរវាងលក្ខខណ្ឌតម្រូវសម្រាប់ការពាររបស់ ADB និងរបស់ DMC និងវាយតម្លៃលទ្ធភាពអនុវត្តរបស់ទីភ្នាក់ងារអនុវត្ត ដើម្បីរៀបចំផែនការបរិស្ថាន និងសង្គម សេចក្តីព្រាងកិច្ចព្រមព្រៀងកម្ចី និងរៀបចំវិធានកសាងសមត្ថភាព។ ប៉ុន្តែ ជាធម្មតា ការវាយតម្លៃនេះបានធ្វើនៅត្រឹមតែកម្រិតគម្រោង ហើយការវិភាគ CSS ឱ្យមានលក្ខណៈប្រព័ន្ធ និងស៊ីជម្រៅមិនដែលត្រូវបានធ្វើឡើយ។

៨. បើទោះជាវិធីសាស្ត្រវាយតម្លៃត្រឹមកម្រិតគម្រោងនេះ អាចផ្តល់នូវបទពិសោធន៍មានប្រយោជន៍ដល់ DMC និង ADB ក៏ដោយ វិធីសាស្ត្រនេះត្រូវបានធ្វើឡើងដោយមិនផ្លូវការ និងគ្មានសង្គតភាពឡើយ។ ហេតុនេះ ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍន៍ជានិរន្តរ៍នៅក្នុងតំបន់ដែល DMC បាននឹងកំពុងបង្កើត និងពង្រឹងប្រព័ន្ធការពារបរិស្ថាន និងសង្គមផ្ទាល់ខ្លួនរបស់ពួកគេ ADB ចាំបាច់ត្រូវបង្កើតឱ្យមាននូវវិធីសាស្ត្រដែលមានលក្ខណៈស៊ីជម្រៅ និងមានតម្លាភាព ក្នុងការវាយតម្លៃ CSS ហើយត្រូវអនុម័តយកនូវវិធីសាស្ត្រជាយុទ្ធសាស្ត្រ ក្នុងការពង្រឹង និងប្រើប្រាស់ CSS ឱ្យមានលក្ខណៈជាប្រព័ន្ធ។

---

[២] នៅឆ្នាំ ២០០៤ ធនាគារពិភពលោក បានបើកដំណើរការកម្មវិធីសាកល្បងរយៈពេល ០២ ឆ្នាំ ក្នុងការប្រើប្រាស់ CSS នៅក្នុងគម្រោងចំនួន ២០ នៅប្រទេសចំនួន ១៤។ នៅខែធ្នូ ឆ្នាំ ២០០៧ ធនាគារពិភពលោកបានចេញរបាយការណ៍វាយតម្លៃកម្មវិធីនេះ ហើយបានសម្រេចបន្តអនុវត្តកម្មវិធីនេះ ០៣ ឆ្នាំបន្ថែមទៀត។ នៅឆ្នាំ ២០០៦ ធនាគារអភិវឌ្ឍន៍អន្តរអាមេរិក បានអនុម័តគោលនយោបាយអនុវត្តតាមលក្ខខណ្ឌតម្រូវបរិស្ថាន និងការការពារដែលបានចែងពីការគិតគូរការប្រើប្រាស់ "ប្រព័ន្ធក្នុងប្រទេស"។

## គ. វិធីសាស្ត្ររួមក្នុងការពង្រឹង និង ប្រើប្រាស់ប្រព័ន្ធការពារក្នុងប្រទេស ក្នុងប្រតិបត្តិការដែលគាំទ្រដោយ ADB :

៩. ADB ប្តេជ្ញាគាំទ្រដល់ការពង្រឹង និងការអនុវត្តឱ្យមានប្រសិទ្ធភាពនូវប្រព័ន្ធការពារក្នុងប្រទេស (CSS) របស់ DMC ដោយផ្តោតសំខាន់លើការអភិវឌ្ឍន៍សមត្ថភាពរបស់អ្នកខ្ចី។ ក្នុងពេលជាមួយគ្នានេះ ADB ចាំបាច់ត្រូវធានាថា ការអនុវត្ត CSS នៅក្នុងគម្រោងរបស់ ADB នឹងមិនធ្វើឱ្យអន្តរាយដល់គោលនយោបាយ កម្មវត្ថុ និងគោលការណ៍របស់ ADB ឡើយ។ ADB អាចនឹងពិចារណាប្រើប្រាស់ CSS របស់អ្នកខ្ចីក្នុងការកំណត់ និងគ្រប់គ្រងផលប៉ះពាល់ និងហានិយភ័យសង្គម និងបរិស្ថានដែលពាក់ព័ន្ធនឹងគម្រោងគាំទ្រដោយ ADB នៅកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់តំបន់ ឬកម្រិតទីភ្នាក់ងារ លុះត្រាតែ (១) CSS មានកម្រិតសមមូលនឹងលក្ខខណ្ឌតម្រូវរបស់ ADB និង (២) អ្នកខ្ចីមានលទ្ធភាព និងការប្តេជ្ញាអាចទទួលយកបាន ក្នុងការគោរពតាមច្បាប់ បទបញ្ញា វិធាន និងនីតិវិធីដែលនៅជាធរមាន។

១០. ***ភាពសមមូល និង ភាពអាចទទួលយកបាន :*** ភាពសមមូល និងភាពអាចទទួលយកបាន គឺជាបុរេលក្ខខណ្ឌពីរក្នុងការសម្រេចប្រើប្រាស់ CSS។ ADB នឹងចាត់ទុកថា CSS របស់អ្នកខ្ចីមានភាពសមមូលនឹងលក្ខខណ្ឌតម្រូវរបស់ ADB ប្រសិនបើ CSS របស់អ្នកឱ្យខ្ចី ត្រូវបានរចនាឡើងដើម្បីសម្រេចកម្មវត្ថុតែមួយ និងគោរពតាមទំហំគោលនយោបាយ គារជម្រុញនិងគោលការណ៍ពាក់ព័ន្ធ ដែលមានចែងក្នុងសេចក្តីថ្លែងការណ៍គោលនយោបាយការពាររបស់ ADB (ទំព័រ ១៦-១៨)។ ADB ក៏នឹងវាយតម្លៃភាពអាចទទួលយកបាននៃទម្លាប់ ប្រវត្តិ និងលទ្ធភាពអនុវត្តរបស់អ្នកខ្ចី នៅមុនពេលសម្រេចប្រើប្រាស់ប្រព័ន្ធរបស់អ្នកខ្ចី។ វិធីសាស្ត្រវាយតម្លៃដូចខាងក្រោម នឹងត្រូវយកមកប្រើ :

(i) ***ការវាយតម្លៃថ្នាក់ជាតិ/ក្រោមជាតិ/តំបន់/ទីភ្នាក់ងារ :*** ADB ទទួលខុសត្រូវវាយតម្លៃ និងកំណត់ភាពសមមូលនៃ CSS និងភាពគ្រប់គ្រាន់នៃលទ្ធភាពអនុវត្តរបស់អ្នកខ្ចី នៅកម្រិតថ្នាក់ជាតិ ក្រោមជាតិ តំបន់ ឬទីភ្នាក់ងារ។ ប្រសិនបើការវាយតម្លៃបង្ហាញថា គំលាតអាចដោះស្រាយបានដោយងាយស្រួល ADB និងអ្នកខ្ចី នឹងព្រមព្រៀងពីវិធានបំបាត់គម្លាតដែលនឹងត្រូវបញ្ចូលក្នុងផែនការសកម្មភាព។ ការវាយតម្លៃ និងការងារវិភាគថ្មីៗរបស់ដៃគូអភិវឌ្ឍន៍ផ្សេងទៀត (ដែលអាចត្រូវធ្វើបច្ចុប្បន្នភាពប្រសិនបើចាំបាច់) អាចនឹងត្រូវយកមកប្រើនៅក្នុងការវាយតម្លៃ CSS។ ការវាយតម្លៃរួមគ្នាជាមួយដៃគូអភិវឌ្ឍន៍ផ្សេងទៀត ត្រូវបានលើកទឹកចិត្ត។ នៅក្នុងដំណាក់កាលនេះ ADB នឹងមិនពិចារណាអនុវត្ត CSS ក្នុងគម្រោងជាក់លាក់ណាមួយដែលផ្តល់ហិរញ្ញប្បទានដោយ ADB ឡើយ ហើយលក្ខខណ្ឌតម្រូវសម្រាប់ការពារដែលមានចែងក្នុងសេចក្តីថ្លែងការណ៍គោលនយោបាយការពារ (SPS) នឹងត្រូវយកមកអនុវត្ត។

(ii) ***ការវាយតម្លៃកម្រិតគម្រោង :*** បន្ទាប់ពី ADB កំណត់ថា CSS មានភាពសមមូលនឹងលក្ខខណ្ឌតម្រូវរបស់ ADB ហើយលទ្ធភាព និងទម្លាប់អនុវត្តរបស់អ្នកខ្ចី អាចទទួលយកបាននៅកម្រិតថ្នាក់ជាតិ ក្រោមជាតិ តំបន់ ឬកម្រិតទីភ្នាក់ងារ ADB អាចនឹងពិចារណាអនុវត្ត CSS ចំពោះគម្រោងដែលទទួលបានហិរញ្ញប្បទានពី ADB

នៅកម្រិតថ្នាក់ជាតិ អនុតំបន់ ឬវិស័យ ឬគម្រោងមានការគាំទ្រហិរញ្ញវត្ថុពីទីភ្នាក់ងារ។ ចំពោះគម្រោងទីមួយៗ ADB ក៏នឹងរៀបចំធ្វើការវាយតម្លៃភាពអាចទទួលយកបាន (ដូចជា លទ្ធភាព ប្រវត្តិ និងទម្លាប់អនុវត្តរបស់ទីភ្នាក់ងារប្រតិបត្តិ) នៅមុនពេលចាប់ផ្ដើមប្រើប្រាស់ CSS។ ការវាយតម្លៃ នឹងត្រូវធ្វើជាផ្នែកមួយនៃដំណើរការរចនាគម្រោង នៅអំឡុងពេលរៀបចំគម្រោង។ ADB ក៏នឹងជួយដល់អ្នកខ្ចីក្នុងការបង្កើតកម្មវិធីកសាងសមត្ថភាព និងបញ្ចូលកម្មវិធីនោះទៅក្នុងប្លង់រចនាគម្រោង ប្រសិនបើចាំបាច់។ លទ្ធផលនៃការវាយតម្លៃភាពអាចទទួលយកបាន នឹងត្រូវកត់ត្រាទុកជាឯកសារ និងត្រូវឆ្លុះបញ្ចាំងក្នុងរបាយការណ៍ និងអនុសាសន៍របស់ប្រធាន ADB។

១១. **ការដោះស្រាយគម្លាតដើម្បីពង្រឹងប្រព័ន្ធក្នុងប្រទេស :** ប្រសិនបើអ្នកខ្ចីត្រូវពង្រឹង CSS របស់ខ្លួន ដើម្បីបំពេញតាមកម្មវត្ថុ និងដើម្បីគោរពទៅតាមទំហំគោលនយោបាយ ការជម្រុញនិងគោលការណ៍ពាក់ព័ន្ធដែលចែងក្នុង SPS របស់ ADB (ទំព័រទី ១៦-១៨) ហើយមានការប្ដេជ្ញានឹងធ្វើបែបនេះ ADB អាចយកវិធានការពង្រឹង CSS របស់អ្នកខ្ចីមកពិចារណា នៅពេលកំណត់ពីភាពសមមូល។ ដូចគ្នានេះដែរ ប្រសិនបើអ្នកខ្ចីចាំបាច់ត្រូវពង្រឹងសមត្ថភាពអនុវត្តរបស់ខ្លួន ដើម្បីអាចអនុវត្តលក្ខខណ្ឌតម្រូវសម្រាប់ការពារឱ្យមានប្រសិទ្ធភាព ហើយមានការប្ដេជ្ញានឹងធ្វើបែបនេះ ADB អាចនឹងពិចារណាពីវិធានការពង្រឹងសមត្ថភាពអនុវត្តរបស់អ្នកខ្ចី នៅពេលកំណត់ពីភាពអាចទទួលយកបាន។ វិធានការនេះ ត្រូវតែធ្វើមុនពេលអ្នកខ្ចីចាប់ផ្ដើមអនុវត្តសកម្មភាពគម្រោងពាក់ព័ន្ធ ហើយវិធានការនេះ អាចបញ្ចូលនូវកិច្ចខិតខំប្រឹងប្រែងដែលគាំទ្រដោយ ADB។ ដោយមានជំនួយពី ADB និងដៃគូផ្សេងទៀត អ្នកខ្ចីត្រូវរៀបចំផែនការសកម្មភាពដែលមាននូវវិធានការទាំងនេះ និងកាលវិភាគពេលវេលាជាក់លាក់។ ផែនការសកម្មភាពដើម្បីពង្រឹងភាពសមមូល នឹងផ្ដោតលើរបៀបដែលអាចធ្វើឱ្យមានស្របគ្នារវាង CSS និងគោលនយោបាយការពារ កម្មវត្ថុ ទំហំ ការជម្រុញនិងគោលការណ៍របស់ ADB តាមរយៈការកែលម្អចាំបាច់នានា ចំពោះក្របខណ្ឌច្បាប់ និងបទបញ្ជា។ ផែនការសកម្មភាពដើម្បីការកសាងសមត្ថភាព នឹងដោះស្រាយបញ្ហាអភិវឌ្ឍន៍សមត្ថភាពរបស់អ្នកខ្ចី និងស្ថាប័នពាក់ព័ន្ធចំបងៗ។

១២. **កម្រិតនៃប្រព័ន្ធការពារក្នុងប្រទេស :** ADB អាចនឹងពិចារណាអនុវត្ត CSS នៅកម្រិតផ្សេងៗ ដូចជា កម្រិតថ្នាក់ជាតិ ក្រោមជាតិ តំបន់ ឬកម្រិតទីភ្នាក់ងារ អាស្រ័យទៅលើ (១) ការជជែកពិភាក្សាជាមួយអ្នកខ្ចីអំពីការជ្រើសជ្រាបរបស់ ADB ពី CSS ប្រទេស តំបន់ ឬទីភ្នាក់ងារជាក់លាក់ណាមួយ និងប្រតិបត្តិការរំពឹងទុករបស់ ADB នៅ DMC។ (២) លទ្ធផលនៃការវាយតម្លៃភាពសមមូល និងភាពអាចទទួលយកបាន និង (៣) ការប្ដេជ្ញារបស់អ្នកខ្ចីក្នុងការអនុវត្តផែនការសកម្មភាពបំបាត់គម្លាត។

១៣. **ទំហំនៃការអនុវត្តប្រព័ន្ធការពារក្នុងប្រទេស :** ដោយសារតែចំណុចសំខាន់នៃភាពសមមូល និងភាពអាចទទួលយកបាន គឺដើម្បីផ្ដល់នូវការពារ ប្រទេស តំបន់ ឬទីភ្នាក់ងារ អាចប្រើប្រាស់ CSS ដើម្បីការពារគោលដៅមួយ ពីរ ឬទាំងបី (បរិស្ថាន ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត និងក្រុមជនជាតិដើមភាគតិច) អាស្រ័យលើលទ្ធផលនៃការវាយតម្លៃ CSS។

១៤. **ការផ្ដល់ព័ត៌មាន និង ការពិគ្រោះយោបល់ :** តាមលទ្ធភាពដែលអាចធ្វើទៅបាន សំណើពង្រឹង និងប្រើប្រាស់ CSS (រួមទាំងមូលហេតុ) ត្រូវបង្ហាញនៅក្នុងយុទ្ធសាស្ត្រ ភាពជាដៃគូប្រចាំប្រទេស ឬនៅក្នុងរបាយការណ៍វិវឌ្ឍន៍នៃយុទ្ធសាស្ត្រភាពជាដៃគូ

ប្រចាំប្រទេស[៣] ។ ឯកសារដែលពាក់ព័ន្ធនឹងយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស ត្រូវផ្សព្វផ្សាយឱ្យស្របតាមលក្ខខណ្ឌតម្រូវនៃ *គោលនយោបាយប្រាស្រ័យទាក់ទងសាធារណៈ* (២០០៥) របស់ ADB ។ ក្រោយពេលបញ្ចប់ សេចក្ដីព្រាងនៃការវាយតម្លៃភាពសមមូល និងភាពអាចទទួលយកបាននៅកម្រិតថ្នាក់ជាតិ ក្រោមជាតិ តំបន់ និងកម្រិតទីភ្នាក់ងារ នឹងត្រូវរៀបចំចងក្រងជាឯកសារ និងផ្សព្វផ្សាយនៅលើគេហទំព័ររបស់ ADB ដើម្បីឱ្យសាធារណៈជនផ្ដល់យោបល់ ។ ADB នឹងរៀបចំសិក្ខាសាលាពិគ្រោះយោបល់នៅក្នុងប្រទេស ដើម្បីសុំមតិយោបល់ពីអ្នកពាក់ព័ន្ធ រួមទាំងរដ្ឋាភិបាល និង NGO ។ នៅពេលបញ្ចប់ របាយការណ៍វាយតម្លៃភាពសមមូល និងភាពអាចទទួលយកបានចុងក្រោយ នឹងត្រូវផ្សព្វផ្សាយលើគេហទំព័ររបស់ ADB ។ នៅពេលបញ្ចប់ ការវាយតម្លៃកែ-សម្រួលថ្មីដើម្បីឆ្លុះបញ្ចាំងពីការប្រែប្រួលរបស់ CSS (ប្រសិនបើមាន) ក៏នឹងត្រូវផ្សព្វផ្សាយលើគេហទំព័ររបស់ ADB ផងដែរ ។ បញ្ហាពាក់ព័ន្ធនឹងការវាយតម្លៃភាពអាចទទួលយកបាននៅកម្រិតគម្រោង នឹងក្លាយជាធាតុមួយនៃដំណើរការពិគ្រោះយោបល់ និងផ្សព្វ-ផ្សាយ ដែលនឹងត្រូវធ្វើនៅក្នុងការរៀបចំគម្រោង ។

១៥. **ការមិនអនុវត្ត CSS :** CSS នឹងមិនត្រូវបានយកទៅអនុវត្តក្នុងគម្រោងមានភាពស្មុគស្មាញ និងងាយរងការប៉ះពាល់ខ្លាំងឡើយ ។ គម្រោងប្រភេទនេះ នឹងត្រូវគោរពតាមលក្ខខណ្ឌតម្រូវសម្រាប់ការវាយតម្លៃគម្រោងជាធម្មតារបស់ ADB ។

១៦. **វិធីសាស្ត្រអនុវត្តជាដំណាក់កាល :** ការប្រើប្រាស់ CSS នឹងធ្វើនៅតាមបណ្ដាប្រទេសក្នុងចំនួនកម្រិតមួយ ដោយផ្ដោតលើកម្រិតក្រោមជាតិ តំបន់ និងកម្រិតទីភ្នាក់ងារ នៅក្នុងអំឡុងពេល ០៣ ឆ្នាំដំបូង បន្ទាប់ពីគោលនយោបាយចូលជាធរមាន ។ ការវាយតម្លៃបណ្ដោះអាសន្នចំពោះប្រសិទ្ធភាពនៃការអនុវត្ត និងប្រើប្រាស់ CSS នឹងធ្វើនៅឆ្នាំទី ០៣ ក្រោយពេលដែលគោលនយោ-បាយចូលជាធរមាន ។

១៧. **ការកែប្រែប្រព័ន្ធការពារក្នុងប្រទេស :** នៅអំឡុងពេលអនុវត្ត CSS ប្រសិនបើមានការកែប្រែច្បាប់ បទបញ្ជា វិធានឬនីតិវិធីនៅកម្រិតថ្នាក់ជាតិ ក្រោមជាតិ តំបន់ ឬកម្រិតទីភ្នាក់ងារ ADB នឹងវាយតម្លៃឥទ្ធិពលនៃការកែប្រែនោះ និងធ្វើការពិភាក្សាជាមួយអ្នកខ្ចី ។ ប្រសិនបើ ADB យល់ឃើញថាការកែប្រែនោះបានលើកកម្ពស់ CSS ឱ្យប្រសើរជាមុន ហើយប្រសិនបើអ្នកខ្ចីស្នើសុំ ADB អាចនឹងព្រមព្រៀង (១) កែសម្រួលកិច្ចព្រមព្រៀងដែលអនុវត្តចំពោះប្រតិបត្តិការឱ្យស្របទៅតាមការកែប្រែនេះ និងធ្វើវិសោ-ធនកម្មកិច្ចព្រមព្រៀង ប្រសិនបើចាំបាច់ និង (២) ធ្វើបច្ចុប្បន្នភាពការវាយតម្លៃភាពសមមូល និងភាពអាចទទួលយកបាន ។ ឯកសារពន្យល់ពីមូលហេតុនៃការកែប្រែកិច្ចព្រមព្រៀង ត្រូវផ្ញើឱ្យក្រុមប្រឹក្សាភិបាលអនុម័តសម្រេច (ដែលធម្មតានឹងគ្មានការជំទាស់ឡើយ) ។ ប្រសិនបើ CSS ត្រូវបានកែប្រែផ្ទុយទៅនឹងកិច្ចព្រមព្រៀងរវាងអ្នកខ្ចី និង ADB វិធីសាស្ត្រកែតម្រូវកិច្ចព្រមព្រៀងរបស់ ADB នឹងត្រូវយកមកអនុវត្ត ។

## ឃ. ការទទួលខុសត្រូវ និង គណនេយ្យភាពរបស់ ADB

១៨. **ការវាយតម្លៃភាពសមមូល និង ភាពអាចទទួលយកបាន :** ADB ទទួលខុសត្រូវវាយតម្លៃ និងកំណត់ភាពសមមូល

---

[៣] ដូចជា យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស ផែនការប្រតិបត្តិការប្រចាំប្រទេស និងរបាយការណ៍វាយតម្លៃពាក់កណ្ដាលត្រីមាស ។

នៃ CSS និងភាពអាចទទួលយកបាននៃលទ្ធភាព និងទម្លាប់អនុវត្តរបស់អ្នកខ្ចី ។ ADB នឹងធ្វើសកម្មភាពដូចខាងក្រោម :

(i) វាយតម្លៃភាពសមមូលនៃ CSS ធៀបជាមួយនឹងគោលនយោបាយការពារ កម្មវត្ថុ ទំហំ ការជម្រុញ និងគោល-ការណ៍របស់ ADB និងភាពអាចទទួលយកបាននៃទម្លាប់ ប្រវត្តិ និងសមត្ថភាពអនុវត្តរបស់អ្នកខ្ចី ព្រមទាំងកំណត់នូវវិធានការ និងសកម្មភាពដែលចាំបាច់ក្នុងការពង្រឹង CSS ដោយធ្វើការសហការជាមួយអ្នកខ្ចី ។

(ii) ជួយអ្នកខ្ចីក្នុងការរៀបចំផែនការសកម្មភាពផ្អែកលើលទ្ធផលនៃការវាយតម្លៃ និងបញ្ចូលផែនការសកម្មភាពនោះក្នុងកិច្ចព្រមព្រៀងប្រើប្រាស់ CSS ។ កិច្ចព្រមព្រៀង នឹងអនុញ្ញាតឱ្យ ADB ព្យួរការប្រើប្រាស់ CSS ហើយដាក់ឱ្យប្រើប្រាស់លក្ខខណ្ឌតម្រូវរបស់ ADB ជំនួសវិញ ប្រសិនបើអ្នកខ្ចីឈប់អនុវត្តផែនការសកម្មភាព ។

(iii) រៀបចំការពិគ្រោះយោបល់ (ដោយការមានចូលរួមពីតំណាង DMC) ជាមួយអ្នកពាក់ព័ន្ធ ដើម្បីពិភាក្សា និងបញ្ជាក់ពីលទ្ធផលនៃការវាយតម្លៃភាពសមមូល និងស្វែងរកការព្រមព្រៀងលើវិធានការស្នើឡើងក្នុងផែនការសកម្មភាព ។

(iv) ផ្តល់នូវការគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេសដែលចាំបាច់ក្នុងការអភិវឌ្ឍន៍ និងអនុវត្តផែនការសកម្មភាព តាមរយៈកម្មវិធីប្រាក់កម្ចី និងជំនួយបច្ចេកទេស និងតាមដានមើលការអនុវត្តផែនការសកម្មភាព ។

១៩. **ការវាយតម្លៃឯកសារ និង ការតាមដានការអនុវត្តគម្រោង :** ការប្រើប្រាស់ CSS មិនអាចគេចផុតពីការវាយតម្លៃលក្ខខណ្ឌតម្រូវសម្រាប់ការពារដោយ ADB នៅមុនពេលដែលក្រុមប្រឹក្សាភិបាលអនុម័តគម្រោងឡើយ ។ ចំណុចខុសគ្នា គឺការវាយតម្លៃនេះ នឹងផ្អែកទៅលើលក្ខខណ្ឌតម្រូវរបស់ CSS និងលក្ខខណ្ឌដែលបានព្រមព្រៀងក្នុងផែនការសកម្មភាព ។ នៅក្រោយពេលដែលក្រុមប្រឹក្សាភិបាលបានអនុម័តយល់ព្រមលើគម្រោងដែលប្រើ CSS ADB នឹងធ្វើការតាមដានតាមនីតិវិធីដែលប្រើសម្រាប់គម្រោងវិនិយោគផ្សេងទៀត ។

២០. **យន្តការគណនេយ្យភាព :** ការប្រើប្រាស់ CSS នឹងមិនធ្វើឱ្យប្រែប្រួលដល់តួនាទី និងមុខងារនៃយន្តការគណនេយ្យភាពរបស់ ADB និងមុខងាររបស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស និងគណៈកម្មការពិនិត្យអនុលោមភាពរបស់ ADB ឡើយ ។ ក្នុងករណីមានបណ្តឹងតវ៉ា គណៈកម្មការពិនិត្យអនុលោមភាព អាចត្រួតពិនិត្យការវាយតម្លៃរបស់ ADB ពីភាពសមមូលរវាងគោលនយោបាយ ទំហំ ការជម្រុញ និងគោលការណ៍ពាក់ព័ន្ធនានារបស់ ADB ជាមួយនឹង CSS (និងវិធានបន្ថែមផ្សេងទៀតដែលបានព្រមព្រៀងអនុវត្តដើម្បីសម្រេចឱ្យបាននូវភាពសមមូល) ដែលមានសារៈសំខាន់ក្នុងការសម្រេចឱ្យបាននូវកម្មវត្ថុរបស់ SPS និងការត្រួតពិនិត្យគម្រោងរបស់ ADB ។ ការប្រើប្រាស់ CSS នឹងមិនធ្វើឱ្យប្រែប្រួលដល់តួនាទីរបស់នាយកដ្ឋានវាយតម្លៃឯករាជ្យរបស់ ADB ឡើយ ។

## ខ. ការទទួលខុសត្រូវរបស់អ្នកខ្ចី

២១. **ការវាយតម្លៃប្រព័ន្ធការពារក្នុងប្រទេស និង ការអភិវឌ្ឍន៍ផែនការសកម្មភាព :** អ្នកខ្ចី នឹងគាំទ្រ និងចូលរួមក្នុងការ

វាយតម្លៃភាពសមមូល និងភាពអាចទទួលយកបាន។ អ្នកខ្ចី/អតិថិជន នឹង ៖

(i) ជួយសម្រួលដល់ការចែករំលែកឯកសារ ទិន្នន័យ និងព័ត៌មានជាមួយក្រុមវាយតម្លៃរបស់ ADB និងរៀបចំសិក្ខា-សាលា និង/ឬ វគ្គសិក្សានានា ប្រសិនបើចាំបាច់។

(ii) ជួយរៀបចំចាត់ចែងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដើម្បីពិភាក្សា និងបញ្ជាក់ពីលទ្ធផលនៃការវាយ-តម្លៃ។ និង

(iii) អភិវឌ្ឍន៍ផែនការសកម្មភាពដែលចែងពីវិធានការដោះស្រាយការកែប្រែដែលចាំបាច់។

២២. **ការអនុវត្ត ៖** អ្នកខ្ចី ជាអ្នកទទួលខុសត្រូវក្នុងការសម្រេច និងរក្សាឱ្យបាននូវភាពសមមូល និងអភិវឌ្ឍន៍នូវទម្លាប់ ប្រតិបត្តិ និងសមត្ថភាពអនុវត្តដែលអាចទទួលយកបានស្របតាមការវាយតម្លៃរបស់ ADB រួមទាំងការអនុវត្តផែនការសកម្មភាពផង។ ចំពោះគម្រោងដែលប្រើប្រាស់ CSS អ្នកខ្ចីជាអ្នកកំណត់បទបញ្ញត្តិរបស់ CSS ដែលចាំបាច់ក្នុងការធានាថាគោលការណ៍គោលនយោបាយដែលមានចែងក្នុង SPS ត្រូវបានបំពេញ។ បទបញ្ញត្តិទាំងនេះ អាចមានភាពខុសប្លែកគ្នាតាមគម្រោងនីមួយៗ អាស្រ័យលើកត្តានានាដូចជារចនាសម្ព័ន្ធរបស់ CSS និងប្រភេទនៃប្រតិបត្តិការជាដើម។ នៅគ្រប់ករណីទាំងអស់ បទបញ្ញត្តិ និងវិធានការបន្ថែមដែលអ្នកខ្ចីត្រូវបំពេញដើម្បីសម្រេច និងរក្សាឱ្យបាននូវភាពសមមូល និងការអនុវត្តដែលអាចទទួលយកបាន នឹងក្លាយជាផ្នែកមួយនៃកាតព្វកិច្ចរបស់អ្នកខ្ចី និងត្រូវអនុលោមតាមការវិធានការកែតម្រូវកិច្ចព្រមព្រៀងរបស់ ADB។

## ច. ផលវិបាកធនធាន

២៣. បើទោះជាដំណើរការពង្រឹង និងប្រើប្រាស់ CSS ត្រូវការធនធានច្រើន[៤] នៅពេលធ្វើការវាយតម្លៃកម្រិតថ្នាក់ជាតិ ក្រោមជាតិ ឬកម្រិតទីភ្នាក់ងារ និងនៅពេលរៀបចំគម្រោងក៏ដោយ សោហ៊ុយចំណាយត្រូវបានរំពឹងថានឹងត្រូវកាត់បន្ថយ នៅរយៈពេលមធ្យម និងរយៈពេលវែង។ នេះក៏ព្រោះតែនៅរយៈពេលវែង ការវាយតម្លៃភាពសមមូល និងភាពអាចទទួលយកបាន នឹងកើនឡើង។ ការអនុវត្ត CSS នៅក្នុងគម្រោងរបស់ ADB ទាមទារឱ្យមានការចំណាយលើ (១) ការវាយតម្លៃភាពភាពសមមូល និងភាពអាចទទួលយកបាន រួមទាំង ការពិគ្រោះយោបល់ដែលត្រូវរៀបចំនៅក្រោយការវាយតម្លៃ (២) សកម្មភាពអភិវឌ្ឍន៍សមត្ថភាពរយៈពេលមធ្យម និងរយៈពេលវែង ដើម្បីពង្រឹង CSS (៣) ការបណ្តុះបណ្តាលបុគ្គលិក ADB និង (៤) តាមដាន និងត្រួតពិនិត្យការអនុវត្ត CSS។

២៤. ក្នុងរយៈពេលមធ្យម សោហ៊ុយចំណាយពាក់ព័ន្ធនឹង CSS នឹងកើនឡើង។ នៅរៀងរាល់ឆ្នាំ បុគ្គលិកអាចនឹងត្រូវធ្វើការបន្ថែមសប្តាហ៍ ដើម្បីរៀបចំវាយតម្លៃភាពសមមូលរបស់ CSS តាមតម្រូវការ។ ការវាយតម្លៃភាពសមមូលនីមួយៗ អាចត្រូវការ

---

[៤] បទពិសោធន៍របស់ធនាគារពិភពលោកបង្ហាញថា ដំណើរនេះត្រូវការបុគ្គលិក និងទីប្រឹក្សាច្រើន ក្នុងការរៀបចំការវាយតម្លៃ និងការពិគ្រោះយោបល់ជាសាធារណៈ និងក្នុងការរៀបចំរបាយការណ៍វាយតម្លៃ។

៥-១២ សប្តាហ៍ ហើយការវាយតម្លៃភាពអាចទទួលយកបាន ត្រូវការប៉ុន្មានសប្តាហ៍ផ្សេងទៀត។ ការប្រើប្រាស់ធនធាន ក៏អាចនឹងត្រូវកើនឡើងផងដែរ នៅពេលដែលត្រូវការជួលបុគ្គលិកទីប្រឹក្សាតាមតម្រូវការ។ លើសពីនេះ ធនាគារពិភពលោក ដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ និងអនុវត្តវិធីសាស្រ្តវាយតម្លៃ CSS និងមានការចាប់អារម្មណ៍ក្នុងការរួមគ្នាជាមួយស្ថាប័នដៃគូក្នុងការធ្វើកិច្ចការនេះ។ ការរួមសហការជាមួយស្ថាប័នដៃគូដូចជាធនាគារពិភពលោក នឹងជួយបង្កើនប្រសិទ្ធភាព និងធានានូវប្រសិទ្ធផលនៃការចំណាយធនធានបន្ថែមមួយកម្រិតទៀត។

# បទពិសោធន៍របស់ស្ថាប័នហិរញ្ញវត្ថុពហុភាគីផ្សេងទៀត

១. ប្រមាណជា ៥ ឆ្នាំកន្លងមកនេះ ស្ថាប័នហិរញ្ញវត្ថុពហុភាគីជាច្រើន បានកែសម្រួល ឬធ្វើបច្ចុប្បន្នភាពគោលនយោបាយការពារបរិស្ថាន និងសង្គមរបស់ពួកគេ។ សនិទានភាព វិធីសាស្ត្រ និងលទ្ធផលនៃការកែសម្រួលគោលនយោបាយ ត្រូវបានមកពិនិត្យដើម្បីធ្វើគោលនយោបាយការពារកែសម្រួលថ្មី (SPU) របស់ ADB។ បទពិសោធន៍របស់ធនាគារពិភពលោក និងស្ថាប័នផ្តល់ប្រាក់កម្ចីដល់ផ្នែកឯកជន សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ធនាគារអភិវឌ្ឍន៍អន្តរអាមេរិក (IDB) ធនាគារអឺរ៉ុបសម្រាប់ការស្ថាបនា និងអភិវឌ្ឍន៍ (EBRD) និងគោលការណ៍អេក្វាទ័ររបស់ស្ថាប័នហិរញ្ញវត្ថុ មានពិភាក្សានៅខាងក្រោម។

## ក. ធនាគារពិភពលោក

២. ធនាគារពិភពលោក មានគោលនយោបាយការពារបរិស្ថាន និងសង្គមចំនួន ១០[១] និងមានក្របខណ្ឌគោលនយោបាយដាច់ដោយឡែកសម្រាប់ការប្រើប្រាស់ប្រព័ន្ធការពារក្នុងប្រទេស។ គោលនយោបាយទាំងនេះ ត្រូវបានបំពេញបន្ថែមដោយគោលនយោបាយផ្សព្វផ្សាយព័ត៌មាន (២០០២) ដែលកំណត់នូវលក្ខខណ្ឌតម្រូវក្នុងការផ្សព្វផ្សាយឯកសាររៀបចំផែនការការពារ។

៣. នៅឆ្នាំ ១៩៩៨ ធនាគារពិភពលោក បានធ្វើបច្ចុប្បន្នភាពគោលនយោបាយក្រុមជនជាតិដើមភាគតិចរបស់ខ្លួន ដោយបានធ្វើការបញ្ជាក់ឱ្យកាន់តែច្បាស់ សម្រួលធ្វើឱ្យងាយស្រួល ពង្រឹងបន្ថែម និងធ្វើឱ្យគោលនយោបាយនោះកាន់តែមានភាពបត់បែន។ គោលនយោបាយប្រតិបត្តិការកែសម្រួលថ្មីស្តីពីក្រុមជនជាតិដើមភាគតិច (២០០៥) (១) បញ្ជាក់នូវចំណុចមិនច្បាស់លាស់មួយចំនួនដែលទាក់ទងទៅនឹងការវាយតម្លៃផលប៉ះពាល់សង្គម ការពិនិត្យ និងទំហំអនុវត្ត (២) សម្រួលលក្ខខណ្ឌតម្រូវសម្រាប់វាយតម្លៃគម្រោង (៣) ណែនាំឱ្យប្រើគោលការណ៍សមមាត្រ និងក្របខណ្ឌរៀបចំផែនការ (ជំនួសឱ្យការរៀបចំផែនការទុកមុន) សម្រាប់គម្រោងដែលមានពាក់ព័ន្ធនឹងការរៀបចំ និងអនុវត្តកម្មវិធីវិនិយោគប្រចាំឆ្នាំ និងមានអនុគម្រោងច្រើន និង (៤) ដាក់កំហិតឱ្យធនាគារពិភពលោកផ្តល់ហិរញ្ញប្បទានតែចំពោះគម្រោងណាដែលមានការគាំទ្រជារួមពីសហគមន៍ជនជាតិដើមភាគតិច (ផ្អែកលើការ

[១] គោលនយោបាយទាំង ១០ នេះមានដូចតទៅ : (i) ការវាយតម្លៃបរិស្ថាន (OP/BP 4.01), (ii) ជម្រកធម្មជាតិ (OP/BP 4.04), (iii) ការគ្រប់គ្រងសត្វល្អិតចង្រៃ (OP 4.09), (iv) ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត (OP/BP 4.12), (v) ក្រុមជនជាតិដើមភាគតិច (OP/BP 4.10), (vi) ព្រៃឈើ (OP 4.36), (vii) ធនធានធម្មជាតិរូបវន្ត (OP 4.11), (viii) សុវត្ថិភាពទំនប់ទឹក (OP/BP 4.37), (ix) គម្រោង នៅលើផ្លូវទឹកអន្តរជាតិ (OP/BP 7.50), និង (x) គម្រោងនៅក្នុងតំបន់មានវិវាទ (OP/BP 7.60)។ ដោយសារតែគោលនយោបាយពីរចុងក្រោយពាក់ព័ន្ធជាចំបងនឹងច្បាប់អន្តរជាតិ គោលនយោបាយទាំងពីរនេះ មិនត្រូវបានយកមកអនុវត្តនៅក្នុងកម្មវិធីសាកល្បង (OP 4.00) ដែលពិភាក្សាក្នុងកថាខណ្ឌ ៥ និង ៦ ឡើយ។

ពិគ្រោះយោបល់ជាមុនពោរពេញដោយអត្ថន័យ និងដោយសេរី) និងដែលមានការព្រមព្រៀងជាមុនចំពោះការអភិវឌ្ឍន៍ពាណិជ្ជកម្មលើចំណេះដឹង និងធនធានវប្បធម៌របស់ពួកគេ[២] ។

៤. នៅឆ្នាំ ២០០៦ ធនាគារពិភពលោក បានធ្វើបច្ចុប្បន្នភាពគោលនយោបាយធនធានវប្បធម៌រូបវន្តរបស់ខ្លួន។ គោលនយោបាយនេះ អនុវត្តចំពោះគម្រោងដែលស្ថិតនៅក្នុង ឬនៅក្បែរតំបន់បេតិកភណ្ឌវប្បធម៌ (ដែលមានសារៈសំខាន់ខាងបុរាណវត្ថុវិទ្យា ហ្វូស៊ីលវិទ្យា ប្រវត្តិសាស្ត្រ និងទីកន្លែងសក្ការៈបូជា) និងគម្រោងដែលរចនាឡើងដើម្បីទ្រទ្រង់ដល់ការគ្រប់គ្រង និងអភិរក្សធនធានវប្បធម៌រូបវន្ត។ គោលនយោបាយនេះ ទាមទារឱ្យមានការពិគ្រោះយោបល់ជាមួយក្រុមរងផលប៉ះពាល់ អាជ្ញាធររដ្ឋាភិបាល និងក្រុមមិនមែនរដ្ឋាភិបាល។

៥. នៅពេលធ្វើបច្ចុប្បន្នភាពគោលនយោបាយខាងលើ ធនាគារពិភពលោក ក៏បានពិចារណាប្រើប្រាស់ប្រព័ន្ធការពារក្នុងប្រទេសនៅក្នុងប្រតិបត្តិការរបស់ខ្លួនផងដែរ។ ក្រោយពីបានទទួលស្គាល់នូវការប្រែប្រួលទំនាក់ទំនងរវាងប្រសិទ្ធភាពអភិវឌ្ឍន៍ និងការប្រើប្រាស់ប្រព័ន្ធការពារក្នុងប្រទេស ធនាគារពិភពលោក បានសិក្សាពីការប្រើប្រាស់ប្រព័ន្ធរបស់អ្នកខ្ចី ក្នុងការដោះស្រាយបញ្ហាការពារបរិស្ថាន និងសង្គម។ នៅឆ្នាំ ២០០៥ ក្រុមប្រឹក្សានាយកប្រតិបត្តិ បានអនុម័តកម្មវិធីសាកល្បងរយៈពេល ២ ឆ្នាំ សម្រាប់គោលបំណងនេះ និងក្របខណ្ឌគោលនយោបាយដើម្បីគ្រប់គ្រងកម្មវិធីសាកល្បងនេះ។ ក្របខណ្ឌគោលនយោបាយនេះ រៀបរាប់ពីវិធីសាស្ត្រវាយតម្លៃប្រព័ន្ធការពារក្នុងប្រទេស និងកំណត់តួនាទីរបស់អ្នកខ្ចី និងរបស់ធនាគារពិភពលោក និងលក្ខខណ្ឌតម្រូវក្នុងការចងក្រងឯកសារ និងការផ្តល់ព័ត៌មាន។ នៅក្នុងគោលនយោបាយ មានសេចក្តីថ្លែងការណ៍គោលនយោបាយរួម និងតារាងសង្ខេបចំណុចត្រូវការពារទាំងប្រាំបី (ដកស្រង់ចេញពីគោលនយោបាយការពារបច្ចុប្បន្នរបស់ធនាគារពិភពលោក [OP 4.00, Table A1]) ហើយក្នុងចំណុចត្រូវការពារនីមួយៗ មានចែងពីកម្មវត្ថុ និងគោលការណ៍ប្រតិបត្តិការពាក់ព័ន្ធដែលត្រូវបំពេញ ដើម្បីសម្រេចឱ្យបាននូវកម្មវត្ថុដែលបានកំណត់។

៦. នៅខែមករា ឆ្នាំ ២០០៨ ធនាគារពិភពលោកបានចេញរបាយការណ៍វាយតម្លៃកម្មវិធីសាកល្បងរយៈពេល ០២ ឆ្នាំនេះ។ យោងតាមរបាយការណ៍វាយតម្លៃ ដើម្បីសម្រេចបាននូវការលើកកម្ពស់សមត្ថភាពរបស់អ្នកខ្ចីជាប្រព័ន្ធ និងប្រកបដោយនិរន្តរភាព ធនាគារពិភពលោកចាំបាច់ត្រូវបោះបង់វិធីសាស្ត្រអនុវត្តត្រឹមថ្នាក់គម្រោងដែលប្រើក្នុងកម្មវិធីសាកល្បង។ របាយការណ៍បានសន្និដ្ឋានថា គំនិតផ្តួចផ្តើមនេះត្រូវពង្រីកបន្តិចម្តងៗពីកម្រិតគម្រោងទៅកម្រិតថ្នាក់ជាតិ ដើម្បីឱ្យអ្នកខ្ចី និងដៃគូអភិវឌ្ឍន៍ផ្សេងទៀតអាចផ្តល់ការការពារបានទូលំទូលាយ និងដើម្បីអាចកសាងសមត្ថភាពអ្នកខ្ចីឱ្យមាននិរន្តរភាពជាងការសម្រេចបាននៅកម្រិតគម្រោង។ ការសន្និដ្ឋានសំខាន់ៗផ្សេងទៀត រួមមាន : (១) ការប្រើប្រាស់ប្រព័ន្ធការពារក្នុងប្រទេស បានជួយដល់ការសម្រេចកម្មវត្ថុនៃគោលនយោបាយរបស់ធនាគារពិភពលោក ជាពិសេស ការវាយតម្លៃបរិស្ថាន និងធនធានវប្បធម៌រូបវន្ត (២) គម្លាតរវាងប្រព័ន្ធការពារក្នុងប្រទេស និងគោលនយោបាយការពារជម្រកធម្មជាតិ ព្រៃឈើ ការគ្រប់គ្រងសត្វល្អិតចង្រៃ និងសុវត្ថិភាពទំនប់ទឹក របស់ធនាគារ

---

[២] គេហទំព័ររបស់ធនាគារពិភពលោកអំពីក្រុមជនជាតិដើមភាគតិច : http://web.worldbank.org/WBSITE/EXTERNAL/TOPICS/EXTSOCIALDEVELOPMENT/EXTINDPEOPLE/0,,menuPK:407808~pagePK:149018~piPK:149093~theSitePK:407802,00.html

ពិភពលោក មានក្តីសង្ឃឹមថានឹងអាចបំបាត់បានដោយវិធានការបំបាត់គម្លាត (៣) ប៉ុន្តែ ចំពោះការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត លក្ខខណ្ឌតម្រូវរបស់ធនាគារពិភពលោក និងប្រព័ន្ធការពារក្នុងប្រទេស មានគម្លាតគ្នាយ៉ាងខ្លាំង ដែលក្នុងករណីភាគច្រើនគម្លាតនោះមិនអាចបំបាត់ដោយវិធានការបំបាត់គម្លាតរបស់គម្រោងបានឡើយ (៤) បើទោះជាលក្ខខណ្ឌតម្រូវសម្រាប់ការពារក្រុមជនជាតិដើមភាគតិច មិនត្រូវបានសាកល្បងនៅក្នុងកម្មវិធីសាកល្បងក៏ដោយ ប្រទេសមួយចំនួនបានធ្វើបច្ចុប្បន្នភាពក្របខណ្ឌច្បាប់ និងគោល-នយោបាយដែលពាក់ព័ន្ធនឹងបញ្ហានេះ (ទោះបីជាពួកគេមិនបានធ្វើបច្ចុប្បន្នភាពក្របខណ្ឌនៃការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្តរបស់ពួកគេក៏ដោយ) (៥) ធនាគារពិភពលោកមានទំនុកចិត្តគ្រប់គ្រាន់ក្នុងការពង្រីកជាលំដាប់នូវការអនុវត្តប្រព័ន្ធការពារក្នុងប្រទេសក្នុងកិច្ចការពារបរិស្ថាន និងសង្គម តែធនាគារនៅមិនទាន់មានទំនុកចិត្តគ្រប់គ្រាន់ក្នុងការប្រើប្រាស់ប្រព័ន្ធនេះនៅរាល់គ្រប់ការផ្តល់កម្ចីរបស់ធនាគារនៅឡើយ ។

៧. សម្រាប់ថ្ងៃអនាគត ធនាគារពិភពលោកកំពុងពិចារណាធ្វើការវាយតម្លៃដាច់ដោយឡែកមួយចំពោះការប្រើប្រាស់វិធីសាស្ត្រផ្អែកតាមគោលការណ៍ ដើម្បីផ្តល់ការពារដល់ប្រភេទនៃប្រតិបត្តិការមួយចំនួន នៅក្រោយពេលដែលធនាគារសិក្សាមេរៀនដែលបានមកពីការអនុវត្តគោលនយោបាយការពាររបស់ IFC និងទីភ្នាក់ងារធានាការវិនិយោគពហុភាគី (MIGA) ។

៨. គោលនយោបាយប្រតិបត្តិការវាយតម្លៃបរិស្ថានរបស់ធនាគារពិភពលោក (OP 4.01) ត្រូវបានធ្វើបច្ចុប្បន្នភាពនៅខែមិនា ឆ្នាំ ២០០៧ ដើម្បីឆ្លុះបញ្ចាំងគោលនយោបាយរបស់ធនាគារក្នុងការ ឆ្លើយតបភ្លាមៗនឹងវិបត្តិ និងគ្រោះអាសន្ន (OP/BP 8.00) ។

## ខ. សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ

៩. គោលនយោបាយការពាររបស់ IFC បានយកគំរូតាមគោលនយោបាយរបស់ធនាគារពិភពលោកនៅឆ្នាំ ១៩៩៨ ដោយមានការកែប្រែមួយចំនួនតម្រូវតាមប្រតិបត្តិការផ្តោតលើវិស័យឯកជនរបស់ខ្លួន ។ នៅឆ្នាំ ២០០៣ IFC បានធ្វើបច្ចុប្បន្នភាពគោល-នយោបាយការពាររបស់ខ្លួន នៅក្រោយពេលទទួលបានលទ្ធផល និងអនុសាសន៍ពីក្រុមទីប្រឹក្សាទទួលបណ្តឹងតវ៉ាពីបញ្ហាអនុលោមភាព និងលទ្ធផលនៃការតាមដាន និងវាយតម្លៃផ្ទៃក្នុងរបស់ IFC ។ ការធ្វើបច្ចុប្បន្នភាពនេះ ត្រូវបានធ្វើដោយសារតែមានតម្រូវការ (១) ឱ្យមានលក្ខខណ្ឌតម្រូវច្បាស់លាស់ សាមញ្ញ និងងាយស្រួលប្រើ (២) ដោះស្រាយបញ្ហាគម្លាតគោលនយោបាយ (៣) ការសង្កត់ធ្ងន់លើវិស័យឯកជនតែធានានូវអនុលោមភាពជាមួយនឹងគោលនយោបាយការពាររបស់ធនាគារពិភពលោក និង (៤) បញ្ចូលទស្សនទាននិរន្តរភាពទៅក្នុងគោលនយោបាយ IFC ។

១០. ក្របខណ្ឌគោលនយោបាយនិរន្តរភាពថ្មីរបស់ IFC ដែលត្រូវបានអនុម័តនៅឆ្នាំ ២០០៦ បានបែងចែងយ៉ាងច្បាស់ពីការទទួលខុសត្រូវរបស់ IFC និងការទទួលខុសត្រូវរបស់អតិថិជន ។ លក្ខខណ្ឌតម្រូវរបស់ IFC ត្រូវបានចែងនៅក្នុងគោលនយោបាយដូចតទៅ : (១) និរន្តរភាពបរិស្ថាន និងសង្គម (២) ការផ្តល់ព័ត៌មាន[៣] និង (៣) នីតិវិធីវាយតម្លៃបរិស្ថាន និងសង្គម ។ លក្ខខណ្ឌ

[៣] គោលនយោបាយផ្តល់ព័ត៌មានរបស់ IFC តម្រូវឱ្យ IFC ធ្វើការផ្សព្វផ្សាយរបាយការណ៍សង្ខេបនៃការវាយតម្លៃបរិស្ថាន និងសង្គម (របាយ-ការណ៍សង្ខេបនៃលទ្ធផលវាយតម្លៃ និងអនុសាសន៍របស់ IFC) នៅចំពោះមុខក្រុមប្រឹក្សាភិបាល ក្នុងរយៈពេល ៦០ ថ្ងៃ ចំពោះគម្រោង

តម្រូវសម្រាប់អតិថិជន មានចែងនៅក្នុងស្តង់ដារអនុវត្ត[៤] ។ លើសពីនេះ កំណត់សម្គាល់គោលការណ៍ណែនាំ (ឯកសារអមនឹងស្តង់ដារអនុវត្ត) សន្ទានុក្រម និងគោលការណ៍ណែនាំពីសុវត្ថិភាព សុខភាព និងបរិស្ថាន[៥] ផ្តល់ការណែនាំដល់អតិថិជន និងបុគ្គលរបស់ IFC ។

១១. ក្របខណ្ឌគោលនយោបាយថ្មី បានត្រូវដាក់បញ្ចូលទាំងស្រុងទៅក្នុងការវាយតម្លៃបរិស្ថាន និងសង្គម បានផ្តល់ឱ្យមាននូវវិធីសាស្ត្រជួបជាមួយសហគមន៍តាមរយៈការពិគ្រោះយោបល់ជាមុនដោយសេរី និងពោរពេញដោយអត្ថន័យ ដែលនាំឱ្យមានការគាំទ្រជារួមពីសហគមន៍ បានបង្កើតឱ្យមាននូវគោលនយោបាយស្តង់ដារពលកម្ម និងលក្ខខណ្ឌការងារ និងស្តង់ដារអនុវត្តថ្មីសម្រាប់សុខភាព និងសុវត្ថិភាពសហគមន៍ និងបានតម្រូវឱ្យបង្កើត និងរក្សាដោយអតិថិជននូវប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម ។ អតីតគោលនយោបាយដាច់ដោយឡែក ដូចជា ការគ្រប់គ្រងសត្វល្អិតចង្រៃ សុវត្ថិភាពទំនប់ទឹក ព្រៃឈើ និងផ្លូវទឹកអន្តរជាតិ ត្រូវបានដាក់បញ្ចូលក្នុងស្តង់ដារអនុវត្តថ្មីទាំង ៨[៦] ។ នៅខែ វិច្ឆិកា ឆ្នាំ ២០០៧ ថ្នាក់ដឹកនាំ IFC បានធ្វើសេចក្តីរាយការណ៍នៅចំពោះមុខក្រុមប្រឹក្សាភិបាលពីការយល់ឃើញរបស់អតិថិជន IFC ចំពោះស្តង់ដារអនុវត្ត ។

## គ. ធនាគារអភិវឌ្ឍន៍អន្តរអាមេរិក

១២. ក្របខណ្ឌគោលនយោបាយការពាររបស់ IDB មានចែងក្នុងគោលនយោបាយតាមវិស័យជាច្រើនរបស់ IDB ដូចជាគោលនយោបាយបរិស្ថាន និងការអនុវត្តតាមលក្ខខណ្ឌការពារ (២០០៦) ការគ្រប់គ្រងហានិភ័យនៃគ្រោះថ្នាក់ (២០០៧) ក្រុមជនជាតិដើមភាគតិច (២០០៦) និងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត (១៩៩៨) ។ លក្ខខណ្ឌតម្រូវក្នុងការផ្តល់ព័ត៌មាន មានចែងនៅក្នុងគោលនយោបាយផ្តល់ព័ត៌មាន (២០០៦)[៧] ។

---

ប្រភេទ ក និង ៣០ថ្ងៃ ចំពោះគម្រោងប្រភេទ ខ ។ ស្តង់ដារអនុវត្ត ចែងពីលក្ខខណ្ឌតម្រូវក្នុងការផ្តល់ព័ត៌មានសម្រាប់អតិថិជនរបស់ IFC ។ ស្តង់ដារអនុវត្ត ១ (ប្រព័ន្ធគ្រប់គ្រងសង្គម និងបរិស្ថាន) តម្រូវឱ្យ IFC ផ្សព្វផ្សាយឯកសារវាយតម្លៃគម្រោងដែលមានផលប៉ះពាល់អវិជ្ជមាននៅមុនពេលចាប់ផ្តើមសាងសង់គម្រោង ។ ពេលវេលាផ្សព្វផ្សាយផែនការសកម្មភាពតាំងទីលំនៅជាថ្មី ឬក្របខណ្ឌតាំងទីលំនៅជាថ្មី និងផែនអភិវឌ្ឍន៍ក្រុមជនជាតិដើមភាគតិច ឬផែនការអភិវឌ្ឍន៍សហគមន៍ មិនឃើញមានចែងឱ្យបានច្បាស់លាស់នៅក្នុងស្តង់ដារអនុវត្តពាក់ព័ន្ធឡើយ ។

[៤] ស្តង់ដារអនុវត្តចំនួន ៨ រួមមាន : (i) ប្រព័ន្ធគ្រប់គ្រង និងវាយតម្លៃបរិស្ថាន និងសង្គម (ii) ពលកម្ម និងលក្ខខណ្ឌការងារ (iii) ការបង្ការ និងការកាត់បន្ថយការបំពុល (iv) សុខភាព សុវត្ថិភាព និងសន្តិសុខសហគមន៍ (v) លទ្ធកម្មដី និងការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត (vi) ការអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព (vii) ក្រុមជនជាតិដើមភាគតិច និង (viii) បេតិកភណ្ឌវប្បធម៌ ។

[៥] សូមមើល : http://www.ifc.org/ifcext/policyreview.nsf/Content/S_FAQs

[៦] IFC. ២០០៥. ស្តង់ដារអនុវត្ត : អ្វីដែលថ្មី និងខុសពីមុន ។

[៧] គោលនយោបាយផ្តល់ព័ត៌មានរបស់ IDB បានចែងថា ចំពោះគម្រោងដែលតម្រូវឱ្យមានការវាយតម្លៃផលប៉ះពាល់បរិស្ថាន ឬការវិភាគបរិស្ថានពាក់ព័ន្ធផ្សេងទៀត ការវិភាគទាំងនេះ ត្រូវផ្សព្វផ្សាយជាសាធារណៈនៅក្នុងប្រទេសកូនបំណុល និងនៅទីស្នាក់ការកណ្តាលរបស់ IDB នៅមុនពេល IDB ចាប់ផ្តើមបេសកម្មវិភាគ (ករណីអ្នកខ្ចីវិស័យសាធារណៈ) ឬបេសកម្មអង្កេតលម្អិត (ករណីអ្នកខ្ចីវិស័យឯកជន) ។

១៣. គោលនយោបាយបរិស្ថាន និងអនុលោមភាពការពារ ដែលដាក់ឱ្យប្រើជំនួសគោលនយោបាយបរិស្ថាន (១៩៧៩) អនុវត្ត និងពង្រឹងយុទ្ធសាស្ត្របរិស្ថានរបស់ IDB (២០០៣)។ ហេតុនេះ គោលនយោបាយនេះ មានចែងពីការណែនាំគោលនយោបាយ បញ្ច្រាប និងការពារបរិស្ថាន[៨] ។ ការណែនាំពីការការពារបរិស្ថាន បានចែងពីបញ្ហាជាច្រើន ដែលក្នុងនោះរួមមាន ការការពារទីជម្រកធម្មជាតិ និងតំបន់វប្បធម៌សំខាន់ៗ ការបញ្ចៀសការប្រើប្រាស់សារធាតុគ្រោះថ្នាក់ និងការបង្ការ និងបន្ថយការបំពុល ។ លើសពីនេះ ដំណើរការវាយតម្លៃបរិស្ថានសម្រាប់ប្រតិបត្តិការដែលមានហានិភ័យការពារខ្ពស់ ក៏មានចែងពីបញ្ហាពាក់ព័ន្ធនឹងសុខភាព និងសុវត្ថិ-ភាពផងដែរ ។ ចំពោះប្រតិបត្តិការសហហិរញ្ញប្បទាន គោលនយោបាយបានធ្វើការជម្រុងឱ្យមានការសហការជាមួយអ្នកខ្ចី និងអ្នកផ្តល់ប្រាក់កម្ចីផ្សេងទៀត ក្នុងការអនុម័តយកនូវដំណើរការទោលក្នុងការវាយតម្លៃបរិស្ថាន និងការចងក្រងឯកសារ ។ ចំពោះប្រព័ន្ធការពារក្នុងប្រទេស គោលនយោបាយបានចែងពីវិធីសាស្ត្រដែលមានលក្ខណៈប្រហាក់ប្រហែលនឹងវិធីសាស្ត្ររបស់ធនាគារពិភពលោក ។ ប្រព័ន្ធការពារក្នុងប្រទេស នឹងត្រូវយកមកអនុវត្តតែនៅក្នុងករណីដែល IDB កំណត់ថាប្រព័ន្ធរបស់អ្នកខ្ចីមានភាពសមមូល ឬប្រសើរជាងប្រព័ន្ធរបស់ IDB តែប៉ុណ្ណោះ ។ នៅឆ្នាំ ២០០៩ ថ្នាក់ដឹកនាំ IDB នឹងរាយការណ៍ជូនដល់ក្រុមប្រឹក្សាភិបាលពីបទពិសោធន៍នៃការប្រើប្រាស់ប្រព័ន្ធការពារក្នុងប្រទេស[៩] ។

១៤. គោលនយោបាយគ្រប់គ្រងហានិភ័យនៃគ្រោះថ្នាក់ (២០០៧) ដែលដាក់ឱ្យប្រើជំនួសគោលនយោបាយគ្រោះធម្មជាតិ និងគ្រោះថ្នាក់ចៃដន្យ (១៩៩៩) តម្រូវឱ្យមានវិធីសាស្ត្រទូលំទូលាយក្នុងការ (១) បង្ការ និងកាត់បន្ថយគ្រោះថ្នាក់ និង (២) ការឆ្លើយតបនៅដំណាក់កាលក្រោយគ្រោះថ្នាក់ ។ គោលនយោបាយថ្មីនេះ តម្រូវឱ្យក្រុមការងារគម្រោង (តាមរយៈការពិនិត្យ និងចាត់ចំណាត់ថ្នាក់ផលប៉ះពាល់បរិស្ថាន និងសង្គម) ធ្វើការវាយតម្លៃទំហំផលប៉ះពាល់របស់គម្រោងចំពោះបរិស្ថាន ឬភាពដែលអាចបង្កឱ្យមានហានិភ័យកាន់តែធ្ងន់ធ្ងរ ធ្វើការវាយតម្លៃហានិភ័យនៃគ្រោះថ្នាក់ចំពោះបរិស្ថាននៃគម្រោងដែលអាចមានផលប៉ះពាល់ចំពោះបរិស្ថាន ឬដែលអាចបង្កឱ្យមានផលប៉ះពាល់បរិស្ថានកាន់តែធ្ងន់ធ្ងរ ធ្វើការវិភាគរកមើលវិធានការផ្សេងទៀតក្នុងការបង្ការ និងកាត់បន្ថយផលប៉ះពាល់ និងធ្វើការដាក់បញ្ចូលនូវវិធានការកាត់បន្ថយសមស្របដែលមានលក្ខណៈជារចនាសម្ព័ន្ធ និងគ្មានរចនាសម្ព័ន្ធ ក្នុងប្លង់រចនា និងការអនុវត្តគម្រោង ។

១៥. គោលនយោបាយប្រតិបត្តិការរបស់ IDB សម្រាប់ក្រុមជនជាតិដើមភាគតិច និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ក្រុមជនជាតិដើមភាគតិច (២០០៦) ព្យាយាមធ្វើការអភិវឌ្ឍន៍ និងការពារក្រុមជនជាតិដើមភាគតិច និងសិទ្ធិរបស់ពួកគេ ពីផលប៉ះពាល់អវិជ្ជមាន និងការមិនរាប់បញ្ចូលក្នុងគម្រោងដែលទទួលហិរញ្ញប្បទានពី IDB ។ វិធីសាស្ត្រថ្មីនេះ បំពេញបន្ថែមនូវលើការយកចិត្តទុកដាក់របស់

---

ប្រសិនបើចាំបាច់ IDB នឹងរៀបចំរបាយការណ៍គ្រប់គ្រងបរិស្ថាន និងសង្គម ដែលនឹងត្រូវផ្សព្វផ្សាយជាសាធារណៈនៅមុនពេលដែលសំណើសុំប្រាក់កម្ចី ឬការធានាត្រូវបានអនុប្រធានប្រតិបត្តិសម្រេចដាក់ឱ្យក្រុមប្រឹក្សាភិបាលពិនិត្យ ។

[៨] នៅក្នុងលក្ខខណ្ឌតម្រូវសម្រាប់ការពារបរិស្ថាន គោលនយោបាយ តម្រូវឱ្យធ្វើការពិនិត្យ និងចាត់ចំណាត់ថ្នាក់ចម្រុះ ផ្អែកលើផលប៉ះពាល់បរិស្ថាន និងសង្គមដោយផ្ទាល់ ដោយប្រយោល តាមតំបន់ ឬបង្ករ រួមទាំង ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ ។ IDB បានអនុម័តយកប្រព័ន្ធចាត់ចំណាត់ថ្នាក់គម្រោងទោល ។

[៩] IDB. ២០០៦. *គោលនយោបាយបរិស្ថាន និងអនុលោមភាពការពារ* Washington, DC.

IDB ក្នុងការបញ្ចៀស ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមានរបស់គម្រោង IDB លើក្រុមជនជាតិដើមភាគតិច។ ដើម្បីផ្តល់ការការពារបន្ថែមដល់សិទ្ធិរបស់ក្រុមជនជាតិដើមភាគតិចក្នុងគម្រោងដែលអាចមានផលប៉ះពាល់ និងហានិភ័យធ្ងន់ធ្ងរ IDB តម្រូវឱ្យសមាសភាគគម្រោងស្វែងរកការឯកភាពចំពោះគម្រោង និងវិធានការកាត់បន្ថយ តាមរយៈការចរចាដោយសុទ្ធចិត្តជាមួយក្រុមជនជាតិដើមភាគ-តិចរងផលប៉ះពាល់ និងផ្តល់ភស្តុតាងបញ្ជាក់ថាបានរៀបចំការចរចានេះ។ គោលនយោបាយក្រុមជនជាតិដើមភាគតិច ក៏បានធ្វើការដោះស្រាយបញ្ហារបស់ក្រុមជនជាតិដើមភាគតិចដែលមិនអាចទំនាក់ទំនង ដោយសារតែលក្ខណៈដោយឡែករបស់ពួកគេ ព្រមទាំងភាពងាយរងគ្រោះពិសេសរបស់ពួកគេ និងភាពមិនអាចអនុវត្តបាននៃយន្តការពិគ្រោះយោបល់ជាមុន និងការចរចាដោយសុទ្ធចិត្ត។ គោលនយោបាយនេះ តម្រូវឱ្យ IDB ផ្តល់ហិរញ្ញប្បទានតែចំពោះគម្រោងណាដែលគោរពសិទ្ធិរបស់ក្រុមជនជាតិដើមភាគតិចដែលមិនអាចទំនាក់ទំនងបាន ក្នុងការរស់នៅដាច់ដោយឡែកដោយស្ម័គ្រចិត្ត និងដោយសេរី ស្របតាមវប្បធម៌របស់ពួកគេ។

១៦. គោលនយោបាយតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត អនុវត្តតែចំពោះការផ្លាស់ទីលំនៅរូបវន្តដោយមិនបង្ខំដែលបណ្តាលមកពីគម្រោង IDB តែប៉ុណ្ណោះ។ គោលនយោបាយនេះ មានគោលបំណងកាត់បន្ថយការកាត់ផ្តាច់មធ្យោបាយចិញ្ចឹមជីវិតរបស់មនុស្សដែលរស់នៅក្នុងតំបន់រងការប៉ះពាល់ពីគម្រោង តាមរយៈការបញ្ចៀស ឬកាត់បន្ថយតម្រូវការក្នុងការផ្លាស់ទីលំនៅរូបវន្ត និងតាម-រយៈការធានាថា ប្រសិនបើចាំបាច់ត្រូវតែផ្លាស់ទីលំនៅ មនុស្សដែលត្រូវផ្លាស់ទីលំនៅនឹងមានសិទ្ធិស្មើៗគ្នា ហើយ (ប្រសិនបើអាច) អាចទទួលបានផលប្រយោជន៍ពីគម្រោងដែលតម្រូវឱ្យពួកគេតាំងទីលំនៅជាថ្មី។ ប្រសិនក្រុមជនជាតិដើមភាគតិចត្រូវផ្លាស់ទីលំនៅ IDB នឹងគាំទ្រដល់ប្រតិបត្តិការនេះតែនៅក្នុងករណីដែល (១) IDE យល់ថា សមាសភាគតាំងពីលំនៅជាថ្មី នឹងអាចផ្តល់អត្ថ-ប្រយោជន៍ ដោយផ្ទាល់ដល់មនុស្សទាំងនេះ ដែលអាចធៀបបាននឹងលក្ខខណ្ឌមុនពេលផ្លាស់ទីលំនៅ (២) សិទ្ធិប្រពៃណីត្រូវបានទទួលស្គាល់ទាំងស្រុង និងទូទាត់សងដោយយុត្តិធម៌ (៣) ជម្រើសទូទាត់មានបញ្ចូលនូវដំណោះស្រាយដោះដូរដី និង (៤) ក្រុមជនជាតិដើមភាគតិចរងផលប៉ះពាល់ បានផ្តល់ការឯកភាពចំពោះវិធានការតាំងទីលំនៅជាថ្មី និងការទូទាត់[១០]។

## ឃ. ធនាគារអឺរ៉ុបសម្រាប់ការស្តារឡើងវិញ និង អភិវឌ្ឍន៍

១៧. នៅខែ ឧសភា ឆ្នាំ ២០០៨ EBRD បានអនុម័តគោលនយោបាយបរិស្ថាន និងសង្គមថ្មី ជាមួយនឹងលក្ខខណ្ឌតម្រូវអនុវត្តចំនួន ១០ ជំនួសឱ្យគោលនយោបាយបរិស្ថានឆ្នាំ ២០០៣ និងអនុវត្តចំពោះគម្រោងទាំងអស់ ដែលវាយតម្លៃនៅក្រោយថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៨។ គោលនយោបាយបរិស្ថាន និងសង្គម រក្សាទុកគោលដៅយុទ្ធសាស្ត្រដែលមានចែងក្នុងគោលនយោបាយឆ្នាំ ២០០៣ និងធ្វើការដោះស្រាយបញ្ហាសង្គមនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ឱ្យមានរចនាសម្ព័ន្ធ និងមានភាពទូលំទូលាយជាងមុន។ បញ្ហាសង្គម មានការទាក់ទងទៅនឹង (១) ស្តង់ដារពលកម្ម និងលក្ខខណ្ឌការងារ (២) ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត (៣) សុខភាព សុវត្ថិភាព និងសន្តិសុខសហគមន៍ (៤) ក្រុមជនជាតិដើមភាគតិច និង (៥) បេតិកភណ្ឌវប្បធម៌។

១៨. គោលនយោបាយរបស់ EBRD យកគំរូតាមវិធីសាស្ត្ររបស់ IFC ប៉ុន្តែបានកែសម្រួលឱ្យស្របតាមប្រតិបត្តិការ ដែលមានលក្ខណៈពិសេស និងការប្តេជ្ញារបស់ EBRD ក្នុងការគោរពតាមគោលការណ៍របស់សហគមន៍អឺរ៉ុបក្នុងកិច្ចការពារបរិស្ថាន ដែល EBRD

[១០] IDB. ១៩៩៨. *គោលនយោបាយប្រតិបត្តិការស្តីពីការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត* Washington, DC.

ជាភាគីហត្ថលេខី។ ប៉ុន្តែ EBRD មានស្តង់ដារអនុវត្តបន្ថែមចំនួន ២ ដែលក្នុងនោះគោលការណ៍មួយសម្រាប់អនុវត្តចំពោះ (១) អន្តរការីហិរញ្ញវត្ថុ និងមួយទៀតសម្រាប់អនុវត្តចំពោះ (២) ការផ្តល់ព័ត៌មាន និងការជួបជាមួយអ្នកពាក់ព័ន្ធ។

១៩. ក៏ដូចជាស្ថាប័នហិរញ្ញវត្ថុពហុភាគីផ្សេងទៀតដែរ EBRD មានគោលនយោបាយព័ត៌មានសាធារណៈ ដែលបានធ្វើបច្ចុប្បន្នភាព និងអនុម័ត និងគោលនយោបាយបរិស្ថាន និងសង្គម នៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៨។ គោលនយោបាយព័ត៌មានសាធារណៈថ្មី ចែងពីរបៀបដែរ EBRD ផ្សព្វផ្សាយព័ត៌មាន និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដើម្បីជម្រុញការជ្រួតជ្រាប និងការយល់ដឹងឱ្យកាន់តែប្រសើរពីយុទ្ធសាស្ត្រ គោលនយោបាយ និងប្រតិបត្តិការរបស់ EBRD។ នៅក្នុងពេលជាមួយគ្នានេះ គោលនយោបាយក៏កំណត់នូវលក្ខខណ្ឌបែងចែកយ៉ាងច្បាស់លាស់រវាងព័ត៌មានដែលអាចផ្សព្វផ្សាយជាសាធារណៈ និងព័ត៌មានសំងាត់ដែលមិនអាចផ្សព្វ-ផ្សាយបាន។ គោលនយោបាយព័ត៌មានសាធារណៈ ក៏មានចែងពីលក្ខខណ្ឌតម្រូវក្នុងការផ្សព្វផ្សាយពីលទ្ធផលនៃការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមផងដែរ[១១]។

## ខ. ស្ថាប័នហិរញ្ញវត្ថុប្រកាន់គោលការណ៍អេក្វាទ័រ

២០. ស្ថាប័នហិរញ្ញវត្ថុប្រកាន់គោលការណ៍អេក្វាទ័រ គឺជាស្ថាប័នទាំងឡាយណាដែលប្រកាន់យកគោលការណ៍អេក្វាទ័រ ដែលជាក្របខណ្ឌឧស្សាហកម្មហិរញ្ញវត្ថុក្នុងការដោះស្រាយហានិភ័យបរិស្ថាន និងសង្គម ក្នុងគម្រោងហិរញ្ញប្បទាន។ អនុម័តនៅឆ្នាំ ២០០៣ ដោយធនាគារពាណិជ្ជកម្មចំនួន ១០ ដែលនាំមុខគេនៅក្នុងពិភពលោក គោលការណ៍អេក្វាទ័រ គឺជាផ្លែផ្កានៃឆន្ទៈក្នុងការបង្កើតឱ្យមាននូវបណ្តុំគោលនយោបាយ និងគោលការណ៍ណែនាំពីបរិស្ថាន និងសង្គម ដែលមានលក្ខណៈរួម និងជាប់ទាក់ទងគ្នា ដែលអាចយកទៅអនុវត្តជាសកល និងគ្រប់វិស័យឧស្សាហកម្មទាំងអស់។ ស្ថាប័នហិរញ្ញវត្ថុនីមួយៗប្រកាសថា ខ្លួនបាន ឬនឹងដាក់ឱ្យអនុវត្តគោល-នយោបាយ ឬធ្វើដំណើរការអាជីវកម្មឱ្យស្របតាមគោលការណ៍អេក្វាទ័រ។ ស្ថាប័នទាំងនេះ ប្តេជ្ញាមិនផ្តល់ប្រាក់កម្ចីឱ្យដល់គម្រោងដែលអ្នកខ្ចីមិន ឬមិនអាចគោរពតាមលក្ខខណ្ឌតម្រូវបរិស្ថាន និងសង្គមឡើយ។

២១. គោលការណ៍អេក្វាទ័រត្រូវបានកែសម្រួលនៅខែកក្កដា ២០០៦ ដើម្បី (១) ឆ្លុះបញ្ចាំងឱ្យស្របនឹង ស្តង់ដារអនុវត្តរបស់ IFC ដើម្បីនិរន្តរភាពសង្គម និងបរិស្ថាន ដែលជាស្តង់ដារដែលគោលការណ៍អេក្វាទ័រយកគំរូតាម និង (២) បញ្ចូលបទពិសោធន៍ដែលបានមកពីការអនុវត្ត និងមតិយោបល់នានារបស់អ្នកពាក់ព័ន្ធ។ គោលនយោបាយអេក្វាទ័រថ្មី អនុវត្តចំពោះគម្រោងហិរញ្ញប្បទានដែល

---

[១១] EBRD នឹងផ្សព្វផ្សាយលទ្ធផលវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមនៃគម្រោងប្រភេទ ក នៅមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្មនៅទីក្រុង London និងនៅទីស្នាក់ការដែលពាក់ព័ន្ធ EBRD យ៉ាងតិច ៦០ ថ្ងៃ មុនពេលដាក់គម្រោង ឱ្យក្រុមប្រឹក្សាភិបាលពិនិត្យពិចារណា (ករណីគម្រោងវិស័យឯកជន) និង ១២០ ថ្ងៃ មុនពេលដាក់គម្រោង ឱ្យក្រុមប្រឹក្សាភិបាលពិនិត្យពិចារណា (ករណីគម្រោងវិស័យសាធារណៈ)។ ការជូនដំណឹងពីភាពអាចរកបានឯកសារទាំងនេះ នឹងផ្សព្វផ្សាយនៅលើគេហទំព័ររបស់ EBRD។

សោហ៊ុយចំណាយមូលធនលើសពី ១០លានដុល្លា[១២] ។ គិតត្រឹមខែ សីហា ឆ្នាំ ២០០៨ ស្ថាប័នហិរញ្ញវត្ថុប្រមាណជា ៦០ ដែលមកពីបណ្តាប្រទេសចំនួន ២៤ និងធ្វើប្រតិបត្តិការនៅក្នុងប្រទេសប្រមាណជា ១០០ បានអនុម័តយកគោលការណ៍នេះ ក្រោយពេលដែលស្ថាប័នទាំងនោះយល់ស្របនឹងអំណះអំណាងថា ការទទួលខុសត្រូវរបស់សាជីវកម្មចំពោះបរិស្ថាន និងសង្គម ជារឿងសមហេតុសមផលមួយផ្នែកពាណិជ្ជកម្ម[១៣] ។

---

[១២] កម្រិតអតិបរិមាដំបូងគឺ ៥០លានដុល្លា ។ សូមមើលសេចក្តីពន្យល់ពីការកែប្រែនេះ និងព័ត៌មានផ្សេងទៀតដែលទាក់ទងនឹងគោលនយោបាយ អេក្វាទ័រនៅ : http://www.equator-principles.com/faq.shtml

[១៣] សូមមើល : http://www.equator-principles.com/join.shtml

# ផែនការសកម្មភាពពាក់កណ្ដាលត្រីមាស (២០១០-២០១២)

| លទ្ធផល | សូចនាករលទ្ធផល | សកម្មភាព | ភាគីទទួលខុសត្រូវ | ធនធានត្រូវការ |
|---|---|---|---|---|
| **កម្មវត្ថុរួម**<br>កម្មវត្ថុ គោលការណ៍ និងលក្ខខណ្ឌតម្រូវសម្រាប់ការពាររបស់ ADB ត្រូវបានបំពេញនៅគ្រប់គម្រោងដែលផ្ដល់ហិរញ្ញប្បទានដោយ ADB ។ | | | | |
| ***តំបន់សកម្មភាព (១)***<br>*គាំទ្រការអភិវឌ្ឍន៍សមត្ថភាពរបស់អ្នកខ្ចី/អតិថិជនក្នុងការអនុវត្តលក្ខខណ្ឌតម្រូវសម្រាប់ការពារ ។* | | | | |
| សមត្ថភាពស្ថាប័នរបស់អ្នកខ្ចី/អតិថិជនក្នុងការអនុវត្តលក្ខខណ្ឌតម្រូវការពារត្រូវបានពង្រឹង ។ | បណ្ដុះបណ្ដាលអ្នកខ្ចី/អតិថិជនពីគោល-នយោបាយថ្មីនៅគ្រប់កម្រិត នៅមុនកាល-បរិច្ឆេទចូលជាធរមាននៃ SPS និងបន្តការបណ្ដុះបណ្ដាលជាប់ជានិច្ច ។<br><br>ផ្ដល់យោបល់ និងការណែនាំបច្ចេកទេសបានទាន់ពេលវេលានៅកម្រិតគម្រោង នៅអំឡុងពេលរៀបចំគម្រោង<br><br>ផ្ដល់យោបល់ និងការណែនាំឱ្យបានទាន់ពេល | ▪ ផ្ដល់ការណែនាំឱ្យស្គាល់ពីគោល-នយោបាយរបស់ធនាគារដល់អ្នកខ្ចី DMC (សិក្ខាសាលា ១ នៅមុនកាលបរិ-ច្ឆេទចូលជាធរមាន និងបន្ទាប់មក ១-២ ក្នុងមួយឆ្នាំ)<br>▪ ផ្ដល់ការបណ្ដុះ-បណ្ដាលក្នុងប្រទេសដល់អ្នកខ្ចី/អតិថិជនវិស័យឯកជន/សាធារណៈ<br>▪ ផ្សព្វផ្សាយច្បាប់ចម្លងនៃគោល-នយោបាយដល់អ្នកខ្ចី/អតិថិជន និងពន្យល់ពីបទបញ្ញត្តិថ្មី | RDs/RSDD<br><br>RDs/PSOD/RSDD<br>RDs/PSOD<br><br>RDs/PSOD<br><br>RDs/PSOD<br><br>PDs/PSOD<br><br>OGC/RSDD/RDs | ▪ កេណ្ឌធនធានបុគ្គ-លិកផ្ទៃក្នុង<br>▪ ជំនួយបច្ចេកទេស ឬមូលនិធិបម្រុង (៨០-១០០លានដុល្លា) សម្រាប់ពេលត្រូវការចាំបាច់ ។<br>▪ បុគ្គលិកទីប្រឹក្សា<br>· ការរួមសហការជាមួយទីភ្នាក់ងារអភិវឌ្ឍន៍ផ្សេងទៀត ។ |

| លទ្ធផល | សូចនាករលទ្ធផល | សកម្មភាព | ភាគីទទួលខុសត្រូវ | ធនធានត្រូវការ |
| --- | --- | --- | --- | --- |
| | វេលានៅកម្រិតគម្រោង នៅអំឡុងពេលរៀបចំគម្រោង<br>ចំនួន និងគុណភាពនៃការវាយតម្លៃភាពសមមូល និងភាពអាចទទួលយកបាននៃ CSS ត្រូវបានរៀបចំ ។<br>ចំនួន និងផែនការសកម្មភាពបំបាត់គម្លាតបានត្រូវព្រមព្រៀងរវាង ADB និងអ្នកខ្ចី/អតិថិជន និងត្រូវបានអនុវត្តដោយអ្នកខ្ចី/អតិថិជន ។ | ▪ វាយតម្លៃសមត្ថភាពរបស់អ្នកខ្ចី/អតិថិ-ជន និងបញ្ចូលការកសាងសមត្ថភាពសមស្របក្នុងប្លង់រចនាគម្រោង<br>▪ គាំទ្រការរៀបចំវាយតម្លៃសង្គម និងបរិស្ថាន និង EMP, RP, IPP ។<br>▪ ផ្តល់ការគាំទ្រដែលចាំបាច់ក្នុងការដោះ-ស្រាយបញ្ហាឥតព្រាងទុកកើតមាននៅពេលអនុវត្តគម្រោង ។<br>▪ រៀបចំការវាយតម្លៃពី ៣-៥ នៃភាពសមមូល និងភាពអាចទទួលយកបាននៃ CSS និងផែនការសកម្មភាពបំបាត់គម្លាតនៅកម្រិតថ្នាក់ក្រោមជាតិ តំបន់ និងទីភ្នាក់ងារ ។ | | |
| *តំបន់សកម្មភាព (២)*<br>*អភិវឌ្ឍន៍ និងរក្សាសម្ភារៈ និងឧបករណ៍ជួយដល់ការអនុវត្តគោលនយោបាយ ។* | | | | |

| *តំបន់សកម្មភាព (៣)*<br>*ធានាសមត្ថភាពអង្គការ និងធនធានរបស់ ADB ក្នុងការអនុវត្តគោលនយោបាយ ។* | | | | |
|---|---|---|---|---|
| ចំណេះដឹងរបស់បុគ្គលិកពីលក្ខខណ្ឌតម្រូវបរិស្ថាន និងសង្គម ត្រូវបានធ្វើបច្ចុប្បន្នភាព ។ សមត្ថភាពស្ថាប័នក្នុងការអនុវត្តគោលនយោបាយត្រូវបានពង្រឹង ។ | ចំនួនបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលបានទាន់ពេលវេលា និងជាប់ជានិរន្តរ៍ ។<br><br>បង្កើនមុខតំណែងបុគ្គលិក និងធ្វើឱ្យប្រសើរឡើងនូវការបែងចែកធនធានបុគ្គលិក ។<br><br>រក្សាបាននូវបណ្តាញចែករំលែកចំណេះដឹងរវាងនាយកដ្ឋាន ។ | ▪ ផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិក HQ និង RM អ្នកជំនាញលក្ខខណ្ឌតម្រូវសម្រាប់ការពារ និង ប្រធានក្រុមការងារ (សិក្ខាសាលា ២ នៅមុនកាលបរិច្ឆេទចូលជាធរមាន និងបន្ទាប់មក ២-៣ ក្នុងមួយឆ្នាំ) ។<br>▪ ជួលអ្នកជំនាញអាជីពបន្ថែមប្រចាំ RD និងមន្ត្រីជាតិនៅ RM នៅអំឡុងពេល ០៣ ឆ្នាំនៃរយៈពេលមធ្យម ។<br>▪ រៀបចំសិក្ខាសាលា/វគ្គសិក្សាពីការចែករំលែកចំណេះដឹង និងបទពិសោធន៍ ។ | RSDD<br><br>BPHR/RDs<br><br>RSDD/RDs/ PSOD | ▪ កេណ្ឌធនធានបុគ្គលិកផ្ទៃក្នុង<br>▪ ជំនួយបច្ចេកទេស<br>▪ កញ្ចប់ថវិកាចំណាយរដ្ឋបាលផ្ទៃក្នុងបន្ថែម ។ |

| *តំបន់សកម្មភាព (៤)*<br>*លើកកម្ពស់ និងរក្សាប្រព័ន្ធវាយតម្លៃផ្ទៃក្នុង និងប្រព័ន្ធតាមដានអនុលោមភាពរបស់ ADB ។* | | | | |
|---|---|---|---|---|
| ប្រព័ន្ធវាយតម្លៃផ្ទៃក្នុង និងប្រព័ន្ធតាមដានអនុលោមភាពរបស់ ADB ដំណើរប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធិផល ។ | នីតិវិធីប្រតិបត្តិច្បាស់លាស់សម្រាប់អនុវត្ត SPS បានត្រូវបង្កើតនៅមុនកាលបរិច្ឆេទចូលជាធរមាននៃ SPS ។<br><br>ការពិនិត្យ និងចាត់ចំណាត់ថ្នាក់គម្រោង<br><br>ការផ្តល់ព័ត៌មាន<br><br>ការពិគ្រោះយោបល់<br><br>ឯកសារលក្ខខណ្ឌតម្រូវការពារ បានត្រូវបញ្ជូនទាល់ពេលវេលា និងបានត្រូវវាយតម្លៃសមស្របនៅអំឡុងពេលរៀបចំគម្រោង ។<br><br>បេសកកម្មត្រួតពិនិត្យ និងតាមដានបានត្រូវរៀបចំទាន់ពេលវេលា ការណែនាំសមស្របបាន | ▪ រៀបចំសៀវភៅណែនាំប្រតិបត្តិការរួមដើម្បីកំណត់នីតិវិធីក្នុងការវាយតម្លៃតាមដាន និងរាយការណ៍ពីការអនុវត្តលក្ខខណ្ឌតម្រូវការពារនៅដំណាក់កាលនីមួយៗនៃវដ្តគម្រោង ។<br>▪ ពិនិត្យ និងចាត់ចំណាត់ថ្នាក់គម្រោងនីមួយៗឱ្យបានទាន់ពេលវេលា និងឱ្យបានសមស្រប ។<br>▪ ផ្សព្វផ្សាយ EIA សម្រាប់គម្រោងបរិស្ថានប្រភេទ ក នៅលើគេហទំព័ររបស់ ADB ចំនួន ១២០ថ្ងៃ មុនការអនុម័តរបស់ក្រុមប្រឹក្សាភិបាល ។ ផ្សព្វផ្សាយ EARF នៅមុនពេលវាយតម្លៃគម្រោង ។ | RSDD<br>RSDD/RDs/PSOD<br>RDs/PSOD<br><br>RDs/PSOD<br><br>RDs/PSOD/RSDD<br><br>RDs/PSOD RSDD<br><br>RSDD | ▪ ធនធានបុគ្គលិកផ្ទៃក្នុង |

| | | | | |
|---|---|---|---|---|
| | ត្រូវផ្តល់ ហើយលទ្ធផលបានត្រូវកត់ត្រានៅអំឡុងពេលអនុវត្តគម្រោង ។<br><br>លទ្ធផល និងស្ថានភាពអនុលោមភាពបានត្រូវកត់ត្រាទាន់ពេលវេលា និងបានរាយការណ៍ជូនថ្នាក់ដឹកនាំធនាគារ ។ | ផ្សព្វផ្សាយ RP/RF សម្រាប់គម្រោង IR ប្រភេទ ក និង ខ នៅមុនពេលវាយតម្លៃគម្រោង ។ ផ្សព្វផ្សាយ IPP/ IPF សម្រាប់គម្រោង IP ប្រភេទ ក និង ខ នៅមុខពេលវាយតម្លៃគម្រោង ។<br>▪ ចូលរួមក្នុងការពិគ្រោះយោបល់សម្រាប់គម្រោងដែលមានផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន IR និង IP ។ កត់ត្រាលទ្ធផលនៃការពិគ្រោះយោបល់ និង បញ្ចូលលទ្ធផលនោះក្នុងប្លង់រចនាគម្រោង ។<br>▪ វាយតម្លៃឯកសារលក្ខខណ្ឌតម្រូវអនុ-វត្តតាមទាំងអស់ ច្រៀបជាមួយនឹង | | |

| | | | | |
|---|---|---|---|---|
| | | គោលការណ៍គោល-នយោបាយ និងលក្ខខណ្ឌតម្រូវនៃ SR1-4 ។ ផ្តល់ការណែនាំសមស្របឱ្យអ្នកខ្ចី/អតិថិជនក្នុងការបញ្ចប់ឯក-សារលក្ខខណ្ឌតម្រូវការពារ ដើម្បីធានាអនុលោមភាពជាមួយលក្ខខណ្ឌតម្រូវរបស់ ADB ។<br>▪ ធ្វើបេសកកម្មត្រួត-ពិនិត្យ និងតាមដាននៅនឹងកន្លែងដោយអ្នកជំនាញលក្ខខណ្ឌតម្រូវសម្រាប់ការពារចំពោះគ្រប់គម្រោងបរិ-ស្ថាន IR និង IP ប្រភេទ ក ទាំង-អស់ ។ ព្រមព្រៀងជាមួយអ្នកខ្ចី/អតិ-ថិជនក្នុងការរៀបចំ និងអនុវត្តផែនការកែតម្រូវ ប្រសិនបើចាំបាច់ និងរៀបចំរបាយការណ៍តាម-ដានដែលមាន | | |

| | | | | |
|---|---|---|---|---|
| | | លក្ខណៈលម្អិត និងមានគុណភាព។<br>▪ រៀបចំរបាយការណ៍ប្រចាំឆ្នាំពីលទ្ធផលជារួមរបស់ធនាគារ និងបញ្ជូនឱ្យថ្នាក់ដឹកនាំធនាគារ។ | | |

ADB = ធនាគារអភិវឌ្ឍន៍អាស៊ី, BPHR = ផ្នែកធនធានមនុស្ស, CSS = ប្រព័ន្ធការពារក្នុងប្រទេស, DMC = ប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក, EARF = ក្របខណ្ឌពិនិត្យ និងវាយតម្លៃបរិស្ថាន, EIA = ការវាយតម្លៃផលប៉ះពាល់បរិស្ថាន, EMP = ផែនការគ្រប់គ្រងបរិស្ថាន, HQ = ទីស្នាក់ការកណ្តាល, IPF = ក្របខណ្ឌក្រុមជនជាតិដើមភាគតិច, IPP = ផែនការក្រុមជនជាតិដើមភាគតិច, IR = ការតាំងទីលំនៅជាថ្មីដោយមិនស្ម័គ្រចិត្ត, OD = នាយកដ្ឋានប្រតិបត្តិការ, OGC = ការិយាល័យអគ្គទីប្រឹក្សា, OM = សៀវភៅណែនាំប្រតិបត្តិការ, PSOD = នាយកដ្ឋានប្រតិបត្តិការវិស័យឯកជន, RD = នាយកដ្ឋានតំបន់, RF = ក្របខណ្ឌតាំងទីលំនៅជាថ្មី, RM = បេសកកម្មទិវាសនជន, RP = ផែនការតាំងទីលំនៅជាថ្មី, RSDD = នាយកដ្ឋានអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងប្រចាំតំបន់, SPS = សេចក្តីថ្លែងការណ៍គោលនយោបាយការពារ, SR = លក្ខខណ្ឌតម្រូវសម្រាប់ការពារ។